# មត៌កវប្បធម៌មន-ខ្មែរ

## តាមរយៈសិល្បៈ និងបុរាណវិទ្យា

## ភាគ ១



ដោយបណ្ឌិត មីសែល ត្រាណេ

២០០៦

"តាមការពិតទៅឥទ្ធិពលទ្រព្យសម្បត្តិអំណាចឬក៏ភាពឃោឃៅព្រៃផ្សៃដូចជាការជិះជាន់ខាងផ្លូវកាយក៏ដូចខាងផ្លូវចិត្តជាដើមគ្រាន់តែទិញទឹកចិត្តមនុស្សឬក៏ធ្វើអោយគេខ្លបខ្លាចខ្លួនបានត្រឹមតែមួយគ្រាប៉ុណ្ណោះ ។

ភាពយុត្តិធម៌ និងសុចរិត ពោលគឺអំពើល្អ គឺជាមធ្យោបាយតែមួយគត់ធ្វើអោយគេស្រលាញ់រាប់អានសេពគប់យើង អាណិតអាសូរដល់រូបយើងមួយជីវិត ។"

# មតិកវប្បធម៌មន-ខ្មែរ
## តាមរយៈសិល្បៈ និងបុរាណវិទ្យា
## ភាគ ១

ដោយបណ្ឌិត **មីសែល ត្រាណេ**

២០០៦

# មាតិកាអត្ថបទ


សេចក្ដីសម្គាល់ I

សេចក្ដីផ្ដើម ក

វិចារណកថា ង


## ជំពូក១


កំណើតនិងមូលដ្ឋានគ្រឹះ ជាប្រវត្តិសាស្ត្រនៃវប្បធម៌ អារ្យធម៌ របស់ជនជាតិខ្មែរ

១-តើជនជាតិខ្មែរមកពីណា ១

២-ស្ថានីយបុរេប្រវត្តិសាស្ត្រនៅឥណ្ឌូចិនជាកម្មសិទ្ធិរបស់ជនជាតិណា? ៣

៣-ដែនដីសិរីទ្ធិនាសម័យវប្បធម៌លោហធាតុ ៨

៤-ភស្តុតាងនៃទំនាក់ទំនងវប្បធម៌មន-ខ្មែរជាមួយចិន : ស្គមហាចឹកនៅភូមិស្នាយ ១០

៥-ការចាក់ឫសនៃវប្បធម៌ឥណ្ឌាលើខឿនវប្បធម៌មន-ខ្មែរ ១៤

៦-នគរូបនីយកម្មនៃរដ្ឋខ្មែរដំបូង ១៧

៧-ការបង្កើតរដ្ឋខ្មែរដំបូងបង្អស់នាស.វ.ទី១នៃគ.ស. ២៥

៨-គម្លាតវប្បធម៌រវាងទំនាបនិងខ្ពង់រាប និងឯកភាពរូបនីយកម្មក្នុងចក្រភពបុរេអង្គរ និងអង្គរ ២៨


## ជំពូក២


សមិទ្ធិកម្មផ្នែកសង្គម សេដ្ឋកិច្ច វប្បធម៌នាសម័យបុរេប្រវត្តិសាស្ត្រ

១-ខ្មែរមានជំនឿសាសនាខ្លួនឯងផ្ទាល់ មុនព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនា ៣៥

## ជំពូក៣

មតិកវប្បធម៌មន-ខ្មែរ ឬខ្មែរលើក្នុងសង្គមខ្មែរ តាំងពីបុរាណកាលមកដល់សព្វថ្ងៃ


១-ប៉ឹងបុរសនៅសម័យអង្គរ ៧០

២-ប៉ឹងស្ត្រីខ្មែរលើ ៧២

៣-ទេពអប្សរនៅប្រាសាទអង្គរវត្តមួយចំនួនស្លៀកប៉ឹង ដូចស្ត្រីកុលសម្ព័ន្ធខ្មែរលើ ៧៤

៤-ប្រពៃណីលែងទ្រូងទទេរបស់ស្ត្រីខ្មែរ ៧៦

៥-ប្រពៃណីទុកត្រចៀកវែងរបស់ស្រីទេពអប្សរខ្មែរ ៧៨

៦-ត្រសាលពាក់ត្រចៀករបស់ជនជាតិខ្មែរ ៨១

៧-ការនិយមកងដៃ កងជើងរបស់ខ្មែរនាសម័យអង្គរ ៨៣

៨-បំពង់ប្រើប្រាស់ប្រចាំថ្ងៃសម្រាប់ខ្មែរបុរាណ លើប្រាសាទបាយ័ន. ៨៥

៩-ជំនឿជីវចលនិយម ៨៧

១០-ហេតុអ្វីប្រជាជនខ្មែរមានជំនឿលើខ្នាយតាន់ជ្រូកព្រៃ ៨៨

១១-ពិធីបូជាក្របីលើប្រាសាទបាយ័នមុនទៅច្បាំង ៩១

១២-ប្រភពពួងលំពែងនិងធ្នូ ៩៣

១៣-ប្រភពពួងនៃផ្គាក់ខ្មែរ ៩៤

១៤-ប្រភពពួងនៃក្បាំងខ្មែរ ៩៦


## ជំពូក៤


១-ពាក្យផ្ដើម ៩៩

២-ប្រភពមន-ខ្មែរនៃពួយ ១០០

២-ស្លាកស្នាម ឬសគល់ នៃវប្បធម៌ខ្មែរតាមស្ថានីយបុរេប្រវត្តិសាស្ត្រ ៣៨
៣-ការទុកសាកសពនាសម័យលោហធាតុ ៤០
៤-ឧស្សាហកម្មឆ្អឹងនាសម័យបុរេប្រវត្តិសាស្ត្រ
យុគសម័យវប្បធម៌លោហធាតុ ៤២
៥-ភ្នុកនិងស្នែងសត្វ ៤៣
៦-ជំនឿរបស់ជនជាតិខ្មែរ ទៅលើស្នែងនិងចង្កូមសត្វ ៤៤
៧-ឧស្សាហកម្មកែវនាសម័យបុរេប្រវត្តិសាស្ត្រ ៤៦
៨-មនុស្សសម័យបុរេប្រវត្តិសាស្ត្រនិយមប្រើបន្ទោងនិមិត្តរូបសត្វខ្លា ៤៨
៩-ការនិយមប្រើត្រសាល់ និងការរលាយបាត់បង់ទៅវិញ ៥០
១០-បុរេប្រវត្តិនៃការខ្មៅ ៥៣
១១-ការត្រចៀកបុរាណរបស់ស្ត្រីខ្មែរ-មន ៥៤
១២-ខ្មែរនិយមសាក់លើខ្លួនប្រហែលមានមកតាំងពី២៥០០ឆ្នាំមុនគ.ស. ៥៦
១៣-កសិកម្មដើមសម័យប្រវត្តិសាស្ត្រ ៥៨
១៤-ឧស្សាហកម្មតម្បាញ សម្លៀកបំពាក់នៅសម័យបុរេប្រវត្តិសាស្ត្រ ៥៩
១៥-សម្លៀកបំពាក់ខ្មែរនាសម័យបុរេប្រវត្តិសាស្ត្រ ៦២
១៦-ការប្រើប៊ីងនាសម័យបុរេប្រវត្តិសាស្ត្រ ៦៤
១៧-ការជក់បារីដោយប្រើខ្សៀនាសម័យបុរេប្រវត្តិសាស្ត្រ ៦៦
១៨-ការរាប់ចំនួននាសម័យបុរេប្រវត្តិសាស្ត្រ ៦៧
១៩-ការផ្សាំងសត្វនាសម័យបុរេប្រវត្តិសាស្ត្រ ៦៩

៧-ជនជាតិខ្មែរលើ និងជំនឿលើចេកត្រណម ១៤៩
៨-ជនជាតិភាគតិចខេត្តមណ្ឌលគិរីគេបានអ្វីខ្លះមកលក់នៅទីផ្សា ១៥៣
៩-ទំនៀមទម្លាប់ជក់បារីរបស់បងប្អូនជនជាតិភាគតិច ១៥៦
១០-គងនិងជំនឿរបស់ជនជាតិខ្មែរលើ ១៥៧
១១-ការសម្រាលកូនរបស់ស្ត្រីជនជាតិព្នង ១៦២
១២-កងដៃមតិករបស់ក្រមុំព្រៃភ្នំ ១៦៤
១៣-ឧបករណ៍ភ្លេងពួយរបស់ជនជាតិព័រនិងជង ១៦៧
១៤-ឧបករណ៍ភ្លេងរហេតរហូត ១៧០
១៥-ទំនាក់ទំនងរវាងទីតាំងរស់ ស្ថានភាពរស់និងជំនឿសាសនាជា ១៧០
ការបញ្ជាក់អំពីប្រវត្តិនៃឧបករណ៍ភ្លេងពួយ
១៦-រលកសម្លេងចាប៉ីឃ្លោករបស់ជនជាតិខ្មែរលើ ១៧២
១៧-សិល្បករភ្លេងម៉ុមជាជនជាតិគ្រឹងនៅខេត្តរតនគិរី ១៧៤
១៨-ជនជាតិភាគតិចនៅភូមិភាគឦសាន ១៧៧

៣-កើ្តដំណែលមន-ខ្មែររបស់រាំត្រុដិ. ១០៧
៤-ការរកឃើញឧបករណ៍ភ្លេងម៉ិម ១០៩
៥-ប្រវត្តនៃការរកឃើញឡើងវិញនូវឧបករណ៍តន្រ្តីម៉ិម ១១១
៦-ប្រភពពូងនៃឧបករណ៍ភ្លេងម៉ិម ១១៤
៧-តែនជាសម្បត្តិវប្បធម៌ជនជាតិខ្មែរ ១១៧
៨-ប្រភពពូងនៃឈ្មោះខ្មែរ ១១៨
៩-ប្រវត្តិមន-ខ្មែរបេស់តែនខ្មែរនៅព្រះរាជាណាចក្រកម្ពុជា
និងប្រទេសលាវ ១២០
១០-រាំវង់ជាកើ្តដំណែលមន-ខ្មែរ ១២២
សំយោគ ១២៤

## ជំពូក៥

## ឧបសម្ព័ន្ធ១

ក)-អត្ថបទជាភាសាខ្មែរ ១២៩
១-ជនជាតិកួយនិងការរស់នៅ ១៣០
២-យកជនជាតិព័រពីរនាក់មកបង្រៀនភាសាព័រ ដើម្បីស្រាវជ្រាវថា
តើសិលាចារឹកប្រាសាទសម្បូរណ៍ជាប់ពាក់ព័ន្ធទៅនឹងភាសាព័រ
យ៉ាងណា ? ១៣២
៣-ជនជាតិខ្មែរព័រនិងជងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ១៣៥
៤-រលាក់កងជើង "ដែនដីដែលគេធ្លាប់ប្រមាថ" ១៣៨
៥-ជនជាតិនៅមណ្ឌលគិរីចោះត្រចៀកសម្គាល "អ្នកជា" ១៤៥
៦-ស្រវឹងកាន់តែខ្លាំងជដែកគ្នាកាន់តែតិច ១៤៧

I

# សេចក្តីសង្ខេប

ចាប់តាំងពីស.វ.ទី៣មុនគ.ស. ឧបទ្វីបឥណ្ឌូចិន និងឥណ្ឌូណេស៊ីបានផ្តើម ការទំនាក់ទំនងយ៉ាងជិតស្និតតាមវិស័យពាណិជ្ជកម្មអន្តរជាតិ ជាមួយប្រទេសឥណ្ឌា និងចិន ។ ក៏ប៉ុន្តែ ទំនាក់ទំនងសេដ្ឋកិច្ចនេះ ត្រូវបានបង្កើនជាមពលយ៉ាងខ្លាំងក្លាចាប់តាំងពីដើមស.វ.ទី១តែប៉ុណ្ណោះ ដោយសារភាពរីកចម្រើនរវាងនាវាចរ និងការរកឃើញនូវខ្យល់រដូវសម្រាប់ធ្វើដំណើរតាមសមុទ្រ ។

ដូចកុលសម្ព័ន្ធដទៃៗទៀតដែរ ដែលរស់នៅពាសពេញដេរដាសទូទៅទាំងឧបទ្វីបឥណ្ឌូចិន ហើយខុសពីជនជាតិអម្បូរណ៍ចិន ថៃ លាវ និងយួន ជនអន្តោប្រវេសន៍ពីយូណាន់និងក្វាងទុង ជនជាតិខ្មែរជាអ្នកស្រុកដើម ឬរដ្ឋវាសីហើយស្ថិតនៅក្នុងអម្បូរណ៍មន-ខ្មែរ បានទទួលនូវអានុភាពនៃវប្បធម៌ឥណ្ឌាចាប់ពីពេលនោះមក ។

នៅដើមស.វ.ទី១នៃគ.ស. ជនជាតិខ្មែរដែលរស់នៅតាមឆ្នេរ ឬឈូងសមុទ្រចិន និងសៀមបច្ចុប្បន្ន ជាពិសេសតាមវាលទំនាបនៃដងទន្លេមេគង្គ និងមេណាម បានកសាងចក្រភពភ្នំ ដោយបានខ្ចីរចនាសម្ព័ន្ធនយោបាយរបបគ្រប់គ្រង អក្សរសាស្ត្រ សាសនា បច្ចេកទេសមួយចំនួនមកពីឥណ្ឌា ដើម្បីអភិវឌ្ឍន៍សហគមន៍របស់ខ្លួន ។ រីឯជនជាតិមនដែលរួមឈាមជរ ដែលជាផែកធាងនៃអម្បូរមន-ខ្មែរក៏ដូច្នោះដែរ ឆ្លៀតក្នុងឱកាសនៃឱនភាពនៃចក្រភពភ្នំ ឬហ្វូណននៅពាក់កណ្តាលស.វ.ទី៦នៃគ.ស. ពួកគេបានផ្តាច់ខ្លួនហើយបានបង្កើតរដ្ឋរបស់ខ្លួនគឺនគរទ្វារវតី ។ ព្រឹត្តិការណ៍នេះ បានប្រព្រឹត្តឡើងក្រោយពីនគរភ្នំប្រមាណជា៦ស.វ. ។

ដូច្នេះ ក្នុងចំណោមអម្បូរមន-ខ្មែរមានតែជនជាតិខ្មែរនិងមនទេ ដែល

បានបង្កើតរដ្ឋរបស់ខ្លួនបានដោយឥទ្ធិពលឥណ្ឌា ។ ក្នុងករណីនេះហើយ ដែលកុលសម្ព័ន្ធមន-ខ្មែរមួយចំនួនធំ មិនបានរក្សាទម្រង់វប្បធម៌ដើមរបស់ខ្លួនទេ រហូតមកដល់សព្វថ្ងៃនេះ ។ តែទោះជាយ៉ាងនេះក្តី មានតែជនជាតិខ្មែរទេ ដែលបានរក្សានូវនិរន្តរភាពនៃរដ្ឋ ឬប្រទេសរបស់ខ្លួនឱ្យបានគង់វង្សរហូតមកដល់សព្វថ្ងៃនេះ ថ្វីត្បិតតែទំហំនៃភូមិសាស្ត្រជាប្រវត្តិសាស្ត្រ ត្រូវបានកែប្រែបំព្រួញយ៉ាងណាក៏ដោយ ។

ក្នុងដំណាក់កាលនៃការបង្រួបបង្រួមជាតិនៅលើកដំបូង ដែលអាចឆ្លុះបញ្ចាំងតាមរូបភាពនៃចម្បាំងរវាងកុលសម្ព័ន្ធ ឬសន្តិវង្ស គប្បីត្រូវជ្រាបថា ចម្បាំងទាំងនោះ ពុំមែនត្រូវបានធ្វើឡើងដោយជនជាតិបរទេសនោះទេ ក៏ប៉ុន្តែដោយមនុស្សស្ថិតក្នុងអម្បូរណ៍ពូជសាសន៍តែមួយ រួមទាំងវប្បធម៌រូបភាពទាំងភាសា ថែមទៀតផង ពោលគឺរវាងខ្មែរ និងខ្មែរ។ អ្វីដែលទើបតែពោលត្រូវបានកត់ត្រាទុកក្នុងកំណត់ហេតុចិនយ៉ាងជាក់លាក់ ។

ចម្បាំងខាងលើនេះ ដើម្បីបង្រួបបង្រួមជាតិខ្មែរ ឱ្យក្លាយទៅជាធ្លុងមួយ ត្រូវបានបន្តរហូតដល់រជ្ជកាលរបស់ព្រះបាទភវវរ្ម័នទី១ ព្រះបាទមហេន្ទ្រវរ្ម័ន និងព្រះបាទឦសានវរ្ម័ន ហើយបន្តដល់រជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី ២ ដូចខ្លឹមសារនៃសិលាចារឹកសម័យបុរេអង្គរនិងអង្គរបានបញ្ជាក់ស្រាប់ ។

គោលដៅនៃការស្រាវជ្រាវនេះ គឺគ្រាន់តែរំលឹកឡើងវិញនូវគោល១ លក្ខណៈវប្បធម៌រួមរវាងជនជាតិខ្មែរ ដែលជឿនលឿន និងជនជាតិខ្មែរដើមរស់តាមព្រៃភ្នំ ឬខ្ពង់រាប តាមរយៈទំនៀមទម្លាប់ ជំនឿ ប្រពៃណីមួយចំនួនតែប៉ុណ្ណោះ ។

យើងក៏សង្ឃឹមយ៉ាងមាំដែរថា តទៅអនាគត និងមានការស្រាវជ្រាវ

III

ស៊ីជម្រៅពីសំណាក់និស្សិតបន្ទាប់ពីការសិក្សាដោយសង្ខេបនេះ របស់យើង ដែលគ្រាន់តែថា ការចាប់ផ្ដើមនៅលើមាគ៌ាដ៏វែងឆ្ងាយមួយតែប៉ុណ្ណោះ ។

បណ្ឌិត មីសែល ត្រាណេ
អនុរដ្ឋមន្ត្រីនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
និងជាអនុប្រធាននៃគណកម្មការជាតិសម្រាប់យូណេស្កូ

# សេចក្តីផ្តើម

សង្គមខ្មែរ វប្បធម៌ខ្មែរបច្ចុប្បន្ន គឺជាលទ្ធផលនៃការវិវត្តន៍ជានិរន្តរ៍ ដោយបានប្រែប្រួលទម្រង់នៃខឿនវប្បធម៌មន-ខ្មែរ ឬខ្មែរ-មនដើម ក្រោមឥទ្ធិពលនៃហេដ្ឋារចនាសម្ព័ន្ធឥណ្ឌា ពោលគឺមានការគ្រប់គ្រងរៀបចំប្រទេសជាតិតាមលំនាំឥណ្ឌា ដែលបានផ្តើមឡើងនៅស.វ.ទី១នៃគ.ស. ដោយយករបបរាជាធិបតេយ្យ ជារបបនយោបាយសម្រាប់ដឹកនាំ ។

ដូច្នេះ ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន គឺជាប្រទេសមួយ ដែលមានប្រវត្តិសាស្ត្រដ៏យូរលង់ណាស់មកហើយ ។ រីឯជនជាតិខ្មែរវិញ ដែលស្ថិតក្នុងអម្បូរមន-ខ្មែរ ឬអូស្ត្រូអស៊ីអាតិច ដូច្នេះគឺជាជនជាតិមួយ ដែលបានកើតនៅលើជ្រោយឥណ្ឌូចិន ឬជ្រោយសុវណ្ណភូមិនេះផ្ទាល់ ហើយស្ថិតនៅក្នុងអម្បូរពូជសាសន៍មួយ ដែលគេហៅថា មន-ខ្មែរ ឬខ្មែរ-មន ។ វត្តមានរបស់អម្បូរមន-ខ្មែរ ដែលបានករកើតជារូបរាងឡើង និងបានវិវត្តតាំងតែពីសម័យបុរេប្រវត្តិសាស្ត្រមកម្លេះ ពោលគឺរាប់ពាន់សែនឆ្នាំមុនសម័យប្រវត្តិសាស្ត្រ ដែលបានចាប់ផ្តើមឡើងនាដើមស.វ.ទី១នៃគ.ស. អាចឆ្លុះបញ្ចាំងតាមចំនួនស្ថានីយ៍បុរេប្រវត្តិសាស្ត្រ ដ៏ច្រើនលើសលុបក្នុងភូមិភាគឥណ្ឌូចិនយើងនេះ ។

តាមពិត ក្នុងកុលសម្ព័ន្ធមន-ខ្មែរ ឬខ្មែរ-មន ដែលមានចំនួនជាង១០០កុលសម្ព័ន្ធ ដែលរស់នៅដេរដាសនៅប្រទេសកម្ពុជាបច្ចុប្បន្ន និងនៅភូមិភាគឥណ្ឌូចិន មានតែជនជាតិខ្មែរនិងមនទេ ដែលទទួលវប្បធម៌ឥណ្ឌា ចំពោះខ្មែរនៅដើមស.វ.ទី១នៃគ.ស. និងមនរដ្ឋទ្វារវត្តីនៅចុងស.វ.ទី៦នៃគ.ស. ។ ដូចនេះ អម្បូរនេះ ដែលរស់នៅតាំងពីសម័យបុរេប្រវត្តិសាស្ត្រ ពីជ្រោយម៉ាឡាយូរ

រហូតដល់ឈូងសមុទ្រសៀម និងព្រំព្រទល់ឥណ្ឌា មានពង្សាវតារប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ប្រពៃណីរួមជាមូលដ្ឋានគ្រឹះ ឬអត្តសញ្ញាណជាតិរបស់ខ្លួនយ៉ាងប្រាកដ ដែលគេពុំអាចប្រដូចនឹងកុលសម្ព័ន្ធអម្បូរចិន ឬទីបេតនានា មកពីតំបន់ឃ្លួណាន់ឡើយ ។ បើនិយាយម្យ៉ាងទៀត មុនការបង្កើតរដ្ឋនគរភ្នំ និងរដ្ឋទ្វារវតី ពុំមានការបែងចែកថាអ្វីជាខ្មែរ និងអ្វីជាមនទេ ដោយមូលហេតុភូមិសាស្ត្របុរេប្រវត្តិសាស្ត្រ និងវិស័យជាតិពន្ធុវិទ្យា ។

ខាងលើនេះ ជាទិដ្ឋភាពទូទៅនៃប្រភពវប្បធម៌ អារ្យធម៌រួម រវាងជនជាតិខ្មែរនិងមនក្នុងចក្រភពភ្នំ ដែលគួរឱ្យកត់សម្គាល់ ។ ក៏ប៉ុន្តែយើងក៏ត្រូវដឹងដែរថា នៅមានសហគមន៍មន-ខ្មែរមួយចំនួនទៀត ដែលស្ថិតក្នុងប្រទេសភូមានៅស្រីក្សេត្រ ឈ្មោះជនជាតិព្យូ ពួកមន-ខ្មែរនេះ ក៏បានបង្កើតរដ្ឋរបស់ខ្លួនឡើង ដែលមានអាយុប្រហាក់ប្រហែលនឹងចក្រភពភ្នំដែរ ។ គឺវប្បធម៌បែបពុទ្ធនិយម ព្យូនេះហើយ ដែលបានជះឥទ្ធិពលលើកុលសម្ព័ន្ធនានាក្នុងចក្រភពភ្នំ ជាពិសេស មុំនគរបឋមបច្ចុប្បន្ន នៅចុងស.វ.ទី៦ ជាមូលហេតុនៃការលេចធ្លោឡើងនូវនគរទ្វារវត្តី ដែលរួមពូជសាសន៍ និងភាសាជាមួយខ្មែរ ។ ទន្ទឹមនឹងនេះ ឥទ្ធិពលរបស់នគរព្យូ តាមរយៈនគរទ្វារវត្តី ដែលទើបតែបានបង្កើត ក៏បានមានអានុភាពលើសិល្បៈនគរភ្នំដែរ ។ គប្បីត្រូវជ្រាបថា សម្ព័ន្ធភាពខាងវប្បធម៌សាសនា ជាតិសាសន៍រវាងខ្មែរនិងមននេះ មិនត្រូវធ្វើឱ្យយើងមានការភ្ញាក់ផ្អើលអ្វីទេ ។

គួរសម្គាល់ដែរថា ក្រៅពីរង្វង់ព្រំដែនខ្មែរបច្ចុប្បន្ន ដែលត្រូវបានបំពេញដោយការរុករានទន្ទ្រានទឹកដីជាបន្តបន្ទាប់ ចាប់ពីស.វ.ទី១៣ នៃគ.ស.

នៅមានជនជាតិខ្មែរ និងកុលសម្ព័ន្ធមន-ខ្មែរ ឬខ្មែរលើចំនួនច្រើនលាននាក់ទៀត ដែលកំពុងរស់នៅដូចជាប្រទេសថៃ លាវ និងយួន ឬវៀតណាមភាគកណ្តាល និងភាគខាងត្បូងសព្វថ្ងៃនេះ ។ ជនជាតិខ្មែរ និងកុលសម្ព័ន្ធខ្មែរលើដែលរួមពូជពង្សសាវតារនិងឈាមជ័រ ពោលគឺជាបងប្អូននឹងជនជាតិខ្មែរ ដែលបានចែកចេញពីសំណង់វប្បធម៌ដើម ដោយការបង្កើតរដ្ឋនគរភ្នំ ទាំងថែរក្សាវប្បធម៌ប្រពៃណីរបស់ខ្លួននៅឡើយ ។

សរុបសេចក្តីមក តាមរយៈការសិក្សាស្រាវជ្រាវខាងជាតិពន្ធុវិទ្យាគួបផ្សំនឹងបុរាណវិទ្យា យើងអាចដឹងថា ទឹកដីខ្មែរបុរាណ មានទំហំធំធេងអស្ចារ្យ ហើយប្រទេសថៃ លាវ និងវៀតណាមខាងត្បូងនាអតីតកាល ស្ថិតក្នុងបរិវេណនៃអតីតព្រះរាជាណាចក្រកម្ពុជាបុរាណទាំងស្រុង ។ ហើយម្យ៉ាងវិញទៀត វប្បធម៌ខ្មែរនាសម័យបច្ចុប្បន្នវិញ បានបន្តពីសម័យបុរេអង្គរ ពោលគឺសម័យនគរភ្នំ សម័យចេនឡា និងសម័យអង្គរ ។

ភស្តុតាងប្រវត្តិសាស្ត្រទាំងនេះ ជាលក្ខណៈសម្បត្តិដ៏វិសេសវិសាលនៃទំព័រប្រវត្តិសាស្ត្រកម្ពុជាជាក់ស្តែង ដែលជាប្រភពនៃមោទនភាពជាតិ ទោះជាជនជាតិខ្មែរ បានទទួលនូវវិនាសកម្មគ្រប់បែបយ៉ាងក៏ដោយ ។ ដោយយោងទៅលើមូលហេតុខាងលើនេះ យើងអាចស្វែងយល់អំពីខឿនវប្បធម៌ ព្រមទាំងអត្តចរិតរបស់មនុស្សខ្មែរ ហើយបញ្ជាក់នូវប្រវត្តិសាស្ត្រដើមរបស់ជនជាតិខ្លួនយ៉ាងត្រឹមត្រូវ ។

ដូចនេះ ការបង្ហាញបញ្ជាក់នូវប្រភពនៃវប្បធម៌ អារ្យធម៌ខ្មែរ ដោយសង្កត់ធ្ងន់ទៅលើរាល់ចំណេះចេះដឹង ឬសមិទ្ធិផលសង្គមនានានាសម័យបុរេ

ប្រវត្តិសាស្ត្រ មានសារៈសំខាន់សម្រាប់ថែរក្សាអត្តសញ្ញាណជាតិ ក្នុងសង្គមមួយ ដែលនៅមានភាពផុយស្រួយនៅឡើយ ។ ម្យ៉ាងទៀត កម្មវត្ថុនៃការស្រាវជ្រាវនេះ គឺការបង្ហាញនូវប្រភពរួមនៃវប្បធម៌ អារ្យធម៌ រវាងអម្បូរជាតិមន-ខ្មែរ ឬខ្មែរ-មន និងខ្មែរ ពោលគឺឫសកែវនៃវប្បធម៌ អារ្យធម៌ខ្មែរក្នុងអតីតកាល និងបច្ចុប្បន្នភាពតែប៉ុណ្ណោះ ថ្វីដ្បិតតែមានការផ្លាស់ប្តូរទម្រង់មួយកម្រិតធំក៏ដោយ ។

ដូច្នេះ តាមរយៈនៃការសិក្សាប្រៀបធៀបទិន្នន័យវិទ្យាសាស្ត្រមួយចំនួននេះ យើងអាចប្រមើលមើលនូវនិរន្តរភាពនៃវប្បធម៌ អារ្យធម៌ខ្មែរ ព្រមទាំងតួនាទីជាប្រវត្តិសាស្ត្រនៃជនជាតិខ្មែរ ក្នុងឧបទ្វីបឥណ្ឌូចិននេះ តាំងពីសម័យបុរេប្រវត្តិសាស្ត្រ រហូតដល់មកបច្ចុប្បន្នភាពនេះ ទោះជាមានការបង្កើតរដ្ឋនគរភ្នំ រដ្ឋស្រីក្សេត្រ និងរដ្ឋទ្វារវត្តី ក្រោយឥទ្ធិពលវប្បធម៌ឥណ្ឌាក៏ដោយ ។

# វិចារណកថា

ការស្រាវជ្រាវនេះ ត្រូវបានចែកជាពីរចំណែកគឺ សម័យបុរេប្រវត្តិសាស្ត្រ និងសម័យប្រវត្តិសាស្ត្រ ។ ក្នុងសម័យបុរេប្រវត្តិសាស្ត្រ យើងនឹងសិក្សាអំពីប្រភពនៃទំនៀមទម្លាប់របស់ជនជាតិខ្មែរ នាសម័យមុនប្រវត្តិសាស្ត្រ ដោយហេតុថា រហូតមកដល់ពេលនេះ គេពុំសូវមានការចាប់អារម្មណ៍លើវប្បធម៌អារ្យធម៌មុនសម័យទទួលវប្បធម៌ឥណ្ឌានោះទេ លើកលែងតែអត្ថបទស្រាវជ្រាវមួយចំនួនតូច ដែលពុំទាន់មានលក្ខណៈសំយោគនៅឡើយ ដោយមូលហេតុផ្សេងៗមួយចំនួន ។ ដូច្នេះ តាមរយៈការរកឃើញនូវវត្ថុវប្បធម៌នាសម័យបុរេប្រវត្តិសាស្ត្រ ដូចជានៅស្ថានីភូមិស្នាយ ក្នុងខេត្តបន្ទាយមានជ័យបច្ចុប្បន្ន យើងអាចស្វែងយល់ ឬបង្ហាញនូវទិន្នន័យថ្មីមួយចំនួន ដែលពាក់ព័ន្ធទៅនឹងឫសកែវនៃអារ្យធម៌ មុនសម័យប្រវត្តិសាស្ត្ររបស់ជនជាតិខ្មែរយើង ដែលស្ថិតនៅក្នុងអម្បូរមន-ខ្មែរ ។ ក្នុងជំពូកទីពីរ យើងនឹងសិក្សាអំពីប្រពៃណីទំនៀមទម្លាប់ខ្មែរមួយចំនួន ដែលបានមានជីវិតរស់រានរហូតដល់សព្វថ្ងៃនេះ ទោះបីជាស្ថិតក្រោមឥទ្ធិពលនៃវប្បធម៌ឥណ្ឌា ឬចិនក៏ដោយ ។ សារៈសំខាន់របស់ជំពូកនេះ គឺបង្ហាញឱ្យឃើញនូវការវិវត្តន៍ និងនិរន្តរភាពនៃលក្ខណៈវប្បធម៌ខ្មែរមួយចំនួន ដែលជាអត្តសញ្ញាណជាតិរបស់ជានជាតិខ្មែរយើង តាមពិតការស្រាវជ្រាវនេះ ដែលទាក់ទងទៅនឹងមត៌កវប្បធម៌មន-ខ្មែរ គ្រាន់តែជាការចាប់ផ្ដើមមួយតែប៉ុណ្ណោះ ព្រោះគេត្រូវផ្សារភ្ជាប់លទ្ធផលនៃការសិក្សាដំបូងរបស់យើងនេះ ទៅនឹងទិន្នន័យទាំងអស់ ដែលបានមកពីស្ថានីយបុរេប្រវត្តិសាស្ត្រក្នុងឧបទ្វីបឥណ្ឌូចិន មុនការធ្វើដំណើរចុះមកទិសខាងត្បូងរបស់ជនជាតិ

អម្បូរចិន ឬម៉ុងហ្គោល ។ សូមបញ្ជាក់ផងដែរថា គេពុំអាចផ្ដាច់វប្បធម៌បុរេប្រវត្តិសាស្ត្រនៃភូមិស្នាយ ក៏ដូចជាវប្បធម៌ម្លូព្រៃ សំរោងសែន ចេញពីវប្បធម៌បុរេប្រវត្តិសាស្ត្រនៃប្រទេសថៃ លាវ និងវៀតណាមឡើយ ដោយមូលហេតុប្រវត្តិសាស្ត្រភូមិសាស្ត្រ និងវប្បធម៌ ។ ម្យ៉ាងទៀត សារៈសំខាន់មួយទៀតនៃការសិក្សាស្រាវជ្រាវរបស់យើង គឺចំណាស់នៃទំនាក់ទំនងខាងវិស័យវប្បធម៌រវាងជនជាតិខ្មែរ និងបរទេស ។ ជាពិសេសជនជាតិចិន និងឥណ្ឌា មុនការបង្កើតរដ្ឋនគរភ្នំ អ្វីដែលពីមុនគេនៅមានការសង្ស័យនៅឡើយ ក៏ប៉ុន្តែឥឡូវនេះ អាចិកំបាំងត្រូវបានលាតត្រដាង ដោយវត្ថុបុរាណនៃភូមិស្នាយ ។

អស់រយៈពេល៤ឆ្នាំមកហើយ ដែលគេបានរកឃើញនូវស្ថានីយភូមិស្នាយនេះ ដែលជាកន្លែងកប់សពមួយយ៉ាងធំជាងគេ ហើយសំខាន់ជាងគេបំផុត ក្នុងទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ក៏ប៉ុន្តែរហូតមកដល់ពេលនេះ នៅតែពុំទាន់មានវិធានការណាមួយហាមឃាត់នៅរាល់ការបំផ្លាញ ឬក៏មានការហាមឃាត់ការជួញដូរនៅទីផ្សានានានៅឡើយដែរ ។

មិនតែប៉ុណ្ណោះសោត ជារៀងរាល់ថ្ងៃ មានពួកជនបរទេសមួយចំនួនដូចជាអង្គការទូតជាដើម បានប្រមូលទិញវត្ថុសិល្បបុរាណ ដើម្បីដឹកយកទៅស្រុកក្រៅ ដោយមានអភ័យឯកសិទ្ធិថែមទៀតផង ។ នេះជាការបំផ្លាញជាតិមួយយ៉ាងធំ ដែលគ្មានក្រសួងណាមួយទទួលខុសត្រូវឡើយ ។

មានតែមន្ត្រីមួយចំនួនតូចប៉ុណ្ណោះ ដែលឈឺចាប់នឹងបញ្ហានេះ ហើយបានចាត់ទុកថា ការជួញដូរវត្ថុបុរាណ ជាអំពើស្មើនឹងការបំផ្លិចបំផ្លាញនូវអត្តសញ្ញាណជាតិខ្មែរ ទោះបីជាចេតនាក្ដី អចេតនាក្ដី បន្តិចម្ដងៗអត្តសញ្ញាណជាតិ

នឹងត្រូវរលាយសាបសូន្យ ដោយមិនដឹងជាសាសន៍អ្វីពិតប្រាកដ ដូចជាប្រវត្តិសាស្ត្ររបស់ចាម ហើយប្រវត្តិសាស្ត្ររបស់ខ្មែរ ក៏កំពុងតែឈានទៅរកសោកនាដកម្មម្តងទៀត ដូចជាការរលំរលាយនៃរាជធានីអង្គរដូច្នេះដែរ ។ តែជាការឥតប្រយោជន៍ ព្រោះគ្មានដាវអាជ្ញាសឹកសម្រាប់អនុវត្តផែនការ ហាមឃាត់ទប់ស្កាត់អំពើខុសច្បាប់ខាងលើនេះឡើយ ។

ចាប់តាំងពីសម័យអង្គររហូតមកដល់បច្ចុប្បន្ននេះ យើងអាចគូសបញ្ជាក់ថា គ្រឹះវប្បធម៌ជាតិយើង ត្រូវបានរង្គោះរង្គើចាប់តាំងពីស.វ.ទី១២ និងទី១៣នៃគ.ស. ដោយមិនស្រាកស្រាន្ត ។ គឺដោយមូលហេតុនេះហើយ ដែលធ្វើឱ្យប្រាង្គប្រាសាទខ្មែរមួយចំនួនធំ បានក្លាយទៅជាគំនរថ្ម រូបចម្លាក់ត្រូវបាត់បង់ និងបែកបាក់ស្ទើរតែទាំងអស់ ។ សល់មួយចំនួនខ្លះដែរ តែការពារមិនបានទៀត ឱ្យជនទុច្ចរិតចូលមកលួចដាប់បំផ្លាញខ្ទេចខ្ទីថែមទៀត ដូចជាប្រាសាទតាព្រហ្ម ប្រាសាទបន្ទាយស្រីជាដើម កាលពីខែកញ្ញា ឆ្នាំ១៩៩៦ កន្លងមកនេះ ។

ទោះជានៅដើមស.វ.ទី២០នេះ មានការជួយជ្រោមជ្រែងដោយអ្នកប្រាជ្ញបារាំង គួបផ្សំជាមួយនឹងវិស្វករខ្មែរខ្លះក៏ដោយ ជាពិសេសទេពកោសល្យរបស់ព្រះមហាក្សត្រខ្មែរ តែទំហំនៃការខូចខាតនៅតែពុំអាចទប់ស្កាត់ឡើងវិញបានមួយរយភាគរយនៅឡើយ ។ ថ្មប្រាសាទខ្មែរ និងរូបចម្លាក់បុរាណ ត្រូវចោរលួចទៅបរទេសថៃចាប់បានហើយក៏ដោយ ក៏មិនប្រគល់ឱ្យខ្មែរវិញដែរ ទាល់តែថា ខ្មែរមានភស្តុតាងបញ្ជាក់ថា ជារបស់ខ្លួន ទើបប្រគល់ឱ្យ តែទោះជាយ៉ាងណាក៏ដោយ បើប្រគល់ឱ្យក៏ប្រគល់តែថ្មមិនសូវមានតម្លៃវិញប៉ុណ្ណោះ ។

ថ្មីៗនេះទៀត គឺចាប់តាំងពីឆ្នាំ១៩៧០រហូតមកទល់បច្ចុប្បន្ននេះ មតិក

វប្បធម៌ខ្មែរទូទាំងប្រទេស ត្រូវបានបំផ្លាញស្ទើរតែទាំងអស់ ។ អំពើខូចខាត ត្រូវបានកត់ដោយអ្នកប្រាជ្ញចិនជូតាក្វាន់ ដែលបានមកប្រទេសកម្ពុជានៅចុង ស.វ.ទី១៣(១២៩៦)នៃគ.ស. បានបញ្ជាក់ថា ប្រទេសមហានគរជំនាន់នោះ ទើបតែបានបញ្ឈប់ច្បាំងជាមួយសៀម ។ ខាងលើនេះជាសង្គ្រាមវាទីនិយម ដែលជនជាតិបរទេសបាននាំមកលើមាតុភូមិខ្មែរ ដើម្បីបំផ្លិចបំផ្លាញ ធ្វើឱ្យខ្ទេចខ្ទីនូវព្រលឹងជាតិងាយស្រួលនឹងត្របាក់យកត្រួតត្រា ។ ទង្វើនេះ មិនខុសពីការប្រល័យពូជសាសន៍ប៉ុន្មានទេ ពីព្រោះនៅពេលដែលទ័ពសៀមមកវាយខ្មែរ នៅខេត្តសៀមរាបម្តង១ ពួកគេប្រើដំរីដើម្បីកម្ទេចប្រាសាទនិងវត្តអារាមនានា ដែលជាទីសក្ការៈរបស់ប្រជាជនខ្មែរ ដោយយកខ្សែពួរចងឱ្យដំរីទាញទម្លាក់ ឱ្យរាបនឹងដី ។ ធ្វើយ៉ាងនេះ ព្រោះគេជឿថា កាលបើកន្លែងណាស័កសិទ្ធិត្រូវ បានគេបំផ្លាញរួមហើយ នៅពេលនោះ ជនជាតិខ្មែរពិតជានឹងមិនអាចងើបមុខរួចទេ។ ព្រោះបារមីនៃវត្ថុស័កសិទ្ធិទាំងឡាយបានរត់ខ្ចាត់ខ្ចាយទៅស្រុកគេអស់ហើយ និងមិននៅការពារកូនចៅឯងបានតទៅទៀតឡើយ ។

ជំនឿនេះ ហាក់ត្រឹមត្រូវដូចនៅក្នុងសម័យទំនើបនេះ ព្រោះស្រុកខ្មែរ ត្រូវបរទេសសង្កត់សង្កិនជាប់ ទាំងសេដ្ឋកិច្ច ទាំងនយោបាយ មិនឃើញរីកចម្រើនអ្វីប៉ុន្មានទេ ទោះជាត្រូវបានចូលរួមក្នុងសមាគមអន្តរជាតិក៏ដោយ ។ ទស្សនៈដ៏ឃោរឃៅនេះហើយ សម្គាល់ដោយគ្រាប់កាំភ្លើង ដោយការទម្លាក់គ្រាប់បែក ការលួចប្លន់វត្តអារាម និងសារមន្ទីរ ព្រមទាំងការជីកគាស់រំលើងគ្រឹះប្រាសាទឥដ្ឋឬថ្ម ឬស្ថានីយបុរេប្រវត្តិសាស្ត្រ ដើម្បីយកវត្ថុបុរាណទៅលក់ដូរ ។ ក្នុងខណៈដែលព្រះអាទិទេពទាល់ច្រកពុំអាចការពារបាន ។ គឺក្នុងបរិបទ

នយោបាយនេះហើយ ដែលយើងឃើញសំណល់នៃព្រះទេវរូប ឬព្រះពុទ្ធរូប បាក់បែកជាច្រើនអន្លើតាមប្រាង្គប្រាសាទសព្វថ្ងៃនេះ ។

នាសម័យអ៊ុនតាក់ ក៏មានការជីកគាស់យ៉ាងធ្ងន់ធ្ងរដែរ ហើយមកសម័យបច្ចុប្បន្នទៀត មិនត្រឹមតែកាត់កព្រះបដិមាចេញទៅបរទេសទេ សូម្បីតែចាន, ឆ្នាំង, ក្រឡ, រូបចម្លាក់ឈើ ដូចជាគ្រឿងអលង្ការបុរាណ ក៏ត្រូវគេជីកចេញទៅបរទេសដែរ ។ ជាការសោកស្ដាយបំផុត ដែលក្រសួងពាក់ព័ន្ធមិនបានចាត់វិធានការឱ្យបានម៉ឺងម៉ាត់ ។

កត្តាមនុស្សមានលក្ខណៈស្រដៀងគ្នាទៅនឹងកត្តាសង្គ្រាម នាសម័យអតីតកាល ។ ដោយសារតែភាពក្រីក្រ ការមិនយល់តម្លៃនៃបុរាណស្ថាន ឬវត្ថុបុរាណ មហិច្ឆិតារបស់មនុស្សចង់មានចង់បានដោយមិនពិចារណា គួបផ្សំនឹងវិទ្ធង្សនារបស់ជនបរទេស ដែលមានគំនិតឈ្នានីសលើខ្មែរ ជាប្រភពនៃការបំផ្លិចបំផ្លាញយ៉ាងដំណំ ។ ដូចនេះ ដើម្បីការពារនូវបេតិកភណ្ឌជាតិ ជាការចាំបាច់បំផុត រដ្ឋត្រូវតែយកចិត្តទុកដាក់អភិវឌ្ឍន៍ជនបទ ជាអាទិភាពចម្បងប្រយោជន៍នឹងកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច ដោយពឹងផ្អែកទៅលើការអប់រំ ដែលជាគន្លឹះសំខាន់ វឌ្ឍនៈភាពជាតិ និងការស្នេហាជាតិ ។ ប្រឈមមុខនឹងការបំផ្លិចបំផ្លាញក្រោមបេតិកភ័ណជាតិរូបភាពនានា តើយើងអាចឱបដៃនៅស្ងៀមបានដែរឬទេ ? ចម្លើយរបស់យើងគឺថាទេ ។ គឺប្រការនេះហើយ ដែលជាមូលហេតុនៃការចងក្រងនេះដែរ ដែលធ្វើឡើងក្នុងបំណងគ្រាន់តែរក្សាស្នាកស្នាមវប្បធម៌ នាសម័យបុរេប្រវត្តិសាស្ត្រ និងដើមប្រវត្តិសាស្ត្រមួយចំនួននៃភូមិស្ថាយកុំឱ្យ សាបសូន្យដូចអំបិលត្រូវថ្ងៃ ។

ស្ថានីយភូមិស្នាយ ស្ថិតក្នុងភូមិស្នាយ ឃុំរហាល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ ស្ថានីយនេះ ជាកន្លែងកប់ខ្មោចដ៏ធំជាងគេក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ដោយមានទំហំដីរាប់សិបហិតា ។ សព្វថ្ងៃនេះ ស្ថានីនេះ កំពុងតែត្រូវអ្នកស្រុកបំផ្លាញ ហើយគេក៏គ្មានវិធានការណាសម្រាប់ទប់ទល់ ការពារនិងការជីករកវត្ថុបុរាណ ដើម្បីលក់ឱ្យឈ្មួញទុច្ចរិតដែរ ។ វិធានការទាំងប៉ុន្មានដែលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានអនុវត្តនឹគ្មានប្រសិទ្ធិភាពខ្ពស់ ព្រោះមន្ត្រីខ្លួនគ្មានឆន្ទៈពិតនិងបង្រ្កាប ដោយមូលហេតុផ្សេងៗ ដែលយើងមិនអាចអធិប្បាយនៅទីនេះ ។ កត្តាដែលសំខាន់ គឺមន្ត្រីដែលទទួលបន្ទុកខាងការពារបេតិកភ័ណ្ឌជាតិ មិនស្គាល់តម្លៃពិតនៃវត្ថុបុរាណទាំងនោះ ដែលពួកគេចាត់ទុកថាជាសិល្បៈបន្ទាប់បន្សំខុសពីចម្លាក់ថ្មធំៗ នៃប្រាង្គប្រាសាទសិលា ។ បើពុំដូច្នោះទេ ពិតជាមិនឈប់មានការជួញដូរវត្ថុបុរាណនៅតាមទីផ្សារនានានោះទេ ។

តាមការវិភាគប្រៀបធៀបវត្ថុវប្បធម៌បុរាណ យើងអាចដឹងថា ស្ថានីយនេះ ស្ថិតនៅក្នុងអន្តរកាលរវាងសម័យបុរេប្រវត្តិសាស្ត្រ រវាង៥០០ឆ្នាំមុនគ.ស. និង៥០០នៃគ.ស. ពោលគឺសម័យវប្បធម៌នគរភ្នំ ។ ក៏ប៉ុន្តែ ទោះជាយ៉ាងនេះក្តី យើងត្រូវរង់ចាំកាលបរិច្ឆេទតាមលក្ខណៈវិទ្យាល័យថ្មីទៀត ដោយក្រុមអ្នកស្រាវជ្រាវទើបធ្វើសេចក្តីសន្និដ្ឋានដាច់ស្រេច ។

វត្ថុវប្បធម៌ដែលគេបានពីស្ថានីយដ៏សំខាន់នេះ ពិសេសរបស់របរប្រើប្រាស់ ដែលជាសំនែនដាក់ក្នុងផ្នូរខ្មោចមានជាអាថិ ក្រឡ. ចាន. ឆ្នាំងគ្រប់ខ្នាតទម្រង់ មានជើងនិងឥតជើង វត្ថុដែលសម្រាប់ធ្វើស្រែចម្ការ ផ្ទៃត្រល់សម្រាប់ត្បាញសំពត់អាវ គ្រឿងអលង្ការ អាវុធ ព្រមទាំងរូបសត្វ និងឆ្អឹងសត្វជាដើម ។

ចំពោះបរិស្ថានសង្គមវប្បធម៌វិញ យើងត្រូវបញ្ចូលស្ថានីយនេះ ក្នុងបរិស្ថានភូមិសាស្ត្រនៃភូមិភាគអាស៊ីអាគ្នេយ៍ ពីព្រោះវប្បធម៌ភូមិស្នាយ គ្រាន់តែជាមែកធាងនៃវប្បធម៌មន-ខ្មែរ នាសម័យបុរេប្រវត្តិសាស្ត្រតែប៉ុណ្ណោះ ។ ធ្វើដូច្នេះ ទើបយើងអាចតាមដានទូវការដុះដាល វិវឌ្ឍន៍ រីកចម្រើន និងការផ្លាស់ប្ដូរទម្រង់វប្បធម៌តាមលំដាប់ថ្នាក់ ពីសម័យបុរេប្រវត្តិសាស្ត្រ ដល់ដើមសម័យប្រវត្តិសាស្ត្រ ។

សារៈសំខាន់ ឬអត្ថប្រយោជន៍នៃស្ថានីយភូមិស្នាយ គឺការផ្ដល់ឱ្យយើងនូវចំណេះចេះដឹងយ៉ាងពិតប្រាកដ អំពីខឿនវប្បធម៌មុនសម័យប្រវត្តិសាស្ត្រ ។ បើនិយាយម្យ៉ាងទៀត ការវិភាគប្រៀបធៀបបុរាណវត្ថុមួយចំនួនតូច ដែលយើងបានទិញមកពីទីផ្សារនានា ព្រោះយើងមិនចង់ឱ្យបរទេសទិញយកចេញទៅប្រទេសក្រៅ បានធ្វើឱ្យយើងដឹងថា ជនជាតិខ្មែរ មានវប្បធម៌របស់ខ្លួនហើយ ដូចជាវប្បធម៌ដាំស្រូវ ឧស្សាហកម្មដីដុត លោហធាតុ និងកែវជាដើម ។

ម្យ៉ាងវិញទៀត តាមការជីកកកាយតាមវិធីសាស្ត្រ យើងក៏អាចឃើញមានស្រទាប់ដីវប្បធម៌ពីរសណ្ឋានខុសផ្ទែកពីគ្នា ។ ក្នុងស្រទាប់ដីដែលចាស់គ្មានវត្ថុវប្បធម៌ ដែលមានលក្ខណៈជាឥណ្ឌា ឬឥណ្ឌូ-ខ្មែរទេ ។ រីឯក្នុងស្រទាប់ដីដែលស្ថិតរវាងស.វ.ទី១ ឬមុននេះបន្តិច ដល់ស.វ.ទី៥នៃគ.ស. យើងសង្កេតឃើញមានការចាក់ឫសនូវវប្បធម៌ឥណ្ឌា ដូចជាការប្រើអង្កាំ, កែវ, ឬថ្ម ឬក៏កំសៀវទឹក ឬកណ្ដិ ។ល។ ដែលមានប្រភពចេញមកពីឥណ្ឌា ។ យោងតាមការសិក្សាវិភាគខាងបុរាណវិទ្យា យើងឃើញមានការផ្លាស់ផ្ដូរវប្បធម៌យ៉ាងប្រាកដ ហើយរីឯវត្ថុវប្បធម៌ក្នុងសម័យនោះ ក៏ប្រកបដោយលក្ខណៈខុសប្លែក

និងសម្បូរណ៍បែបជាងសម័យចុងលោហធាតុ ។

ដូចពោលខាងលើ ស្ថានីយបុរេប្រវត្តិសាស្ត្រភូមិស្នាយ កំពុងស្ថិតក្នុងគ្រោះថ្នាក់ដោយការជីកគាស់ ដែលមិនទាន់ស្រាកស្រាន្តនៅឡើយ ដើម្បីរាវរកវត្ថុបុរាណពីសំណាក់អ្នកស្រុក ដែលឃុបឃិតជាមួយឈ្មួញបរទេស ។ ក្នុងករណីនេះ យើងពិតជានឹងបាត់បង់នូវភស្តុតាងប្រវត្តិសាស្ត្ររបស់ជនជាតិខ្មែរពុំខាន បើសិនជាគ្មានការចងក្រងនូវឯកសារណាមួយសម្រាប់រក្សាទុកទេនោះ ។ អ្វីដែលយើងនឹងខិតខំលាតត្រដាងជាបន្តបន្ទាប់ ក្នុងទំព័រខាងក្រោមនេះ ។

ជាអវសានសូមជម្រាបថា ទំនាក់ទំនងរវាងវប្បធម៌ភូមិស្នាយ និងសហគមន៍មនុស្សនៅក្នុងខេត្តសៀមរាប, អង្គរបុរី, សុរិន្ទ្រ, និងបុរីរម្យ ដែលសព្វថ្ងៃស្ថិតនៅក្នុងបង្គោលសីមានៃទឹកដីថៃ ក៏ដូចតំបន់កំពង់ចាម កំពង់ឆ្នាំង កំពង់ធំជាដើម ពុំមែនជាការចៃដន្យទេ ក៏ប៉ុន្តែ ជាភស្តុតាងនៃសម្ព័ន្ធភាពខាងវប្បធម៌ និងជាតិពន្ធុវិទ្យា ឬថាលើសពីនេះទៅទៀត ជាកត្តាបញ្ជាក់នូវប្រភពរួមនៃខឿនវប្បធម៌មន-ខ្មែរនាសម័យបុរេប្រវត្តិសាស្ត្រ ដែលត្រូវបានបន្តក្នុងគតិណាមួយ រហូតដល់សម័យទំនើបនេះ ។

ជារួម គេបានយល់ច្បាស់ហើយថា មតិកវប្បធម៌ខ្មែរនាសម័យទំនើបនេះ ជាជ្រុងមួយនៃខឿនវប្បធម៌មន-ខ្មែរ ដ៏សម្បូរណ៍បែប ដែលបានប្រសូតចេញពីបុព្វសម័យ មិនមែនមកពីឥណ្ឌាតែម្យ៉ាងនោះទេ ។

លក្ខណៈគោល១នៃខឿនមតិកវប្បធម៌មន-ខ្មែរនេះ ត្រូវបានបំផុសឡើងតាមខ្លឹមសារនៃការសិក្សានេះ ដែលនៅមានកម្រិតទាបនៅឡើយ បញ្ហាកង្វះខាតឯកសារនិងពេលវេលា ។ បើនិយាយម្យ៉ាងទៀត សៀវភៅ(ភាគ១)

នេះ គ្រាន់តែជាការចាប់ផ្ដើមតែប៉ុណ្ណោះ ហើយអ្វីដែលនៅសេសសល់ យើងនិងខំព្យាយាមអធិប្បាយក្នុងពេលដ៏ខ្លីខាងមុខនេះ ឱ្យស្របតាមឆន្ទៈរបស់យើង ដែលបានអនុឡោមតាមការណែនាំរបស់លោកសាស្ត្រាចារ្យហ្ស សឺដេស ដែលថា ខ្មែរគឺជាជនជាតិពួង (ក្នុងន័យជនជាតិខ្មែរដើម) ទទួលឥទ្ធិពលវប្បធម៌ឥណ្ឌាតែប៉ុណ្ណោះ ។

ដូច្នេះ បើទោះបីជាឯកសារនេះ ដែលជាលទ្ធផលនៃការស្រាវជ្រាវជាដំណាក់កាល១ ចង់រៀបរាប់ឱ្យអស់សេចក្ដី ដែលពាក់ព័ន្ធទៅនិងជំនឿមតិកវប្បធម៌មន-ខ្មែរ ក្នុងសង្គមបុរាណ ក៏ដូចជាក្នុងសង្គមបច្ចុប្បន្ន ក៏យើងមិនអាចធ្វើទៅរួមដែរ ឬធ្វើឱ្យពេញលេញគ្រប់ជ្រុងជ្រោយបានដែរ ដ៏រាបណាទាល់តែយើងនិងវិភាគនូវរាល់ទិន្នន័យនៃស្ថានីយបុរេប្រវត្តិសាស្ត្រទាំងអស់ ដែលមានក្នុងឧបទ្វីបឥណ្ឌូចិនយើងនេះ ឬក៏សិក្សាមុខវិជ្ជាផ្សេងៗទៀត ដូចជា ភាសាសាស្ត្រ ចារឹកសាស្ត្រ មនុស្សសាស្ត្រ និងភូមិសាស្ត្រ ប្រវត្តិសាស្ត្រជាដើម ។

ទោះជាយ៉ាងណាក៏ដោយ សម្ព័ន្ធភាពរវាងមុខវិជ្ជាមូលដ្ឋានជាច្រើនដូចដែលទើបពោលខាងលើ ត្រូវតែពង្រឹងពង្រីកដោយការខិតខំប្រឹងប្រែងផ្ទាល់របស់អ្នកស្រាវជ្រាវយើង ដើម្បីឈានទៅរកការស្វែងយល់ដែលមានលក្ខណៈ សំយោគទូលំទូលាយនូវជំនឿនវប្បធម៌មន-ខ្មែររួម ។

ចំពោះលទ្ធផលនៃការខិតខំប្រឹងប្រែងប្រមូលទិន្នន័យថ្មីៗទៀត ដែលមានប្រភពផ្សេងៗ យើងនិងផ្សព្វផ្សាយក្នុងពេលខាងមុខនេះទៀត ។ រីឯវត្ថុបុរាណមួយចំនួនដែលយើងបានទិញពីផ្សារសៀមរាប ទួលទំពូង និងបាត់ដំបងជាដើម ដែលគេចាត់ទុកថាគ្មានសារសំខាន់ យើងនិងថែរក្សាវា ក្រោយពីធ្វើ

បញ្ជីសារពើភ័ណ្ឌរួម ចៀសវាងការចោទប្រកាន់នានា ដែលកើតចេញពីការប្រែណែនល្បានីស្តត្តាក្នុងការដែលគ្មានការហាមឃាត់ ឬបង្រ្កាបឈ្មួញទុចរិតលក់ដូរវត្ថុសិល្បៈបុរាណទាំងនោះ ។ ក្នុងករណីនេះ យើងនឹងខិតខំបញ្ចប់ការសាងសង់នូវសារមន្ទីជាតិពន្ធុវិទ្យាមួយ សម្រាប់តម្កល់វត្ថុសិល្បៈទាំងនោះ ប្រយោជន៍នឹងថែរក្សាស្នាកស្នាមវប្បធម៌បុរាណកុំឱ្យបាត់បង់តទៅទៀត ។ អ្វីដែលយើងធ្វើនេះ គឺគ្រាន់តែជាតំណក់ទឹកមួយតំណក់ក្នុងមហាសាគរតែប៉ុណ្ណោះ ក៏ប៉ុន្តែដូចព្រះភិក្ខុពិន សែម ដែលមានកូនសារមន្ទីរឯកជននៅក្នុងវត្តបូរាណនៅខេត្តសៀមរាប ក្នុងនាមយើងជាអ្នកស្រឡាញ់វប្បធម៌ជាតិ យើងត្រូវខិតខំធ្វើ ទោះជាមានការលះបង់ច្រើនយ៉ាងណាក៏ដោយ បើពុំដូច្នោះទេ អ្វីៗដែលជាគ្រឹះ ឬមូលដ្ឋានគ្រឹះនៃខឿនវប្បធម៌ជាតិ នឹងត្រូវបាត់បង់ទាំងអស់ពុំខាន បើគ្មានការអភិរក្ស ឬការសិក្សាស្រាវជ្រាវណាមួយទេនោះ ។

ឆ្លៀតក្នុងឱកាសនេះ យើងក៏សូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រៅលជ្រៅបំផុត ចំពោះសម្តេចព្រះ ***នរោត្តមបុប្ផាទេវី*** អតីតរដ្ឋមន្ត្រីនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលបានអនុវត្តអនុសាសន៍អភិរក្សសម្រាប់អភិវឌ្ឍ និងអភិវឌ្ឍសម្រាប់អភិរក្ស ដ៏ថ្លៃថ្លារបស់រាជរដ្ឋាភិបាល ដែលដឹកនាំដោយសម្តេច ***ហ៊ុន សែន*** នាយករដ្ឋមន្ត្រី បានអនុញ្ញាតិច្បាប់ឱ្យបើកសារមន្ទីរជាតិពន្ធុវិជ្ជាខាងលើនេះរបស់យើងហើយ ក៏ប៉ុន្តែយើងពុំទាន់មានលទ្ធភាពនិងបើកនៅឡើយ ដោយបញ្ហាថវិកា និងបច្ចេកទេស ។

ក៏ប៉ុន្តែ យើងសង្ឃឹមយ៉ាងមុតមាំថា មិនយូរប៉ុន្មានទេ ប្អូនៗនិស្សិតអ្នកស្រាវជ្រាវជាតិនិងអន្តរជាតិ ឬក៏ទេសចរណ៍អាច និងគយគន់នូវមតិកវប្ប

ធម៌មន-ខ្មែរទាំងនេះពុំខាន ហើយជួយផ្សព្វផ្សាយផង នេះជាអ្វីដែលជាវត្ថុបំណងដ៏ពិសិដ្ឋរបស់អ្នកនិពន្ធយើង ហើយម្យ៉ាងទៀត វាក៏ជាការរួមវិភាគទានមួយដ៏ធំធេង ដែលយើងបានធ្វើសម្រាប់ឧត្តមប្រយោជន៍ជាតិ ។ កុំភ្លេចថាមនុស្សស្លាប់តែស្លាដៃនៅរស់ លើសពីនេះទៅទៀតវាក៏ជាន័យនៃជីវិតរបស់យើងដែរ ។

## ជំពូក១

ដើមកំណើតនិងមូលដ្ឋានគ្រឹះជាប្រវត្តិសាស្ត្រនៃវប្បធម៌ អារ្យធម៌ ប្រវត្តិសាស្ត្ររបស់ជនជាតិខ្មែរ ។

### ១.តើជនជាតិខ្មែរមកពីណា ?

បញ្ហាដែលចោទនៅទីនេះ គឺជាបញ្ហាសំខាន់បំផុត ដោយហេតុថា វាពាក់ព័ន្ធទៅនឹងប្រទេសជាតិ និងវប្បធម៌ អារ្យធម៌ខ្មែរទាំងមូល ។ យ៉ាងណាមិញ សំណួរខាងលើនេះ ក៏ទាក់ទងទៅនឹងសមិទ្ធិផលសង្គមទាំងឡាយ ដែលគេបានរកឃើញនៅក្នុងលំនៅស្ថាន កន្លែងផ្នូរកប់ខ្មោច វត្ថុសិល្បៈបុរាណ ដែលមានអាយុរាប់ពាន់ឆ្នាំមកហើយ ដូចជាក្នុងស្ថានីយបុរេប្រវត្តិសាស្ត្រ ។ មុនការហូរចូលនៃជនជាតិឥណ្ឌា និងថៃ វៀតណាមក្នុងឧបទ្វីបឥណ្ឌូចិនយើងនេះ ។

តាមការស្រាវជ្រាវរបស់យើង ដោយផ្អែកទៅលើការវិភាគនៃបុរាណវត្ថុ បានឱ្យយើងដឹងថា សម្ព័ន្ធភាព និងឯកភាពនៃវត្ថុបុរាណនាសម័យបុរេប្រវត្តិសាស្ត្រ និងប្រវត្តិសាស្ត្រ ដែលបុព្វការីជនខ្មែរបានប្រើប្រាស ហើយវាជាសំណង់មូលដ្ឋាននៃវប្បធម៌ខ្មែរ បញ្ជាក់នូវនិរន្តរភាពរបស់ខឿនវប្បធម៌ខ្មែរ ព្រមទាំងការកាន់កាប់ភូមិភាគឥណ្ឌូចិននេះ ដោយជនជាតិខ្មែរតាំងតែពីអតីតកាល រហូតដល់បច្ចុប្បន្នកាល ។

សូមបញ្ជាក់ថា គេអាចផ្សាភ្ជាប់សំណង់វប្បធម៌សម័យបុរេប្រវត្តិសាស្ត្រ ( មុន២០០០ឆ្នាំ និងសម័យប្រវត្តិសាស្ត្របាន លុះត្រាតែវត្ថុសិល្បៈទាំងនោះ ដែលបានផលិតឡើងដោយសហគមន៍មនុស្ស មានទម្រង់ ឬខ្នាតដូចគ្នា

ឬស្រដៀងគ្នា) ។ ឧទាហរណ៍ដូចជា ការប្រើគ្រសាលត្រចៀក ដើម្បីលំអររូបរាងកាយមនុស្ស ខ្មែរនិងពួងទាំងពីរប្រភេទ ។ កត្តានេះហើយ ដែលជាភស្តុតាងជាក់ស្តែងបញ្ជាក់នូវដើមកំណើតពូជសាសន៍ និងប្រភពវប្បធម៌រួមរវាងខ្មែរនិងខ្មែរលើ ។ ពោលគឺអ្វីដែលគេពុំអាចប្រៀបធៀប និងខឿនវប្បធម៌នៃជនជាតិថៃវៀត ឬវៀតណាមដែលមានលក្ខណៈចិន ។

ការស្រាវជ្រាវខាងលើនេះ សមស្របនឹងសេចក្តីសន្និដ្ឋានរបស់លោកសស្ត្រាចារ្យហ្សកសឺដេស ដែលបានពោលថា ជនជាតិខ្មែរគឺជាពួង ដែលទទួលឥទ្ធិពលឥណ្ឌាតែប៉ុណ្ណោះ ។ មានន័យថា ខ្មែរជាជនជាតិមួយ ដែលបានកកើតឡើងនៅលើទឹកដីនេះ ឬជាអ្នកស្រុក ហើយបានតពូជពង្សតាំងពីសម័យបុរេប្រវត្តិសាស្ត្ររហូតសម័យបច្ចុប្បន្ននេះ ក៏ប៉ុន្តែជនជាតិនេះ គ្រាន់តែបានទទួលនូវអានុភាពវប្បធម៌ពីឥណ្ឌានាសម័យគ្រឹស្តតែប៉ុណ្ណោះ ។ តាមពិត គឺការទទួលឥទ្ធិពលវប្បធម៌ឥណ្ឌា ដែលមានរបៀបគ្រប់គ្រងដោយមានព្រះរាជាជាប្រមុខ ការប្រារព្ធនិយមព្រាហ្មសាសនា និងព្រះពុទ្ធសាសនា និងការនិយមអក្សរ បានធ្វើឱ្យខ្មែរនៃវាលទំនាបទាំងឡាយ មានភាពរុងរឿងធ្វើការលឿន ហើយក្លាយខ្លួនជាអរិយប្រទេសដ៏ល្បីល្បាញខុសពីបងប្អូនខ្មែរលើតែប៉ុណ្ណោះ នេះសឱ្យឃើញថា ជនជាតិខ្មែរនិងខ្មែរលើ ជាជនជាតិតែមួយខុសពីពូជសាសន៍ដទៃៗទៀត ។

ម្យ៉ាងទៀត គប្បីយើងពិនិត្យនូវកាលប្បវត្តិនៃប្រវត្តិសាស្ត្រកម្ពុជាឱ្យបានច្បាស់លាស់ជាមុនសិន មុនឈានជើងទៅវិភាគនូវបញ្ហាផ្សេងៗ ដែលយើងយល់ថា ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ។ គឺក្នុងន័យខាងលើនេះហើយ ដែលយើង

អាចសន្និដ្ឋានបានថា ជនជាតិខ្មែរ ពិតជាជនជាតិដែលកើតនៅលើទឹកដីដូនតាខ្លួនយ៉ាងពិតប្រាកដ ដូចជាបទចម្រៀងដែលគេចូលចិត្តច្រៀង "ជនជាតិខ្មែរកើតនៅលើដីខ្មែរ តែងតែយើងថែឱ្យបានរុងរឿង......." ។

ម្យ៉ាងវិញទៀត ជនជាតិខ្មែរស្ថិតក្នុងអម្បូរណ៍មន-ខ្មែរ ខុសពីជនជាតិថៃ លាវ វៀតណាម ដែលស្ថិតនៅក្នុងអម្បូរណ៍ចិន ដែលមានលំនៅស្ថានដើមនៅក្នុងប្រទេសចិនភាគខាងត្បូង ។

## ២-ស្ថានីយបុរេប្រវត្តិសាស្ត្រនៅឥណ្ឌូចិន ជាកម្មសិទ្ធិរបស់ជនជាតិណា ?

ក្នុងការស្រាវជ្រាវផ្នែកបុរាណវិទ្យា តើជនជាតិណា មនុស្សណា ដែលបានផលិតវត្ថុបុរាណ លំនៅស្ថាន ឬក៏សំណង់វប្បធម៌បុរាណ ដែលគេបានរកឃើញយ៉ាងច្រើននៅក្នុងប្រទេសថៃ លាវ កម្ពុជា និងវៀតណាមបច្ចុប្បន្ននេះ ?

សំណួរនេះ ត្រូវបានបកស្រាយថា ជនជាតិខ្មែរ គឺជាជនជាតិចាស់ជាងគេនៅលើជ្រោយឥណ្ឌូចិនយើងនេះ រីឯជនជាតិដទៃទៀត គឺជាជនជាតិចំណូលថ្មី អាចនិយាយបានថា ជាអ្នកតវេនពីមនុស្ស ឬវប្បធម៌នាសម័យបុរេប្រវត្តិសាស្ត្រមុនអង្គរ និងអង្គរ បើនិយាយម្យ៉ាងទៀត យើងអាចសន្និដ្ឋានបានថា គ្រប់សមិទ្ធិផលសង្គមជាកម្មសិទ្ធិរបស់ជនជាតិខ្មែរដើម ។ មិនមែនដូចជាគេនិយាយថា បុរាណស្ថានដែលគេបានរកឃើញនៅក្នុងប្រទេសថៃ ឬវៀតណាមខាងត្បូងសព្វថ្ងៃនេះ មិនមែនជាកេរមតិកវប្បធម៌ខ្មែរនោះទេ ។

បើយើងរាល់គ្នាតាមដាន ឬស្រាវជ្រាវស្នាកស្នាមនៃមនុស្សខ្មែរ យើង

ពិតជាឃើញថា ដូនតារបស់ជនជាតិខ្មែរយើង (មនខ្មែរ ឬខ្មែរមន) បានបន្សល់ទុកនូវស្ថានីយប្រវត្តិសាស្ត្ររាប់ម៉ឺនកន្លែងក្នុងឧបទ្វីបឥណ្ឌូចិន ទោះបីទឹកដីត្រូវបាននៅសល់តូចដូចបច្ចុប្បន្ននេះក៏ដោយ ប៉ុន្តែបុរាណស្ថានប្រវត្តិសាស្ត្រទាំងនោះ ពិតជាសមិទ្ធិផលរបស់ជនជាតិខ្មែរដដែល ។

ថ្វីត្បិតតែខឿនវប្បធម៌ អារ្យធម៌ខ្មែរ ត្រូវបានទទួលនូវសន្ទុះថ្មី ក្រោមឥទ្ធិពលឥណ្ឌា និងចិន ក៏ប៉ុន្តែ នៅតែថែរក្សាលក្ខណៈសម្គាល់របស់ខ្លួនយ៉ាងពិតប្រាកដ ។

យើងអាចបញ្ជាក់បានថា ការរកឃើញនូវសាកសពនាសម័យបុរេប្រវត្តិសាស្ត្រ បានអះអាងឱ្យឃើញយ៉ាងប្រាកដថា ជនជាតិខ្មែរ គឺជាជនជាតិដើម ដែលទទួលឥទ្ធិពលឥណ្ឌូបនីយកម្ម ។

គួររំលឹកថា នៅសម័យសិរិទ្ធិ១៥០០ឆ្នាំមុនគ.ស. រហូតដល់បច្ចុប្បន្នបង្ហាញថា ជនជាតិខ្មែរ នៅតែនិយមត្រសាល់ត្រចៀកជាគ្រឿងតុបតែង ។ តាមការស្រាវជ្រាវបន្តរហូតបានឱ្យដឹងថា ក្នុងសម័យដែលជនជាតិខ្មែរមានទំនាក់ទំនងជាមួយជនជាតិអឺរ៉ុបនៅស.វ.ទី១៦-១៧មក ប្រពៃណីនេះ ត្រូវសាបសូន្យបន្តិចម្តងៗ រហូតដល់ដើមស.វ.ទី២០ទើបរលត់ ។

សរុបសេចក្តីមក វត្ថុបុរាណជាប្រភពនៃវប្បធម៌ អារ្យធម៌ ។ តូចក្តី ធំក្តី វាឆ្លុះបញ្ចាំងនូវកំណើតប្រពៃណី ព្រមទាំងនិរន្តរភាពរបស់ខឿនវប្បធម៌នៃជនជាតិមន-ខ្មែរ ដែលជាជនជាតិដើមនៅឧបទ្វីបឥណ្ឌូចិន មុនការហូរចូលនៃជនជាតិថៃ វៀតណាម ។

តាមការស្រាវជ្រាវរបស់លោកហ្សេរ៉ាហ្គេសឡាំង អ្នកប្រវត្តិវិទូបាន

ឱ្យដឹងថា ដើមឡើយជនជាតិយួនមានឈ្មោះថា យេ (Yué) ហើយជនជាតិនេះ គឺជាជនជាតិចិនបុរាណ ឬបើនិយាយម្យ៉ាងទៀតគឺពួងចិន ។ ប្រភពឯកសារជាច្រើនបានបញ្ជាក់អំពីដើមកំណើតចិន របស់ជនជាតិយួន ។

តទៅនេះ គឺជាប្រភពពតិមានមួយចំនួន ដែលយើងត្រូវលើកយកមកបកស្រាយ ដើម្បីជូនជាពតិមានអំពីដើមកំណើយយួន ។

**ប្រភពរបស់ពាក្យយួន និងស្រុកកំណើតដើម**

ប្រភពឯកសារចិនបានឱ្យដឹងថា ដើមឡើយជនជាតិយួន (YOUN) មានឈ្មោះថា វៀត (VIET) ដែលចិនហៅថា យេ (YUE)។ ចិនបានឱ្យដឹងទេត្យតថា ស្រុកកំណើតរបស់ជនជាតិយួនមានឈ្មោះថាណានយេ (NAN YUE) ដែលមានន័យថា យេនៃភាគខាងត្បូង បើប្រៀបធៀបទៅនឹងប្រទេសចិន ដែលស្ថិតនៅភាគខាងជើង ។

ម្យ៉ាងទៀតសូមជម្រាបថា ចំណែកពាក្យចិនណាន (NAN)វិញ ជនជាតិយួនប្រើពាក្យណាម (NAM) ដែលមានន័យដូចគ្នា ជំនួសទៅវិញ ដូចដែលបានពោលខាងលើ ។ គប្បីជម្រាបថា ចំពោះពាក្យណានយេ (NAN YUE) ឬណាមយេ (NAM YUE) ជនជាតិយួនបានប្រើពាក្យណាមវៀត (NAM VIET) ឬវៀតណាម (VIET NAM) ដែលមានន័យដូចពាក្យចិនខាងលើនេះ ទៅវិញ ។

សរុបសេចក្ដីមក គេអាចកំណត់ថា ដើមឡើយជនជាតិយួន ឬវៀត ជាអម្បូរចិន ក្នុងភូមិភាគខាងត្បូងនៃចក្រភពចិន មុនការធ្វើដំណើរឆ្ពោះទៅកាន់ទិសខាងលិច ។

ឥឡូវ សូមក្រឡេកមើលទីតាំងរបស់ស្រុកដើមនៃពួកណាមយេ ឬ

ណាមវៀតវិញម្តង ។ ដើម្បីបញ្ជាក់បញ្ហានេះ យើងត្រូវដកស្រង់ពតិមានស្តីពីភូមិសាស្ត្រនៃប្រទេសចិនបុរាណ ។

## ស្រុកកំណើតដើមរបស់ជនជាតិយេ ឬយួន

ទាក់ទងទៅនិងករណីនេះ យើងត្រូវដឹងថា ព្រំប្រទល់ ឬបង្គោលសីមានៃបុព្វបុរសនៃជនជាតិយេ ឬវៀត គឺស្ថិតនៅយ៉ាងជ្រៅក្នុងបច្ចុប្បន្នប្រទេសចិន ពោលគឺនៅខេត្តកាំងតុង ដែលស្ថិតឆ្ងាយពីព្រំប្រទល់យៀកណាមខាងជើងសព្វថ្ងៃ ។ តាមពិតទីតាំងនេះ មិនឆ្ងាយពីទន្លេខៀវស៊ីនសេតាំងប៉ុន្មានទេ ។ នេះជាស្ថានភាពភូមិសាស្ត្រដើម ជាប្រវត្តិសាស្ត្រនៃជនជាតិយួន ។

ព្រឹត្តិការណ៍មួយទៀតយ៉ាងសំខាន់ ក៏អាចបញ្ជាក់ឱ្យយើងដឹងថា អ្វីដែលបានពោលខាងលើវាជាការពិត ។ តាមរយៈកំណាយផ្នូរខ្មោចនៃស្តេចយេ (YUE) មួយអង្គ ដែលគេបានធ្វើឡើងនៅខេត្តកាំងតុង ហើយក្រោយពីការវិភាគឯកសារជាលាយល័ក្ខណ៍អក្សរ និងវត្ថុបុរាណមួយចំនួន យើងអាចដឹងថាតំបន់ណានយេមែន យ៉ាងហោចណាស់ក៏ចាប់តាំងពីដើមរៀងរបួតមកដល់ឆ្នាំ ១៣០០ នៃគ.ស. ។

ក្នុងអំឡុងពេលនេះ ជនជាតិយេ ឬយួន បានប្រកាន់យកយ៉ាងជាប់លាប់ នូវសំណង់វប្បធម៌ចិនបុរាណសុទ្ធសាធ ។

ដូចនេះ ការដែលអ្នកនយោបាយយួនសព្វថ្ងៃខិតខំកែប្រែអម្បូរដើមជាអម្បូរចិនទៅជាអម្បូរខ្មែរ-មនពុំមានលក្ខណៈជាវិទ្យាសាស្ត្រទេ ។ តាមពិតអ្វីដែលពួកគេបានអះអាងនេះ គឺគេគ្រាន់តែធ្វើឡើងតាមបន្ទាត់នយោបាយរបស់អ្នកដឹកនាំយួន ឬវៀតណាម ដើម្បីប្រឆាំងនឹងចិនតែប៉ុណ្ណោះ ។ ម្យ៉ាង

ទៀត ប្រហែលជាគេធ្វើឡើងសម្រាប់ធ្វើឱ្យស្របច្បាប់ នូវវត្តមានចុះច្បាប់របស់ជនជាតិវៀតណាម ដោយហេតុថា ដូនតាពួកគេជាអន្តោប្រវេសន៍ ដែលបានភៀសខ្លួនពីស្រុកចិនខាងត្បូងរវាងស.វ.ទី៣មុនគ.ស. ឆ្ពោះទៅកាន់ភូមិភាគឥណ្ឌូចិននេះ ។ ទោះជាពួកគេបំផ្លើសបំភ្លែការពិតយ៉ាងណាក៏ដោយ ដើម្បីឱ្យខ្លួនខុសប្លែកពីចិន ក៏ពួកគេមិនអាចបិទបាំង ឬពន្លិចនូវខឿនវប្បធម៌ចិន នាអតីតកាល និងបច្ចុប្បន្នកាលរបស់ខ្លួនទាំងស្រុងបានដែរ ។

មជ្ឈដ្ឋានយួន ឬវៀតណាម សុទ្ធតែដឹងថា ដើមកំណើតរបស់ខ្លួនជាចិន ហើយវប្បធម៌ អារ្យធម៌របស់ជាតិខ្លួន បានកើតចេញពីប្រភពពីពុម្ពតែមួយជាមួយជនជាតិចិនបុរាណ ដែលមានអាយុច្រើនពាន់ឆ្នាំមកហើយដែរ មុនការបង្កើតរដ្ឋយួននៅក្នុងភូមិភាគវៀតណាមខាងជើងសព្វថ្ងៃ ។

អ្នកបុរាណវិទ្យាខ្មែរមួយចំនួនបានយល់ទៅ និងការស្រាវជ្រាវរបស់លោកហ្សេរ៉ាហ្គេសឡាំង ពីព្រោះតាមការវិភាគទៅលើបុរាណវត្ថុ គេអាចសម្គាល់ទម្រង់វប្បធម៌ ដោយសារវប្បធម៌របស់បុព្វបុរសជិតនៃជនជាតិវៀតណាមសព្វថ្ងៃនេះ ពុំមែនជាវប្បធម៌របស់វៀតណាមឡើយ ។

ការសន្និដ្ឋានបានបញ្ជាក់ថា ជនជាតិយួនមានដើមកំណើតជាជនជាតិមួយស្ថិតនៅក្នុងអម្បូរចិន មិនខុសពីជនជាតិថៃ និងលាវឡើយ ហើយជនជាតិនេះ បន្តិចម្តងៗ បាននិរទេសចេញពីទឹកដីកំណើតរបស់ខ្លួន ដោយការវាយលុកវាតទីនិយមឥតឈប់ឈរ ពីអំណាចកណ្តាលនៃជនជាតិចិន អាស្រ័យហេតុនេះហើយ បានជាកំហឹងរវាងចិន និងយួនបានក្លាយទៅជាសមរភូមិ ដែលដើមឡើយស្ថិតក្នុងអម្បូរចិនតែមួយ ។

សូមជម្រាបថា ជនជាតិថៃ-លាវក៏ស្ថិតនៅក្នុងអម្បូរចិនដូចគ្នាដែរ ដោយសារប្រការនេះហើយ បានជាគេឱ្យឈ្មោះថាអម្បូរថៃ-វៀត ។

ដូចលោកសាស្ត្រាចារ្យឡុង សៀម យើងគឺតឃើញថា ការបញ្ចូលជនជាតិខ្មែរ និងកុលសម្ព័ន្ធមន-ខ្មែរ ដែលជាខ្មែរព្រៃក្នុងអម្បូរយូន ឬយៀក ជាការខុសឆ្គងមួយយ៉ាងធំ ដែលគេធ្វើឡើងក្នុងក្របខ័ណ្ឌនយោបាយ ។

## ៣.ដែនដីសុវណ្ណភូមិនាសម័យវប្បធម៌លោហធាតុ

ជនជាតិខ្មែរ ដែលស្ថិតក្នុងអម្បូរមន-ខ្មែរ មានវប្បធម៌របស់ខ្លួនហើយ មុនការទាក់ទងជាមួយឥណ្ឌា ចិន ។ ពឹងផ្អែកទៅលើសេដ្ឋកិច្ច ដែលមានពាណិជ្ជកម្ម ការផ្សាំងសត្វ និងការធ្វើកុលាភាជន៍ប្រើប្រាស់ជាមូលដ្ឋានវប្បធម៌យុគថ្មរំលីង បានរីកដុះដាលទូទាំងភូមិភាគអាស៊ីអាគ្នេយ៍ ដោយបានបន្សល់ទុកនូវបុរាណស្ថានជាច្រើនកន្លែង នៅលើទឹកដីឥណ្ឌូចិនបច្ចុប្បន្ន ។ ការបរបាញ់សត្វ ការដាំដើមឈើសម្រាប់យកផ្លែ មើមមកបរិភោគ និងការនេសាទត្រី ក៏បានរួមវិភាគទានក្នុងសេដ្ឋកិច្ចសង្គមនាសម័យនោះដែរ ។ បន្តិចម្តងៗ វប្បធម៌ថ្មរំលីងក៏ត្រូវបានផ្លាស់ប្តូរទម្រង់វប្បធម៌ ហើយឈានចូលយុគវប្បធម៌លោហធាតុ ។

ការរកឃើញនិងការនិយមលោហធាតុ (ស្ពាន់, សំណ និងដែក) ដើម្បីធ្វើអាវុធ ឧបករណ៍សម្រាប់ធ្វើកសិកម្ម និងគ្រឿងអលង្ការ ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយយ៉ាងសំខាន់បំផុត ហើយដែលគេអាចចាត់ទុកថា ជាការបដិវត្តន៍សង្គម និងវប្បធម៌ដ៏សម្បើមអស្ចារ្យរបស់មនុស្សខ្មែរ នាសម័យមុនឥណ្ឌាវូបនិយកម្ម មូលហេតុនៃការសន្និដ្ឋានខាងលើនេះ បណ្តាលមកពីការផលិតនូវ

សំរិទ្ធិដោយកុលសម្ព័ន្ធ ដែលជាបុព្វហេតុនៃការបង្កើតសង្គ្រាម ដោយសហគមន៍មនុស្ស ដែលពុំធ្លាប់មានពីមុនមក ដែលជាកត្តាឆ្ពុះបញ្ជាំងឱ្យឃើញនូវការលេចធ្លោនូវអំណាចកណ្តាល ដឹកនាំដោយមេទ័ព មេកន្ទ្រាញសំខាន់ៗ មុនសម័យប្រវត្តិសាស្ត្រ ។

ការផលិតដែក និងសំរិទ្ធិ ក៏ជាមូលហេតុនៃការបង្កើននូវចំនួនប្រជាជនផងដែរ ។

"ពីមុនគេជឿថា សម័យវប្បធម៌លោហធាតុ បានផ្តើមឡើងនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ នៅស.វ.ទី៣ មុនគ.ស.ប៉ុណ្ណោះ ។ ថ្មីៗនេះការវិភាគនូវឧបករណ៍សំរិទ្ធិតាមវិទ្យុសកម្ម (C 14) បានឱ្យដឹងថា បុព្វបុរសខ្មែរបានបង្កើតដោយនិយមប្រើប្រាស់សំរិទ្ធិ និងទង់ដែង រវាងពី២000ឆ្នាំ ទៅ១៥00ឆ្នាំមុនគ.ស. ពោលគឺមុនការទំនាក់ទំនងវប្បធម៌ឥណ្ឌា និងចិន ។

ចំណាស់នៃឧស្សាហកម្មលោហធាតុនៃបុព្វបុរសខ្មែរ មានអាយុប្រ-ហាក់ប្រហែល និងលោកធាតុនៃប្រទេសអេហ្ស៊ីប (egypt) ដែរ ។

ឆ្លងកាត់ការស្រាវជ្រាវថ្មីៗនេះ អ្នកប្រាជ្ញមួយចំនួនបានសន្និដ្ឋានថា ដែនដីខ្មែរ ដែលប្រែថា " សុវណ្ណភូមិ" ដែនដីមាសនោះ គឺជាដែនដីសំរិទ្ធិទៅវិញទេ ឬ "សំរិទ្ធិភូមិ"។ " ម្យ៉ាងវិញទៀត គឺការប្រើនូវលោហធាតុដូចជាសំរិទ្ធិ និងមាសខាងលើនេះ បានធ្វើឱ្យទីតាំងភូមិសាស្ត្រនេះថា សុវណ្ណភូមិ ឬដែនដីមាស ។

## ៤.អត្ថតាងនៃទំនាក់ទំនងវប្បធម៌ជាមួយចិន ស្គរមហាធឹកសិរិទ្ធិនៅភូមិស្នាយ

ក្នុងសង្គមខ្មែរបច្ចុប្បន្ន មានមនុស្សជាច្រើនជឿថា គេអាចរស់នៅយ៉ាងសុខស្រួល ដោយមិនបាច់គិតពីអតីតកាល ដោយហេតុថា បញ្ហានេះ គឺជាបញ្ហារបស់លោកអ្នកស្រាវជ្រាវខាងប្រវត្តិសាស្ត្រទេ ។ ទស្សនៈបែបនេះ ពិតជានាំមកនូវផលវិបាកជាច្រើន ព្រោះថា បានផ្ដាច់ជាតិខ្មែរ ដែលមានប្រវត្តិសាស្ត្រដ៏យូរលង់ពីឫសកែវនៃវប្បធម៌ អារ្យធម៌របស់ខ្លួន ។

ទង្វើដ៏ប្រពៃសម្រាប់ប្រជាជនខ្មែរ ដើម្បីស្ដារព្រលឹងជាតិរបស់ខ្លួន គឺការស្វែងយល់អំពីអតីតកាល និងការរក្សាអតីតកាលរបស់ជនជាតិខ្លួន តាមរយៈការអប់រំ ដែលជាអាទិភាព បើពុំដូច្នោះទេ ជ្រុងមួយនៃខឿនសតិសម្បជញ្ញ និងបង់ពុំខាង ។ ទិសដៅនៃអត្ថបទនេះ ស្ដីពីប្រភពនៃស្គរសិរិទ្ធិហៅទឹកភ្លៀង ឬស្គរមហាធិក ព្រមទាំងអត្ថប្រយោជន៍របស់ឧបករណ៍នេះ ក្នុងវប្បធម៌ខ្មែរ ។

យោងតាមគំហើញថ្មី១ខាងបុរាណវិទ្យា ដែលបានមកពីភូមិស្នាយ ក្នុងខេត្តបន្ទាយមានជ័យ គប្បីយើងត្រូវពិចារណាឡើងវិញ ចំពោះសម្មតិកម្មស្ដីពីប្រភពនៃស្គរមហាធឹក ដូចដែលបានសរសេរក្នុងសៀវភៅមួយចំនួន ។ ដូចគ្នាដែរ ចំពោះចំណាស់នៃឧស្សាហកម្មលោហធាតុ នាសម័យបុរេប្រវត្តិសាស្ត្រដែលគេជឿថា មានអាយុត្រឹមតែស.វ.ទី៣-២មុនគ.ស.តែប៉ុណ្ណោះ ។

ការសិក្សាថ្មីមួយរបស់យើង........បានឱ្យឃើញថា ប្រជាជនដែលបានសាងវប្បធម៌ភូមិស្នាយ បាននិយមស្គរមហាធឹកធ្វើអំពីសិរិទ្ធិ ដូចនៅតំបន់នានាក្នុងភូមិភាគឥណ្ឌូចិន ។ ដូចការរកឃើញបំណែកស្គរនៅភូមិស្នាយ និងនៅមេ

មត់ជាសក្ខីភាពស្រាប់ ដោយឥតប្រកែកបានឡើយ ។

ដូចនេះ តាមរយៈការកឃើញនូវវត្ថុវប្បធម៌បុរាណនេះ តម្រូវឱ្យយើងកែប្រែចំណុចមួយចំនួននៃប្រវត្តិសាស្ត្រកម្ពុជា ។ នៅទីនេះ យើងកាន់ទស្សនៈមួយដែលថា បុរេប្រវត្តិសាស្ត្រ គឺជាប្រវត្តិសាស្ត្រ គ្រាន់តែពុំទាន់ប្រើអក្សរមកកត់ត្រាព្រឹត្តិការណ៍តែប៉ុណ្ណោះ ។

ជាការពិតណាស់ បើនិយាយពីអតីតកាល ជនជាតិខ្មែរធ្លាប់បានទទួលក្នុងប្រវត្តិសាស្ត្រនូវភាពរុងរឿង សម្បូណ៌សប្បាយផូរផង់អស្ចារ្យ មុនយន្តកម្មឥណ្ឌូបនីយកម្ម ឬចិនូបនីយកម្ម ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី សៀវភៅសិក្សានៅកម្ពុជា ពុំបានលាតត្រដាងនូវភស្តុតាងពាក់ព័ន្ធទៅនឹងសម្មិទ្ធិផលសង្គម ឬសិល្បៈ ពីចំណាស់នៃខឿនវប្បធម៌ខ្មែរគួរឱ្យមោទនៈនោះទេ ។ គឺក្នុងស្ថានភាពនេះហើយ ដែលស្ថានីយស្នាយ និងមេមត់ បានផ្តល់នូវការបំភ្លឺព្រមទាំងចម្លើយតាមរយៈវត្ថុវប្បធម៌ជាច្រើន បញ្ជាក់ឱ្យឃើញពីវឌ្ឍនភាព នាសម័យបុរេប្រវត្តិសាស្ត្រ និងការលេចធ្លោឡើងនៃឧស្សាហកម្មលោហធាតុ ។ នៅទីនេះ យើងចង់បញ្ជាក់ផងដែរថា ដូចសម័យបច្ចុប្បន្ន នាសម័យមុនយន្តការឥណ្ឌូបនីយកម្ម ជនជាតិខ្មែរ ទោះមានវប្បធម៌យ៉ាងមាំទាំរបស់ខ្លួនរួចហើយក្តី ក៏ពុំអាចរស់នៅដោយមិនមានការទំនាក់ទំនង និងប្រទេសចិន ឬបិទព្រំដែនឱ្យជិតឈឹងបានឡើយ ។ បើនិយាយម្យ៉ាងទៀត ប្រសិនបើយើងពិចារណាឱ្យស៊ីជម្រៅ យើងអាចទទួលស្គាល់ថា ជនជាតិខ្មែរ យ៉ាងហោចណាស់ក៏ច្រើនពាន់ឆ្នាំមុនគ.ស. បានមានទំនាក់ទំនងផ្នែកវប្បធម៌ជាមួយចិនទៅហើយ ។ ហើយកត្តាសកម្មនៃឥទ្ធិពលវប្បធម៌ចិន គឺការពង្រឹងពង្រីកអត្តសញ្ញាណជាតិរបស់ខ្លួនឯង ឱ្យក្លាយ

ទៅជាចក្រភពនាដើមសម័យប្រវត្តិសាស្ត្រ ក្រោមឥទ្ធិពលរបស់ឥណ្ឌាយ៉ាងសកម្មម្តងវិញ ។

សូមបញ្ជាក់ថា ការទទួលឥទ្ធិពលបរទេសដូចជាបច្ចេកវិទ្យា ឬមនោ-គមន៍វិទ្យាជាដើម ពុំមែនជាសញ្ញាណនៃការអន់ថយនោះទេ ក៏ប៉ុន្តែផ្ទុយទៅវិញ គឺជាវិធានការចាំបាច់ សម្រាប់កសាងវប្បធម៌អោយ ឱ្យកាន់តែត្រចះត្រចង់ផ្ទូរផង់ឡើងជាលំដាប់ ដោយហេតុថា អ្វីៗដែលមកពីនាយត្រូវបញ្ចូលក្នុងឡាល់កិនខ្មែរ មុននឹងប្រសូត្រចេញនូវរូបមន្តថ្មីមួយទៀត ។

និយាយអំពីអាយុនៃឧស្សាហកម្មលោហធាតុវិញ សូមបញ្ជាក់ថា ជនជាតិខ្មែរយើង ចេះប្រើស្ពាន់សំរិទ្ធិតាំងតែពី១៥០០ឆ្នាំមុនគ.ស.មកម្លេះ ពោលគឺមុនទំនាក់ទំនងនឹងឥណ្ឌា ។ ប៉ុន្តែចំណាស់នេះ នៅក្មេងខ្ចីបើយើងប្រៀបធៀបទៅនិងប្រទេសអេហ្ស៊ីប ឬមេហ្សូពោតាមីជាដើម អ្នកស្រាវជ្រាវរមែងតែចោទសំនួរសួរថា តើហេតុដូចម្តេចបានជាកុលសម្ព័ន្ធមន-ខ្មែរ ដែលជាបុព្វបុរសរបស់ជនជាតិខ្មែរចេះប្រើស្គរមហាធឹក ហើយតើស្គរនេះមកពីណា ? ឬក៏ហេតុដូចម្តេចបានជាឧបករណ៍ភ្លេងធ្វើអំពីសំរិទ្ធិនេះ បានក្លាយទៅជាមតិកវប្បធម៌របស់ជនជាតិវៀតណាមទៅវិញ ? ។ ទាំងនេះ ជាសំនួរដែលមានសារៈសំខាន់បំផុតដែលយើងត្រូវតែខិតខំដោះស្រាយ ។

និយាយអំពីប្រភពនៃស្គរមហាធឹក ជាការពិតណាស់ ដែលមានទ្រឹស្តីជាច្រើន ដែលបានលើកឡើង ប៉ុន្តែអាទិភាព ត្រូវបានទៅលើប្រភពចិននៃស្គរមហាធឹកនៃជនជាតិយៀកណាម និងខ្មែរ ដោយសារតម្លាតនៃអាយុកាលខុសគ្នានៃស្គរចិន និងស្គរដែលគេបានរកឃើញនូវស្ថានីយងុងសើង នៅវៀតណាម

ខាងត្បូង នៅកម្ពុជាគឺទស្សនៈនេះហើយ ដែលយើងទទួលបាន ព្រោះសមស្រប តាមលក្ខណៈវិទ្យាសាស្ត្រ និងប្រវត្តិសាស្ត្រក្នុងតំបន់ ។ គេអាចទទួលស្គាល់ថា ជនជាតិយួន និងខ្មែរ ជាអ្នកបង្កើតផលិតមុនគេទៅបាន ប្រសិនបើស្គរចិនមាន អាយុតិចជាង ។ បញ្ហានេះ ត្រូវបានកែតម្រូវជជែកវែកញែកនិងដោះស្រាយ ដោយអ្នកឯកទេសចិនទៅហើយ ។

ដូច្នេះ ការរកឃើញនូវស្គរ និងបំណែកស្គរសំរិទ្ធិនៅក្នុងស្ថានីយបុរេ ប្រវត្តិសាស្ត្រខ្មែរមួយចំនួន ក៏ដូចជានៅកម្ពុជាក្រោម និងប្រទេសថៃបច្ចុប្បន្ន គឺមានតម្លៃជាប្រវត្តិសាស្ត្រ ព្រោះវាបញ្ជាក់ឱ្យឃើញនូវទំនាក់ទំនងខាងវប្បធម៌ និងមនោគមន៍វិជ្ជាសាសនា និងសេដ្ឋកិច្ច ព្រមទាំងបច្ចេកទេសធ្វើស្គរ សំរិទ្ធិនេះ រវាងជនជាតិចិន និងបុព្វការីជនយួន និងខ្មែរ ក្នុងជ្រោយឥណ្ឌូចិន ។ នេះជាតម្លៃបរានុម័តយ៉ាងប្រាកដ ដែលកាត់ថ្លៃមិនបាន ដែលប្រកបដោយភាព ថ្លៃថ្នូរ សីលធម៌ខ្ពង់ខ្ពស់ ។

សរុបសេចក្ដីមក ស្គរសំរិទ្ធិសម្រាប់សូមទឹកភ្លៀង មិនមែនជាជនជាតិ ខ្មែរទេ ដែលបង្កើតមុនគេ ប្រសិនបើគេមិនបានរកឃើញវានៅស្រុកចិនរវាង ៦០០ឆ្នាំមុនគ.ស. ។ ម្យ៉ាងវិញទៀត តម្លៃដ៏ខ្ពង់ខ្ពស់របស់វា គឺស្ថិតនៅលើ លក្ខណៈ ដែលទាក់ទងទៅនិងទេវកថា ក្បាច់ក្បូរដែលគេលំអរ ឬក៏ជូនកាល ទិដ្ឋភាពទូទៅលើថាសនេះ ឥតនិយាយអំពីប្រភេទស្គរជាច្រើនថែមទៀតផង ។ នេះជាសញ្ញាជាក់ស្ដែងនៃការចម្លងតួយ៉ាង ដោយស្មារតីពីស្គរចិន ប្រឌិតខ្ពស់ ដែលមានចំណាស់ច្រើនជាងនិងលក្ខណៈផ្សេងបន្តិចបន្តួច ពីស្គរនៅប្រទេស កម្ពុជាយើងស្ថិតនៅក្នុងកាលបរិច្ឆេទ៣០០-២០០មុនគ.ស.តែប៉ុណ្ណោះ ។

ដូច្នេះចង់ឬមិនចង់ បច្ចេកទេស និងនិមិត្តរូបនៃស្គរ ដើម្បីសូមទឹកភ្លៀងក្នុងពិធីសាសនា ដែលប្រកបដោយលក្ខណៈជីវចលនិយម ដែលត្រូវបានផលិតឡើងដោយប្រជាជនចិននៅភាគខាងត្បូងនៃប្រទេសចិន បានរួមចំណែកក្នុងការស្ថាបនានូវខឿនវប្បធម៌ខ្មែរនាសម័យបុរេប្រវត្តិសាស្ត្រយ៉ាងប្រាកដ ។ ចំពោះបញ្ហានេះ យើងមានករណីកិច្ច និងកាតព្វកិច្ច និងលើកឡើង ឬកត់ត្រាទុកក្នុងទំព័រប្រវត្តិសាស្ត្រដ៏យូរលង់របស់ជាតិហើយ ។

សូមជម្រាបថា ជនជាតិខ្មែរយើង បានរស់រានជាច្រើនពាន់ឆ្នាំមកហើយ ក៏អាស្រ័យនូវទេពកោសល្យខ្ពស់នៃសមានកម្ម នូវអ្វីដែលមកពីក្រៅឱ្យជ្រួតជ្រាបទួលយ៉ាងជ្រៅក្នុងខឿនវប្បធម៌ជនជាតិរបស់ខ្លួន ដោយការច្នៃប្រឌិតយ៉ាងប៉ិនប្រសព្វ ។ ទង្វើនេះ មិនមែនជាការស្រុតចុះនៃតម្លៃសិល្បៈលុម្ពិនខ្មែរនៅក្នុងសម័យបុរេប្រវត្តិសាស្ត្រនោះទេ ក៏ប៉ុន្តែជាវឌ្ឍនភាពកប់កំពូលនៃវប្បធម៌នេះ ។ តាមពិតលក្ខណៈពិសេសនៃវប្បធម៌ខ្មែរខាងលើនេះ គឺជាសារជាតិទូទៅនៃសង្គមមនុស្ស ដែលមានកល្លណៈជាសាកល ព្រោះយើងពុំអាចរស់នៅដោយឯកឯងបាននោះទេ ។ នេះជាការយល់ឃើញរបស់យើង ស្តីអំពីមនុស្សក្នុងសហគមន៍ ដោយមានឥត្ថភាពក្នុងវិចារឥតក្លែងក្លាយ ។

## ៥_ការចាក់ឫសនៃវប្បធម៌ឥណ្ឌា

តាមពិតការទំនាក់ទំនងវប្បធម៌រវាងខ្មែរនិងឥណ្ឌា ត្រូវបានអនុវត្តន៍ឡើងតាំងតែពីសម័យបុរេប្រវត្តិសាស្ត្រមកម្ល៉េះ ក៏ប៉ុន្តែនៅដើមស.វ.ទី១នៃ គ.ស. ទើបជនជាតិខ្មែរបានទទួលឥទ្ធិពលយ៉ាងសកម្មជាងពេលមុនៗ ដោយការ

រីកចម្រើនខាងបច្ចេកទេស សាងសង់សំពៅធំៗឆ្លងសមុទ្រ ដើម្បីមូលហេតុសេដ្ឋកិច្ច និងវប្បធម៌ ។

ជនជាតិខ្មែរនៅក្នុងអម្បូរមន-ខ្មែរ មានវប្បធម៌របស់រួចមកហើយ នៅពេលដែលទទួលវប្បធម៌នយោបាយឥណ្ឌាយ៉ាងខ្លាំងក្លាបំផុត នៅនាដើមស.វ.ទី១នៃគ.ស. ។ ព្រឹត្តិការណ៍នេះ ត្រូវបានគេហៅថា ឥណ្ឌារូបនីយកម្ម ដោយបានធ្វើឡើងយ៉ាងសន្សឹមៗ ពីឆ្នេរសមុទ្រដល់វាលរាប និងជ្រៅទៅក្នុងផ្ទៃប្រទេស ជាហេតុបណ្ដាលឱ្យមានការពូនផ្តុំជាសហគមន៍កសិកម្មនានា ហើយបង្កើតឡើងនូវរដ្ឋខ្មែរដំបូង តាមបែបឥណ្ឌានិយម គឺចក្រភពភ្នំ ឬនគរភ្នំ ។

ចក្រភពភ្នំជាភាសាចិនហៅថា ហ្វូណន (ទីក្រុង +ភ្នំ) មានទឹកដីធំសម្បើម គួរជាទីមោទនៈ ចាប់តាំងពីជ្រោយម៉ាឡាកាដល់កំពង់ផែកម្ពុជាក្រោមអូកែវ ហើយពីនោះលាតសន្ធឹងដល់តំបន់ខ្ពង់រាបនគររាជសីមា បន្ទាយមានជ័យ សៀមរាប វត្តភូ ចម្បាស័ក្តិប្រទេសលាវបច្ចុប្បន្ន ស្ទឹងត្រែង ដោយរួមបញ្ចូលមកក្នុងអតីតដែនដីខ្មែរនូវប្រទេសកម្ពុជា និងថៃបច្ចុប្បន្នថែមទៀតផង ។ នេះជាការចាក់ឫសកែវនៃវប្បធម៌ឥណ្ឌា ដែលគេពុំនឹកស្មានដល់ ។

នៅក្នុងសម័យនោះ ខ្មែរបានខ្ចីរបបគ្រប់គ្រងពីជនជាតិឥណ្ឌា ដូចជារបបរាជាធិបតេយ្យ ព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា ទាំងមហាយាន និងហីនយាន តួអក្សរបល្លវៈ ដើម្បីបង្កើតអក្សរប្រចាំជាតិរបស់ខ្លួន បានធ្វើឱ្យខ្មែរផ្លាស់ប្ដូរទម្រង់វប្បធម៌ អារ្យធម៌ដើមរបស់ខ្លួន ដូចការរស់នៅប្រចាំថ្ងៃជាដើម ហើយក្លាយទៅជាអារ្យប្រទេសរុងរឿងអស្ចារ្យ ។ ពីសហគមន៍មនុស្សដែលគ្មានអំណាចកណ្ដាល ជនជាតិខ្មែរបានសាងនូវព្រះរាជាណាចក្រកម្ពុជា

ដែលមានស្តេច និងសព្វនាម៉ឺនមន្ត្រីជាប្រមុខ ។

ពីវប្បធម៌ទន្ទេញចាំមាត់ ជនជាតិខ្មែរបានមានពង្សាវតារជាលាយលក្ខអក្សរ ព្រមទាំងអក្សរសិល្ប៍របស់ខ្លួនយ៉ាងប្រាកដដូចជា សិលាចារឹកវ៉ូកាញ់ ដែលសរសេរនៅស.វ.ទី៣នៃគ.ស.ជាសក្ខីភាពស្រាប់ ។ ច្បាប់ក្រិត្យក្រម ព្រមទាំងក្បួនខ្នាតដូចជាហោរាសាស្ត្រ តារាសាស្ត្រខ្មែរ សុទ្ធសឹងចេញពីប្រភពឥណ្ឌា ......។ល។

តាមពិតការខ្ចីរបបគ្រប់គ្រង និងរចនាសម្ព័ន្ធនយោបាយឥណ្ឌា ពុំបានបំផ្លាញនូវសំណង់វប្បធម៌ដើមរបស់ខ្មែរទេ ផ្ទុយទៅវិញ វប្បធម៌ឥណ្ឌា និងក្លិងជាកម្លាំងរុញច្រានដ៏ពិសិដ្ឋមួយធ្វើឱ្យមតិកវប្បធម៌មន-ខ្មែរ កាន់តែរីកដុះដាលឡើងថែមទៀត នេះជាវប្បធម៌សំយោគ ។

តាមរយៈការស្រាវជ្រាវយើងដឹងថា ខ្មែរយើងប្រើភាសាបាលីនៅចុងស.វ.ទី៦ និងដើមស.វ.ទី៧ និងទី៨ នៃគ.ស. ។ ដោយហេតុនេះហើយ បានជាយើងដឹងថា ខ្មែរពុំបានខ្ចីភាសាបាលីតាមរយៈពួកមនឬសៀមទេ ព្រោះបុព្វការីជនខ្មែរបានទំនាក់ទំនងត្រង់ជាមួយឥណ្ឌានិង ស្រីលង្កា ទោះបីជាខ្មែរយើងក្រោយអង្គរនិយមភាសាសំស្ក្រឹតវិញក៏ដោយ ប៉ុន្តែខ្មែរស្គាល់ភាសាបាលីច្បាស់។

ការជីកកកាយតាមវិធីសាស្ត្រដោយក្រុមស្រាវជ្រាវខ្មែរ និងបរទេសនៅភូមិស្វាយរបាល ស្រុកព្រះនេត្រព្រះបានកត់សម្គាល់ឃើញថា ថ្វីដ្បិតតែសព្វថ្ងៃនេះ ព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ និងជនជាតិខ្មែរគឺតែមួយក៏ដោយ ក៏ប៉ុន្តែលទ្ធិសាសនានេះមានប្រភពពីប្រទេសឥណ្ឌា ។ ម្យ៉ាងវិញទៀត ឥទ្ធិពលនៃព្រហ្មញ្ញសាសនា ក៏ពុំទាន់រលាយរលត់ទាំងស្រុងដែរ ទោះបី

ជាសាសនានេះ ឈប់ក្លាយទៅជាសាសនារដ្ឋក្រោយពីរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៧ ។ ជានិច្ចកាលទំនៀមទំលាប់នៃសាសនា និងព្រះពុទ្ធសាសនា រមែងតែទាក់ទិនជាមួយនិងប្រព័ន្ធគំនិត ដែលមានលក្ខណៈជាជំនឿជីវចលដែរ ។ ទាំងនេះ ជាបរិយាកាសនៃមនោគមន៍វិជ្ជាសាសនា ក្នុងរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ។

តទៅនេះ យើងសូមលើកបញ្ហានគររូបនីយកម្មនៃប្រជាជនខ្មែរ ចាប់តាំងពីដើមស.វ.ទី១ នៃគ.ស.មកនិយាយ ប្រយោជន៍និងវាយតម្លៃឱ្យបានត្រឹមត្រូវនូវឥទ្ធិពលរបស់ឥណ្ឌា ក្នុងការស្ថាបនាខឿនវប្បធម៌សំយោគរបស់ជនជាតិខ្មែរ ដែលមានលក្ខណៈជាសាកល ។

តាមពិតទំនាក់ទំនងផ្នែកវប្បធម៌រវាងខ្មែរ និងឥណ្ឌា ដែលបានចាប់បដិសន្ធិឡើងនូវរជ្ជកាលនៃព្រះអសោកមហារាជ នាស.វ.ទី៣មុនគ.ស.មកម្លេះ តាមរយៈការផ្សព្វផ្សាយលទ្ធិព្រះពុទ្ធសាសនា ក៏ប៉ុន្តែនាដើមស.វ.ទី១នៃ គ.ស. ទើបមានសន្ទុះយ៉ាងខ្លាំងក្លាអស្ចារ្យ អ្វីដែលគេឱ្យឈ្មោះថា ឥណ្ឌូរូបនីយកម្ម ។

## ៦_នគររូបនីយកម្មនៃរដ្ឋខ្មែរដំបូង

ដូចប្រទេសមួយចំនួន ក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ព្រះរាជាណាចក្រកម្ពុជាបុរាណ ដែលមានឈ្មោះថា នគរភ្នំ ស្ថិតនៅក្រោមឥទ្ធិពលនៃខ្យល់រដូវ គឺប្រការនេះហើយ ដែលបានញ៉ាំងឱ្យមានការរៀបចំដែនដី និងសង្គមជាតិមួយ ដែលមានទាក់ទងយ៉ាងជិតស្និត នឹងកត្តាអាកាសធាតុ ដោយមានវិស័យកសិកម្មជាមូលដ្ឋានគ្រឹះនៃសង្គមថែមទៀតផង ។

ដំណើរការនៃប្រវត្តិសាស្ត្របានឱ្យដឹងយ៉ាងច្បាស់ថា មជ្ឈមណ្ឌលវប្បធម៌ដំបូងបង្អស់របស់ជនជាតិខ្មែរ បានចាប់បដិសន្ធិឡើងស្ថិតនៅតាមតំបន់វាលទំនាប ជាពិសេសនៅក្នុងដែនដីសណ្ដរ និងនៅតាមឈូងសមុទ្រសៀមបច្ចុប្បន្ន ពីព្រោះនៅលើទីតាំងទាំងនោះ ធម្មជាតិមានអំណោយផលច្រើនជាងតំបន់ខ្ពង់រាប ។ ម្យ៉ាងវិញទៀត ភូមិភាគខាងលើនេះ ក៏ជាផ្លូវត្រឡែងកែងនៃការផ្លាស់ប្ដូរវប្បធម៌ជនជាតិខ្មែរ និងបរទេសផងដែរ ។ ដូចនេះ នៅក្នុងតំបន់ទាំងនោះមនុស្សបានផ្ដុំគ្នាជាស្រុកភូមិ ហើយបានក្លាយជាសហគមន៍កសិករ ក្រោមការដឹកនាំរបស់កន្ទ្រាញ ។ កសិករខ្មែរដំបូង បានចាប់កំណើតឡើងដោយសង្គមបានវិវត្តន៍ពីសម័យមួយទៅសម័យមួយទៀតមិនដាច់ ពោលគឺពីសម័យបុរេប្រវត្តិសាស្ត្រ ដល់សម័យប្រវត្តិសាស្ត្រ ដែលបានផ្ដើមឡើងនៅដើមស.វ.ទី១នៃគ.ស. ។ ក្នុងបរិបទភូមិសាស្ត្រនេះហើយ ដែលគេអាចកំណត់ព្រំប្រទល់យ៉ាងជាក់ គេបានរកឃើញផងដែរ នូវស្នាកស្នាមវប្បធម៌ដ៏ចំណាស់របស់ដូនតាខ្មែរ មុនការមកដល់នៃវប្បធម៌ឥណ្ឌា និងចិនក្នុងតំបន់ ។

ជាការពិតណាស់ ដែលគេអាចកត់សម្គាល់ នាសម័យបុរេប្រវត្តិសាស្ត្របរិបទ ឬលំហសង្គម និងភូមិសាស្ត្ររបស់សហគមន៍មន-ខ្មែរដំបូងទាំងនោះមានលក្ខណៈសង្គមផ្ទាល់របស់ខ្លួនរួចមកហើយ ដូចជាការរស់នៅ វប្បធម៌រូបិយនិងអរូបិយ ការផលិតនូវផលដំណាំ ដូចជាវិស័យកសិកម្ម ឧស្សាហកម្មលោហធាតុ និងតម្បាញ ការសាងសង់ផ្ទះសម្បែងខ្ពស់ហួសពីដីជាដើម ក៏ប៉ុន្តែរដ្ឋខ្មែរពុំទាន់មាននៅឡើយទេ ព្រោះកុលសម្ព័ន្ធមន-ខ្មែរទាំងនោះ នៅខ្វះរចនាសម្ព័ន្ធនយោបាយ គឺរបបរាជាធិបតេយ្យ ដើម្បីអភិវឌ្ឍន៍សហគមន៍កសិករឱ្យ

ក្លាយទៅជាប្រទេសដោយមានការរៀបចំមនុស្សតាមឋានានុក្រមវណ្ណៈ ។

អ្វីដែលទើបពោលបញ្ជាក់ឱ្យឃើញថា សមិទ្ធិផលសង្គមនាគ្រាបឋមនៃប្រវត្តិសាស្ត្រខ្មែរ ត្រូវបានអភិវឌ្ឍឡើងសមស្របតាមលក្ខណៈបរិស្ថានសង្គម ឬលំហសង្គមខ្មែរ ដែលបានកើតចេញពីមូលដ្ឋានសេដ្ឋកិច្ច ដោយមានកសិកម្មជាអត្ថិភាពចម្បង ប៉ុន្តែវឌ្ឍនភាពនេះ ពុំអាចកើតមានឡើងបាន បើសិនជាគ្មានជឿនវប្បធម៌ ដែលជាកម្លាំងរុញច្រាន ដោយហេតុថា ជានិច្ចកាលគ្រប់សមិទ្ធិផលសង្គម ជាពិសេសដូចជាវិស័យសេដ្ឋកិច្ចជាដើម នាសម័យបុរាណរមែងតែស្ថិតនៅក្រោមឥទ្ធិពលនៃទម្ងន់ជំនឿប្រពៃណី ។ បើនិយាយម្យ៉ាងទៀតលំអសង្គមខ្មែរស្ថិតក្រោមអានុភាពរបស់វិស័យសេដ្ឋកិច្ច និងមនោគមន៍វិជ្ជាសាសនា ដែលមានសម្ព័ន្ធភាពយ៉ាងជិតស្និតនិងគ្នា ។

នាដើមស.វ.ទី១នៃគ.ស. មួយភាគធំនៃកុលសម្ព័ន្ធមន-ខ្មែរ បានមានទំនាក់ទំនងផ្នែកវប្បធម៌ជាមួយឥណ្ឌា ហើយបានតាំងខ្លួនថាជាខ្មែរ ។ ដោយសង្គមមន-ខ្មែរទទួលវប្បធម៌មកពីប្រទេសឥណ្ឌា គេឃើញមានការលេចធ្លោឡើងនូវបច្ចេកទេសផលិតផលសេដ្ឋកិច្ចបែបថ្មី ជាបច្ចេកទេសនាសម័យវប្បធម៌នគរភ្នំ ពីស.វ.ទី១ដល់ស.វ.ទី៦នៃគ.ស. អាចកត់សម្គាល់ឃើញតាមរយៈប្រព័ន្ធទឹក ដែលគេបានជីកពីទន្លេមេគង្គ និងតាមដៃទន្លេនេះ គឺទន្លេបាសាក់ ដើម្បីបង្ហូរទឹកចូលវាលស្រែដ៏មហាធំធេងល្វឹងល្វើយនៅម្តុំកម្ពុជាក្រោម ប្រយោជន៍និងធ្វើស្រែចំការ ។ តាមពិតប្រព័ន្ធធារាសាស្ត្រនាសម័យឥណ្ឌូរូបនីយកម្ម មានលក្ខណៈខាត់ខ្វែង ហើយទម្រង់ខ្នាតធំជាងប្រព័ន្ធធារាសាស្ត្រ ដែលធ្លាប់មានពីមុនៗ នាសម័យបុរេប្រវត្តិសាស្ត្រតែប៉ុណ្ណោះ ដែលគេគ្រាន់តែធ្វើស្រែដេញតាម

ទឹកក្នុងមួយឆ្នាំម្តង ឬក៏តាមរបៀបធម្មតា ដោយគ្រាន់តែពឹងផ្អែកលើរដូវ ដែលគេបង្ហូរចូលស្រែតែប៉ុណ្ណោះ ។ វិធីសាស្ត្រនៅកម្ពុជាក្រោម ក៏ត្រូវបានជួបប្រទះនៅក្នុងប្រទេសថៃ និងឡាវបច្ចុប្បន្ននេះដែរ សឱ្យឃើញថា វិធីសាស្ត្រទូទៅដែលជនជាតិខ្មែរបាននិយមទូទាំងអតីតប្រទេសរបស់ខ្លួន មុនការហូរចូលរបស់ជនជាតិថៃ-ឡាវ ។

ព្រឹត្តិការណ៍សំខាន់នេះ ដែលជាបច្ចេកវិទ្យា ដែលខ្មែរបានទទួលពីឥណ្ឌា ហើយដែលជាលទ្ធផលនៃការអនុវត្តន៏នូវកម្មវិធីផលិតផលថ្មី បានកើតមានឡើងនៅកម្ពុជាក្រោម និងនៅម្តុំឈូងសមុទ្រសៀមសព្វថ្ងៃ ។ ទង្វើនេះ ជាដើមហេតុធំនៃការប្រែប្រួលបរិស្ថាន ឬទិដ្ឋភាពសង្គមខ្មែរ ដែលគេឱ្យឈ្មោះថាលំអសង្គម ។

ដូចនេះ គេអាចឃើញនៅលើផែនដីនៃនគរភ្នំទាំងមូល ជាពិសេសនៅតំបន់ទំនាប នៅវាលស្រែដែលមានរបស់ទម្រខាង ដូចក្រឡាជើងអក ដោយមានទំនប់តពីវាលស្រែមួយទៅវាលស្រែមួយទៀត មិនដាច់កន្ទុយភ្នែក ទឹកពីទន្លេ ដើម្បីផលិតផល គេជីកព្រែក ដែលគេបង្ហូផ្ទាល់ចូលទៅក្នុងវាលស្រែ ។

នេះហើយគួបផ្សំនឹងរចនាសម្ព័ន្ធនយោបាយសាសនាឥណ្ឌា គឺមធ្យោបាយផលិតថ្មី ដែលចងខ្មែរជាថ្នុងមួយ ដែលបានធ្វើឱ្យនគរភ្នំផ្លាស់ប្តូរទម្រង់សង្គម ដោយបានចាកចេញពីភាពជាកុលសម្ព័ន្ធកសិករតូចៗ ទៅជាសង្គមចក្រភពបន្តិចម្តងៗ ជាលំដាប់រហូតដល់សម័យអង្គរ (ពីព្រោះបច្ចេកទេសខាងផលិតតម្រូវឱ្យមានការប្រមូលផ្តុំនូវអំណាចកណ្តាល ស្ថិតក្រោមការដឹកនាំរបស់ព្រះមហាក្សត្រខ្មែរ ដែលជាអ្នកគ្រប់គ្រង ។ មួយវិញទៀត ផលិតផលកសិកម្មក្នុង

អម្បុងនេះ ក៏ពឹងពាក់លើវិស័យពាណិជ្ជកម្មទាំងស្រុងដែរ រវាងតំបន់មួយទៅតំបន់មួយទៀត និងបរទេសជាប្រភពនៃវឌ្ឍនភាព ។ សូមរំលឹកថា កាលនោះជនជាតិខ្មែរ មានទំនាក់ទំនងផ្នែកវប្បធម៌ មិនត្រឹមតែនឹងប្រទេសឥណ្ឌាតែប៉ុណ្ណោះទេ ក៏ប៉ុន្តែជាមួយនឹងចក្រភពរ៉ូម៉ាំងផងដែរ ។

គប្បីរំលឹកផងដែរថា នៅមាននគរមួយទៀត ដែលមានឈ្មោះបោះសំឡេងដូចខ្មែរដែរ គឺនគរចម្ប៉ា ឬលីនយី ដែលត្រូវបានបង្កើតឡើងនាដើម ស.វ.ទី១នៃគ.ស. ក្រោយឥទ្ធិពលនៃវប្បធម៌ អារ្យធម៌ឥណ្ឌា ដូចនគរភ្នំរបស់ជនជាតិខ្មែរដែរ ។ ប៉ុន្តែខុសពីជនជាតិខ្មែរ ដែលជាអ្នកស្រុកអាយ ជនជាតិចាមមានប្រភពចេញពីកោះជ្វា ហើយមានឈ្មោះយ៉ាងល្បីល្បាញក្នុងអតីតកាល ។ នគរចម្ប៉ា ដែលមានទឹកដីលាតសន្ធឹងពីអាណាម រហូតដល់ត្រង់ចំណុចមួយដែលស្ថិតមិនឆ្ងាយប៉ុន្មានពីទីក្រុមហ្វេបច្ចុប្បន្ន ត្រូវបានសាបសូន្យទៅហើយ ដោយការដណ្តើមទឹកដីពីជនជាតិយួន ។

ទំព័រប្រវត្តិសាស្ត្របានឱ្យដឹងទៀតថា ក្នុងការពង្រឹងអំណាច ការបង្រួបបង្រួមជាតិ ការអភិវឌ្ឍន៍សង្គមជាតិ ព្រះមហាក្សត្រ និងអ្នកដឹកនាំខ្មែរនាសម័យនគរភ្នំ បានពឹងផ្អែកទៅលើកសិកម្ម ដោយប្រើផ្ទៃដីធំ ដែលលាតសន្ធឹងពីតំបន់ដីសណ្ត ឬតំបន់ដែលស្ថិតនៅតាមដង និងដៃទន្លេនានា ដើម្បីបង្ហូរទឹកចូលយ៉ាងជ្រៅទៅក្នុងស្រែផ្នែកខាងក្នុងប្រទេស តាមរយៈប្រព័ន្ធធារាសាស្ត្រ ដែលគេបានជីក ដើម្បីភ្ជាប់តំបន់មួយទៅតំបន់មួយទៀត ។ ក្នុងអតីតកាល ប្រវត្តិសាស្ត្រក៏បានឱ្យដឹងផងដែរថា មូលដ្ឋានសេដ្ឋកិច្ចរបស់

នគរភ្នំ ក៏ពឹងផ្អែកទាំងស្រុងទៅលើពាណិជ្ជកម្មអន្តរជាតិខ្មែរ ដូចជាបានពោលខាងលើ ស្របតាមគោលនយោបាយរបស់អំណាចកណ្តាលជំនាន់នោះ ដែលរមែងតែមានគោលការណ៍រួបរួម ក្នុងការស្ថាបនាសង្គមជាតិ ។

សូមរំលឹកថា ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ក្នុងទិសដៅទៅរកសេចក្តីរីកចម្រើនដល់ជនជាតិខ្មែរ កម្លាំងពលកម្មត្រូវបានគេជ្រើសរើសតាមស្រុកភូមិជិតឆ្ងាយ ដោយមានផែនការទ្រង់ទ្រាយសហព័ន្ធមានលក្ខណៈជារួម ។ ដូចនេះ កុលសម្ព័ន្ធមន-ខ្មែរបន្តិចម្តងៗត្រូវបានកែទម្រង់ ហើយរលាយចូលក្នុងរចនាសម្ព័ន្ធរដ្ឋ ដែលមានអំណាចកណ្តាលដ៏រឹងមាំ ។ ការបញ្ចូលកុលសម្ព័ន្ធនានាយ៉ាងឆាប់រហ័សក្នុងប្រព័ន្ធរដ្ឋបាល ដែលមានអំណាចកណ្តាលជាមូលដ្ឋាន តាមរយៈប្រព័ន្ធសេដ្ឋកិច្ច ដែលពឹងផ្អែកទៅលើប្រព័ន្ធធារាសាស្ត្រ និងពាណិជ្ជកម្ម មានសារៈសំខាន់ណាស់ ក្នុងការបង្រួបបង្រួមជាតិខ្មែរ ឱ្យក្លាយទៅជារដ្ឋមួយយ៉ាងធំ ។

ដូចនេះ សហគមន៍ខ្មែរ-មនតូចធំទាំងឡាយនៃអាណាចក្រភ្នំ ត្រូវបានពង្រឹងនូវហេដ្ឋារចនាសម្ព័ន្ធ និងក្នុងផ្នែកសង្គមកិច្ច និងសេដ្ឋកិច្ចជាអាទិភាព ជាពិសេស ក្នុងវិស័យកសិកម្មនិងអភិវឌ្ឍន៍ ដែលស្ថិតក្រោមការផ្តួចផ្តើមរបស់ព្រះមហាក្សត្រ ដែលជាអ្នកគ្រប់គ្រង ។

ការអភិវឌ្ឍន៍ប្រទេសជាតិ គួបផ្សំនឹងរចនាសម្ព័ន្ធនយោបាយ ដែលមានរបបរាជានិយមជាមូលដ្ឋាន បានបង្ករលក្ខណៈងាយស្រួលបន្ថែមទៀតដល់ការពង្រីកតំបន់ ឬដំណាំដាំដុះ ព្រមទាំងទីប្រជុំជន ហើយនៅទីបញ្ចប់ គឺទំហំទឹកដីរបស់នគរភ្នំ ដែលត្រូវបានពង្រីក និងពង្រឹងឡើងជាលំដាប់នៅក្នុងជ្រោយឥណ្ឌូចិននេះ ។

ចាប់តាំងពីថ្ងៃដំបូងនៃការបង្កើតរដ្ឋរបស់ខ្លួនមក ដែលផ្ដើមឡើងគ្រាន់តែគ្រប់គ្រងដោយមេកន្ទ្រាញ ហើយពុំទាន់មានអំណាចកណ្ដាលនៅឡើយ ជនជាតិខ្មែរបានទទួលនូវឧត្ដមគតិ និងវិបុលភាពគ្រប់វិស័យ ហើយបានសម្រេចលទ្ធផលដោយផ្ទៃផ្កា គឺការបង្ករបង្កើតទឹកដីឬប្រទេសជាតិ និងប្រវត្តិសាស្ត្រជាតិរបស់ខ្លួន ដែលជាគ្រឹះដ៏សំខាន់សម្រាប់សង្គមជាតិ ។ ម្យ៉ាងវិញទៀត ក្នុងការរៀបចំស្រុកទេស អ្វីដែលគេហៅថា នគររូបនីយកម្មនោះ យើងឃើញនូវកត្តាដែលចាំបាច់និងមិនអាចខ្វះខាតបាននៃការលេចធ្លោឡើង នូវទីក្រុងបុរាណនានាបាន គឺវិស័យជំនឿ ដែលដើមឡើយមានលក្ខណៈជាជំនឿជីវចលនិយម ដូចជា គោរពសក្ការបូជាដូនតា ឬបុព្វការីជន ដែលដំណាងដោយ (មេ) និងធាតុប្រុស(បា) គូបដិបក្ខមេ (ស្រី) និង(បា)ប្រុស ឬធាតុត្រជាក់និងធាតុក្ដៅ ទឹកនិងភ្លើង នាគនិងគ្រុឌ ដែលជាគូវិវាទ ក៏ប៉ុន្តែខ្វះមួយមានមួយមិនបាន ។

សូមជំរាបថា គូបដិបក្ខនាគនិងគ្រុឌនៅទីនេះ គឺជានិមិត្តរូបនៃឥទ្ធិពលធម្មជាតិ ឬដំណាងភូមិសាស្ត្រនៃដែនដីសណ្ដរ ដែលមានទឹកហ៊ុំព័ទ្ធដោយទួល ភ្នំគឺជាខ្ពង់រាបតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ទឹកក៏ជាវត្ថុសញ្ញាតំណាងមេ រីឯភ្នំវិញតំណាងបា ។ ដោយសារទស្សនៈផ្ទុយគ្នានេះហើយ ដែលជានិមិត្តរូបនៃធាតុឬសារជាតិជីវិត បានជាព្រះរាជាខ្មែរនៃចក្រភពភ្នំ តាំងព្រះបរមនាមរបស់ខ្លួនថា ជាស្ដេចភ្នំ ។ ការតាំងឈ្មោះនៃប្រទេស មិនត្រឹមតែអាចធ្វើឱ្យយើងឃើញនូវចំណាស់នៃវប្បធម៌ អារ្យធម៌ខ្មែរប៉ុណ្ណោះទេ ក៏ប៉ុន្តែក៏ផ្ដល់នូវលទ្ធភាពជូនយើង ក្នុងការស្វែងយល់អំពីទស្សនៈ ដែលមានលក្ខណៈជីវចល ស្ដីអំពីលោករបស់មនុស្សខ្មែរនាសម័យបុរាណតាមស្ថាននាម ។

រដ្ឋនគរភ្នំដំបូងនេះ ជាក្សត្ររដ្ឋ ពោលគឺជាការផ្គុំផ្គុំនូវរដ្ឋតូចធំទាំងឡាយ ដែលមានសហគមន៍កសិកម្មជាមូលដ្ឋាន ដែលស្ថិតតាមឆ្នេរសមុទ្រ ដែនដីសណ្ដរ វាលទំនាប និងតាមដងទន្លេធំតូចទាំងឡាយ ហើយបន្តិចម្ដងៗ បានលាតសន្ធឹងទៅតំបន់ខ្ពង់រាប ដូចជារដ្ឋចេនឡាជាដើម ដែលមានទីក្រុងស្រេដ្ឋបុរៈ នៅម្ដុំចម្ប៉ាសាក់ ប្រទេសលាវបច្ចុប្បន្នជាឧទាហរណ៍ស្រាប់ ។ ប៉ុន្តែក្នុងដំណាក់កាលដំបូងនៃប្រវត្តិសាស្ត្រនេះ ដែលរដ្ឋខ្មែរទើបតែចាប់បដិសន្ធិឡើង ហើយផ្ដើមការបង្រួបបង្រួមសន្តរដ្ឋតូចធំទាំងឡាយឱ្យទៅជាធ្លុងមួយ នគរភ្នំពុំអាចសម្រេចវត្ថុបំណងពិសិដ្ឋទាំងហេដ្ឋារចនាសម្ព័ន្ធ ទាំងមូលដ្ឋានបច្ចេកទេស និងសម្ភារៈសេដ្ឋកិច្ចភ្លាមៗទាំងស្រុងបានឡើយ ។ ជាស្ថានភាពជាក់ស្ដែងក្នុងចក្រភពភ្នំមានរដ្ឋតូចធំជាច្រើន ហើយស្ថានភាពស្វយ័ត្ត ឬអធិបតេយ្យភាពរបស់ខ្លួន ។ ក្នុងរយៈពេលជិត៦ស.វ. វឌ្ឍនៈភាពនៃនគរភ្នំ គឺពឹងផ្អែកលើកសិកម្ម និងពាណិជ្ជកម្មអន្តរជាតិ ដែលធ្វើតាមរយៈកំពង់ផែសមុទ្រនានា ហើយស្លាកស្នាមនៃភាពរុងរឿងនេះ អាចឆ្លុះតាមរយៈស្ថានីយប្រវត្តិសាស្ត្រ ដូចជាទីក្រុងអង្គរបុរី (កម្ពុជា) អូថង (ប្រទេសថៃ) អូកែវ និងផ្លូវមួយរយនៅកម្ពុជាក្រោម ។

ជ្រុងមួយទៀតនៃសង្គមខ្មែរ តូចធំនាសម័យបុរេអង្គរ ឬនគរភ្នំនិងចេនឡា ព្រមទាំងសម័យអង្គរ គឺគម្លាតផ្នែកវប្បធម៌ រវាងទីក្រុង និងជនបទ ឬក៏តំបន់ព្រៃភ្នំ ខ្ពង់រាបនានា ដែលវប្បធម៌ឥណ្ឌាមិនបានជ្រួតជ្រាបដល់ ដោយកត្តាមួយចំនួន ។ គឺប្រការនេះហើយ ដែលធ្វើឱ្យយើងឃើញតាមរយៈអត្ថបទសិលាចារឹកនូវវត្តមានរបស់ពួកខ្មែរព្រៃភ្នំ ដែលជាអ្នកបម្រើក្នុងទីប្រជុំជន ឬទីក្រុងខ្មែរ ដូចជាពួកជង ព្រៅ ភ្នង មលេងជាដើម ។ ប្រការនេះហើយ ដែលជា

ភស្តុតាងបង្ហាញឱ្យឃើញថា ការជ្រួតជ្រាបនៃវប្បធម៌ឥណ្ឌា ត្រូវបានធ្វើឡើងដោយសន្សឹមៗ ហើយត្រូវបានបន្តរហូតដល់បច្ចុប្បន្ននេះទៀត ជាពិសេសតាមតំបន់រលាក់កងជើង ឬតំបន់ដាច់ស្រយាល ។

## ៧_ការបន្តើរជ្ជខ្មែរជំបូងបន្តស់នៃគ្រិស្តសករាជ

យោងលើមូលដ្ឋានជាក់ស្តែងនេះ ដោយពឹងផ្អែកទៅលើការស្រាវជ្រាវផ្នែកចារឹកសាស្ត្រ យើងអាចដឹងថា មានការសាងសង់ពីសំណាក់អ្នកដឹកនាំខ្មែរនូវផ្នូវគមនាគមន៍ ព្រះបដិមា ដូចជាព្រះទេវរូប ព្រះពុទ្ធរូប ព្រមទាំងបូជនីយដ្ឋានទូទាំងប្រទេស ។ ទទឹមនិងនេះដែរ ដើម្បីដំណើរការនៃទីតាំងពិសិដ្ឋទាំងនេះ គេបានសាងផ្លូវ ជីកព្រែក ស្រះទឹក រហាល ឬបារាយណ៍ជាដើម ។ ក្នុងកិច្ចការសង្គមសាសនានេះ គេឃើញមានការធ្វើអំណោយនូវដីធ្លី និងខ្ញុំកំដរផងប្រយោជន៍និងអភិវឌ្ឍន៍តំបន់ទាំងនោះ ដោយព្រះមហាក្សត្រខ្មែរ ។ វណ្ណកម្មទាំងនេះ ស្ថិតក្នុងបន្ទាត់នយោបាយរដ្ឋ ដើម្បីបង្រួបបង្រួមនិងអភិវឌ្ឍន៍ប្រទេសជាតិ ។ ដូចនេះ ស្ថិតនៅក្រោមឥទ្ធិពលនៃសាសនាឥណ្ឌា ទីក្រុងឬរដ្ឋតូចធំទាំងនោះ បន្តិចម្តងៗក៏បានក្លាយទៅជាមជ្ឈមណ្ឌលវប្បធម៌ ដែលមានព្រះរាជាធំៗឬរណបជាប្រមុខ ប្រកបដោយបច្ចេកវិទ្យា និងការចេះដឹងផ្នែកសាសនា និងវប្បធម៌ខ្ពស់ ដោយមានលទ្ធិព្រហ្មញ្ញសាសនា ដែលជូនកាលគួបផ្សំនិងព្រះពុទ្ធសាសនាជាមូលដ្ឋានគ្រឹះ ឬសសរទ្រូង ។

តាមរយៈការអភិវឌ្ឍន៍នេះ គេឃើញមានការលេចធ្លោឡើងនៅលើទីតាំង ឬមណ្ឌលវប្បធម៌ ដែលចាប់បដិសន្ធិឡើងតាំងពីសម័យបុរេប្រវត្តិសាស្ត្រ

នូវទីក្រុងឬបុរីជាច្រើន ដែលឈ្មោះជាភាសាសំស្ក្រឹតហៅថា បុរៈ ឬបុរី ។ ដូចជាអង្គបុរី ស្រេដ្ឋបុរៈ លិង្គបុរៈ ក្នុងចក្រភពខ្មែរ ដែលជាលទ្ធផលនៃការប្រែព្រួល ឬអភិវឌ្ឍន៍នៃសង្គមនាសម័យបុរាណ ។

នេះជាភស្តុតាង ឬស្លាកស្នាមជាក់ស្តែងយ៉ាងសំខាន់ផ្នែកប្រវត្តិសាស្ត្រ ដែលបង្ហាញនូវលក្ខណៈសង្គមខ្មែរ នាដើមសម័យប្រវត្តិសាស្ត្រពីកុលសម្ព័ន្ធ ឬសហគមន៍មនុស្ស ដែលជាស្រុកភូមិជាបុរី ឬរដ្ឋ ។ ក្នុងសម័យប្រវត្តិសាស្ត្រនេះហើយ ដែលគេឃើញមានការតាំងឈ្មោះថ្មីនៃទីតាំងចាស់ ឬលំនៅដ្ឋានចាស់មួយចំនួន ក៏ប៉ុន្តែទន្ទឹមនឹងនេះដែរ តំបន់មួយចំនួន នៅតែរក្សាឈ្មោះដើមរបស់ខ្លួនដដែល ។ ឧទាហរណ៍ ប្រភពឯកសារចិនបានឱ្យដឹងថា ឈ្មោះនៃទីក្រុងអង្គរបុរី (នគរ +អង្គរ +បុរី) ដើមឡើយមានឈ្មោះជាសំស្ក្រឹតថា វ្យាធបុរៈ ដែលជាទីក្រុងរបស់អ្នកព្រានព្រៃ ដែលជាអ្នកទាក់ដំរី ។ មូលហេតុ ដែលអ្នកស្រុកតាំងឈ្មោះនេះ គឺបណ្តាលមកពីអ្នកស្រុកបានជ្រើសរើសទ្រមាក់ដំរីម្នាក់ យ៉ាងចំណាន ឱ្យធ្វើជាស្តេចរបស់ពួកខ្លួន បើតាមកំណត់ហេតុចិន សិក្សាដោយលោក *ពេលីយ៉ូ* ។

ផ្អែកលើយុទ្ធសាស្ត្រស្ថាបនាជាតិថ្មីនេះ ដោយយកសាសនាជាត្រីវិស័យ មូលដ្ឋានសម្រាប់ការអភិវឌ្ឍន៍ ហើយក្នុងគោលបំណងផ្សារភ្ជាប់មណ្ឌលវប្បធម៌ជិតឆ្ងាយនៅជនបទទៅនឹងស្ថាប័នរដ្ឋអំណាច គឺព្រះរាជធានី សមស្របនឹងនយោបាយបង្រួបបង្រួមជាតិផង អតីតអ្នកដឹកនាំបានផ្តោតការយកចិត្តទុកដាក់ចាប់អារម្មណ៍លើវិស័យសាសនាសន្តិភាព ។ ដូចនេះ ទាំងព្រះរាជា មន្ត្រីជាន់ខ្ពស់ រមែងទៅកាន់ទេវស្ថាននានាក្នុងប្រទេស ទៅកាន់ទីរួមខេត្តជិតឆ្ងាយ

ដោយមានវត្តមានរបស់ពួកព្រាហ្មបុរោហិត ។ ពីព្រោះទ្រង់ឈ្វេងយល់ថា វិស័យសាសនា គឺជាមធ្យោបាយតែមួយគត់ ដើម្បីមិនតែចងខ្មែរជាបាច់ ប៉ុន្តែពង្រឹងពង្រីកអំណាចកណ្តាល ដែលមានព្រះអង្គម្ចាស់ជាប្រមុខ ហើយបើមណ្ឌលវប្បធម៌នៅតាមខេត្តនានា ត្រូវបានរឹងប៉ឹងកាលណាអំណាចកណ្តាលរបបរាជាធិបតេយ្យ និងមានឥទ្ធិពលខ្លាំងក្លាឡើងកាលនោះ ។ មណ្ឌលទាំងនោះ គឺជាទីប្រជុំជនយ៉ាងកុះករ ដែលផ្សារភ្ជាប់និងព្រះរាជធានី ដែលមានព្រះរាជាប្រថាប់គង់នៅទីនោះ ។ ការប្រមូលផ្តុំអំណាចរដ្ឋបាលតាមរយៈមណ្ឌលនយោបាយ សេដ្ឋកិច្ច និងវប្បធម៌តូចធំទាំងឡាយ ដែលស្ថិតនៅជុំវិញព្រះរាជធានី ត្រូវបានអនុវត្តន៍ដោយពួកអភិជន ដែលជានិច្ចកាលទទួលនូវកិត្តិយសលាភសក្ការៈ ពីសំណាក់ព្រះមហាក្សត្រ ព្រោះគេជាមន្ត្រីរបស់ព្រះបរមរាជវាំង ដូចជាការដំឡើងស័ក្តិយស ឬការផ្តល់អំណាចជាដីធ្លីជាដើម សម្រាប់សាងសង់ត្រួតត្រា ឬធ្វើស្រែចំការ ។

ស្ថានភាពនេះ ពុំធ្លាប់មានឡើយនាសម័យមុនឥទ្ធិពលឥណ្ឌា ។ ដូចនេះការផ្សព្វផ្សាយអំពីលទ្ធិសាសនាដល់ប្រជានុរាស្ត្រ តាមរយៈព្រះមហាក្សត្រ ឬពួកអភិជន ព្រមទាំងពួកព្រាហ្មណបុរោហិត ឬព្រះសង្ឃជាចំណុចនៃការរៀបចំស្រុកទេស ឬការគ្រប់គ្រងសង្គមជាតិដោយមានវណ្ណៈ ឬប្រភេទខុសៗគ្នាក្នុងប្រទេសកម្ពុជា ក៏ប៉ុន្តែពុំមែនលក្ខណៈតឹងរ៉ឹងដូចប្រទេសឥណ្ឌាឡើយ ។

ការរៀបចំរចនាសម្ព័ន្ធឱ្យមានអ្នកដឹកនាំ មានឋានៈនិងវត្តមានរបស់អ្នកស្រែចំការ ដែលមានសេរីភាព និងអ្នករកស៊ីឈ្នួលគេ ពោលគឺបាវព្រាវដែលរស់នៅជុំវិញទីក្រុងតូចធំខាងលើនេះ ឆ្លុះបញ្ចាំងនូវរបៀបគ្រប់គ្រងចាត់

ថែងសង្គមជាតិនាសម័យបុរាណយ៉ាងពិតប្រាកដ តាមឋានានុក្រម ។ រីឯអំណាចរបស់ព្រះមហាក្សត្រក៏ដូច្នោះដែរ ពោលគឺមិនអាចផ្តាច់ចេញពីស្ថាប័នរដ្ឋបាលឡើយ ពីព្រោះព្រះអង្គស្ថិតនៅលើកំពូលនៃរចនាសម្ព័ន្ធ ។

## ៨-គម្លាតវប្បធម៌រវាងទំនាប ខ្ពង់រាប និង ឯកភាពរូបនីយកម្មក្នុងចក្រភពមុនអង្គរ និងអង្គរ

ក្នុងពេលដែលសង្គមខ្មែរស្ថិតក្រោមឥណ្ឌូរូបនីយកម្ម ហើយបានទទួលការប្រែប្រួលខាងរចនាសម្ព័ន្ធនយោបាយ និងសេដ្ឋកិច្ច ប្រជាជនខ្មែរក៏ត្រូវឆ្លងកាត់នូវការផ្លាស់ប្តូរ ប្រែប្រួលទម្រង់ដ៏ស៊ីជម្រៅខាងវិស័យមនោគមន៍វិជ្ជា ឬខាងចិត្តសាស្ត្រ ដោយសារមូលហេតុនេះហើយ ដែលតួបផ្សំនឹងទេពកោសល្យខ្ពស់របស់ដូនតា ជនជាតិខ្មែរបាននទទួលនូវវឌ្ឍនភាពដ៏ខ្ពង់ខ្ពស់ មាំមួនក្នុងអតីតកាល ។

ចំពោះអតីតកាលដ៏មហារុងរឿងនេះ ប្រជាជនខ្មែរជានិច្ចកាល មិនថាជាអ្នកមាន ឬអ្នកក្រនោះទេ រមែងតែនឹកដល់មនោសញ្ចេតនារបស់គេ រមែងតែជិតដាមទៅនឹងស្លាកស្នាមវប្បធម៌បុរាណ ផ្តេកផ្តួលលើចំណុចនេះ ឬក៏បានកត់ត្រាទុកក្នុងក្រអៅបេះដូងយ៉ាងជ្រៅផង ។

តាមពិត អតីតកាលរបស់ខ្មែរ មានតួនាទីយ៉ាងសំខាន់បំផុត ក្នុងការថែរក្សាអត្តសញ្ញាណជាតិខ្មែរ ហើយបើប្រសិនជាអតីតកាលនេះ គេបំផ្លាញតើជនជាតិខ្មែរនៅមានអ្វីទៀតសម្រាប់សំអាង ឬសម្គាល់ ឬក៏ជាជំនួយទំនុក

ប៉ះរុងចិត្តសាស្ត្រ ឬស្មារតី ។ ផ្ទុយទៅវិញ ប្រសិនបើរាល់ស្នាកស្នាមពាក់ព័ន្ធទៅនឹងអតីតកាលត្រូវថែទាំឱ្យបានគង់វង់ សេចក្ដីទុកចិត្តលើខ្លួនឯង និងលើវាសនាជាតិ មោទនភាពជាតិ និងក្លាយទៅជាត្រីវិស័យរុញច្រានមួយយ៉ាងសំខាន់ ក្នុងការកសាងសម្បជ្ជញ្ញៈជាតិ ។

ក្នុងករណីនេះ ប្រការដែលធ្វើឱ្យយើងព្រួយបារម្ភណ៍ជាងគេនោះគឺចាប់តាំងពីឆ្នាំ១៩៩២មក គ្មានសញ្ញាអ្វីមួយបញ្ជាក់ឱ្យយើងឃើញថា វិធានការទប់ស្កាត់ការជួញដូរវត្ថុបុរាណនៅប្រទេសខ្មែរ ត្រូវគេអនុវត្តន៍តាម ថ្វីដ្បិតតែយើងបានខិតខំតាមរយៈអត្ថបទយ៉ាងណាក៏ដោយ ។

ទន្ទឹមនឹងនេះ ជាការសោកស្ដាយណាស់ ដែលអសកម្មរបស់មនុស្សខ្លះ ត្រូវបិតបាំង ភូតកុហកដោយរបាយការណ៍ខ្យល់ មិនស៊ីជម្រៅ គួបផ្សំនឹងមហិច្ឆិតាចង់កែប្រែទំព័រប្រវត្តិសាស្ត្រ ដោយប្រទេសជិតខាង។ ទាំងនេះអាចជាគ្រោះថ្នាក់មួយយ៉ាងធំ ដែលប្រទេសជាតិខ្មែរអាចនឹងជួបប្រទះក្នុងពេលអនាគតដ៏ខ្លីខាងមុខនេះ ។

និយាយពីវឌ្ឍនភាពនៃខឿនវប្បធម៌ខ្មែរ ត្រូវចងចាំថា វឌ្ឍនភាពនេះពុំអាចមានលក្ខណៈទូទៅនោះទេក្នុងអតីតកាល ព្រោះមានគម្លាតរវាងវាលទំនាបនិងខ្ពង់រាបនៅសម័យបុរេអង្គរ ភូមិភាគឦសាននៃប្រទេសថៃបច្ចុប្បន្នស្ថិតនៅក្នុងចក្រភពអង្គរ ។ ខុសពីតំបន់វាលទំនាប ដែលមានភាពរុងរឿងខាងសង្គមកិច្ច ភូមិភាគនេះជាតំបន់ខ្ពស់ ភាគដែលសម្បូរទៅដោយព្រៃភ្នំ ។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្ដី គេក៏មិនអាចផ្ដាច់ភូមិសាស្ត្រនេះ ដែលសម្បូរណ៍ទៅដោយ

ភាពក្រីក្រ ពីភាគផ្សេងៗ ឯទៀតនៃទឹកដីខ្មែរដែរ ។ ដោយសារមូលហេតុចម្បងនេះហើយ ទើបអំណាចកណ្តាលមូលដ្ឋាន មិនបានគ្រប់គ្រងភូមិភាគនេះឱ្យបានជិតដល់ ។ ម្យ៉ាងវិញទៀត ភាពមិនអនុគ្រោះខាងភូមិសាស្ត្រ និងសេដ្ឋកិច្ចក៏ជាមូលហេតុនៃភាពយឺតយ៉ាវនៃការអភិវឌ្ឍន៍តំបន់ ដូចបណ្តាជនបទនានានៃដែនដីសណ្តរ ។ គេត្រូវរង់ចាំដល់ចុងស.វ.ទី៥ និងដើមស.វ.ទី៦នៃគ.ស. ទើបឃើញរីកចម្រើនខាងវប្បធម៌ និងវិចិត្រសិល្បបែបព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា ។

បើនិយាយម្យ៉ាងទៀតស្ថាបត្យកម្មប្រាសាទ និងចេតិយវត្តអារាម បានកើតមានឡើងយ៉ាងសន្សឹមៗចាប់ពីសម័យចេនឡា ដោយសន្ទុះនៃជំនឿសាសនាដែលបានជ្រាបចូលក្នុងភូមិភាគនេះ បានបង្ករជាកម្លាំងរុញច្រានមួយបណ្តាលឱ្យមានការលេចធ្លោនូវបុរាណស្ថានជាច្រើនយ៉ាងឆាប់រហ័ស ឈានទៅរកវឌ្ឍន ភាពដូចតំបន់ផ្សេងៗទៀតនៃសម័យបុរេអង្គរ ជាពិសេសសម័យអង្គរ ។

ដូច្នេះហើយ ទើបយើងឃើញវត្តមានរបស់បូជនីយដ្ឋានជាច្រើនគួរឱ្យចាប់អារម្មណ៍ ។ ទាំងនេះ ក៏បញ្ជាក់ឱ្យឃើញថា ប្រជាជនក្នុងតំបន់ទាំងនោះមានជំនឿស៊ុបទៅលើមនោគមន៍វិជ្ជាសាសនាឥណ្ឌា ។

ថ្វីត្បិតតែបុរាណស្ថាននាសម័យចេនឡា មានចំនួនស្តួចស្តើងយ៉ាងណាក៏ដោយ ហើយបញ្ហានេះ ពុំបានទទួលការចាប់អារម្មណ៍យ៉ាងណាក៏ដោយ តែវត្តមានរបស់ស្នាកស្នាមវប្បធម៌បែបឥណ្ឌា ត្រូវបានយើងចាត់ទុកថាជាការបដិវត្តន៍មួយក្នុងតំបន់ ។ ដូច្នេះប្រាង្គប្រាសាទ ឬក៏ចេតិយវត្ថុបុរាណទាំងនោះ អាចបង្ហាញឱ្យឃើញថា ភាគច្រើនប្រជាជនមានការគោរពប្រតិបត្តិ មានសណ្តាន

ចិត្តរាប់អានស្រឡាញ់ចូលចិត្តលទ្ធិព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា ដោយសារតែសីលធម៌ដ៏ខ្ពង់ខ្ពស់នៃមនោគមន៍វិទ្យាសាសនាថ្មី ដែលទើបតែត្រូវបាននាំចូល ។

សេចក្តីដែលរៀបរាប់ខាងលើ បញ្ជាក់ឱ្យឃើញថា ពីបរិស្ថានវប្បធម៌ចាប់តាំងពីសស.វ.ទី១ ដល់ទី៦ក្នុងភូមិភាគឦសាននៃប្រទេស ថៃបច្ចុប្បន្ន ដែលជាចំណែកមួយនៃអតីតប្រទេសកម្ពុជា ដែលមិនបានទទួលឥណ្ឌូបនីយកម្ម ហើយលុះឈានមកដល់សស.វ.ទី៦នៃគ.ស. ទើបទទួលការគ្រប់គ្រងបែបរាជាធិបតេយ្យពហុទេវៈ មានហេដ្ឋារចនាសម្ព័ន្ធ និងបូជនីយដ្ឋានដូចគ្នានឹងតំបន់ផ្សេងៗ និងវាលទំនាបឯទៀត ។

ដូច្នេះទិន្នន័យខាងបុរាណវិជ្ជា បញ្ជាក់ពីបញ្ហាវត្តមាននៃប្រាង្គប្រាសាទខ្មែរ ក្នុងភូមិភាគឦសាននៃប្រទេសថៃបច្ចុប្បន្ន ដែលពាក់ព័ន្ធទៅនឹងការផ្សព្វផ្សាយនៃមនោគមន៍វិជ្ជាសាសនាឥណ្ឌា ។ គឺក្នុងករណីនេះហើយ ដែលបន្ថិចម្តងៗជំនឿថ្មឈរដែលជាសញ្ញានិមិត្តតំណាងបុព្វការីជន និងដូនតាត្រូវលុបបំបាត់ចោល ឬជំនួសដោយសីមាវត្តបន្តិចម្តងៗ ដោយវប្បធម៌សីមាវត្តក៏ចាប់បដិសន្ធិឡើង ។ សូមជម្រាបថា ជំនឿបែបនេះ ដែលតែងតែជឿថា ថ្ម តំណាងឱ្យអង្គជាតិរបស់ដូនតា ហើយមានជីវិត ដូចជាករណីថ្មដុះជាដើម ក៏នៅមានដែររហូតមកដល់ពេលបច្ចុប្បន្ននេះទៀត តែសម្រាប់ជនបទដាច់ស្រយាល ឬតំបន់ព្រៃភ្នំ ។

នៅប្រទេសកម្ពុជា ក៏ដូចជានៅប្រទេសថៃភាគឦសានដែរ នៅមានប្រជាជនតិចតួចទេ ដែលនៅរក្សាទស្សនស្តីពីនិមិត្តរូបនៃថ្មដុះ ឬមានជីវិត ។

នេះជាការពិតជាក់ស្តែង ព្រោះថា ជំនឿនេះ ជាជំនឿជីវចលនិយម ដែលលក្ខណៈជាទូទៅមុនការផ្លាស់ប្តូរសាសនា ពីជំនឿជីវចល ឬលើព្រលឹង មកព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា ។

បើពិនិត្យសង្កេតឱ្យស៊ីជម្រៅទៅឃើញថា អវត្តមាននៃប្រាង្គប្រាសាទ ឬបូជនីយដ្ឋាននៃព្រះពុទ្ធសាសនានាសម័យនគរភ្នំ ឬក្រោយនេះបន្តិច នៅក្នុងភូមិភាគខាងលើនេះ ពុំមែនមានន័យថា តំបន់ទាំងនោះ ពុំមានជនជាតិខ្មែររស់នៅនោះទេ ។ អវត្តមាននៃមតិកវប្បធម៌បែបឥណ្ឌា ឆ្លុះបញ្ចាំងឱ្យឃើញថា មនោគមន៍វិជ្ជាសាសនាឥណ្ឌា មិនទាន់មកដល់ទីនេះ ឬក៏តំបន់នេះ ពុំទាន់រៀបចំឱ្យបានជាទីគាប់ចិត្ត ដូចតំបន់វាលទំនាបនៅឡើយ ។

ដូច្នេះហើយ គោលនយោបាយរបស់ព្រះមហាក្សត្រខ្មែរនាសម័យបុរេអង្គរ ជាពិសេសព្រះបាទមហេន្ទ្រវរ្ម័នបានសង្កត់លើកំណែទម្រង់សង្គម ក្នុងនោះមានការសាងសង់ប្រាង្គប្រាសាទ ទេវតាថ្មីនៃលទ្ធិព្រហ្មញ្ញសាសនា និងសញ្ញានិមិត្តនៃព្រះពុទ្ធសាសនា ដូចជាព្រះពុទ្ធបាទជាដើម ជុំនួសជំនឿលើថ្មធម្មជាតិរបស់ដូនតាក្នុងភូមិភាគនេះ ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់រាជរដ្ឋាភិបាលរបស់ព្រះអង្គ ។ ការយកចិត្តទុកដាក់របស់ព្រះមហាក្សត្រនេះ ចំពោះការបង្រួបបង្រួមជាតិ តាមរយៈការសាងសង់នូវបូជនិយដ្ឋានជាច្រើន ដែលអាចឆ្លុះបញ្ចាំងតាមរយៈផ្ទាំងសិលាចារឹកជាច្រើន ពាសពេញដេរដាសទាំងចក្រភពចេនឡា ដែលគេបានរកឃើញពីវត្តភូ (ស្រេដ្ឋបុរៈ) ដល់ (សម្បូរណ៍ព្រៃគុក) និងកំពង់ចាម ហើយពីនេះដល់កម្ពុជាក្រោម ហើយពីវត្តភូ ដល់នគររាជសីមា ដោយឆ្លងកាត់ខេត្តអ៊ូប៊ុន រាជធានីសុរិន្ទ្រ បុរីរម្យ យសោធន ។ល។

ម្យ៉ាងវិញទៀតទំនាក់ទំនងរវាងព្រះរាជធានីធំៗ នៃចក្រភពចេនឡា និងតំបន់ផ្សេងៗទៀត បន្តិចម្តងៗ ក៏បានក្លាយទៅជាអាណាខេត្តនានា ហើយដែលទើបតែត្រូវបានបញ្ចុះបញ្ចូល អ្វីដែលគេឱ្យឈ្មោះថា ការធ្វើឯកសមោធាន ឬការប្រមូលរួបរួមឱ្យក្លាយទៅជាប្រទេសតែមួយ ក៏មិនអាចរលួនស៊ីចង្វាក់គ្នាភ្លាមៗដែរ ព្រោះកត្តាពេលវេលា ។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏ការកែទម្រង់សាសនា និងសង្គមអាចគូសបញ្ជាក់តាមរយៈសំណង់សាសនា និងសិលាចារឹកបុរាណ ។

យោងតាមកត្តាខាងលើ យើងគប្បីសិក្សាស្វែងយល់អំពីស្ថានភាពទូទៅរបស់ភូមិភាគឦសាននៃព្រះរាជាណាចក្រថៃ និងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ន ដែលពុំបានឆ្លងកាត់ការវិវឌ្ឍន៍ដូចភូមិភាគនៃតំបន់វាលទំនាប ហើយត្រូវភ្ជាប់ទៅនិងភូមិសាស្ត្រប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជា ដែលជាជនជាតិធំក្នុងភូមិភាគអាស៊ីអាគ្នេយ៍ដែនគោក ប្រយោជន៍នឹងថែរក្សាឱ្យបាននូវអត្តសញ្ញាណជាតិ និងការចងចាំរួមនៃជនជាតិខ្មែរ ដែលជាជនជាតិចាស់ ហើយដែលធ្លាប់មានទឹកដីដ៏មហាធំធេងមហិមា ។

រួមសេចក្តីមក គប្បីកូនខ្មែរទាំងឡាយត្រូវតែថែរក្សានូវទំព័រប្រវត្តិសាស្ត្រខាងលើនេះឱ្យបាន ទើបរកអត្តសញ្ញាណជាតិរបស់ខ្លួនឃើញ បើពុំដូច្នោះទេ ប្រវត្តិសាស្ត្រខ្មែរ និងត្រូវពិការពុំខាន ឬពុំមានលក្ខណៈពេញលេញឡើយ ។

ជាអវសានគួបញ្ជាក់ផងដែរថា គម្លាតនៃវប្បធម៌ខាងលើនេះ មានលក្ខណៈជាទូទៅក្នុងចក្រភពបុរេអង្គរ ជាពិសេសក្នុងតំបន់ខ្ពង់រាបនានា ពីស.វ.ទី១ ដល់ស.វ.ទី៧នៃគ.ស. នេះគឺជាទិដ្ឋភាពរួម កាលបើយើងធ្វើដំណើរស្រាវ

ជ្រាវ ពីព្រោះកម្រណាស់ ដែលយើងជួបប្រទះនូវស្នាកស្នាមវប្បធម៌បែបព្រាហ្មណ៍និយម ឬពុទ្ធនិយម ក្នុងទឹកដីទាំងនោះ ។ ប៉ុន្តែចាប់តាំងពីស.វ.ទី ១០ មក គេឃើញមានការលេចធ្លោនៅក្នុងសង្គម នូវស្ថាបត្យកម្មប្រាង្គប្រាសាទ និងព្រះបដិមាឥណ្ឌា-ខ្មែរ ។ នេះគឺជាព្រឹត្តិការណ៍វប្បធម៌សំខាន់បំផុត ឆ្លុះបង្ហាញឱ្យឃើញការអភិវឌ្ឍន៍នៃតំបន់ខ្ពង់រាបទាំងនោះ តាមទម្រង់វប្បធម៌សម័យទំនើប ដែលទើបតែហូរចូល និងឆន្ទៈរបស់ប្រជាជនខ្មែរ ដែលទទួលមតិកវប្បធម៌ឥណ្ឌា ។ ដូច្នេះហើយទើបគេសាងសង់ប្រាង្គប្រាសាទជាច្រើន ដើម្បីវិស័យជំនឿសាសនា និងសីលធម៌ ហើយបន្ទាប់មកទៀតស្ថានភាពនេះ មិនបានប្រែប្រួលអ្វីទេក្នុងសម័យអង្គរ ប៉ុន្តែផ្ទុយទៅវិញ សង្គមខ្មែរចេះតែរីកចម្រើនឡើងជាលំដាប់ បានជានៅតាមជនបទគេឃើញភស្តុតាងនៃស្ថាបត្យកម្មប្រាង្គប្រាសាទ និងវត្តអារាមជាច្រើនកុះករ យ៉ាងទូលំទូលាយខុសពីសម័យបុរេអង្គរ ។ ទាំងនេះ ក៏បញ្ជាក់ឱ្យដឹងថា នៅសម័យមហានគរ ការចេះដឹងកាន់តែមានកម្រិតខ្ពស់ឡើងៗ ជាលំដាប់ដូចជាចំនួនទេវស្ថានក្នុងតំបន់ទីក្រុង ឬជនបទជាសក្ខីកម្មស្រាប់ ។

ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏ប្រជាជនខ្មែរ ដែលប្រកបដោយអរិយធម៌សំយោគ ហើយមានលក្ខណៈសាកលនៅតែរក្សានូវប្រពៃណី ទំនៀមទំលាប់មន-ខ្មែរ ជូនតានាសម័យបុរេប្រវត្តិសាស្ត្រមួយចំនួន ឱ្យបានគង់វង់រហូតដល់សព្វថ្ងៃនេះ អ្វីដែលយើងនិងចងក្រងក្នុងទំព័រខាងក្រោមនេះ ។

# ជំពូក២

## សម្ពទ្ធិកម្មផ្នែកសង្គម សេដ្ឋកិច្ច វប្បធម៌ នាសម័យបុរេប្រវត្តិសាស្ត្រ

## ១-ខ្មែរមានជំនឿសាសនាខ្លួនឯងផ្ទាល់ មុនព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា

ជនជាតិខ្មែរជាជនជាតិមានចំណាស់បំផុត រីឯវប្បធម៌ អារ្យធម៌ក៏ដូច្នេះដែរ ។ ប៉ុន្តែគួរឱ្យស្តាយណាស់ រហូតមកដល់សព្វថ្ងៃនេះទៅហើយ យើងនៅមិនទាន់មានឃើញការស្រាវជ្រាវណាមួយស្តីពីជំនឿសាសនា សម័យបុរេប្រវត្តិសាស្ត្រទេ ។ មានសៀវភៅជាច្រើនបាននិពន្ធឡើង ប៉ុន្តែគេគ្រាន់តែអត្ថាធិប្បាយអំពីព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា ដែលបានហូរចូលមកក្នុងទឹកដីខ្មែរនាដើមស.វ.ទី១នៃគ.ស. ហើយជំនឿសាសនាខ្មែរ ដែលមានមុនការនាំឥចូលនៃសាសនាសំខាន់ទាំងពីរនេះ ត្រូវគេបោះបង់ចោល ឬមិនបានស្រាវជ្រាវឱ្យបានដិតដល់ ។ តាមពិតកង្វះខាតនេះ បណ្តាលមកពីទស្សនៈមួយដែលយល់ថា មុនវត្តមានរបស់ព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា ខ្មែរគ្មានជំនឿសាសនាទេ ហើយអ្វីដែលមានជាជំនឿសាសនាអកុសល ឬអបិយជំនឿទាំងអស់ ។ ជាការវិភាគមួយក្នុងការស្រាវជ្រាវស្តីពីប្រភពនៃវប្បធម៌ អារ្យធម៌ខ្មែរ ជំនឿសាសនាខ្មែរទាក់ទិនទៅនិងធម្មជាតិ ទឹក ដី ភ្លើង ឆ្នាំ១៩៩០ ១៩៩១ នៅមហាវិទ្យាល័យការំង បានឱ្យដឹងថា ជនជាតិខ្មែរដើមក៏ដូចជាអារ្យធម៌ដទៃទៀតដែរ បានមានជំនឿសាសនាជីវចលផ្ទាល់របស់ខ្លួនច្រើនពាន់ឆ្នាំ មុនសម័យប្រវត្តិសាស្ត្រ ហើយសំណង់វប្បធម៌នេះ បានវិវឌ្ឍន៍ពីយុគមួយទៅយុគមួយទៀត ដោយមានទំនាក់ទំនងនឹងវប្បធម៌ឥណ្ឌា ចិន និងចក្រភពក្រិក រ៉ូម៉ាំង នា

ដើមស.វ.ទី១នៃគ.ស. ។

មិនតែប៉ុណ្ណោះ ការស្រាវជ្រាវនេះ បានឱ្យដឹងទៀតថា ជំនឿសាសនាខ្មែរបច្ចុប្បន្ននេះ មានលក្ខណៈជាវប្បធម៌សំយោគ ហើយមានឈ្មោះថា ទ្រឹស្តីត្រីកោណនៃជំនឿសាសនាខ្មែរ ពោលគឺភាពបូកផ្សំគ្នារវាងអ្វីៗ ដែលជាលក្ខណៈខ្មែរបែបព្រហ្មញ្ញសាសនា និងពុទ្ធសាសនានិយម ។

ដោយពឹងផ្អែកទៅលើការវិភាគ អំពីកំណាយស្ថានីយបុរេប្រវត្តិសាស្ត្រ ការសិក្សាតាមរយៈជាតិពន្ធុវិទ្យានៃជនជាតិខ្មែរ និងកុលសម្ព័ន្ធខ្មែរលើ ដែលពុំបានទទួលឥទ្ធិពលពីក្លឹង្គ ហើយបានថែរក្សាជំនឿប្រពៃណី ជំនឿដូនតាតាំងតែពីសម័យបុរាណកាលមកម្ល៉េះ ។

មុនសម័យបុរេប្រវត្តិសាស្ត្រ ជនជាតិខ្មែរយើងគោរពព្រះ (ពាក្យខ្មែរ) ទេវតា ឬអាទិទេព (ពាក្យសំស្ក្រឹត) ដែលពុំមានរូបរាងដូចជាខ្យល់ ទឹក ដី ពី ព្រោះគេជឿថា ធម្មជាតិទាំងឡាយ ដែលស្ថិតនៅជុំវិញខ្លួន សុទ្ធសឹងតែមានព្រលឹងដ៏មានឫទ្ធានុភាព ឬភាពស័ក្តិសិទ្ធិ អាចផ្តល់ចំពោះគេនូវរាល់សេចក្តីសុខសប្បាយ ។ ដោយហេតុនេះហើយ បានជាគេសូន្យរូបសត្វ (គោ ក្របី ស្វា....) ឬយកថ្មមកគោរពបូជា ដើម្បីសេចក្តីសុខចម្រើនរបស់គេ ។ ការបូជានូវវត្ថុនិងសត្វដែលមានជីវិត ដែលតំណាងនូវធាតុ ឬសារជាតិអ្វីមួយ គេបានប្រឌិតនូវសត្វអច្ឆរិយដែរ ។ ថ្មធម្មជាតិ ដើមឈើ ឬសត្វទាំងនោះ គេចាត់ទុកថាជាកេតនភណ្ឌតំណាងនូវអ្វីដែលខ្ពង់ខ្ពស់ពិសិដ្ឋ អាចជួយសង្គ្រោះគេពេលមានអាសន្ន ឬមានគ្រោះថ្នាក់ម្តងៗ ។

គួនិយាយឱ្យដឹងដែរថា ការបូជាសត្វពុំមែនមានន័យថា សត្វជាសត្វទេ

ក៏ប៉ុន្តែជាឥទ្ធិពលធម្មជាតិ ដែលសត្វទាំងនោះ ជាតំណាង ដូចជាគេតំណាងជីវិត ឬធាតុដីដែលផ្តល់នូវធញ្ញជាតិ ។

ទន្ទឹមនិងនេះដែរ គេគោរពបូជាបុព្វការីជន ដែលបានចែកឋានទៅ ដោយយកសពទៅកប់ ហើយបញ្ចុះនូវគ្រឿងបរិភោគ ប្រការនេះហើយដែល ទាក់ទិនទៅនិងទ្រឹស្តីចាប់ជាតិឡើងវិញ ឬអមតៈរបស់ព្រលឹង ហើយដែល មានលក្ខណៈសាកល ។ ការបូជាបុព្វការី ឬបុព្វបុរសមានអត្ថន័យខ្ពង់ខ្ពស់ ណាស់ ពីព្រោះសម្តែងឡើងនូវកតញ្ញូតាធម៌ចំពោះដូចតា ឪពុកម្តាយ ចាស់ទុំ ដែលមានគុណភាពដោយបានដោះស្រាយដី ព្រៃ ឬបង្កើតវប្បធម៌ គឺទំនៀម ទម្លាប់និងបច្ចេកទេសផ្សេងៗ ។ ការស្រាវជ្រាវ ក៏បានបង្ហាញនូវស្នាកស្នាម សាសនាដើម ដោយភ្ជាប់មកនូវបដិមាសាស្ត្រ និងវប្បធម៌ជាច្រើន នេះជាសម្មិទ្ធិផលផ្នែកបញ្ញាញាណនាសម័យថ្មរំលីង ដែលគេបានជួបប្រទះក្នុងស្ថានីយ មួយចំនួនធំ ក្នុងភូមិភាគឥណ្ឌូចិនយើងនេះ ដែលជាដែនដីកំណើតនៃជនជាតិ ខ្មែរ ។

ក្នុងយុគ្គសម័យវប្បធម៌លោហធាតុ គេក៏ជួបប្រទះការគោរពបុព្វការី ជន ឬបុព្វបុរសក្រោមរូបភាពមនុស្សប្រុស និងស្រីដែរ ដែលនាំឱ្យពួកគេអាច បន្តវង្សត្រកូល ឬខ្សែស្រឡាយបាន ។ គេបានរកឃើញរបស់ណាកជាច្រើន តំណាងបុព្វការីជនទៅតាមផ្នូរខ្មោច ធ្វើពីដីដុត ភក់និងសំរិទ្ធ ។

ក្នុងសម័យប្រវត្តិសាស្ត្រ ក្រោមឥទ្ធិពលក្លឹង្គបន្តិចម្តងៗ ជំនឿទៅលើ អាទិទេព ដែលជារូបសត្វ ឬជំនឿលើបុព្វការីជនត្រូវកែប្រែទម្រង់លក្ខណៈ សម្បត្តិរបស់ខ្លួន ហើយក្លាយទៅជាអាទិទេពនៃព្រហ្មញ្ញសាសនា ។ ក៏ប៉ុន្តែ

ទោះជាយ៉ាងណាក៏ដោយ ជំនឿលើបុព្វការីជនដែលតំណាងទឹក ដី ភ្នំ ភ្លើង ដូចជាអារក្សអ្នកតានៅតែមានឥទ្ធិពលខ្លាំងដដែល ។

តទៅនេះ យើងនឹងសិក្សាអំពីការទុកសព ដែលជាប្រពៃណីមួយទាក់ទងទៅនឹងការគោរពបុព្វការីជននាសម័យមុនឥណ្ឌាចូលមកស្រុកខ្មែរ ដែលបណ្តាលឱ្យមានការផ្លាស់ប្តូរពីការកប់សពនៅជាការដុតសពទៅវិញ តាមបែបឥណ្ឌានិយម ។

## ២~ស្លាកស្នាមនៃមូសកែវចវប្បធម៌ខ្មែរ តាមស្ថានីយបុរេប្រវត្តិសាស្ត្រ

ក្នុងអតីតកាល ជនជាតិខ្មែរដែលបានកើតហើយស្លាប់វិលចុះឡើងនៅលើជ្រោយឥណ្ឌូចិនយើងនេះ បានបន្សល់ទុកនូវគ្រឹះវប្បធម៌ដ៏ចំណាស់ និងរុងរឿងសម្រាប់មនុស្សជំនាន់ក្រោយ ។ ប៉ុន្តែជាការគួរឱ្យសោកស្តាយណាស់ ដែលភស្តុតាងនៃស្លាកស្នាមទាំងនោះ ត្រូវបានប្រជាជនយើងខ្វះការយល់ដឹងពីផ្នែកវប្បធម៌ជាតិ បែរជាជីកនាំយកទៅលក់ឱ្យប្រទេសជិតខាងទៅវិញ ។

សមិទ្ធិកម្ម ដែលបុព្វបុរសបានបន្សល់ទុក តាមរយៈវត្ថុបុរាណទាំងអស់នោះ ក្នុងបំណងទុកសម្រាប់ការគោរពសក្ការៈនៃញោមញាតិ ឬបងប្អូនដែលបានចែកឋានទៅហើយ ដោយត្រូវបានយកទៅកប់ជាមួយសព ដើម្បីជានិមិត្តរូបនៃជីវិតអមតៈនៅបរលោក ។ កេរតំណែលទាំងអស់នេះ អាចបង្ហាញនូវប្រពៃណីនិងជំនឿជាបន្តពីដូនតាយើងមក ។

ការសិក្សាស្វែងយល់អំពីបរិយាកាស នៃការអភិវឌ្ឍន៍វប្បធម៌ខ្មែរ ពីសម័យមួយទៅសម័យមួយទៀត ប្រសិនបើយើងបាត់បង់នូវភស្តុតាងទាំង

អស់នេះ ប្រៀបបាននឹងការបាត់អត្តសញ្ញាណជាតិយ៉ាងដូច្នោះដែរ ។ ផ្ទុយទៅវិញ បើយើងថែរក្សាស្លាកស្នាមវប្បធម៌ទាំងអស់នោះ កុំឱ្យបាត់បង់បានគឺជាការថែរក្សាមរតកបេតិកភណ្ឌជាតិ និងភាពសម្បូរណ៍បែបរបស់វា ។

នៅក្នុងការលួចជីកគាស់កកាយ នៅស្ថានីយបុរេប្រវត្តិសាស្ត្រភូមិស្នាយខេត្តបន្ទាយមានជ័យ ដែលប្រជាជននាំគ្នាយករូបចម្លាក់មនុស្សកាន់អាវុធ (ដាវ) នៅក្នុងដៃយកទៅលក់ឱ្យជនជាតិថៃ គឺជាការបាត់បង់គ្រឹះវប្បធម៌យ៉ាងពិតប្រាកដ ។ ព្រោះការបន្សល់ទុកនូវរូបចម្លាក់មនុស្សកាន់អាវុធនេះយើងអាចដឹងនូវខឿនវប្បធម៌របស់ជាតិយើង ។

តាមអ្នកប្រវត្តិសាស្ត្រជនជាតិចិនបានឱ្យដឹងថា មនុស្សកាន់អាវុធ (ដាវ) នៅក្នុងដៃនេះ បានបង្ហាញឱ្យយើងឃើញនិងដឹងថា ចម្លាក់បុរាណនេះតំណាងឱ្យជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្មែរនាសម័យវប្បធម៌នគរភ្នំ កាលពីស.វ. ទី១ដល់ទី៦នៃគ.ស. ។ អ្នកស្រុកសម័យនោះ កាន់ដាវជាប់និងដៃពេលចេញទៅណាមកណា គឺជាទម្លាប់មួយសម្រាប់ទុកការពារខ្លួនរបស់គេផ្ទាល់តែប៉ុណ្ណោះ ។ ទម្លាប់នេះ មានតាំងពីសម័យបុរេប្រវត្តិមកម្លេះ ។

យើងមានការបាត់បង់ស្លាកស្នាមខឿនវប្បធម៌យ៉ាងដំណំមួយ នាពេលកន្លងមកនេះ ។ ប្រជាជនបាននាំគ្នាទៅបំផ្លិចបំផ្លាញសស្ថានីយបុរេប្រវត្តិសាស្ត្រនៅភូមិកញ្ច្រៀចខេត្តព្រៃវែង និងនៅស្ថានីយបុរេប្រវត្តិសាស្ត្រនៅភូមិស្នាយខេត្តបន្ទាយមានជ័យ ។

ស្ថានីយបុរេប្រវត្តិសាស្ត្រទាំងពីរខាងលើនេះ ជាឃ្លាំងនៃខឿនវប្បធម៌និងអារ្យធម៌មានតម្លៃពុំអាចកាត់ថ្លៃបានឡើយ ។ ព្រោះស្ថានីនេះ វានឹងបង្ហាញ

ឱ្យដឹងពីទំនាក់ទំនងប្រវត្តិសាស្ត្រនៃជនជាតិខ្មែរ ពីស.វ.ទី៤ដល់ទី៥ ។ តាមរយៈវត្ថុសិល្បៈបុរាណទាំងអស់នេះ កាន់តែធ្វើឱ្យយើងដឹងថែមទៀតនូវឧត្តមភាព និងអារ្យធម៌ដ៏រុងរឿងកាលពីសម័យបុរាណកាលមក ។

ការជីកគាស់ស្ថានីយប្រវត្តិសាស្ត្រ និងបុរេប្រវត្តិសាស្ត្រព្រមទាំងការជួញដូរវត្ថុសិល្បៈបុរាណនៅតាមទីផ្សារ គឺជាគ្រោះថ្នាក់ដល់អាយុជីវិតជាតិ និងវប្បធម៌នៃជាតិខ្មែរយើងដ៏ពិតប្រាកដ ។

ប៉ុន្តែជាការសោកស្តាយ ព្រោះគំនិតដ៏ត្រឹមត្រូវនេះ ពួកឈ្មួញនៅទីផ្សារទូលទំពូង និងចោរប៉ែត ពុំបានយកទៅអនុវត្តន៏ទេ ដើម្បីឧត្តមប្រយោជន៍ជាតិ ។ ហើយដោយសារភ័យបាត់នូវស្លាកស្នាមវប្បធម៌ទាំងនោះហើយ បានជាយើងខិតខំចងក្រងឯកសារនេះឡើង ។

## ៣_ការទុកសាកសពនាសម័យលោហធាតុ

តាមការពិនិត្យវិភាគនូវផ្នែរខ្មោចមួយចំនួន ដែលគេបានជីកកកាយនៅភូមិស្វាយដោយវិធីសាស្ត្រ យើងអាចសង្កេតឃើញថា នាដើមសម័យប្រវត្តិសាស្ត្រ ដែលជាសម័យកាលវប្បធម៌មួយ ពុំទាន់មានទទួលឥណ្ឌូបនីយកម្ម ឬក៏នៅពេលដែលទំនៀមទំលាប់ឥណ្ឌា ពុំទាន់បានជ្រួតជ្រាបចូលខ្លាំងនៅឡើយ បុព្វបុរសខ្មែរយើងបានធ្វើពិធីបញ្ចុះសព ដោយយកទៅកប់នៅក្នុងអន្លង់ ដូចកុលសម្ព័ន្ធខ្មែរលើ ( ព្នង, ស្ទៀង, ជ្រាយ, ទំពួន និងគ្រឹងជែរ ។ល ។

ការកប់សាកសពចូលក្នុងផ្នូរ ដែលមានជម្រៅពី១.២០ ទៅ១.៣០ម បុព្វការីជនខ្មែរ ដែលជាញាតសន្តាន បានបញ្ចុះនៅក្នុងអន្លង់សពមានកែវកង

អាវុធ ក្រឡ ឆ្នាំងផ្ទុកដោយម្ហូបអាហារ ឬស្លា ។ល។ ពោលគឺជាទ្រព្យសម្បត្តិរបស់ខ្មោច ដើម្បីទុកជាទ្រព្យទៅបរលោក ។

អ្នកស្រាវជ្រាវខាងបុរាណវិទ្យាបានឱ្យដឹងផងដែរថា ការដែលអ្នកស្រុកជីកគាស់កកាយវត្ថុបុរាណ ឬគ្រឿងអលង្ការ ដែលមាននៅក្នុងរណ្ដៅខ្មោច គឺជាអំពើខុសច្បាប់មួយ លើសពីនេះទៅទៀត គឺជាការបំផ្លាញនូវពតិមានមានតម្លៃសម្រាប់ការចងក្រងប្រវត្តិសាស្ត្រ ។

តាមរយៈនៃការកប់ខ្មោច អ្នកស្រាវជ្រាវ គេអាចមើលឃើញនូវរបៀបបែងចែកឋានៈ ភេទច្បាស់លាស់ណាស់ ។ ដូចជាផ្នូរខ្មោចប្រុស គេមានដាក់ដាវ អាវុធ ប៉ុន្តែបើភេទស្រីវិញ គេឃើញមានផ្ដៅត្រល់សម្រាប់រវៃអំបោះ ។ល។

ម្យ៉ាងវិញទៀត គេរមែងកប់សាកសពដោយដាក់ក្បាលបែរទៅទិសខាងកើត ដែលជាទិសនៃព្រះអាទិត្យរះ ។ នេះជាជំនឿរបស់មនុស្សបុរាណ ជឿថា ព្រះអាទិត្យតំណាងនូវភាពអមតៈ ។ ព្រះអាទិត្យកើតលិច១ មនុស្សលោកស្លាប់ហើយកើត១មិនចេះចប់ ។ មនុស្សបុរាណចូលចិត្តកប់សពក្នុងផ្នូរ មិនមែនមានន័យថា ខ្មែរបុរាណមិនចេះបូជានោះទេ ក៏ប៉ុន្តែ នេះជាការពេញនិយមមួយលើកលែងតែករណីពិសេស ។

## ៤-ឧស្សាហកម្មឆ្អឹងសម័យបុរេប្រវត្តិសាស្ត្រ យុគ្គវប្បធម៌លោហធាតុ

គេចែកប្រវត្តិសាស្ត្រខ្មែរជាពីរសម័យកាលធំៗគឺ សម័យបុរេប្រវត្តិសាស្ត្រ និងសម័យប្រវត្តិសាស្ត្រ ដែលសម្រាប់ប្រទេសកម្ពុជាយើង បានផ្ដើមឡើងចាប់តាំងពីដើមស.វ.ទី១នៃគ.ស. ។ ឬក៏អាចនិយាយបានថា គេចែកសម័យកាលជាបី គឺសម័យវប្បធម៌ថ្មបំបែក, យុគ្គវប្បធម៌ថ្មរំលីង, និងយុគ្គវប្បធម៌លោហធាតុ ។ល។

គួររំលឹកថា នៅប្រទេសអឺរ៉ុប ឧស្សាហកម្មឆ្អឹង ពោលគឺការផលិតឧបករណ៍ប្រើប្រាសធ្វើអំពីឆ្អឹង ខ្យង ភ្លុកដំរី និងស្នែងសត្វ ត្រូវបានបង្កើតឡើងរវាងប្រមាណជា៣០០០០ មក២៥០០០ឆ្នាំមុនគ.ស. ។ រីឯនៅព្រះរាជណាចក្រកម្ពុជា ការធ្វើឧបករណ៍ពីឆ្អឹងសម្រាប់ប្រើប្រាស់ បានត្រូវកត់សម្គាល់យ៉ាងតិចចាប់ពី២៥០០ឆ្នាំមុនគ.ស. និង១០០០ឆ្នាំមុនគ.ស. ។ ក្នុងសម័យកាលនោះ គេឃើញមានមនុស្សកើនឡើងយ៉ាងច្រើន ព្រោះស្ថានីយមានចំនួនច្រើនលើសពីសម័យមុនៗ ហើយគ្រឿងឧបករណ៍ប្រើប្រាស់ក៏កាន់តែមានភាពសុក្រឹត និងភាពសម្បូរបែបឡើងជាលំដាប់ ហើយក្នុងអន្តរកាលនេះ ពូថៅថ្មរំលីងត្រូវបានជំនួសដោយផ្លែដែក ដែលត្រូវប្រជាជនប្រើរហូតមកដល់សព្វថ្ងៃនេះ ។

សូមជម្រាបថា ការដែលគេជួបប្រទះនូវឧបករណ៍ឆ្អឹងក្នុងស្ថានីយបុរេប្រវត្តិសាស្ត្រ ដែលចាស់ជាង៤៥០០ឆ្នាំ ពុំមែនមានន័យថា គ្មានការនិយមឆ្អឹងក្នុងសម័យនោះទេ ក៏ប៉ុន្តែវត្ថុធាតុដើមនេះ អាចមិនរេចរឹលជាមួយនឹងអាកាសធាតុក្នុងតំបន់យើងនេះ ។

ការដែលបុព្វបុរសយើងយកធ្មេញ ចង្កូមសត្វ មកឆ្លាក់ប្រើប្រាស់ជាគ្រឿងតុបតែង បង្ហាញឱ្យឃើញនូវលក្ខណៈពិសិដ្ឋរបស់វា ដោយហេតុថាមនុស្សបុរាណជឿថា វត្ថុទាំងនោះ តំណាងនូវភាពរឹងមាំ ដោយបង្កប់នូវឥទ្ធិពលធម្មជាតិ ដែលជាសេចក្ដីសុខសប្បាយ កាលបើគេពាក់វាជាប់និងខ្លួន ។

សរុបសេចក្ដីមក សំណល់នៃឧស្សាហកម្មឆ្អឹង មិនគ្រាន់តែបញ្ជាក់បង្ហាញថា បុព្វបុរសខ្មែរចេះលំអកាយដោយវត្ថុធម្មជាតិប៉ុណ្ណោះទេ លើសពីនេះទៅទៀត ឆ្លុះបញ្ចាំងឱ្យឃើញនូវទស្សនៈស្ដីពីគំនិតរបស់គេទៀតផង ដែលផ្ដោតទៅលើភាពមាំទាំអង់អាចក្លាហានជាដើម ។

## ៥.ភ្លុកនិងស្នែងសត្វ

គេបានជួបប្រទះនូវវត្ថុជាច្រើនដែលមានរាងជាស្នែងសត្វ ឬក៏ភ្លុកដីរក្នុងស្ថានីយភូមិស្នាយ ។ តើវត្ថុបុរាណដែលគេកប់ជាមួយសាកសពនាសម័យនោះមានន័យដូចម្ដេច ?

ចំពោះមនុស្សបុរាណ សត្វមានស្នែង គឺជាអច្ឆរិយភាពគួរឱ្យស្ញប់ស្ញែងដូច្នេះហើយ បានជាស្នែងតំណាងនូវថាមពលពិសិដ្ឋនៃធម្មជាតិ ។ តាមពិតស្នែងទាក់ទិនទៅនិងជំនឿជីវចល ពីព្រោះការបង្ហាញនូវសោភណភាពរបស់មនុស្ស និងបុព្វការីជន ដែលជាសត្វ ដូចជាប្រើស ទន្សោង គោ ក្របី ។ល។ ការដែលប្រើវត្ថុដែលមានរូបរាងជាស្នែង ឬក៏ការប្រើស្នែងសត្វដើម្បីធ្វើជាគ្រឿងអលង្ការ ឆ្លុះបញ្ចាំងនូវមនោគមនិវិជ្ជារបស់មនុស្ស នៅក្នុងខេត្តបន្ទាយមានជ័យនាសម័យបុរាណ ចំពោះសារជាតិពិសិដ្ឋរបស់ស្នែង ឬភ្លុកសត្វដែរ ។

រូមសេចក្តីមក វត្ថុដែលធ្វើឡើងអំពីស្នែង ឬភ្ជុកមានលក្ខណៈស័ក្តិសិទ្ធិ អាចចៀសវាងបានសកម្មភាពមិនល្អ ឬគ្រឿងឧបទ្រពចង្រៃ ដែលបៀតបៀន មនុស្សលោក ឬនាំមកនូវភាពត្រជាក់ត្រជុំ ភាពសុខសប្បាយ ។ ដោយមូល ហេតុនេះហើយ បានជាគេយកស្នែងកប់ជាមួយមនុស្សស្លាប់ ។

មានមូលហេតុទាក់ទិនទៅជាមួយនិងការចាប់ជាតិឡើងវិញ ដែល បណ្តាលឱ្យគេយកស្នែង ដូចជាស្នែងប្រើសជាដើម កប់ជាមួយមនុស្សស្លាប់ ។ យ៉ាងណាក៏ដោយ ក៏ការឱ្យតម្លៃបែបនោះ មិនខុសពីការពិតប៉ុន្មានឡើយ ព្រោះ ដោយសារតែស្នែងជ្រុះហើយដុះវិញ បានជាស្នែង ឬចៃរបស់សត្វអាចជាវត្ថុ និមិត្តតំណាងនូវភាពអមតៈរបស់ជីវិតបានដែរ ។

## ៦_ជំនឿរបស់ជនជាតិខ្មែរនៅលើស្នែងនិងចង្កូមសត្វ

ក្នុងការស្រាវជ្រាវចំពោះជនជាតិខ្មែរ នាសម័យបុរេប្រវត្តិសាស្ត្រ ក៏ដូច គ្នានិងដើមសម័យប្រវត្តិសាស្ត្រផងដែរ ជនជាតិខ្មែររស់នៅក្នុងបរិស្ថានវប្បធម៌ មួយ ប្រកបដោយភាពអច្ឆរិយៈណាស់ ពោលគឺគ្មានការបែងចែកអ្វីដែលគេចាត់ ទុកថា ជាភាពប្រក្រតី និងអ្វីដែលជាភាពមិនប្រក្រតីនោះឡើយ ។

ទស្សនៈរបស់ជនជាតិខ្មែរនាសម័យបុរាណ គឺអ្វីៗទាំងអស់ដូចជារុក្ខ ជាតិ ព្រៃភ្នំ ធរណី សុទ្ធសឹងតែមានវិញ្ញាណទាំងអស់ ។ នៅរាល់អ្វីៗ ដែល ទាក់ទងនិងជីវិត គឺត្រូវបានគេគោរពបូជា និងខ្លបខ្លាចទៀតផង ។

យោងតាមការស្រាវជ្រាវនាពេលថ្មីៗនេះបានឱ្យដឹងថា បន្ទាប់ពីសិក្សា នៅក្នុងស្ថានីយប្រវត្តិសាស្ត្រមួយចំនួន យើងអាចដឹងថា លក្ខណៈចម្បង ដើម្បី

សម្គាល់ពពួកសត្វដែលស៊ីសាច់ជាអាហារ ឬមិនស៊ីសាច់ត្រូវបញ្ជាក់តាមរយៈចង្កូមជ្រូកព្រៃ, ខ្លា និងឆ្មារ ផ្លែជាដើម ។ នៅក្នុងមជ្ឈដ្ឋានទូទៅនាសម័យបុរេប្រវត្តិសាស្ត្រស្នែង ធ្មេញ ចង្កូមសត្វព្រៃទាំងអស់នោះ គឺជាគ្រឿងសិរីមង្គលដែលនាំមកនូវភាពត្រជាក់ត្រជុំ សេសចក្ដីសុខចម្រើន ។

ស្នែង ធ្មេង ចង្កូមសត្វទាំងនោះ ជនជាតិខ្មែរយល់ឃើញថា វាបានជួយបំបាត់នូវភាពចង្រៃឧបទ្រព ដោយសារឥទ្ធិពលតេជៈរបស់វា ។ ការសន្និដ្ឋាននេះបានបញ្ជាក់បង្ហាញយ៉ាងច្បាស់ តាមរយៈវត្តមានរបស់វត្ថុទាំងនោះដែលជនជាតិខ្មែរសម័យបុរេប្រវត្តិសាស្ត្របានកប់ជាមួយសព ។

ដោយឡែកទៀត គេក៏បានជួបប្រទះនូវស្នែងប្រើសក្ដាន់ ឬវត្ថុធ្វើអំពីស្នែងគោ ក្របីដូចជាចិញ្ចៀន កែវ កងដៃ ដែលបានកប់រាប់ពាន់ឆ្នាំមកហើយនោះ សុទ្ធសឹងតែត្រូវបានបង្ហាញពីអត្ថន័យដូចគ្នា ។

វត្តមានរបស់ស្នែង និងចង្កូម ដែលដុះលើក្បាល ឬក្នុងមាត់សត្វព្រៃ ពុំមែនជារឿងសាមញ្ញសម្រាប់មនុស្សខ្មែរបុរាណនោះទេ ។ ផ្ទុយទៅវិញ ជនជាតិខ្មែរសម័យបុរាណ មានជំនឿយ៉ាងមុតមាំថា របស់ទាំងនោះ (ស្នែង, ចង្កូមលើក្បាល) គឺជាវត្ថុអច្ឆរិយៈយ៉ាងស័ក្ដិសិទ្ធិណាស់ ។ ព្រោះកន្លែងដែលរបស់ទាំងនោះនៅ ជាទីដៅដែលផ្ទុកឥទ្ធិពលយ៉ាងខ្ពស់សម្រាប់សត្វ ។

ដោយសារតែមានជំនឿក្នុងសម័យនោះហើយ ទើបជនជាតិខ្មែរនាសម័យដើម ឬបុព្វការីជន តែងបានប្រើប្រាស់ស្នែង ចង្កូម ចែសត្វ ធ្វើជាគ្រឿងតុបតែងកាយរបស់គេ មិនថាភេទប្រុសឬស្រីឡើយ ។ សូម្បីតែរហូតមកដល់សព្វថ្ងៃនេះទៅហើយ ក៏ជនជាតិខ្មែរលើ ដែលរស់នៅតាមព្រៃភ្នំ និងតំបន់ចុង

កាត់មាត់ញួក ក៏បានបង្ហាញឱ្យយើងដឹងថា ពួកគេនៅតែមានជំនឿគោរពបូជារបស់ទាំងនោះនៅឡើយ ។ គេយល់ថា ស្នែង ចង្កូមសត្វ ជារបស់ត្រជាក់ត្រជុំ និងជួយការពារសភាវៈអាក្រក់ មិនឱ្យបៀតបៀនដល់រាងកាយរបស់គេបានថែមទៀតផង ។

នៅមានជំនឿលើសនេះទៀត ដែលទាក់ទងដល់ការធ្វើសឹកសង្គ្រាម ឬការពារគ្រាប់រំសេវនាសម័យបន្តបន្ទាប់មកទៀត ។ ស្នែងនិងចង្កូមសត្វមួយប្រភេទទៀត ត្រូវបានគេគិតថា អាចជួយមិនឱ្យសត្រូវបាញ់ចេញ ឬផ្ទុះចេញពីអាវុធមកចំរូបរបស់គេឡើយ ។

## ៧-ឧស្សាហកម្មកែវនាសម័យបុរេប្រវត្តិ

កែវជាជាតិរ៉ែមួយប្រភេទ ដែលរឹងស្រួយ ហើយមានលក្ខណៈស្តើងថ្លាឆ្លុះថែមទៀតផង ។ ដើម្បីធ្វើវត្ថុអំពីកែវ គេត្រូវកម្តៅរ៉ែដល់កម្រិតសីតុណ្ហភាព៧៥០ អង្សា ឬលើសពីនេះ ។ អ្នកប្រាជ្ញអឺរ៉ុបបានឱ្យដឹងថា គឺជាជនជាតិផេនស៊ីអាំងទៅដែស បានបង្កើតកែវមុនគេបង្អស់មានប្រមាណ២០០០ឆ្នាំមុនគ.ស. ដោយស្ងួចម្រុះក្នុងក្រឡតូចមួយរវាងខ្សាច់និងជាតិសូយ៉ូម, ប៉ូតាស្យូម និងសំណឱ្យរលាយទៅជាទឹក ។ ជនជាតិក្រិក និងរ៉ូម៉ាំង បានទទួលចំណេះដឹងនេះ ពីពួកផេនស៊ីអាំង (Phenician) ហើយបន្ទាប់មក ក៏បានផ្ទេរទៅឱ្យជនជាតិឥណ្ឌា និងខ្មែរនាដើមគ.ស.បន្តិច ។

ឧស្សាហកម្មកែវនេះ ជនជាតិខ្មែរនាសម័យបុរេប្រវត្តិសាស្ត្រ (ស.វ.ទី២និងទី៣មុនគ.ស.) បានច្នៃវត្ថុធាតុដើមពីធម្មជាតិ ឱ្យក្លាយទៅជាគ្រឿង

អលង្ការ យ៉ាងល្អប្រណិត ថ្វីដ្បិតតែបច្ចេកវិទ្យាបានខ្ចីពីបរទេស ក៏ប៉ុន្តែមិនយូរប៉ុន្មាន ខ្មែរយើងបានផលិតអង្ការ និងគ្រឿងអលង្ការតែម្តង ។

ឧស្សាហកម្មកែវនេះ បានមានប្រភពកើតចេញពីស្នាដៃខ្មែរពិត១ ហើយភស្តុតាងជាប្រវត្តិសាស្ត្រទាំងឡាយដូចជា អូរកែវ អូរទង ។ល។ គឺបណ្តាលមកពីការផលិតជាហូរហែដោយវិចិត្រករ តាំងពីសម័យមុនមកម្ល៉េះ ។ មួយវិញទៀត គេបានរកឃើញនៅទីក្រុងអង្គរបុរី ដែលជាព្រះរាជធានីខ្មែរបុរាណ នូវកំទេចកែវជាច្រើន ដែលជាស្នាដៃរបស់ជាងស្លនៅក្នុងស្រុក ឬនៅឯ នាយ ។

តែមិនទាន់បានដឹងពិតប្រាកដទេថា តើជនជាតិឥណ្ឌា ឬចិនដែលបាននាំឧស្សាហកម្មកែវនេះ ចូលក្នុងព្រះរាជាណាចក្រកម្ពុជានោះទេ ក៏ប៉ុន្តែឧស្សាហកម្មនេះ ត្រូវបានជនជាតិខ្មែរមានភាពប៉ិនប្រសប់ច្នៃប្រឌិតខ្ពស់ ពីវត្ថុធាតុដើមទាំងនោះ ។

មានសំណល់នៃការប្រើប្រាស់កែវ នាសម័យបុរេប្រវត្តិសាស្ត្រ ជាច្រើនដូចជាគ្រឿងតុបតែងខ្លួនប្រាណ ស្រិលត្រចៀក ភ្លួងសក់ជាដើម សម្រាប់ឱ្យអ្នកស្រាវជ្រាវធ្វើការវិភាគអំពីប្រវត្តិសាស្ត្រសំខាន់នេះ ។

ការរីកលូតលាស់របស់ឧស្សាហកម្មកែវ បានរីកលូតលាស់ឡើងនាសម័យនគរភ្នំស.វ.ទី១ដល់ ទី៧នៃគ.ស. ។ ហើយវត្ថុបុរាណដែលគេបានរកឃើញ បានក្លាយទៅជាកេរមតិកវប្បធម៌ជាតិ ហើយទោះជាប្រទេសឧស្សាហកម្មធ្វើកែវនេះ បានមកពីប្រភពដទៃក៏ដោយ ។ ទាំងនេះ បង្ហាញនូវភាពប៉ិនប្រសប់របស់ជនជាតិខ្មែរក្នុងការផលិតគ្រឿងអលង្ការអំពីកែវ ដែលមានពណ៌ចម្រុះលើសលប់ ។

## ៨_មនុស្សសម័យបុរេប្រវត្តិសាស្ត្រ និយមប្រើបន្តោងរូបសត្វខ្លា

នាសម័យបុរេប្រវត្តិសាស្ត្រ មនុស្សភាគច្រើនបានកំណត់ថា ខ្លាគឺជាសត្វព្រៃមានភាពខ្លាំងក្លានិងកាចសាហាវ ដែលត្រូវបានគេប្រៀបប្រដូច និងឥទ្ធិពលដ៏ពិសិដ្ឋ ដ៏គួរឱ្យកោតខ្លាច លាយឡំទៅដោយការគោរពសក្ការៈផងដែរ ។

បន្ទាប់ពីមានការសិក្សាស្រាវជ្រាវនាពេលថ្មីៗនេះបានឱ្យដឹងថា មនុស្សបុរេប្រវត្តិសាស្ត្របានចាត់ទុករូបសត្វខ្លា គឺជានិមិត្តសញ្ញានៃឥទ្ធិពល ឬអំណាចដ៏ពិសិដ្ឋមានមកពីធម្មជាតិ ។ និមិត្តសញ្ញារូបខ្លា អាចប្រឆាំងនិងឥទ្ធិពលអាក្រក់ទាំងឡាយ ដែលមនុស្សសម័យនោះ តែងតែមានជំនឿជារៀងរហូតមក ។

ជំនឿលើនិមិត្តសញ្ញាសត្វខ្លា ក៏អាចជួយឱ្យអ្នកមានចិត្តស្រាល ឬទន់ខ្សោយប្រែក្លាយទៅជាមនុស្សមានចិត្តអង់អាចក្លាហាន ស្វាហាប់ឡើងវិញបានដែរ ។

រហូតមកទល់ពេលនេះ យើងពុំទាន់ជួបឯកសារណា ដែលបញ្ជាក់ថាខ្មែរយើងបានគោរពបូជាសត្វខ្លាពីសម័យណានៅឡើយទេ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏ពេលថ្មីៗនេះ យើងបានដឹងថា នាចុងសម័យវប្បធម៌យុគលោហធាតុមនុស្សបុរាណបានឆ្លាក់សត្វខ្លា ដើម្បីធ្វើជាបន្តោងពាក់កតកូនចៅរៀងមក ។

នៅក្នុងឯកសារស្រាវជ្រាវបានបង្ហាញឱ្យដឹងទៀតថា និមិត្តសញ្ញាសត្វខ្លា ដែលជាវត្ថុបុរាណនេះ វាស្ថិតនៅក្នុងអំឡុងតែរវាង១០០ទៅ៥០០ឆ្នាំមុនគ.ស.តែប៉ុណ្ណោះ ។ ឯកសារទាំងនេះ រួមជាមួយនិងទិន្នន័យមួយចំនួនទៀតដែលយើងអាចយកជាការបានថា មនុស្សសម័យបុរេប្រវត្តិសាស្ត្រ មានការ

និយមប្រើបន្តោងនិមិត្តរូបសត្វខ្លានេះមែន ។

ការស្រាវជ្រាវបានឱ្យដឹងទៀតថា នៅប្រទេសអ៊ីរ៉ាក់ អ៊ីរ៉ង់ គឺជាការបូជាសត្វខ្លា ត្រូវបានគេកត់សម្គាល់តាំងតែពី២៥០០ឆ្នាំមុនគ.ស.រាជមកម្លេះ ។ ប្រវត្តិសាស្ត្រសត្វខ្លាគេបានចាត់ទុកថា ជាសត្វមានអំណាចដ៏ពិសិដ្ឋរបស់ព្រះមហាក្សត្រទៀតផង ។ ហេតុនេះហើយ នៅក្នុងឯកសាររបស់មនុស្សខ្មែរនាសម័យបុរេប្រវត្តិសាស្ត្រ ទាក់ទងទៅនិងនិមិត្តរូបសត្វខ្លា ក៏យើងមិនគួរភ្ញាក់ផ្អើលអ្វីទេ ។

ចំពោះបុព្វការីជនខ្មែរសម័យដើមប្រើបន្តោងរូបសត្វព្រៃបែបនេះ គឺទុកធ្វើជាគ្រឿងលំអសិរីមង្គលផង និងជានិមិត្តរូបដើម្បីការពារខ្លួនឱ្យមានភាពត្រជាក់ត្រជុំសុខដុមរម្យនាថែមទៀតផង ។ និយាយរួមសត្វខ្លា គឺជានិមិត្តសញ្ញាមួយ ដែលមានលក្ខណៈជាសាកលផងដែរ ។

ការពាក់គ្រឿងអលង្ការមានរូបសត្វខ្លា ដែលធ្វើអំពីថ្លើមថ្ម ឬថ្មភក់ មិនគ្រាន់តែសម្រាប់ធ្វើជាគ្រឿងលំអរាងកាយមនុស្ស ឱ្យល្អផូរផង់តែប៉ុណ្ណោះទេ តែវាអាចការពារកម្ចាត់ភាពឧបទ្រពចង្រៃផ្សេងៗ ដូចជាខ្មោចព្រាយបិសាចទៀតផង ។

ម្យ៉ាងវិញទៀត ក្នុងគំនិតរបស់មនុស្សខ្មែរបុរាណគេយល់ថា បើនរណាម្នាក់មានសាក់ជាសញ្ញារូបសត្វខ្លានៅលើខ្លួនប្រាណរបស់គេនោះ គឺមនុស្សនោះ មានឥទ្ធិពលប្រៀបដូចជាសត្វខ្លាមិនខាន ។

## ៩. ការនិយមប្រើត្រសាល់ និងការលោយធាត់បង់នៅវិញ

ស្ថានីយបុរេប្រវត្តិសាស្ត្រជាច្រើន បានបន្សល់ទុកនូវវត្ថុបុរាណ ដែលបុព្វបុរសខ្មែរយើងបានប្រើប្រាស់ជាឧបករណ៍វប្បធម៌ សម្រាប់ជីវិតប្រចាំថ្ងៃរបស់ពួកគេ ដូចជាកងដៃ កងជើង កាំបិត លំពែង ដឹង ដែលធ្វើអំពីសំរិទ្ធ ចាន ឆ្នាំង ក្រឡ ធ្វើពីដីដុតជាដើម ។ ក្នុងចំណោមវត្ថុបុរាណទាំងនោះ គេបានជួបប្រទះនូវត្រសាល់ត្រចៀកជាច្រើន ដែលធ្វើអំពីឆ្អឹង សំបកខ្យង និងដីដុត ។

តាមរយៈស្ថានីយប្រវត្តិសាស្ត្រជាច្រើនដូចជាល្អាងស្ពាន ម្លូព្រៃ សំរោងសែន (កម្ពុជា) អូរកែវ (កម្ពុជាក្រោម) តាខេភូមិប្រាសាទ (នគររាជសៀមបច្ចុប្បន្ន) និងត្រើងនិញ (លាវបច្ចុប្បន្ន) គឺអាចឱ្យយើងដឹងថា ជនជាតិអម្បូរមន-ខ្មែរ មានការនិយមពាក់ត្រសាល់ត្រចៀកតាំងពីសម័យមុនប្រវត្តិសាស្ត្រមកម្លេះ ។ ម្យ៉ាងទៀត គេក៏បានជួបការនិយមពាក់ត្រសាល់នេះ នៅដុងសឿន ដែលជាស្ថានីយបុរេប្រវត្តិសាស្ត្រ សព្វថ្ងៃស្ថិតនៅក្នុងប្រទេសវៀតណាមខាងជើងដែរ ប៉ុន្តែមិនមែនជាសមិទ្ធិផលរបស់បុព្វបុរសយួនទេ ដែលដើមឡើយរស់នៅក្នុងខេត្តក្វាងតុង និងយូណាន់ ឯណោះទេ ។ សមិទ្ធិផលវប្បធម៌ទាំងនោះ គឺជាមតិកវប្បធម៌មន-ខ្មែរ ។

គួរបញ្ជាក់ផងដែរថា ការដែលកុលសម្ព័ន្ធមន-ខ្មែរនាសម័យបុរេប្រវត្តិសាស្ត្រ និយមពាក់ត្រសាល់ សម្រាប់លំអការ ហើយបន្តរហូតមកដល់បច្ចុប្បន្ននេះ មានន័យថា ពួកគេមានការ ឯកភាពក្នុងវិស័យវប្បធម៌ ហើយក៏ជាកត្តាដែលបង្ហាញឱ្យដឹងថា វប្បធម៌របស់ពួកគេបានប្រសូត្រចេញពីពុម្ពតែមួយ ។

សូមបញ្ជាក់ទៀតថា ភាពចំណាស់នៃត្រសាល់ត្រចៀក មិនមានភាពស្មើគ្នាទេ ។ ស្ថានីយបុរេប្រវត្តិសាស្ត្រ ដែលចាស់ជាងគេបំផុតនៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ គឺនៅសំរោងសែន មានអាយុពី១០០០ ទៅ៣០០០ឆ្នាំមុនគ.ស. ។ ចំពោះត្រសាល់ធ្វើអំពីខ្យង និងដីដុតនៃស្ថានីយតាខេនៅខេត្តនគររាជសីមា មានអាយុត្រឹមតែ២៥០០ ទៅ២៣០០ឆ្នាំមុនគ.ស.តែប៉ុណ្ណោះ ។

ថ្វីដ្បិតតែនៅដើមស.វ.ទី១នៃគ.ស. ឥទ្ធិពលនៃវប្បធម៌ អារ្យធម៌ក្លឹង្គមានសន្ទុះមកលើខ្មែរក៏ដោយ ក៏ខ្មែរយើងសម័យនោះ (នគរភ្នំ និងចេនឡា) នៅតែប្រើប្រាស់គ្រឿងតុបតែងដូចបានរៀបរាប់ខាងលើនេះដដែល បន្តិចម្តងៗរហូតមកដល់សព្វថ្ងៃនេះ ។

លោកអាដឺម៉ាឡឺក្លែរ បានសរសេរនៅក្នុងកំណត់ហេតុរបស់លោកថា នៅរជ្ជកាលរបស់ព្រះបាទនរោត្តម ប្រពៃណីនេះ បានត្រូវខ្មែរ ទាំងមន្ត្រី ទាំងអ្នកក្រុងឈប់និយមប្រើប្រាស់ ។ ការឈប់និយមប្រើប្រាស់ត្រសាល់ ត្រូវបានសាបសូន្យក្នុងសម័យអាណាព្យាបាលបារាំងសេស ចាប់តាំងពីឆ្នាំ១៨៦៣មក ។

មានស្ថានីយជាច្រើនទៀត ដែលស្ថិតនៅក្នុងបង្គោលសីមានៃប្រទេសថៃ ដែលមានអាយុប្រហែលនឹងស្ថានីយបុរេប្រវត្តិសាស្ត្រត្រឹងនិញ (លាវ) និងស្ថានីយហាងហ្គុំនៅយួនខាងត្បូង (អតីតកម្ពុជាក្រោម) ។ម្យ៉ាងវិញទៀត គេក៏បានជួបប្រទះនូវត្រសាល់ធ្វើអំពីថ្មកែវ នៅល្ពាងស្ពាន ខេត្តបាត់ដំបងផងដែរ ។ សក្ខីភាពនេះ បានបញ្ជាក់ថា ខ្មែរយើងចេះយកថ្មកែវធ្វើជាគ្រឿងអលង្ការសម្រាប់លំអរ តាំងពីសម័យមុនបុរេប្រវត្តិសាស្ត្រមកម្លេះ ។

មូលហេតុនៃការនិយមប្រពៃណីនេះ គឺមកពីប្រពៃណីនេះ សមស្រប

តាមចំណូលចិត្តខ្មែរជំនាន់នោះ ។

តាមរយៈការសិក្សាស្រាវជ្រាវ ឯកសារដែលបានមកពីប្រភពនានា បានបង្ហាញថា មានការប្រែប្រួលមួយកើតឡើងចំពោះជនជាតិខ្មែរផ្នែកភូមិភាគកណ្ដាល និងវាលទំនាប ដែលមានការទំនាក់ទំនងជាមួយបរទេស ជាពិសេសអាណានិគមបារាំង ដូច្នេះហើយបានជានៅឆ្នាំ១៨៦៣ គេសង្កេតឃើញនូវទំនៀមទម្លាប់នេះ បានត់បង់ត្រសាល់នេះ បណ្ដាលមកពីគេយល់ថា វាហួសសម័យចាស់គម្រិលពេក ។ ធ្វើយ៉ាងនេះ គេក៏មានបំណងផ្ដាច់ខ្លួនចេញពីជនជាតិព្នង ឬខ្មែររស់នៅតាមព្រៃភ្នំដែរ ។ ឧទាហរណ៍ជាក់ស្ដែងមួយ នៅសារមន្ទីខេត្តអាឡាំងសុង ប្រទេសបារាំង គេឃើញមានត្រសាល់ខ្មែរមួយគូរ ដែលមន្ត្រីវាំងខ្មែរមួយរូប បានជូនទៅលោកអាជីមាឡឺត្បែរទុកជាអនុស្សាវរីយ ពីព្រោះគាត់ឈប់ប្រើវា ។

ទោះបីជាមានការបោះបង់ចោល ឈប់ប្រើវានាសម័យអាណានិគមនិយមបារាំង (១៨៦៣-១៩៥៣) ឬដើមស.វ.ទី១នៃគ.ស. ក្រោមឥទ្ធិពលនៃឥណ្ឌូរូបនីយកម្មក៏ដោយ ក៏បងប្អូនខ្មែរលើ នៅតែប្រើត្រសាល់មិនដាច់ ដោយហេតុថា គេពុំបានស្ថិតនៅក្រោមឥទ្ធិពលនៃវប្បធម៌បរទេសឡើយ ។

## ១០-បុរេប្រវត្តិនៃការ

ថ្មីៗនេះ នៅខេត្តបន្ទាយមានជ័យ អ្នកស្រុកបានធ្វើការជីកគាស់កកាយកន្លែងបុរាណស្ថានមួយ ដើម្បីរាវរកវត្ថុបុរាណសិរិទ្ធិក្រឡ ឆ្នាំង រាប់ពាន់ម៉ឺនទៅលក់នៅប្រទេសថៃ ។ ទង្វើនេះ ជាការបំផ្លាញ ទោះបីជាអាជ្ញាធរមានវិធានការហាមឃាត់យ៉ាងណាក៏ពុំមានប្រសិទ្ធិភាពដែរ ។

អ្នកស្រុកក៏បានរកឃើញនូវវត្ថុមានរបស់ការ ដែលគេកប់ជាមួយមនុស្សស្លាប់ សម្រាប់យកទៅប្រើប្រាស់នៅបរលោក ។ ការកប់គ្រឿងអលង្ការដែលជាគ្រឿងលំអរស្លឹកត្រចៀកនេះ សឱ្យឃើញថា បុព្វបុរសខ្មែរមានជំនឿថា ក្រោយពីស្លាប់ មនុស្សនិងចាប់ជាតិឡើងវិញ ដោយហេតុថាព្រលឹងរបស់មនុស្ស មានលក្ខណៈជាអមតៈ ។

ការដែលស្ត្រីរីយចំណាស់សព្វថ្ងៃ ( មាសនិងប្រាក់) ឆ្លុះបញ្ចាំងនូវនិរន្តរភាពនៃការប្រើប្រាស់ការខាងលើនេះ ដែលបានចាប់បដិសន្ធិឡើងតាំងពីសម័យបុរេប្រវត្តិសាស្ត្រ ។

វប្បធម៌ថ្មខ្មោចនេះ ស្ថិតនៅក្នុងយុគសិរិទ្ធិរវាងស.វ.ទី៥ និងទី១នៃគ.ស. ។ ប៉ុន្តែទាល់តែមានការជីកកកាយតាមលក្ខណៈវិទ្យាសាស្ត្រ ទើបកំណត់កាលបរិច្ឆេទពិតប្រាកដ ។ វត្ថុមានរបស់ពួថៅថ្មរំលីងអាចបញ្ជាក់ថា ការកាន់កាប់តំបន់នេះ បានធ្វើឡើងដោយមានរយៈពេលយូរឆ្នាំ ដូច្នេះអាចចាស់ជាង ២៥០០០ឆ្នាំក៏ថាបាន ។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ គួរតែស្នើរឱ្យប្រធានមន្ទីរខេត្តបញ្ឈប់សកម្មភាពជីកកកាយខុសច្បាប់ទាំងនេះ កុំឱ្យមានតទៅទៀត ។ ការធ្វើព្រងើយ

កន្តើយជាឧក្រិដ្ឋកម្មចំពោះវប្បធម៌ជាតិ ។

## ១១_ការត្រចៀកបុរាណរបស់ស្ត្រីខ្មែរ

កន្លងមកនេះ យើងបានបង្ហាញនូវប្រភពបុរេប្រវត្តិនៃទំនៀមទម្លាប់ការប្រើការត្រចៀកជាគ្រឿងអលង្ការ ដែលជាវត្ថុវប្បធម៌ ដែលបានរកឃើញ ។ ថ្វីត្បិតតែបុរាណវត្ថុទាំងនោះ ពុំមែនជាចម្លាក់លោតធំៗតំណាងព្រះអាទិទេព ឬព្រះពុទ្ធអង្គក៏ដោយ ក៏ប៉ុន្តែការសិក្សារបស់គ្រឿងតុបតែងបុរាណទាំងនោះ អាចផ្តល់ឱ្យអ្នកស្រាវជ្រាវខ្មែរយើងនូវពត៌មានសំខាន់ៗ ស្តីអំពីទ្រង់ទ្រាយនៃអារ្យធម៌ជាតិយើង ។

ការបុរាណខ្មែរមានច្រើនបែបណាស់ ប៉ុន្តែពេលនេះ យើងលើកយកតែការដែលធ្វើអំពីកែវស្ល និងសំរិទ្ធិមកសិក្សាតែប៉ុណ្ណោះ ។ យើងបានប្រទះឃើញការធ្វើជាក្រវិលត្រចៀក និងអង្កាំធ្វើអំពីកែវស្ល តាំងពីសម័យបុរេប្រវត្តិសាស្ត្រមកម្លេះ ដែលជាគ្រឿងតុបតែងកាយ ប៉ុន្តែពុំដែលជួបប្រទះនូវការត្រចៀកស្ត្រីសោះ ។ ថ្មីៗនេះ ការរកឃើញនូវការត្រចៀកមួយចំនួន ដែលបានមកពីការជីកគាស់កកាយដោយខុសច្បាប់នៅកន្លែងកប់ខ្មោច ក្នុងខេត្តបន្ទាយមានជ័យ បានបង្ហាញថា បុព្វបុរសខ្មែរ ក៏បានប្រើការដែរក្នុងអម្បុងស.វ.ទី៣មុនគ.ស. និងនៅដើមស.វ.ទី១នៃគ.ស. ជាពិសេសនៅសម័យនគរភ្នំ ។ ការធ្វើអំពីកែវស្លមានពណ៌ច្រើនប្លែកៗពីគ្នា ពណ៌ស ខៀវ បៃតង ប្រផេះ ហើយជួនកាលប្រកបដោយក្បាច់រចនាជាច្រើនថែមទៀតផង ។ សូមជម្រាបថែមទៀតផងដែរថា ក្រៅពីការស្ល ក៏ឃើញការសំរិទ្ធិនិងមាសផងដែរ ក៏ប៉ុន្តែមានចំនួនតិចជាង

ហើយវត្ថុមានរបស់លោហធាតុទាំងពីរខាងលើនេះ ក៏បញ្ជាក់ឱ្យបានស្គាល់នូវបរិយាកាសសង្គម និងវប្បធម៌ជឿនលឿនមុនការមកដល់បន្តិចនៃខឿនអារ្យធម៌ឥណ្ឌានាដើមស.វ.ទី១នៃគ.ស. ។

ការស្រាវជ្រាវរបស់យើងបានឱ្យដឹងទៀតថា ជនជាតិខ្មែរនាសម័យនគរភ្នំ ជាពិសេសនៅទីក្រុងអង្គរបុរី និងនៅអូរកែវ (អូរដែលមានកែវកង) នៅកម្ពុជាក្រោមធ្លាប់ប្រើការត្រចៀកធ្វើអំពីកែវស្លនេះដែរ ហើយភាពសម្បូរបែបនៃប្រភេទកែវ ដែលមានលក្ខណៈប្លែក១ពីគ្នា ក៏ជាសក្ខីកម្មមួយបង្ហាញនូវតម្លៃរបស់ស្ត្រីខ្មែរនាសម័យបុរាណដែរ ដែលប្រកបដោយភាពថ្លៃថ្នូរខ្ពង់ខ្ពស់ ។

នៅសម័យអង្គរ នៅក្នុងបរិវេណទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គេក៏ជួបប្រទះនូវការដែរ នៅតាមរូបចម្លាក់បុរាណ ។ ក្រៅពីចម្លាក់គេក៏បានជួបប្រទះនូវការសិរិទ្ធិ ដែលជាគ្រឿងលំអរត្រចៀកនៃស្ត្រីភេទ ឬទេវតា ។ ការសិក្សាអំពីការត្រចៀកខាងលើនេះ សឱ្យឃើញទៀតថា បុព្វបុរសខ្មែរយើងតាំងពីសម័យបុរេប្រវត្តិសាស្ត្ររហូតមកដល់បច្ចុប្បន្ននេះ ចេះផលិតគ្រឿងអលង្ការគ្រប់ប្រភេទសម្រាប់លំអររាងកាយរបស់ខ្លួន ។

ការប្រើកែវដើម្បីធ្វើគ្រឿងអលង្ការ ក៏អាចបញ្ជាក់ឱ្យយើងដឹងដែរថា សិប្បកម្មខ្មែរមានការលូតលាស់ និងមានការវិវត្តន៍ហូរហែរ ពីសម័យមួយទៅសម័យមួយទៀតមិនដាច់ ។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ គួរតែស្នើរទៅប្រធានមន្ទីរនានាតាមខេត្តក្រុង និងអាជ្ញាធរខេត្តគ្រប់លំដាប់ថ្នាក់ ហាមឃាត់នូវរាល់ការជីកកកាយ និងការលក់ដូរនូវរាល់វត្ថុបុរាណគ្រប់ជំនាន់ គ្រប់ទម្រង់ គ្រប់ខ្នាត និងគ្រប់

ប្រភេទ ដែលមានចំណាស់ជាង៨០ឆ្នាំជាដាច់ខាត បើមិនដូច្នោះទេ ជនជាតិខ្មែរពិតជាបាត់បង់ឫសកែវជាតិជាពុំខាន ។ ការជួញដូរវត្ថុបុរាណ ពិតជាគ្រោះថ្នាក់ចំពោះជាតិ ព្រោះមួយភាគធំនៃវត្ថុសិល្បទាំងនោះ បានជីកចេញពីភូមិបុរាណ និងបុរាណស្ថាន ដែលមានប្រាង្គប្រាសាទ និងព្រះចេតិយ ។ល។ ទន្ទឹមនិងនេះ ការដឹកចេញទៅប្រទេសទី២ ដើម្បីតម្កល់ក្នុងសារមន្ទីរឯកជន ឬរបស់រដ្ឋក៏ត្រូវហាមឃាត់ដែរ ដូចជាមាត្រាក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងយ៉ាងច្បាស់ ។

## ១២-ខ្មែរនិយមសាក់លើខ្លួនប្រាណ មានមកតាំងពី២៥០០មុនគ្រិស្តករាជ

នៅចុងសម័យថ្មរំលីង និងដើមសម័យលោហធាតុ (២៥០០-៥០០ឆ្នាំមុនគ.ស.) គឺជាសម័យមួយ ដែលបុព្វការីជនខ្មែររស់នៅជាកុលសម្ព័ន្ធកសិករ ដោយបានចេះស្លលោហធាតុសម្រាប់ធ្វើឧបករណ៍ប្រើប្រាស់ក្នុងសង្គម និងបានទទួលនូវការលូតលាស់ខាងវប្បធម៌គ្រប់វិស័យទៅហើយ ។ នៅសម័យនោះ តាមឯកសារក៏បានបញ្ជាក់ឱ្យដឹងដែរថា ខ្មែរបុរាណមានការនិយមប្រពៃណីសាក់លើខ្លួនប្រាណជាលើកដំបូងរួចទៅហើយ ។

មុនសម័យប្រវត្តិសាស្ត្របន្តិច គឺរវាងស.វ.ទី៣-២មុនគ.ស. អ្នកប្រវត្តិវិទូចិនបានបញ្ជាក់ផងដែរថា ជនជាតិខ្មែរនៅម្តុំភូមិភាគខាងត្បូងនៃប្រទេសចិនមានទម្លាប់ "ស៊ីមួស្លា ប្រើធ្មូ លែងខ្លួនប្រាណ ដែលដងខ្លួនរបស់គេមានសាក់ថែមទៀតផង ។

ការគត់សម្គាល់ខាងលើនេះ គឺសំដៅទៅលើកុលសម្ព័ន្ធនានា ដែលក្នុងនោះ មានកុលសម្ពន្ធមន-ខ្មែរជាច្រើន ហើយពួកគេក៏មានវត្តមានរហូតមកដល់ដើមស.វ.ទី២០នៅដែរ ។ ការលើកឡើងខាងលើនេះ ផ្អែកតាមឯកសារជាលាយល័ក្ខអក្សរ ស្តីពីការសាក់ខ្លួន ។

ថ្មីៗនេះ គេបានរកឃើញនៅក្នុងបរិវេណនៃរូងភ្នំល្អាងស្ពាន និងនៅស្រុកព្រះនេត្រព្រះ នូវរូបចម្លាក់មនុស្ស និងសត្វគោមួយចំនួន ដែលពាក់ព័ន្ធទៅនិងប្រពៃណីសាក់ខ្លួនដ៏គួរឱ្យចាប់អារម្មណ៍បំផុត ។

ស្នាមជារង្វង់នៅជុំវិញយោនីស្រី ឬក៏ស្នាមលើដងខ្លួនសត្វគោនេះ ពុំមែនឥតមានហេតុផលនោះឡើយ ។ ពិតណាស់ថា សញ្ញាណនីមួយៗ វាមានអត្ថន័យ ឬមូលហេតុរបស់វាច្បាស់លាស់ និងជាក់លាក់ណាស់ ។ លើសពីនេះទៅទៀត គឺជាភស្តុតាងមួយ បង្ហាញនូវចំណាស់នៃការនិយមសាក់ តាំងតែពីសម័យបុរាណកាលដ៏យូរលង់ណាស់មកហើយ ។

តាមពិតការសាក់នេះ ពុំមែនគ្រាន់តែជាការសាក់ជាសញ្ញាសម្រាប់ទាក់ទាញការយកចិត្តទុកដាក់ពីព្រះអាទិទេព ដែលគេមានជំនឿថា ជាឥទ្ធិពលធម្មជាតិ ឬព្រលឹងបុព្វការីជន ឬក៏មនុស្សក្នុងសង្គម ។ ក្រៅពីនេះ សាក់ក៏ជាកត្តាមួយបង្ហាញនូវអំណាច (មហិទ្ធិរិទ្ធិ) ឋានៈ ដោយភាពអង់អាចក្លាហានផងដែរ ។ ការសាក់នេះ ក៏គេធ្វើឡើងសម្រាប់ការពារថាមពលពិសិដ្ឋ ដែលបុព្វបុរសបានផ្តល់ជូន ។

ការសាក់លើខ្លួនប្រាណកុលសម្ព័ន្ធខ្មែរលើ រស់នៅតាមព្រៃភ្នំមួយចំនួននៅតែពេញនិយមពីប្រពៃណីសាក់នេះ ដែលជាការបង្ហាញនូវភាពចាស់ជរាតាម

ក្រុមរបស់គេ ។ ការសាក់នេះ គឺជាការកត់សម្គាល់ផងដែរថា ការសាក់ដើម្បីសម្គាល់ក្រុមរបស់គេ បើពុំដូច្នោះទេ គេជាក្រុមគ្មានអត្តសញ្ញាណ អនាមិក គ្មានប្រវត្តិនឹងគ្មានវប្បធម៌ ។ ទោះជាយ៉ាងណាក្តី ក៏រហូតមកដល់សព្វថ្ងៃនេះ ប្រពៃណីសាក់ក៏ជនជាតិខ្មែរនៅតែបន្តការនិយមមកដដែលនៅឡើយទេ ។

## ១៣_កសិកម្មដើមសម័យប្រវត្តិសាស្ត្រ

សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ផ្អែកទៅលើវិស័យកសិកម្ម ហើយស្ថានភាពនេះ សមស្របទៅនឹងបរិស្ថាននៃភូមិភាគអាស៊ីអាគ្នេយ៍ ក្រោមឥទ្ធិពលខ្យល់រដូវទៀងទាត់ ។

ការប្រកបរបរកសិកម្ម បានចាប់ផ្តើមឡើងនាសម័យនពសិលា (ថ្មរំលីង) បានដុះដាលរីកចម្រើនរហ័សបំផុត នៅពេលដែលបុព្វបុរសខ្មែរបានប្រើឧស្សាហកម្មលោហធាតុសំរិទ្ធ និងដែកសម្រាប់ធ្វើជាឧបករណ៍ ដូចជានង្គ័លកណ្ដៀវ ផ្លែជីងសម្រាប់ឆ្ការព្រៃ ។៧។ ក្នុងករណីនេះហើយ ដែលអត្រាប្រជាជនមានការដុះដាលលើសពីសម័យមុនៗ ហើយវាជាមូលហេតុនៃការផ្ទុះឡើងដោយការផ្តុំគ្នានៃសហគមន៍កសិកម្មនានា មុនៗសម័យប្រវត្តិសាស្ត្រក្នុងភូមិភាគអាស៊ីអាគ្នេយ៍យើងនេះ ជាពិសេស នៅកន្លែងណាដែលធម្មជាតិអំណោយផលច្រើនជាងគេ ដូចជាវាលទំនាបនៃទន្លេមេគង្គ ទន្លេចៅប្រាយ៉ា ទន្លេមូលបាសាក់ដុលជាដើម ។

គួររំលឹកផងដែរថា ក្រោមឥទ្ធិពលវប្បធម៌ក្លឹង ការខ្ចីរចនាសម្ព័ន្ធនយោបាយ និងសាសនាឥណ្ឌា សហគមន៍កសិកម្មទាំងនោះ បានប្រមូលផ្តុំគ្នាឡើង

ដោយក្លាយទៅជាចក្រភពភ្នំ ឬនគរភ្នំ ដែលចិនហៅថា ហ្វូណន ។

ការរកឃើញភស្តុតាងកសិកម្មនៅក្នុងតំបន់នានា ដែលមានការកាន់កាប់ដោយជនជាតិខ្មែរ តាំងពីដើមសម័យប្រវត្តិសាស្ត្រ បញ្ជាក់នូវចំណាស់របស់វប្បធម៌ដាំស្រូវនៃជាតិខ្មែរយើង ។

ជាឧទាហរណ៍ យើងបានបង្ហាញនូវវត្ថុវប្បធម៌ ដែលគេបានរកឃើញនៅស្ថានីយប្រវត្តិសាស្ត្រមួយចំនួន ដូចជាស្ថានីយដូនណៃ និងអូរកែវកម្ពុជាក្រោម សំរោងសែន និងក្នុងស្ថានីយបុរេប្រវត្តិសាស្ត្រនៅភូមិស្នាយ ឬនៅបានឈៀង ដែលសព្វថ្ងៃស្ថិតនៅក្នុងទឹកដីនៃប្រទេសថៃ ។

ដោយសារអត្ថិភាពនៃកសិកម្មខ្មែរយើង បានបង្កើតឡើងពីពិធីមួយចំនួន ទាក់ទងទៅនិងដើមស្រូវ ដូចជាបុណ្យហៅព្រលឹងស្រូវជាដើម ដែលឆ្លុះបញ្ចាំង នូវលក្ខណៈពិសិដ្ឋរបស់ស្រូវក្នុងការទ្រទ្រង់ជីវិតរបស់ខ្មែរ ។

ដូចនេះ ជនជាតិខ្មែរបច្ចុប្បន្ន ដែលភាគច្រើន គឺជាអ្នកស្រែចំការ គឺបានទទួលនូវបច្ចេកទេស និងពូជស្រូវពីបុព្វការីជនរបស់ខ្លួនយ៉ាងប្រាកដ ដែលបានផ្ដើមឡើងជាច្រើនពាន់ឆ្នាំមុនសម័យប្រវត្តិសាស្ត្រ ។

## ១៤-ឧស្សាហកម្មសម្លៀកបំពាក់នៅសម័យបុរេប្រវត្តិសាស្ត្រ

នាសម័យបុរេប្រវត្តិសាស្ត្រ ដោយសំអាងទៅលើវិស័យបុរាណវិទ្យា យើងអាចបញ្ជាក់ថា បុព្វការីជនខ្មែរយើងចេះយកកប្បាសមកហូតជាអំបោះ ដើម្បីយកមកត្បាញឱ្យកើតជាសាច់ក្រណាត់សំពត់ ឬភួយសម្រាប់ប្រើប្រាស់ ។ ម្យ៉ាងវិញទៀត គេក៏អាចយកសំបកឈើ ដើម្បីធ្វើជាសម្លៀកបំពាក់ផងដែរ ។

ដូចសម័យបច្ចុប្បន្ននេះ ខ្មែរយើងនាសម័យនោះ ពិតជាមិនប្រើកីដូចខ្មែរសព្វថ្ងៃនេះទេ ដែលជាវិធីត្បាញសំពត់យ៉ាងជឿនលឿន ក៏ប៉ុន្តែគេយកចុងអំបោះ ដែលគេទើបតែអន្ទងរួចយកទៅចងជាប់នឹងកន្លែងណាមួយ ហើយយកចុងអំបោះម្ខាងទៀតទៅចងជាប់ពាក់នឹងចង្កេះវិញ ។ ហើយនៅពេលត្បាញចង្កេះរបស់គេប្រឹងទាញអំបោះដែលគេអន្ទងរួចនោះឱ្យតឹង ដោយដៃម្ខាងបោះត្រល់ចុះឡើងយ៉ាងសមសួន ។ រីឯដៃម្ខាងទៀត គេកាន់ថ្នេញឈើគោះបង្ហាប់សាច់សំពត់ ដែលគេកំពុងត្បាញយ៉ាងស្វាហាប់ ។

ជាទូទៅ គេសង្កេតឃើញបុរសនិយមប៉ឹង មិនពាក់អាវ ។ រីឯស្ត្រីវិញខ្លះពាក់អាវ ខ្លះលែងខ្លួនទទេ ក៏ប៉ុន្តែភាគច្រើនលែងខ្លួនទទេ ដែលជាប្រពៃណី ។ គួរជម្រាបផងដែរថា ការសន្និដ្ឋាននេះ ផ្អែកលើគំនូរផាត់ពណ៌មួយចំនួន ព្រមទាំងចម្លាក់ធ្វើអំពីសំរិទ្ធិ និងដីដុត ដែលគេបានជួបប្រទះក្នុងស្ថានីយមួយចំនួនក្នុងភូមិភាគឥណ្ឌូចិនយើងនេះ ដូចជានៅស្ថានីយភូមិស្នាយ ដុនសឿង បានឈៀងជាដើម ។

ដោយឡែក សូមបញ្ជាក់ថា រហូតដល់សម័យអង្គរ និងក្រោយអង្គរ គេក៏ឃើញការស្លៀកពាក់របស់ជនជាតិខ្មែរ និងមន-ខ្មែរ មិនបានប្រែប្រួលប៉ុន្មានដែរ ពិសេស នៅក្នុងពេលធម្មតា មិនមែនជាពេលបុណ្យទាន ។

រួមសេចក្តីមក បុព្វការីជនខ្មែរចេះស្លៀកពាក់ទៅហើយ ដើម្បីបិទបាំងកេរ្តិ៍ខ្មាសរបស់ខ្លួន ពុំមែនជនជាតិបរទេស ដែលបង្រៀនខ្មែរឱ្យចេះស្លៀកពាក់នោះឡើយ ។ ការដែលលែងខ្លួនទទេ មិនមែនមានន័យថា មិនស៊ីវិល័យនោះទេក្នុងបរិបទវប្បធម៌មន-ខ្មែរ ក៏ប៉ុន្តែជាសញ្ញាបញ្ជាក់ថា គេសម្រួលកាយវិការ ឬ

ឥរិយាបថតាមធម្មជាតិសុទ្ធសាធតែប៉ុណ្ណោះ ។ យ៉ាងណាមិញ ការដើរដោយជើងទទេ ក៏មិនមែនជាសញ្ញាអន់ថយដែរ ។

នៅចុងស.វ.ទី១៩នៃគ.ស. អ្នកស្រាវជ្រាវបារាំងបានធ្វើការកត់ត្រាថា សំពត់សារុងរបស់ស្ត្រីខ្មែរលើ ដែលរស់នៅភូមិភាគឥសានខ្មែរបច្ចុប្បន្ននេះ មានលក្ខណៈមិនខុសពីសំពត់សារុងរបស់ស្ត្រីខ្មែរនៅវាលទំនាបទេ ។

អ្វីដែលខុស គឺក្រណាត់សំពត់ទៅវិញ ដែលមានសភាពគ្រើម ឬហ្មត់តែប៉ុណ្ណោះ ពោលគឺមានសរសៃទន់ ឬរឹង គួរបញ្ជាក់ផងដែរថា កំណត់ហេតុដ៏ត្រឹមត្រូវខាងលើនេះ គួបផ្សំនឹងការពិនិត្យល្អិតល្អន់របស់យើង លើសម្លៀកបំពាក់របស់បងប្អូនខ្មែរលើបច្ចុប្បន្ន អាចជាសញ្ញាណបង្ហាញនូវប្រភពពួងនៃសំពត់ស្ត្រីខ្មែរបច្ចុប្បន្ន មុនឥទ្ធិពលពីក្រៅ ។ បើនិយាយម្យ៉ាងទៀត សម្លៀកបំពាក់ទាំងនោះ គឺជាលក្ខណៈសម្គាល់រួមនៃវប្បធម៌ខ្មែរ-មនយ៉ាងប្រាកដ ។

ក្នុងការស្រាវជ្រាវរបស់យើង បានរកឃើញវត្ថុមានរបស់ផ្លែត្រល់ នៅតាមស្ថានីយមួយចំនួន ដែលអ្នកស្រុកគិតថាជា "កូនឃ្លី" សម្រាប់លេង ឬក៏ "លេវអាវ" ទៅវិញ ប្រការនេះ មិនអាចយកជាការបានទេ ។ តាមពិតអំពីផ្លែត្រល់ធ្វើឡើងសម្រាប់រវៃអំបោះ ធ្វើអំពីសំបកឈើ កប្បាសនោះជាឧបករណ៍សម្រាប់ត្បាញទេ ។ ការវិភាគស្រាវជ្រាវរបស់យើងបានឱ្យដឹងថា វត្ថុទាំងនោះត្រូវបានកុលសម្ព័ន្ធខ្មែរចាត់ទុកថា ជាទ្រព្យសម្បត្តិដ៏ប្រសើររបស់ស្ត្រីភេទទៅវិញ ដែលគេយកទៅកប់ជាមួយសព ផ្ទុ ។ ដូច្នេះ ផ្លែត្រល់ទាំងនោះ ធ្វើអំពីដីដុត ឬឆ្អឹងសត្វ មិនមែនធ្វើឡើងសម្រាប់ជាល្បែង ឬតាមគំនិតរវើរវាយផ្ដេសផ្ដាសនោះទេ ក៏ប៉ុន្តែ ជាភស្តុតាងវប្បធម៌មួយ បង្ហាញនូវការរីកចម្រើនខាង

ឧស្សាហកម្មតម្បាញតាមស្រុកភូមិ ។

អ្វីដែលទើបពោល បើយើងប្រៀបធៀបមើល និងវិធីការប្រើប្រាស់ឧបករណ៍ត្បាញ ដែលកុលសម្ព័ន្ធខ្មែរលើ ឬអ្នកស្រែចំការកំពុងនិយម អាចធ្វើឱ្យយើងយល់ដល់អត្ថន័យ គោលគំនិតរបស់បុព្វការីជនខ្មែរ នាសម័យបុរាណចំពោះតម្លៃនៃផ្លែត្រល់ទាំងនោះ ។ លើសពីនេះទៅទៀតនោះ យើងក៏អាចវិនិច្ឆ័យបានទៀតថា ប្រការដែលដូនតាខ្មែរយើង យកផ្លែត្រល់ទាំងនោះកប់ជាមួយម្ចាស់សព គឺបណ្ដាលមកពីមូលហេតុជំនឿសាសនាដែរ ។ តាមការវិភាគរបស់យើងៗអាចឃើញថា ខ្មែរនាសម័យនោះជឿថា វិញ្ញាណជាធម្មជាតិមិនចេះរលត់សាបសូន្យ ពោលគឺមនុស្សលោកយើងនេះស្លាប់ហើយ តែវិញ្ញាណមិនស្លាប់ទេ ព្រោះនឹងត្រូវកើតជាថ្មីទៀត ។ យើងយល់ឃើញដូច្នេះ ទើបគេកប់ជាមួយសពនូវគ្រឿងឧបករណ៍សម្រាប់ជីវិតនៅឯបរលោក នេះជាការយល់ឃើញរបស់មនុស្សទាំងឡាយក្នុងសម័យវប្បធម៌បុរេប្រវត្តិសាស្ត្រ ។

## ១៥-សម្លៀកបំពាក់ខ្មែរនាសម័យបុរេប្រវត្តិសាស្ត្រ

ឆ្លងកាត់រយៈកាលជិតមួយស.វ.មកហើយ មតិមហាជនបារាំង និងខ្មែរមួយចំនួនធំនៅតែជឿថា គឺជនជាតិឥណ្ឌាទេ ដែលបានបង្ហាត់បង្រៀនខ្មែរឱ្យចេះស្លៀកពាក់នៅដើមស.វ.ទី១នៃគ.ស. ។ ទស្សនៈនេះ សំអាងទៅលើកំណត់ហេតុចិនស្ដីពីឥណ្ឌូបនីយកម្មនៃប្រទេសកម្ពុជាបុរាណ ដែលចិនបានឱ្យឈ្មោះថា ហ្វូណន ឬ(នគរភ្នំ) ។ កំណត់ហេតុបានសរសេរថា ព្រះបាទហ៊ុនទៀនបានយកសំពត់មកស្លៀកឱ្យប្រពន្ធ គឺព្រះនាងលីវយី បុត្រីរបស់ម្ចាស់ស្រុក ។

គំហើញបែបនេះ ត្រូវបានអ្នកប្រវត្តិវិទូចាត់ទុកថា ជាការភ័ន្តច្រឡំមួយ ពីព្រោះវាត្រូវតែមួយជ្រុងប៉ុណ្ណោះ ។ មុនការមកដល់នៃពួកក្លឹង្គ ជនជាតិខ្មែរនិយមប៉ឹង និងប្រើប្រាស់សំពត់វែង ដើម្បីបិទបាំងកេរ្តិ៍ខ្មាស់ និងលំអររូបរាងកាយ ការពារអាកាសធាតុ ដូចជាបងប្អូនខ្មែរលើយើងសព្វថ្ងៃនេះ តាំងពីសម័យបុរេប្រវត្តិសាស្ត្រ ។

ម្យ៉ាងវិញទៀត គួរគួសបញ្ជាក់ផងដែរថា នៅដើមស.វ.ទី១នៃគ.ស. ទើបមានការនិយមក្បិនតាមរបៀបពួកព្រាហ្មណ៍ឥណ្ឌា ដែលជាប្រពៃណីមួយនៅរស់រវើករហូតមកដល់សព្វថ្ងៃនេះ នៅប្រទេសឥណ្ឌាខាងត្បូង និងនៅប្រទេសកម្ពុជា ។ ដូច្នេះ ការដែលថា ខ្មែរយើងមិនចេះស្លៀកពាក់មុនឥណ្ឌារូបនីយកម្ម វាគឺជារឿងមិនពិតទាល់តែសោះ ។

នៅពេលដែលសួរថា តើមានភស្តុតាងអ្វីដើម្បីបញ្ជាក់បញ្ហានេះឬទេ? ខ្ញុំសូមធ្វើការលាតត្រដាងនូវការពិត ដែលជាលទ្ធផលនៃការវិភាគនូវវត្ថុបុរាណដែលគេបានរកឃើញនៅក្នុងស្ថានីយបុរេប្រវត្តិសាស្ត្រមួយចំនួន ដែលស្ថិតនៅក្នុងប្រទេសកម្ពុជា ថៃ និងយួនបច្ចុប្បន្ននេះ ដែលដើមឡើយជាទីតាំងនៃបុព្វបុរសខ្មែរ ។ ឆ្លងតាមការវិភាគទាំងនោះបានឱ្យដឹងថា ខ្មែរយើងចេះស្លៀងពាក់តាំងពីសម័យវប្បធម៌លោហធាតុមកម្លេះ ។

ការពិតទៅ ការប្រើប្រាស់នូវគ្រឿងស្លៀកពាក់ត្រូវគេពិនិត្យឃើញតាមរយៈវត្ថុតាងនាសម័យមុនប្រវត្តិសាស្ត្រមួយចំនួន ដូចជារូបចម្លាក់ សំណង់សរសៃរអំបោះ ផ្លែត្រល់សម្រាប់រវៃអំបោះត្បាញ គំនូរលើគុហារ ។ល។ ហើយសម្លៀកបំពាក់គឺសំពត់ ឬសារុងសម្រាប់ស្រីភេទ និងប៉ឹងសម្រាប់ប្រុសភេទ ។

ប្រពៃណីស្លៀកពាក់របស់ជនសាមញ្ញនៅតាមជនបទ មិនបានប្រែប្រួលទេ ទោះជាឆ្លងកាត់ដំណាក់កាលឥណ្ឌូរូបនីយកម្មរហូតដល់ស.វ.ទី១៦-១៧នៃគ.ស. ។ ចម្លាក់នៃប្រាសាទបុរាណខ្មែរ ដូចជាប្រាសាទបាយ័ន បន្ទាយឆ្មា និងអង្គរវត្ត អាចជាកញ្ចក់ឆ្លុះបញ្ចាំងឱ្យឃើញពីសម្លៀកបំពាក់ខ្មែរបុរាណរវាងស.វ. ទី១២-១៣នៃគ.ស. ។

គួរបញ្ជាក់ផងដែរថា កំណត់ហេតុចិនមានភាពលំអៀងទៅខាងវប្បធម៌ហាន ពីព្រោះអ្វីដែលមិនមែនចិនសុទ្ធតែជារបស់ព្រៃទាំងអស់ ។ ជាទម្លាប់ខ្មែរយើងទាំងពីរភេទ តាំងពីដើមស.វ.ទី១រហូតដល់បច្ចុប្បន្ន នៅតែនិយមសំពត់ចងក្បិនតាមរបៀបពួកព្រាហ្មណ៍ ជាពិសេស ពួកឥណ្ឌាខាងត្បូង តាមមើលប្រហែលជាកំណត់ហេតុចិនចង់និយាយអំពីក្បិន ដែលឥណ្ឌាបង្ហាត់បង្រៀនឱ្យខ្មែរស្លៀកតាមទេដឹង ។

នេះជាលើកទីមួយហើយ ដែលអ្នកស្រាវជ្រាវខ្មែរយើង បានប្រមូលឯកសារស្តីពីការស្លៀកពាក់របស់ខ្មែរមុនសម័យប្រវត្តិសាស្ត្រ និងដើមសម័យប្រវត្តិសាស្ត្រមកវិភាគសិក្សា ។

## ១៦_ការប្រើប៊ីុងនាសម័យមុនប្រវត្តិសាស្ត្រ

ការស្លៀកប៊ីុងរបស់ជនជាតិខ្មែរលើ បានបង្ហាញឱ្យដឹងតាមរយៈឯកសារជាច្រើនថា មានអាយុកាលរាប់ពាន់ឆ្នាំមកហើយ ដែលជាការឆ្លុះបញ្ចាំងឱ្យដឹងថា ជនជាតិខ្មែរមានភាពចំណាស់នៃប្រពៃណីស្លៀកប៊ីុង មិនចាញ់ជនជាតិដទៃឡើយ ។

តាមរយៈភស្តុតាងរូបភាព និងឯកសារជាច្រើននាពេលថ្មីៗនេះទៀត បានបញ្ជាក់ឱ្យដឹងថា ប្រពៃណីស្ទៀកប៉ឹងរបស់ជនជាតិខ្មែរ ត្រូវបានសំអាងលើគំនូរពណ៌នាកាលពីសម័យលោហធាតុ ដែលគេបានរកឃើញនៅក្នុងខេត្តនៃប្រទេសថៃសព្វថ្ងៃនេះ រួមទាំងចម្លាក់នៅក្នុងប្រទេសខ្មែរយើងផងដែរ ។

ភស្តុតាងទាំងអស់នេះ ត្រូវបានចាត់ទុកថា វាជាសមិទ្ធិផលសង្គមនៃមនុស្សខ្មែរបុរាណ ។

ការស្ទៀកប៉ឹងរបស់ជនជាតិខ្មែរយើង មានអាយុកាលតមកប្រមាណជា២៥០០ឆ្នាំមកហើយ ។ ឯកសារនិងភស្តុតាងចំពោះការស្ទៀកប៉ឹងនេះ គេក៏បានយកចម្លាក់សិរិទ្ធិតូចៗចំនួន៣ ដែលលោកដាំឈឿនទើបបានឃើញនៅភូមិព្រីងទុំ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ មកធ្វើការសិក្សាជាបន្ថែមទៀត ។

ដោយឡែកនៅតាមឯកសាររូបភាពសម័យអាណានិគមបារាំង បានឱ្យដឹងថា សូម្បីប្រជាជនក្រីក្រអំឡុងស.វ.ទី១៩ និងដើមស.វ.ទី២០ ក៏ពួកគេនៅបន្តការស្ទៀកប៉ឹងដូចជាសម័យរាប់ពាន់ឆ្នាំកន្លងមកហើយដែរ ។

តាមឯកសារស្រាវជ្រាវបានធ្វើឱ្យយើងដឹងបន្ថែមទៀតថា មានតែជនជាតិខ្មែរទេ ដែលមានភាពចំណាស់ជាងគេក្នុងការស្ទៀកប៉ឹងនេះ ។ ឯនជនជាតិថៃ និងវៀតណាម ដែលជាប្រទេសមានភូមិសាស្ត្រជិតជាប់ជាមួយប្រទេសខ្មែរយើងក៏គេមិនចេះស្ទៀកប៉ឹង ដូចជាកុលសម្ព័ន្ធខ្មែរយើងឡើយ ។

យើងអាចបន្ថែមទៀតថា ក្រៅពីឯកសារ និងភស្តុតាងរូបចម្លាក់ស្ទៀកប៉ឹង និងរួមទាំងប្រពៃណីស្ទៀកប៉ឹងរបស់ជនជាតិខ្មែរ ដែលមានជារបាំរបស់ជន

ជាតិស្ទៀកប៉ឹងនេះ គឺជាក់ស្ដែងជនជាតិភាគតិចនៅខេត្តតំបន់ភូមិភាគឦសាន ក៏នៅតែបន្តស្ទៀកប៉ឹងរហូតមកដល់បច្ចុប្បន្ននេះនៅឡើយដែរ ។

## ១៧_ការជក់បារីដោយប្រើខ្សៀនាសម័យបុរេប្រវត្តិសាស្ត្រ

តាមប្រភពបុរាណវិទ្យា ជាពិសេសកំណាយខុសច្បាប់ ដើម្បីរាវរកវត្ថុបុរាណមកលក់ក្នុងទីផ្សារនានាបានបង្ហាញឱ្យយើងដឹងថា ការនិយមជក់ថ្នាំ (ជក់បារី) ដោយមានប្រើខ្សៀស្ពាន់ ដីដុតនាសម័យបុរេប្រវត្តិសាស្ត្រ គឺជាការបញ្ជាក់ពីចំណាស់ប្រើខ្សៀនៅក្នុងប្រទេសកម្ពុជា ។

ការស្រាវជ្រាវតាមវត្ថុបុរាណនៃខ្សៀ ដែលគេបានរកឃើញជាខ្សៀដែលមានអាយុកាលរវាងពី១០០០ឆ្នាំទៅ៣០០ឆ្នាំមុនគ.ស. (មុនគ.ស.រាប់ពីច្រើនទៅតិច)។ ការរកឃើញនេះ ជាខ្សៀជក់បារីនាសម័យបុរាណ ប៉ុន្តែការនិយមខ្សៀជក់បារី ត្រូវបានគេប្រើប្រាស់បន្តរហូតមកដល់សព្វថ្ងៃនេះ នៅតាមសហគមន៍ខ្មែរជនជាតិភាគតិច ។

តាមការរកឃើញខ្សៀបុរាណមានដូចជាស្ពាន់ និងដីដុតខាងលើជាការបញ្ជាក់ឱ្យឃើញថា ការប្រើខ្សៀនៅប្រទេសកម្ពុជាវាពិតជាមានចំណាស់ និងនិរន្តរភាពរៀងរហូតមក ។

ក្រៅពីការឃើញខ្សៀបុរាណទាំងនោះនៅលើទឹកដីខ្មែរហើយ គេក៏បានរកឃើញខ្សៀដូចគ្នានេះដែរ នៅក្នុងឧបទ្វីបឥណ្ឌូចិនផងដែរ ។

សូមជម្រាបផងដែរថា រហូតមកដល់សព្វថ្ងៃនេះ គេបានរកឃើញនូវខ្សៀសរិទ្ធិមួយចំនួននៅក្នុងខេត្តសៀមរាបអង្គរ ដែលមានទ្រង់ទ្រាយស្រដៀង

ទៅនឹងខ្សែនៃភូមិស្ពាយ និងខ្សែនៅស្ថានីយបានឆៀង ក្នុងខេត្តឧត្តរធានីនៃប្រទេសថៃបច្ចុប្បន្ន ក៏ប៉ុន្តែជាសមិទ្ធិផលសង្គមរបស់ពួកមន-ខ្មែរ ។ ការរកឃើញនេះ សបញ្ជាក់ឱ្យឃើញនូវឯកភាពផ្នែកវប្បធម៌ ក្នុងសម័យបុរេប្រវត្តិសាស្ត្រ ហើយវាក៏បង្ហាញនូវចំណាស់របស់ប្រពៃណីជក់ថ្នាំរបស់ជនជាតិខ្មែរដែរ ។

## ១៨. ការរាប់ចំនួននាសម័យបុរេប្រវត្តិសាស្ត្រ

ការរាប់ចំនួនវត្ថុ ឬសត្វជាប្រពៃណី ឬជាទំនៀមទម្លាប់មួយ ដែលមានលក្ខណៈសាកល ដោយហេតុថា គ្រប់សញ្ជាតិនៅលើពិភពលោកយើងនេះ សុទ្ធតែនិយមប្រតិបត្តិទាំងអស់ ។ម្យ៉ាងវិញទៀត យើងក៏បានដឹងទៀតថា ការរាប់ចំនួន ឬលេខខាងលើនេះ ជាមតិកវប្បធម៌មួយ ដែលបានប្រសូតឡើងតាំងពីសម័យបុរេប្រវត្តិសាស្ត្រមកម្លេះ ពោលគឺមានអាយុច្រើនពាន់ម៉ឺនឆ្នាំមុនគ.ស. ទៅទៀត ។ ប៉ុន្តែអ្វីដែលគេពុំដឹងរហូតមកទល់សព្វថ្ងៃនេះ គឺជាភស្តុតាងដើម្បីបញ្ជាក់ ។

តទៅនេះ យើងសូមបង្ហាញនូវគំនិតមួយចំនួនលើផ្លែត្រល់ ដែលមានអាយុប្រមាណជា២.៣០០ឆ្នាំមកហើយ ដោយហេតុថា វត្ថុបុរាណនេះ ត្រូវបានគេរកឃើញនៅក្នុងស្ថានីយប្រវត្តិសាស្ត្រមួយ មានកាលបរិច្ឆេទរវាង៣០០ ឆ្នាំមុនគ.ស. និង៥០០ឆ្នាំក្រោយគ.ស. ។

ថ្វីត្បិតតែវត្ថុបុរាណទាំងនោះ ជាប្រភពពណ៌មានយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍន៍ ការចេះដឹងរបស់យើង ពោលគឺជាវត្ថុតាងបង្ហាញថា ដូនតាខែរយើងជំនាន់នោះ បានចេះរាប់ចំនួន ឬលេខតាំងតែពីសម័យបុរាណកាលដ៏យូរ

លង់មកហើយ មិនមែនជាទម្លាប់បានមកពីបរទេសនោះទេ ។

ការពិនិត្យនៅលើផ្លែត្រល់ ដែលបានយកមកពីភូមិស្នាយ ខេត្តបន្ទាយមានជ័យ ជាត្រល់សម្រាប់រវៃអំបោះ ដើម្បីយកទៅត្បាញសំពត់បានឱ្យយើងដឹងថា ការដែលស្ត្រីខ្មែរចោះរន្ធតូចៗ ជាជួរនៅលើផ្លែត្រល់ធ្វើអំពីដីដុត ពុំមែនជារឿងចៃដន្យនោះទេ ប៉ុន្តែវាជាសញ្ញាណបង្ហាញនូវគណិតសាស្ត្រផងដែរ ។ ផ្នែកខាងលើនៃផ្លែត្រល់ធ្វើអំពីដីដុត យើងឃើញមានរង្វង់មូលតូចៗ៤ជួរ ដែលបានយកចុងឈើស្រួចមកចុច មុនពេលដែលគេយកផ្លែត្រល់ទៅដុតកម្ដៅឱ្យរឹង ដោយមួយជួរៗមានរង្វង់មូល៤ ដូច្នេះរង្វង់មូលមានទាំងអស់១៦រង្វង់ ។

រីឯនៅផ្នែកខាងក្រោមនៃផ្លែត្រល់វិញ គេបានឃើញមានរន្ធមូលតូចៗទាំងអស់១៨ ថ្វីត្បិតតែមួយចំហៀងនៃផ្លែត្រល់ត្រូវរេចរិលលុបបាត់ក៏ដោយ ។

នេះជាលើកដំបូងហើយ ដែលអ្នកស្រាវជ្រាវបានទទួលនូវវប្បធម៌បង្ហាញនូវពត៌មានយ៉ាងប្រាកដប្រជា ស្តីពីការប្រើលេខសម្រាប់រាប់ចំនួនវត្ថុផ្សេងៗ នាដើមសម័យប្រវត្តិសាស្ត្រ ។

សរុបសេចក្ដីមក វត្ថុបុរាណមានសារសំខាន់ណាស់ ព្រោះវាផ្ដល់នូវពត៌មានសម្រាប់ការស្វែងយល់អំពីវប្បធម៌ អារ្យធម៌ខ្មែរ ។ ដូច្នេះ គ្រប់ការជួញដូរវត្ថុបុរាណគ្រប់ប្រភេទ ត្រូវតែហាមឃាត់ជាដាច់ខាត ។

## ១៩_ការផ្សាំងសត្វនាសម័យមុនប្រវត្តិសាស្ត្រ

គេដឹងថា ការផ្សាំងសត្វ ឬការយកសត្វព្រៃមកចិញ្ចឹម ដើម្បីឱ្យក្លាយទៅជាសត្វស្រុក ត្រូវបានដូនតាខ្មែរយើងផ្ដើមធ្វើឡើងតាំងពីសម័យថ្មរលីងមម្លេះ ពោលគឺនៅរវាង៨០០០០ទៅ២០០០ឆ្នាំមុនគ.ស. ។ ប៉ុន្តែរហូតមកដល់ពេលនេះ កម្រណាស់ដែលគេមានឯកសារជាក់ស្ដែងស្ដីពីសមិទ្ធិផលសង្គមនេះ ។

ថ្មីៗនេះ តាមរយៈការស្រាវជ្រាវរបស់យើងនៅភូមិព្រីងជូ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យបានឱ្យដឹងថា ក្នុងចំណោមសត្វជាច្រើន ដែលដូនតាយើងបានផ្សាំង ហើយដែលបានរួមរស់ជាមួយមនុស្សយើងរហូតមកដល់សព្វថ្ងៃនេះ មានសត្វជ្រូក សត្វឆ្កែ និងសត្វមាន់ជាដើម ។ អ្វីដែលយើងបានបង្ហាញនេះ គឺជាភស្តុតាងវប្បធម៌ ដែលមានកាលបរិច្ឆេទច្បាស់លាស់ ឥតប្រកែកបាន ហើយក៏ជាសក្ខីកម្មមួយដែលថា ទង្វើនេះក៏ពុំមែនជាការចៃដន្យដែរ គឺជាសកម្មភាពរបស់មនុស្សយ៉ាងពិតប្រាកដ ពោលគឺបានកើតឡើងដោយបញ្ញាញាណភាពឆ្លាតវាងវៃរបស់មនុស្ស ។ លើសពីនេះទៅទៀតនោះ ការដែលសត្វព្រៃបានក្លាយទៅជាសត្វស្រុក ក៏ជាភស្តុតាងបង្ហាញនូវចំណាស់នៃវប្បធម៌ខ្មែរ ដែលតាំងពីការកកើតវប្បធម៌ បានរួមរស់យ៉ាងសុខដុមរម្យនាជាមួយគ្នា និងបរិស្ថានជុំវិញខ្លួន ។

# ជំពូកទី៣

## ទំនាក់ទំនងវប្បធម៌មន-ខ្មែរ ក្នុងសង្គមខ្មែរតាំងពីបុរាណកាលមកដល់សព្វថ្ងៃ

## ១-ប៉ឹងបុរសនៅសម័យអង្គរ

"ប៉ឹង" គឺជាសម្លៀកបំពាក់ប្រពៃណីមួយបែប មិនថាស្ដេច ឬប្រជារាស្ត្រធម្មតាទេ តែងតែនិយមស្លៀកពាក់សម្លៀកបំពាក់នេះ តាំងតែពីសម័យបុរេប្រវត្តិសាស្ត្រម្ល៉េះ ដែលជាសមិទ្ធិផលរបស់ជនជាតិខ្មែរសុទ្ធសាធ ។

បច្ចុប្បន្ននេះ ទោះបីជាសម្លៀកបំពាក់ប៉ឹងនេះ ត្រូវបានរលាបសាបសូន្យ លែងសូវមានការនិយមរាប់អានអំពីសំណាក់មនុស្សក្នុងសម័យជឿនលឿនហើយក៏ដោយ គេនៅតែសង្កេតឃើញមានបងប្អូនខ្មែរលើយើងខ្លះ ដូចជានៅខេត្តមណ្ឌលគិរី និងរតនគិរីនៅនិយមស្លៀកប៉ឹងនេះនៅឡើយដែរ ។

ការដែលបងប្អូនខ្មែរលើនៅតំបន់ភូមិភាគព្រៃសាន នៅតែនិយមប្រើប្រាស់ប៉ឹងនេះនៅឡើយ ធ្វើឱ្យគេនឹកឃើញនូវសម័យវប្បធម៌ភ្លឹង្គ ។ ព្រោះថាថ្វីដ្បិតតែខ្មែរបានទទួលវប្បធម៌អារ្យធម៌ក្លិង្គ ដែលជាប្រភពនៃភាពរុងរឿងកប់កំពូលក៏ដោយ ជនជាតិខ្មែរពុំបានលះបង់ចោលនូវលក្ខណៈវប្បធម៌ដើមមួយចំនួន ដែលសតិអារម្មណ៍ប្រពៃណីជាតិដាក់តម្លៃ ឬចាត់ទុកថា ជាទំនៀមទម្លាប់ល្អរបស់ខ្លួន ។

ត្រង់នេះហើយ ដែលអ្នកស្រាវជ្រាវបានខិតខំបង្ហាញពីប្រពៃណី "ប៉ឹងបុរស" ដែលសង្គមខ្មែរទាំងមូលនាសម័យអង្គរបាននិយមប្រើប្រាស់ មិនថាត្រកូលក្សត្រ ឬរាស្ត្រនោះឡើយ ដើម្បីឆ្លុះបញ្ចាំងនូវនិរន្តរភាពរបស់ជនជាតិ

ខ្មែរយើងតាំងពីសម័យមហានគរ ។

មានភស្តុតាងមួយចំនួន ដែលអ្នកស្រាវជ្រាវបានលើកយកមកបង្ហាញពីភាពចំណាស់របស់ប្រពៃណីខ្មែរស្លៀកប៉ឹង ។ ប្រសិនបើយើងទៅទស្សនានៅប្រាសាទបន្ទាយឆ្មារ និងប្រាសាទបាយ័ន យើងនឹងឃើញនូវរូបភាព ដែលស្មានមិនដល់ គឺព្រះបាទជ័យវរ្ម័នទី៧ ដែលជាព្រះមហាក្សត្រដ៏ខ្លាំងកប់កំពូល បានកសាងប្រាសទបុរាណរាប់រយក្នុងអតីតមហានគរខ្មែរ និងជាស្តេចសឹក ក៏បានស្លៀក "ប៉ឹង" ដូចជាប្រជារាស្ត្រខ្មែរទូទៅដែរ ។ នេះហើយ ដែលសបញ្ជាក់ឱ្យឃើញថា ទោះបីជាឥទ្ធិពលដ៏ខ្លាំងក្លារបស់ឥណ្ឌា បានបោកបក់មកលើសង្គមខ្មែរជំនាន់នោះក្តី ក៏មិនអាចលុបបំបាត់នូវប្រពៃណីស្លៀកប៉ឹង ដែលជាសមិទ្ធផលរបស់សង្គមខ្មែរសុទ្ធសាធនេះបានដែរ ។ រួមសេចក្តីមក គឺព្រះមហាក្សត្រនិងប្រជារាស្ត្រខ្មែរ ជាអ្នកឱ្យតម្លៃយ៉ាងខ្ពស់នូវសម្លៀកបំពាក់ខាងលើនេះ ។

ប្រពៃណីស្លៀកប៉ឹងនេះ បានកើតមានឡើងតាំងពីសម័យវប្បធម៌ថ្មរំលីងមកម្ល៉េះ ។ "ដំបូងយើងបានសង្ស័យថា វាបានកើតចេញពីជឿនវប្បធម៌នាសម័យបុរេប្រវត្តិសាស្ត្រ ប៉ុន្តែឥឡូវយើងមិនច្រឡំទេ វាពិតជាដូច្នេះមែនព្រោះយើងបានជួបប្រទះនូវគំនូរបុរាណលើជញ្ជាំងថ្មជាច្រើនផ្ទាំង ព្រមជាមួយនិងវត្ថុសិល្បៈ" ។

ប្រៀបធៀបចម្លាក់បុរាណនាសម័យអង្គរវត្តទៅនឹងសម័យនគរភ្នំ គេនឹងឃើញទេវតានាសម័យនគរភ្នំ ដូចជាព្រះនារាយណ៍នៅប្រាសាទស្រីទេព (ប្រទេសថៃបច្ចុប្បន្ន) និងព្រះនារាយណ៍នៅអង្គរបុរី (តាកែវ) ដែលជាមតិកវប្បធម៌ខ្មែរ នៅតែស្លៀកពាក់ប៉ឹង ថ្វីបើមានស្លួចស្តើងណាស់ក៏ដោយ ។

សរុបសេចក្តីមកការនិយមប៉ឹង ដោយព្រះមហាក្សត្រខ្មែរ ដូចជាប្រជានុរាស្ត្រនាសម័យអង្គរពុំមែនមានន័យថា ជនជាតិខ្មែរមិនចេះប្រើសំពត់ ឬសារុងចរបាប់ធ្វើអំពីសូត្រ ដែលមានពណ៌ចម្រុះនោះទេ ។ តាមពិត គេប្រើនៅក្នុងពិធីបុណ្យទានធំៗ ដែលនៅពេលធ្វើដំណើរ ឬទៅសឹកសង្គ្រាមក្នុងជីវភាពប្រចាំថ្ងៃធម្មតាឡើយ ។ ការប្រើប៉ឹងខាងលើនេះ គឺជាភស្តុតាងបង្ហាញនូវលក្ខណៈខ្មែរសុទ្ធសាធនៃសម្លៀកបំពាក់ខ្មែរ ដែលបានតពីប្រពៃណីខ្មែរលើ ឬខ្មែរដើមតែប៉ុណ្ណោះ ។

## ២-ប៉ឹងស្ត្រីខ្មែរលើ

នៅក្នុងអត្ថបទមុននេះ យើងបានបានរៀបរាប់អំពីការស្លៀកប៉ឹងរបស់បុរសនាសម័យអង្គរ តែក្នុងអត្ថបទនេះ យើងនិយាយអំពីការស្លៀកប៉ឹងរបស់ស្ត្រីខ្មែរនាសម័យអង្គរ និងក្រោយអង្គរបន្តិច ចូលចិត្តលែងដោះ បណ្តាលមកពីទម្ងន់ប្រពៃណី ដែលកើតចេញពីជឿនអារ្យធម៌ខ្មែរសុទ្ធិសាធ មានអាយុតាំងពីសម័យបុរេប្រវត្តិសាស្ត្រ ថ្វីដ្បិតតែមនុស្សខ្មែរបានទទួលឥទ្ធិពលវប្បធម៌ក្លឹង្គយ៉ាងខ្លាំងក្លាក៏ដោយ ។ ឥឡូវនេះ នឹងលើកយកនូវភស្តុតាងមួយមកបង្ហាញនៅទីនេះទៀត គឺអំពីប៉ុងខ្មែរនាសម័យអង្គរ និងប៉ុងកុសម្ព័ន្ធខ្មែរលើ ដែលកំពុងប្រើរហូតមកដល់សព្វថ្ងៃនេះ ។

អ្វីទៅដែលហៅថាប៉ឹង ? ប៉ឹងគឺជាក្រណាត់ ដែលបងប្អូនខ្មែរលើភេទស្រី ស្លៀកដើម្បីបិតបាំងនូវកេរ្តិ៍ខ្មាសរបស់ខ្លួន ។ ពោលគឺជាសម្លៀកបំពាក់របស់បងប្អូនខ្មែរលើ ។

ប៉ឹងវែងមានលក្ខណៈដូចជាប៉ឹងរបស់បុរស តែខ្លីជាងបន្តិច ហើយជូន

កាលមានក្បាច់ផ្ការល្អប្រណិត មិនខុសពីសំពត់របស់ស្ត្រីខ្មែរនាសម័យនេះប៉ុន្មានដែរ ។ ប៉ុងនេះ មានប្រវត្តិយ៉ាងយូរលង់ណាស់មកហើយ ។ តាមការវិភាគចម្លាក់នាសម័យលោហធាតុបានឱ្យដឹងថា បុព្វបុរសខ្មែរបានប្រើប្រាស់សម្លៀកបំពាក់ប្រភេទនេះយ៉ាងហោចណាស់ក៏១០០០ឆ្នាំមុនគ.ស.ដែរ ។

មូលហេតុនៃការស្រុតចុះប្រពៃណីខាងលើនេះ ត្រូវបានអ្នកបុរាណវិទ្យាស្រាវជ្រាវតាមរយៈសម្លៀកបំពាក់បុរាណ តាមរូបចម្លាក់នាសម័យនគរភ្នំបានផ្ដល់នូវពត៌មានគួជាទីមោទនៈមួយថា ជនជាតិខ្មែរយើងដែលនៅតាមតំបន់ទំនាប ដូចជានៅកម្ពុជាក្រោម និងខេត្តតាកែវ ព្រៃវែងជាដើម ថ្វីដ្បិតតែស្ថិតនៅក្រោមឥទ្ធិពលក្លឹង្គក៏ដោយ ក៏ពួកគេនៅតែនិយមប៉ុងនឹងសំពត់ ឬសារុងជានិច្ច ។

ទន្ទឹមនិងការបន្តទម្រង់ខឿនវប្បធម៌ចាស់ ខ្មែរយើងបានស្គាល់នូវការបដិវត្តន៍មួយផ្នែក គឺសម្លៀកបំពាក់ដែលបរទេសបាននាំចូល ហើយដែលជាការពេញចិត្ត និងពេញនិយមនាសម័យនេះ ។

ភាពឆើតឆាយ និងភាពសម្បូរណ៍នៃសម្លៀកបំពាក់នាសម័យនគរភ្នំត្រូវបានបញ្ជាក់ដោយបដិមាសាស្ត្រ ។

សូមបញ្ជាក់ថា បណ្ដាអ្នកស្រាវជ្រាវបានខិតខំជាច្រើនឆ្នាំក្នុងការសិក្សានូវស្ថានីយបុរេប្រវត្តិសាស្ត្រអង្គរបុរីបានឱ្យដឹងថា សង្គមខ្មែរបានស្គាល់នូវសម្លៀកបំពាក់ថ្មី ដូចជាគ្រែ. សំពត់ចរបាប់. សូត្រគ្រប់ពណ៌ ក៏ប៉ុន្តែការនិយមប៉ុងនៅតែបន្តរហូតដល់សម័យអង្គរដដែល ។ ភាពមិនបោះបង់ចោលនូវប្រពៃណីដូនតា ដែលជាកេរ្តិ៍មតិកបុរេប្រវត្តិសាស្ត្រត្រូវបានកត់ត្រាទុក តាមចម្លាក់

ទេវតាមួយចំនួនទាំងនេះ សឱ្យឃើញថា និរន្តភាពរបស់ទំនៀមទម្លាប់ខ្មែរនៅតែបន្តរហូតដល់សម័យអង្គរ ។

ការដែលកុលសម្ព័ន្ធខ្មែរលើ ដែលរួមឈាមជ័រជាមួយខ្មែរ ដែលរស់នៅតាមវាលទំនាបនៃជ្រោយឥណ្ឌូចិន នៅតែបន្តកាន់កាប់ទំនៀមទម្លាប់ខាងលើនេះ ជាភស្តុតាងមួយយ៉ាងសំខាន់ ដើម្បីឆ្លុះបញ្ចាំងបង្ហាញនូវការរួមពូជសាសន៍តែមួយរវាងខ្មែរ និងពួកខ្មែរលើ ដែលរស់នៅពាសពេញដេរដាសក្នុងឧបទ្វីបឥណ្ឌូចិននេះ ។ ផ្ទុយពីជនជាតិយួន លាវ និងសៀម ជនជាតិខ្មែរ និងកុលសម្ព័ន្ធខ្មែរលើ មិនមែនជាជនជាតិ ដែលបានជន្លៀសខ្លួនមកពីក្រៅនោះទេ ផ្ទុយទៅវិញ គឺជាជនជាតិដែលបានកើតនៅលើទឹកដីឥណ្ឌូចិននេះ ដែលជាមាតុភូមិរបស់ខ្លួន ហើយជាម្ចាស់កម្មសិទ្ធិនៃសំណង់វប្បធម៌បុរេប្រវត្តិសាស្ត្រទាំងឡាយ គេបានរកឃើញក្នុងស្ថានីយផ្សេងៗមុនសម័យក្លឹង្គចូលស្រុក ។

## ៣. ទេពអប្សរនៅប្រាសាទអង្គរវត្ត មានរូបរាងដូចស្ត្រីកុលសម្ព័ន្ធខ្មែរលើ

ចាប់តាំងពីសម័យឥណ្ឌូបនីយកម្មបានឈានមកដល់ គឺនាំមកនូវការបោះបង់ចោលទម្លាប់ស្លៀកប៉ឹងរបស់ជនជាតិខ្មែរលើ ដែលមានមកតាំងតែពីសម័យបុរេអង្គរ សម្ព័ន្ធភាពវប្បធម៌រវាងខ្មែរ និងកុលសម្ព័ន្ធខ្មែរលើមានភាពជិតស្និទ្ធនឹងគ្នា ដែលបានបន្តមកទល់សព្វថ្ងៃ រហូតមានចម្លាក់ទេពអប្សរា មានលក្ខណៈជនជាតិដូច្នោះដែរ ។

នៅលើជញ្ជាំងប្រាសាទអង្គរវត្តមានចម្លាក់ស្រីរបាំ ឬស្រីទេពអប្សរជាង១៥០០នាក់គួរឱ្យចង់គយគន់ជាអនេក ។ ជាមួយគ្នានេះ នៅមានរូបស្រី

ទេពអប្សរមួយចំនួន ដែលផ្តល់បរិយាកាសសង្គម និងវប្បធម៌ខ្មែរនាសម័យមហានគរកាលពីរយៈពេល៨៥០ទៅ១០០០ឆ្នាំមុន សម្រាប់ធ្វើជាការពិចារណាតទៅ ។

រហូតមកដល់សព្វថ្ងៃនេះ ការស្រាវជ្រាវបានផ្តោតជាអាទិភាពតែទៅលើផ្នែកស្ថាបត្យកម្មនៃប្រាសាទបុរាណតែប៉ុណ្ណោះ ។ ឯការសិក្សាអំពីសម្លៀកបំពាក់រវាងស្រីទេពអប្សរ និងជនជាតិខ្មែរលើបូឱិនបានបង្ហាញឱ្យដឹងថា នៅខេត្តសៀមរាបអង្គរវត្ត កាលដំណាក់កាលវប្បធម៌សម័យអង្គរ ជនជាតិខ្មែរនៅទីនោះ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយកុលសម្ព័ន្ធខ្មែរលើ ដែលពួកគេរស់នៅក្នុងភូមិភាគឥណ្ឌូចិន ។

ទោះបីជាមានទំនាក់ទំនងល្អជិតស្និទ្ធ រវាងជនជាតិខ្មែរនៅខេត្តសៀមរាបអង្គរវត្តជាមួយកុលសម្ព័ន្ធខ្មែរលើយ៉ាងណាក៏ដោយ ក៏វប្បធម៌ទាំងពីរនេះមានចំណុចមិនដូចគ្នាទាំងអស់នោះឡើយ ។ បញ្ហាសំខាន់គឺប្រពៃណីរវាងជនជាតិទាំងពីរមានសភាពខុសគ្នា ត្រង់ជនជាតិខ្មែរនៅសៀមរាបមានភាពសម្បូរបែប និងការស្ថាបនា ឯជនជាតិខ្មែរលើកុលសម្ព័ន្ធនៅតែរក្សាប្រពៃណី និងការស្លៀកពាក់មានការខុសគ្នាតិចតួចនាសម័យបុរេប្រវត្តិសាស្ត្រនៅឡើយ ។

ដោយសារមានទំនាក់ទំនងជិតស្និទ្ធល្អបែបខាងលើនេះហើយ ទើបវិចិត្រករនាសម័យអង្គរវត្ត បានឆ្លាក់រូបស្រីទេពអប្សរនៅជាប់និងប្រាសាទអង្គរវត្តមានលក្ខណៈដូចគ្នាទៅនិងកុលសម្ព័ន្ធយ៉ាងដូច្នោះដែរ ។

នៅតាមភូមិស្រុកដាច់ស្រយាលនាសម័យអង្គរ វត្តមានរបស់កុលសម្ព័ន្ធខ្មែរលើពិតជាមានយ៉ាងប្រាកដ ។ វត្តមាននេះហើយ ទើបធ្វើឱ្យវិចិត្រករ

នៅប្រាសាទអង្គរវត្តឆ្លាក់រូបស្រីទេពអប្សរមានលក្ខណៈដូចគ្នា និងកុលសម្ព័ន្ធអំពីការស្លៀកពាក់នេះឯង ។

ស្រីទេពអប្សរទាំងនេះ មានតែក្រណាត់គ្របកេរ្តិ៍ខ្មាស់របស់គេតែប៉ុណ្ណោះ ។ ជនជាតិខ្មែរលើ "ព្នង" បានរក្សានូវទម្លាប់ស្លៀកប៉ឹងសម្រាប់បិតបាំងកេរ្តិ៍ខ្មាស់ដោយទុកដងខ្លួនរបស់គេនៅទទេគ្មានអាវគ្របដណ្តប់ឡើយ បើទោះបីជាពួកគេស្ថិតនៅក្នុងវ័យពេញក្រមុំហើយក៏ដោយ ។ ប៉ុន្តែនៅសម័យឥណ្ឌូបនីយកម្ម ត្រូវបាននាំមកនូវការបោះបង់ចោលទម្លាប់ស្លៀកប៉ឹងនេះអស់ទៅហើយ ។

## ៤_ប្រពៃណីលែងខ្លួនទទេរបស់ស្ត្រីខ្មែរ

នៅតាមជញ្ជាំងប្រាសាទខ្មែរបុរាណនាសម័យបុរេអង្គរ និងអង្គរ គេឃើញមានចម្លាក់បុរាណជាច្រើនដូចជាព្រះទេពី ស្រីរាំ ឬទេពអប្សរាព្រមទាំងប្រជានុរាស្ត្រ ដែលមានឋានៈទាប ឬខ្ពង់ខ្ពស់ជាទីបំផុតស្ថិតនៅក្នុងឥរិយាបថលែងខ្លួនទទេរដូចគ្នាដែរ ។ ឧទាហរណ៍ យើងក្រឡេកមើលចម្លាក់ព្រះអង្គម្ចាស់ក្សត្រីឥន្ទ្រទេវីជាដើម ដែលជាព្រះជាយារបស់ព្រះមហាក្សត្រខ្មែរដ៏ខ្លាំងពូកែកប់កំពូល (ជ័យវរ្ម័នទី៧) ក៏ព្រះនាងស្ថិតក្នុងឥរិយាបថលែងខ្លួនទទេដែរ ។ ដោយឡែកតាមការវិភាគរូបសំណាកនាសម័យនគរភ្នំស.វ.ទី១ ដល់ទី៧ និងសម័យចេនឡា (ស.វ.ទី៨ ដល់ទី៩នៃគ.ស.) ក៏បានបញ្ជាក់នូវការនិយមប្រតិបត្តិនូវទម្លាប់ខាងលើនេះដែរ ។

យោងតាមប្រភពឯកសារបុរាណវិទ្យា យើងអាចសន្និដ្ឋានបានថាប្រពៃណី "ដោះអាវ" នេះ មានឡើងតាំងពីសម័យបុរេប្រវត្តិសាស្ត្រមកម្លេះ ។

ដូច្នេះ ទំនៀមទម្លាប់លែងខ្លួនរបស់ស្ត្រីខ្មែរ គឺជាប្រពៃណីទូទៅ ដែលមានតាំងតែពីបុរាណកាលមក ក្នុងលក្ខណៈអាវាសែទេ ។ ម្យ៉ាងទៀត តាមរយៈឯកសារបានបញ្ជាក់ឱ្យយើងដឹងថា កាលដែលគេឆ្លាក់រូបទេវតា ឬរូបមនុស្សនាសម័យបុរាណ គឺពុំមែនជារឿងប្រឌិតនោះទេ គឺជាប្រពៃណីពិតៗ ដែលទាក់ទងទៅនឹងប្រពៃណីដូនតាខ្លួន ។

សូមបញ្ជាក់ថា ការដែលស្រីខ្មែរដោះអាវ ឬអត់អាវចំហដើមទ្រូងឱ្យលេចសុដន់ទាំងគូរនៅទទេរបែបនេះ គឺមិនមែនមានន័យថា ស្ត្រីខ្មែរមិនចេះពាក់អាវនោះទេ នោះជាកានិយមឱ្យតម្លៃជាទូទៅក្នុងព្រះរាជនគរខ្មែរបុរាណរហូតដល់សម័យបារាំងចូលមកស្រុក ទើបប្រពៃណីនោះក៏ត្រូវរអាក់រអួលទៅវិញ ។

រហូតមកដល់ស.វ.ទី១៩នៃគ.ស. ស្ត្រីខ្មែរនៅតែនិយមប្រពៃណីដោះអាវនេះរហូត ទោះជាស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ ព្រោះវាបានក្លាយទៅជាទម្លាប់ធម្មជាតិនៅគ្រប់ទីច្រកល្ហកទៅហើយ ប៉ុន្តែតាមលទ្ធផលនៃការស្រាវជ្រាវក្រោយមកទៀត ទើបគេដឹងថា ប្រពៃណីនេះ បានប្រែប្រួលបន្តិចម្តងៗរហូតដល់បាត់អស់ នៅពេលដែលឥទ្ធិពលអឺរ៉ុប និងក្លឹង្គបានជះមកលើសង្គមខ្មែរនាជំនាន់នោះ ។ ប៉ុន្តែជនជាតិខ្មែរដែលរស់នៅតាមតំបន់ព្រៃភ្នំ នៅតែរក្សាប្រពៃណីនេះបានគង់វង់ស្ថិតស្ថេររហូតមកដល់សព្វថ្ងៃនេះ ។

គួរបញ្ជាក់ផងដែរថា បងប្អូនខ្មែរលើទាំងនោះ ក៏ដូចជាបុព្វបុរសនាសម័យអង្គរ និងមុនអង្គរផងដែរ ។ កាយវិកាស្រាតនទលជងខ្លួន ពុំមែនមានន័យថា ឆ្អេះឆ្អាបនោះទេ ក៏ប៉ុន្តែប្រកបដោយលក្ខណៈស្អាតស្អំបរិសុទ្ធិ ។ សូម

ជម្រាបថា ថ្មីៗនេះ អ្នកស្រាវជ្រាវគេបានរកឃើញនូវរូបបុរាណនាស.វ.ទី១២ នូវរូបអ្នករបាំនាសម័យអង្គរ ពាក់អាវយ៉ាងស្តើងខុសពីស្ត្រីទេពអប្សរមួយភាគធំនៅលើប្រាសាទអង្គរ បាពួន......... ។ល។

## ៥.ប្រពៃណីទងត្រចៀកវែងរបស់ទេពអប្សរ

ទស្សនិកជនខ្មែរ ដែលបានអញ្ជើញទៅទស្សនាប្រាសាទបន្ទាយស្រី នៅខេត្តសៀមរាប បានផ្ចោតអារម្មណ៍យ៉ាងខ្លាំង ចំពោះសោភ័ណភាពរបស់ស្រីទេពអប្សរបុរាណជាច្រើន ដែលបុព្វបុរសរបស់ខ្លួនបានឆ្លាក់សម្រាប់តុបតែងទេវស្ថាននេះ ដែលបានស្ថាបនាឡើយនៅឆ្នាំ៩៦៧នៃគ.ស. ពោលគឺនៅពាក់កណ្តាលទី២ នៃស.វ.ទី១០ ក្នុងរជ្ជកាលរបស់ព្រះបាទរាជេន្ទ្រវរ្ម័ន។ ដើមឡើយបូជនីយដ្ឋាននេះ មានឈ្មោះថា ឥស្វរបុរៈ ឬបុរីនៃព្រះឥសូរ ។

ស្រីទេពអប្សរាទាំងនោះ ដែលឆ្លាក់ក្នុងឥរិយាបទឈរក្នុងស៊ុមកោងផ្ដិតលើប្រាសាទថ្មមានទឹកមុខស្រស់សុភាពរាបសារទន់ភ្លន់ ញញឹមស្រស់ ហើយនៅត្រចៀកដែលយារធ្លាក់ដល់ស្មារ គេឃើញមានពាក់គ្រឿងអលង្ការជាក្រវិលធ្វើអំពីមាស ឬសំរិទ្ធិ ។ គឺលក្ខណខុសពីភាពប្រក្រតីនេះហើយ ដែលធ្វើឱ្យគេធ្វើការស្រាវជ្រាវអំពីមូលហេតុ ឬអត្ថន័យរបស់ប្រពៃណីដាក់ត្រចៀកវែងលំអដោយមានក្រវិលធំៗនៅចុងស្លឹកត្រចៀកផង ។ ហេតុដូច្នេះហើយបានជានាងៗ ទេពអប្សរទាំងអស់នោះនៅប្រាសាទបន្ទាយស្រី មានស្លឹកត្រចៀកធ្លាក់ដល់ដើមទ្រូង ខុសពីទេពធីតាផ្សេងៗឯទៀតដូចនៅអង្គរវត្ត ឬបាយ័នជាដើម ?

ការគយគន់នូវចម្លាក់បុរាណទាំងនោះ ដែលមានភាពញញឹមស្រស់ប្រិមប្រិយ ធ្វើឱ្យយើងមានអារម្មណ៍សប្បាយរីករាយ ព្រោះថា អ្នកដំណើរមក

កាន់ទេវស្ថាន ដើម្បីបន់ស្រន់បូជាទេវតាមានការនឿយហត់យ៉ាងខ្លាំង ។ សូមបញ្ជាក់ថា ប្រាសាទបន្ទាយស្រីស្ថិតនៅឆ្ងាយដាច់ស្រយាលពីទីប្រជុំជន ។ ស្ថានភាពទីតាំងពុំមែនធ្វើឡើងដោយគ្មានមូលហេតុសាសនាជំនឿដែរ ។ ប្រាសាទដែលស្ថិតនៅកាន់តែឆ្ងាយ សាសនិកជនដែលអញ្ជើញមកដោយធ្មើជើង ជិះសេះ ជិះដំរី ឬដោយរែគ្រស្នែង កាន់តែធ្វើឱ្យសាមីខ្លួនបានទទួលកុសលផលបុណ្យច្រើន ។ម្យ៉ាងវិញទៀតទីតាំងនេះ អាចឆ្លុះបញ្ចាំងឱ្យគេឃើញនូវទស្សនៈខ្មែរនាសម័យបុរាណ ដែលជឿលើប្រាសាទ ឬអាស្រមដែលជាកន្លែងសម្រាប់អង្គុយតាំងធម៌ ឬស្ទឹងស្មាធិ៍នៃតាបស ឬព្រាហ្មណ៍ មិនត្រូវស្ថិតនៅក្បែរសង្គមមនុស្សឡើយ ដែលប្រកបដោយអស្ថិរភាពហិង្សាទោសៈ លោភៈ មោហៈ ។ល។

លើសពីនេះទៅទៀត រូបចម្លាក់ដ៏ស្រស់បស់ មាត់រីកស្ពុះស្ពាយដូចបុប្ផា និងឥរិយាបថដ៏ទន់ភ្លន់របស់ស្រីទេពអប្សរ មានតួនាទីធ្វើឱ្យអ្នកហត់ឈប់ហត់ មានទុក្ខអស់ទុក្ខ អ្នកមានកង្វល់ក្លាយទៅជារីករាយសប្បាយទៅវិញ ព្រោះនៅទីនោះ ដែលជាទេវស្ថាន ហើយដែលមានរូបនាងជាអ្នកបម្រើគឺស្ថានសួគ៌ ។

តាមរយៈរូបចម្លាក់ទាំងឡាយនៅបន្ទាយស្រី ដំបូងឡើយគេគិតថា ប្រពៃណីនិយមត្រចៀកវែង និងពាក់ក្រវិលនៅចុងទងត្រចៀក ជាឥទ្ធិពលនៃវប្បធម៌ឥណ្ឌូណេស៊ី ដោយហេតុថា ជនជាតិដាយ៉ាកជាជនជាតិដើមរស់នៅតាមព្រៃភ្នំ បាឱ្យតម្លៃយ៉ាងខ្ពស់ទៅលើទំនៀមទម្លាប់នេះណាស់ ។ ប៉ុន្តែឥឡូវនេះចំពោះទស្សនៈខាងលើនេះ គេបានផ្លាស់ប្តូរចិត្តគំនិតវិញហើយ ព្រោះថា គេពុំទាន់បានប្រមូលឯកសារ ដើម្បីយកទៅពិគ្រោះពិភាក្សាឱ្យឃើញច្បាស់លាស់

លើបញ្ហានេះនៅឡើយទេ ។

ម្យ៉ាងទៀត មួយរយៈកន្លងមកនេះ គឺរវាងឆ្នាំ១៩៧៣-១៩៩៩ ក្រោយពេលដែលគេបានសិក្សាប្រពៃណីបងប្អូនខ្មែរលើ ដែលរស់នៅតាមដងព្រៃភ្នំ ហើយដែលពុំបានទទួលឥទ្ធិពលនៃវប្បធម៌ អារ្យធម៌ក្លឹង្គ ដូចខ្មែរនៅតាមវាលទំនាប និងឆ្នេរសមុទ្រ គេបានកត់សម្គាល់ថា ការដែលខ្មែរនា១០០០ឆ្នាំមុន ឆ្លាក់ស្រ្តីមានស្នឹកត្រចៀក និងទងត្រចៀកដ៏វែងដល់ថ្ពាល់ ដូច្នេះ ពុំមែនជាការច្នៃដន្យទេ ប៉ុន្តែវាមានអត្ថន័យរបស់វា ។

ទស្សនៈស្ដីពីសម្ផស្សស្រ្តី ឬបុរសក្នុងសង្គមនីមួយៗ មានលក្ខណៈខុសៗពីគ្នា ហើយមានលក្ខណៈប្រែប្រួលទៅតាមយុគ្គសម័យ ពោលគឺអាចផ្លាស់ប្ដូរទម្រង់ ។ ដូចគ្នានេះដែរ តែកាលណាគេឈប់និយមប្រពៃណីណាមួយហើយ ប្រពៃណីនោះ ត្រូវតែរលត់រលាយសាបសូន្យ ដូចការពាក់ក្រវិល ត្រសាលត្រចៀក ដូចជនជាតិខ្មែរយើងពីដើម ។

ចំពោះការដាក់ក្រវិលត្រចៀកវែង យើងគួរគិតថា ជាម៉ូតបុរាណមួយដែលខ្មែរធ្លាប់និយម ដើម្បីលំអខ្លួនប្រាណ ក៏ប៉ុន្តែឥឡូវនេះ វាហួសសម័យទៅហើយៗ គ្រាន់តែមានឆ្លាក់ជាភស្តុតាងនៃការឱ្យតម្លៃរបស់បុព្វការីជន តែប៉ុណ្ណោះ ។

ប្រពៃណីនេះ កើតចេញពីជំនឿវប្បធម៌ស្រុក ដែលមានអាយុច្រើនពាន់ឆ្នាំមកហើយ គឺបានផ្ដើមឡើងនៅសម័យលោហធាតុ រវាង២០០០ឆ្នាំ និង១០០០ឆ្នាំមុនគ.ស. បើយើងសំអាងទៅលើក្រវិលត្រចៀកសិរិទ្ធិ ដែលគេបានរកឃើញនៅក្នុងអត្ថន័យបុរេប្រវត្តិសាស្រ្តជាច្រើន ក្នុងឧបទ្វីបឥណ្ឌូចិនយើងនេះ

ដែលជាទឹកដីរបស់កុលសម្ព័ន្ធមន-ខ្មែរ ។

មួយវិញទៀត មានភស្តុតាងជាច្រើនបញ្ជាក់ថា នៅតំបន់ព្រៃភ្នំ កុលសម្ព័ន្ធខ្មែរយើងច្រើន ជាទូទៅនៅតែនិយមទំនៀមទម្លាប់ពាក់ក្រវិលត្រចៀកសិរិទ្ធិនេះមិនដាច់ តាំងតែពីសម័យបុរេប្រវត្តិសាស្ត្រ រហូតដល់បច្ចុប្បន្ននេះ ហើយការនិយមនេះ ត្រូវធ្វើឡើងចំពោះតែស្ត្រីភេទណាដែលស្តុកស្តម្ភ ឬមានឋានៈខ្ពង់ខ្ពស់ ។ លើសពីនេះទៅទៀត ការនិយមក្រវិលនេះ ពុំមែនធ្វើឡើងដោយឯកឯងនោះទេ ឬក៏ពុំបានប្រារព្ធពិធីនោះដែរ ។

ពិតមែនតែខ្សែភ្នែកយើងសព្វថ្ងៃនេះ ដែលឃើញថា ប្រពៃណីព្ទងនាជំនាន់បុរាណ គេទទួលស្គាល់ថា ទងត្រចៀកកាន់តែវែងសម្ផស្សរបស់ស្ត្រីកាន់តែមានកិរិតខ្ពស់ ទន្ទឹមនឹងនេះដែរ កិត្តិនាមរបស់ស្ត្រីនោះកាន់តែធំ ។

ឆ្លងតាមការស្រាវជ្រាវខាងលើបានឱ្យដឹងថា ថ្វីដ្បិតតែចំណាស់គួរឱ្យមោទនភាពនៃប្រពៃណីរបស់ជាតិយើង បានរលត់បាត់ទៅហើយក៏ដោយ ក៏ប៉ុន្តែនៅសល់ភស្តុតាងជាច្រើន ដែលបង្ហាញនូវចំណាស់វប្បធម៌របស់ជនជាតិខ្មែរ ដែលមានការវិវឌ្ឍន៍ពីសម័យមួយទៅសម័យមួយយ៉ាងពិតប្រាកដ ។

## ៦-ត្រសាលត្រចៀករបស់ជនជាតិខ្មែរ

នៅដើមស.វ.ទី១នៃគ.ស. ជនជាតិខ្មែរមួយភាគធំរស់នៅតាមវាលទំនាបដែនដីសណ្ត ព្រមទាំងឆ្នេរ និងឈូងសមុទ្រសៀមជាដើម បានស្ថិតក្រោមឥទ្ធិពលវប្បធម៌យ៉ាងខ្លាំងក្លានៃពួកឥណ្ឌា ដែលមករកស៊ីជួញដូរជាមួយខ្មែរ ។ ដោយសារបានទទួលឥទ្ធិពលពីឥណ្ឌា (ក្លឹង្គ) បន្តជាច្រើនស.វ. ក្រោមមកទៀត ស្ត្រីខ្មែរមួយភាគធំនៅតាមជនបទ នៅតែបន្តការនិយមប្រើប្រាស់ត្រសាលពាក់

ត្រចៀក ដែលពួកគេចាត់ទុកថា ជាគ្រឿងអលង្ការសម្រាប់លំអខ្លួនប្រាណ ។

តាមប្រភពឯកសារប្រវត្តិសាស្ត្របានឱ្យដឹងបន្ថែមទៀតថា នៅដើម ស.វ.ទី១នៃគ.ស.នោះហើយ ដែលសង្គមខ្មែរបានខ្ចីវប្បធម៌ អារ្យធម៌ក្លិង្គ ដើម្បីអភិវឌ្ឍសង្គមរបស់ខ្លួនដោយជោគជ័យជាស្ថាពរ ខុសពីជនជាតិមួយចំនួនផ្សេងទៀត ដែលរស់នៅតាមខ្ពង់រាប ឬព្រៃភ្នំ ហើយពួកគេពុំមានទំនាក់ទំនងជាមួយជនជាតិក្លិង្គ ។

ដូចប្រវត្តិសាស្ត្រខាងលើនេះ បានជាសំណង់សង្គមដើមរបស់គេ ពុំបានកែប្រែ ឬអភិវឌ្ឍតាមរបៀបក្លិង្គឡើយ ជាហេតុបណ្តាលឱ្យអ្នកប្រាជ្ញប្រវត្តិសាស្ត្រម្នាក់ គឺលោកហ្សកសឺដេសសរសេរនៅឆ្នាំ១៩៦៥ ថា "ខ្មែរជាពួង" ដែលបានទទួលវប្បធម៌ អារ្យធម៌ពីក្លិង្គ ឬឥណ្ឌូបនីយកម្ម ។

បើនិយាយឱ្យចំទៅ ចំពោះអ្នកស្រាវជ្រាវខាងលើនេះ ខ្មែរជាជនជាតិកើតនៅលើដីឥណ្ឌូចិននេះ បានតពូជពង្សរហូតមកដល់សព្វថ្ងៃនេះ ពីបុព្វបុរសដែលបានកាន់កាប់ភូមិភាគនេះ តាំងពីមុនសម័យបុរេប្រវត្តិសាស្ត្រ ។

ផ្អែកលើសៀវភៅប្រវត្តិសាស្ត្របានឱ្យដឹងថា មុនការបង្កើតព្រះរាជាណាចក្រភ្នំ ខ្មែរនិងខ្មែរលើ គឺជាជនជាតិតែមួយ ។ ក្រោមអានុភាពវប្បធម៌បរទេស សង្គមខ្មែរ-មនបុរាណ បានផ្លាស់ប្តូរទ្រង់ទ្រាយបន្តិចម្តងៗ ពីលក្ខណៈកុលសម្ព័ន្ធ ដែលគ្មានអំណាចកណ្តាលទៅជារបបរាជានិយម ដោយមានស្តេចជាប្រមុខ ព្រាហ្មណ៍បុរោហិត ព្រះសង្ឃ សព្វមុខនាម៉ឺនមន្ត្រី ដែលជាមែកធាងនៃរចនាសម្ព័ន្ធថ្មី ។

តែទោះបីជាយ៉ាងនេះក្តី ក៏ជនជាតិខ្មែរ ដែលកាន់កាប់វប្បធម៌ក្លិង្គ នៅ

តែរក្សាដដែលនូវទំនៀមទម្លាប់ប្រពៃណីមួយចំនួន ដែលមានតាំងពីមុនសម័យក្លិង្គចូលស្រុកបានយ៉ាងខ្ជាប់ខ្ជួន ដូចជាការនិយមប្រើត្រសាល់ត្រចៀកសម្រាប់ការលំអរ ជាគ្រឿងអលង្ការពាក់ត្រចៀកមនុស្សទាំងពីរភេទ ។

ការស្រាវជ្រាវបានបញ្ជាក់បន្ថែមទៀតថា ឫសគល់នៃជនជាតិខ្មែរយើងបានរួមពូជសាសន៍ និងវប្បធម៌ អារ្យធម៌ជាមួយបងប្អូនជនជាតិខ្មែរលើ ។ ថ្វីដ្បិតតែកុលសម្ព័ន្ធខ្មែរលើសព្វថ្ងៃនេះ បានក្លាយខ្លួនទៅជាជនជាតិភាគតិច ដែលរស់នៅពាសពេញដេរដាសត្រង់នេះបន្តិចត្រង់នោះបន្តិច ក្នុបឧបទ្វីបឥណ្ឌូចិន ដោយសារតែគ្មានអំណាចកណ្តាលដូចខ្មែរយើងក៏ដោយ ហើយមិនបានរួបរួមក្រោមការដឹកនាំរបស់ព្រះមហាក្សត្រ ក៏ពួកគេនៅមានតួនាទីសំខាន់បំផុតក្នុងវិស័យវប្បធម៌ អារ្យធម៌ខ្មែរ ។

ដោយហេតុថា វប្បធម៌ អារ្យធម៌កើតចេញពីវប្បធម៌ខ្មែរលើ ដែលមានតាំងពីសម័យបុរេប្រវត្តិសាស្ត្រមកម្ល៉េះ ។

## ៧-ការនិយមកងដៃ កងជើងរបស់កុលសម្ព័ន្ធ និងខ្មែរនាសម័យអង្គរ

បើយើងពិនិត្យមើលទិដ្ឋភាពជាទូទៅ ក្នុងសង្គមកុលសម្ព័ន្ធខ្មែរលើដែលរស់នៅតាមព្រៃភ្នំនៃខេត្តរតនៈគិរីជាដើម យើងសង្កេតឃើញថា ក្រុមកុលសម្ពន្ធខ្មែរលើទាំងនោះ ចូលចិត្តនិយមកងដៃ ឬកងជើង ដែលគេចាត់ទុកថាជាប្រពៃណីមួយខកខានពុំបាន ។ មតិកវប្បធម៌បរមបុរាណនេះ ដែលត្រូវបានប្រសូត្រឡើងនៅសម័យលោហធាតុ ពោលគឺនៅសម័យបុរេប្រវត្តិសាស្ត្រយ៉ាងហោចណាស់ ក៏មានអាយុប្រមាណជា៣០០០ឆ្នាំមកហើយដែរ កំពុងពេញ

និយម ពិសេសក្រមុំព្រៃភ្នំខ្មែរលើតែម្តង ។

គួរកត់សម្គាល់ផងដែរថា ចំពោះកងដៃ កងជើងដែលជាគ្រឿងអលង្ការខាងលើនេះ គឺឪពុកម្តាយ ឬក៏យាយតាដែលជាអ្នកផលិត ដើម្បីលំអរខ្លួនប្រាណរបស់ចៅ កូនស្រីខ្លួនផ្ទាល់ ពិសេសនៅពេលដែលពួកគេពេញរូបពេញរាង ឬក៏ក្លាយខ្លួនជាក្រមុំ ។

ដោយពឹងផ្អែកលើការសិក្សា យើងដឹងថា កងដៃ កងជើងទាំងនោះដែលគេពាក់ផ្គុំគ្នានៅដៃទាំងពីរ ឬជើងទាំងពីរ សុទ្ធសឹងតែធ្វើអំពីស្ពាន់ ឬដែកមានរង្វង់កងច្រើនលើសពីមួយ គឺ២០-៣០រង្វង់ក៏មាន ហើយចំនួនរង្វង់ពាក់ព័ន្ធនិងឋានៈ ឬភាពធូធាររបស់អ្នកពាក់ ។ រីឯទំហំរបស់រង្វង់កងដៃ កងជើងទាំងនោះ មានទំហំខុសៗគ្នា ។ កងដៃ ឬកងជើង " មានរង្វង់កងមួយៗ ដាច់ដោយឡែកៗពីគ្នា ហើយវាមានទំហំខុសៗគ្នា ដោយចាប់ផ្តើមចេញពីកងដៃតូចនៅត្រង់កដៃ (ឬកជើង) រួចហើយពង្រីកទៅធំនៅត្រង់កំភួនដៃ (ឬជើង) ដោយដាក់ត្រួតគ្នា " ។ (cf លី គិរីសមុទ្រ កងដៃមតិករបស់ស្រីព្រៃភ្នំ. រស្មីកម្ពុជា ថ្ងៃសុក្រទី៤ សីហា ឆ្នាំ១៩៩៥) ។

ទន្ទឹមគ្នានិងនេះផងដែរ សោភ័ណភាពគេអាចនឹងសំលឹងឃើញចំណុចសំខាន់មួយទៀតនៅពីក្រោយនេះ គឺកងដៃទាំងនោះ ជាគ្រឿងអលង្ការឬបញ្ចៀសនូវរាល់អំពើឧបទ្រពចង្រៃ ដែលអាចនឹងមកបៀតបៀនយាយីអ្នកពាក់ ។ ភាពពិសិដ្ឋរបស់គ្រឿងអលង្ការនេះ អាចឆ្លុះបញ្ចាំងតាមរយៈ "ការផ្ទុំផ្សែងឱ្យជះទៅលើកងដៃ (កងជើង) ទៀតផង ដើម្បីឱ្យកូនស្រីរីយក្រមុំរស់នៅត្រជាក់ត្រជុំ បានយូរអង្វែងតរៀងទៅ និងទៅណាមកណាមានគេនិយម

ចូលចិត្តរាប់អានគ្រប់ៗគ្នា" ។

មិនតែប៉ុណ្ណោះសោត ក្នុងសង្គមខ្មែរលើ គេក៏អាចសង្កេតកត់សម្គាល់ឃើញថា ជនជាតិខ្មែរលើក៏បានចាត់ទុកថា កងដៃ ឬកងជើងទាំងនោះ ជាវត្ថុមានតម្លៃបំផុតដែរ ហើយក៏ជាអត្តសញ្ញាណប្រចាំត្រកូលនីមួយៗ ថែមទៀតផង ។ តាមការជាក់ស្តែងកងដៃកងជើងទាំងនោះ ត្រូវគេពាក់តៗគ្នាជាច្រើនសម័យ ឬជំនាន់ ដោយមិនដាច់ ។ និរន្តរភាពនៃការនិយមកងដៃ កងជើងនេះត្រូវបានគូសបញ្ជាក់តាមរយៈចម្លាក់បុរាណនៅលើប្រាសាទបាយ័ន ដែលគេបានជួបប្រទះជាភស្តុតាងស្រាប់ ។

ម្យ៉ាងវិញទៀត ពួកខ្មែរសព្វថ្ងៃនេះ ក៏នៅតែពាក់កងដៃកងជើងដែរ ថ្វីដ្បិតតែប្រពៃណីនេះ កំពុងត្រូវបានគេឈប់ប្រើប្រាស់ជាបណ្តើរៗ ហើយក៏ដោយ ក៏ប៉ុន្តែទង្វើនេះ បានបង្ហាញនូវប្រវត្តិសាស្ត្រដ៏យូរលង់នៃប្រពៃណីមួយដែលផ្សារភ្ជាប់រចនាសម្ព័ន្ធខ្មែរ និងខ្មែរយ៉ាងជាក់ស្តែង ពោលគឺប្រភពរួមនៃឌឿនវប្បធម៌ ។

## ៨-បំពង់ជារបស់ប្រើប្រាស់ប្រចាំថ្ងៃសម្រាប់ខ្មែរបុរាណ

ជនជាតិខ្មែរធ្លាប់មានវប្បធម៌ និងអារ្យធម៌ដ៏ខ្ពង់ខ្ពស់ ដោយបានជះឥទ្ធិពលដ៏ល្បីល្បាញសុសសាយនៅក្នុងឧបទ្វីបឥណ្ឌូចិន តាំងពីសម័យមុនអង្គរនិងអង្គរវត្តមកម្ល៉េះ ។ ប៉ុន្តែការរក្សាប្រពៃណីមួយចំនួន ដែលមានលក្ខណៈបុរាណ ដូចជាការប្រើបំពង់សម្រាប់បឺតស្រា ឬផឹកទឹក ដែលខ្មែរបុរាណមានការនិយមនាសម័យអង្គរ និងបន្តមកក្រោយសម័យអង្គរទៀតនោះ ក៏បងប្អូនខ្មែរកុលសម្ព័ន្ធនៅបន្តប្រើរហូតមកដល់បច្ចុប្បន្ននេះ ។

ថ្វីដ្បិតតែជនជាតិខ្មែរមានគំនិតច្នៃប្រឌិតដ៏ចំណាន ដូចសម័យមហានគរភ្នំ ដែលខ្មែរមានអារ្យធម៌ខ្ពស់កប់កំពូលក៏ដោយ ក៏ខ្មែរនៅតែរក្សាប្រពៃណីមានលក្ខណៈបុរាណ ហាក់ដូចជាពុំបានទទួលឥទ្ធិពលពីណាឡើយ ។ តាមពិតទៅក្រុមកុលសម្ព័ន្ធខ្មែរលើ ពោលគឺខ្មែររស់នៅតាមព្រៃភ្នំ ដែលពុំបានទទួលឥទ្ធិពលវប្បធម៌ឥណ្ឌា ឬចិនមែន ។

ប្រពៃណីរបស់ពួកគេដូចជាលៀងអារ័ក្ស ពិធីបូជាក្របីជាដើម គេនៅតែប្រើប្រាស់បំពង់ដើម្បីផឹកស្រា ឬផឹកទឹក ដែលបានបន្តរហូតមកដល់បច្ចុប្បន្ននេះទៀតផង ។

នៅក្នុងការស្រាវជ្រាវរបស់យើងបញ្ជាក់ឱ្យដឹងថា តាមចម្លាក់ប្រាសាទបាយ័នបានបង្ហាញឱ្យយើងដឹងថា បុព្វបុរសយើងនៅសម័យអង្គរ បានរក្សាទំនៀមទម្លាប់ផឹក ឬបឺតស្រាដោយបំពង់ តាមបែបជនជាតិពួកងដែរ ដែលខុសពីសម័យបច្ចុប្បន្ន ប៉ុន្តែទំនៀមទម្លាប់នេះ បានសាបសូន្យស្ទើរតែអស់ទម្រង់ដើមហើយ ដោយគេប្រើបំពង់ផ្លាស់ស្ទិចជាជំនួសវិញ ដែលធ្វើតាមបែបអឺរ៉ុប ។

ឯបុព្វបុរសយើងនាសម័យអង្គរ មានប្រពៃណីដូចបងប្អូនកុលសម្ព័ន្ធពួងសព្វថ្ងៃនៅប្រទេសកម្ពុជា ឡាវ និងវៀតណាមកណ្ដាលផងដែរ ដោយសារតែខ្មែរ គឺជនជាតិរួមពូជសាសន៍ជាមួយបងប្អូនកុលសម្ព័ន្ធខ្មែរលើ ។

តែទោះជាយ៉ាងណាក៏ដោយ ក៏ទំនៀមទម្លាប់ផឹកស្រា ឬផឹកដោយប្រើបំពង់បែបខ្មែរ សម័យអង្គរត្រូវបងប្អូនរួមជាតិភាគតិចបានប្រើប្រាស់រហូតមកដល់សព្វថ្ងៃនេះ ។ នេះជាការសបញ្ជាក់ឱ្យឃើញថា បងប្អូនកុលសម្ព័ន្ធនៅតែអនុវត្តន៍តាមប្រពៃណីរបស់ខ្លួននៅឡើយ ដោយពុំមានការការភិវឌ្ឍចំពោះ

សម្ភារៈប្រើប្រាស់របស់ពួកគេប៉ុន្មានឡើយ ។

## ៩.ជំនឿលើជីវចល

នៅពេលអ្នកណាម្នាក់បានមើលឃើញប្រាសាទអង្គរវត្ត ហើយបើពិនិត្យឱ្យស៊ីជម្រៅបន្តិច គេនឹងឃើញរូបសម្លាក់នៅលើជញ្ជាំងនេះ ជាក្បួនទ័ពក្នុងសង្គ្រាម ។ ក្នុងចំណោមក្បួនទ័ព ដែលកំពុងច្បាំងនិងទ័ពយួន (ដាវវៀត) និងទ័ពច្បាំងទាំងនេះ ត្រូវបានដឹកនាំដោយមេទ័ពម្នាក់ពាក់ក្បាំងជារូបស្នែង ។

ចំពោះអ្នកស្រាវជ្រាវបានឱ្យដឹងថា ការដែលមេទ័ពខ្មែរនាស.វ.ទី១២ពាក់ក្បាំងរូបប្រើសបែបនេះ មិនមែនជារូបភាពល្អមើល ឬចៃដន្យឡើយ វាមានអត្ថន័យ ធ្វើឱ្យមេទ័ពនោះអង់អាចក្លាហានដូចជាសត្វប្រើស ។

សិល្បករបុរាណបានឆ្លាក់រូបភាពនេះ បញ្ជាក់ពីគុណសម្បត្តិនិង សេចក្តីក្លាហានរបស់បុគ្គលមេទ័ពដ៏ចំណាន ។ សូមបញ្ជាក់ថា មេទ័ពធម្មតា ដែលពុំបានទទួលជ័យជំនះ គេមិនពាក់ស្នែងប្រើសនៅលើក្បាលទេ ។ នេះជាជំនឿលើជីវចល ។

សញ្ញាក្បាលប្រើសមានស្នែង អាចជាសត្វតំណាងឱ្យបុព្វការីជន ដែលគេចាត់ទុកសត្វប្រើសជាសត្វប្រចាំត្រកូលមេទ័ព ដ៏ខ្លាំងក្លាពូកែ ។

បច្ចុប្បន្ន ជំនឿជីវចលត្រូវបានគេប្រមូលផ្តុំតែចំពោះអ្នកស្រុកអាចជាខ្មែរលើ ម្យ៉ាងទៀតជំនឿខាងលើនេះ បានធ្លាក់ចុះដោយសារឥទ្ធិពល វប្បធម៌ឥណ្ឌា ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ជំនឿលើជីវចលនៅពុំទាន់រលត់នៅឡើយ ។

ឧទាហរណ៍មួយជាក់ស្តែង ជនជាតិខ្មែរនៅប្រទេសកម្ពុជា ក៏ដូចជានៅ

ព្រំប្រទល់បច្ចុប្បន្ន នៅតែចាត់ទុកថា ស្នែងប្រើស ស្នែងខ្ទីង រមាស រមែងមាន អំណាចពិសេស អាចជួយការពារពួកគេបាន ជាហេតុបណ្ដាលឱ្យគេមានស្នែង សត្វទាំងនោះតុបតែងផ្ទះសម្បែងរបស់គេ ។ ទង្វើនេះ មិនមែនគ្រាន់តែលំអរ ប៉ុណ្ណោះទេ ក៏ប៉ុន្តែកើតចេញអំពីមូលដ្ឋានជំនឿសាសនាយ៉ាងប្រាកដ ព្រោះមាន លក្ខណៈសាកល ។

## ១០.ហេតុអ្វីប្រជាជនខ្មែរមានជំនឿលើខ្នាយតាន់ជ្រូកព្រៃ ?

ប្រជាជនខ្មែររស់នៅក្នុងខេត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជា រួមមាន ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ពោធិសាត់ ក៏ដូចគ្នានិងប្រជាជនខ្មែរ ដែល រស់នៅក្នុងខេត្តសុរិន្ទ ស៊ីសាកេត និងខេត្តបុរីរម្យក្នុងប្រទេសថៃនាពេល បច្ចុប្បន្ននេះដែរ ពួកគេនៅតែមានជំនឿថា ខ្នាយតាន់របស់ជ្រូកព្រៃ គឺជាវត្ថុ ស័ក្តិសិទ្ធិ ដែលនាំមកនូវសិរីមង្គល និងសេចក្តីសុខចម្រុងចម្រើន ។

ជំនឿលើខ្នាយតាន់ជ្រូកព្រៃ ក៏កើតមានទៅដល់ប្រជាជនខ្មែរភាគតិច ដែលរស់នៅតាមច្រករបៀងនៃព្រំដែនខ្មែរ-ឡាវផងដែរ ។ ជនជាតិខ្មែរលើ ទាំងនេះ មានដូចជាពួកទំពួន, ព្នង, និងស្ទៀងជាដើម ដែលភាគច្រើននៃពួក នេះ ពាក់ខ្នាយតាន់ជ្រូកព្រៃជាប្រចាំថ្ងៃទៀតផង ។

ការនិយមមានជំនឿលើខ្នាយតាន់ជ្រូកព្រៃរបស់ប្រជាជនខ្មែរ ស្ទើរ តែជាទូទៅក៏ដោយ ក៏គេនៅតែមានជំនឿខ្លាំងជាងគេ គឺខ្នាយតាន់ជ្រូកព្រៃនៅ តំបន់ជួរភ្នំដងរែក ។ ជួរភ្នំដងរែកជាតំបន់អាថិកំបាំង ដែលគេយល់ថា ជាកន្លែង រស់នៅដ៏សុខសាន្តរបស់សត្វជ្រូកព្រៃ ព្រោះនៅទីនោះ មានសម្បូរចំណីអាហារ ដ៏គាប់ចិត្តរបស់ហ្វូងជ្រូក គឺមើមដំឡូងព្រៃ ។

តាមការស្រាវជ្រាវបានឱ្យដឹងថា ជ្រូកព្រៃមានទម្លាប់រស់នៅជាហ្វូង១ របស់វា ។ នៅក្នុងហ្វូងជ្រូកព្រៃនីមួយ១ គេឃើញមានមេហ្វូងមួយជាជ្រូកឈ្មោល ដែលមិនត្រឹមតែមានមាឌធំហើយខ្លាំងជាងគេទេ វាថែមទាំងកាចសាហាវទៀតផង ។ នៅក្នុងខណៈពេលដែលមានកូនជ្រូកព្រៃទើបនឹងកើតមក មេហ្វូងជ្រូកព្រៃដ៏កាចសាហាវខ្លាំងនេះ សម្លាប់នូវកូនជ្រូកឈ្មោលណាដែលវាទទួលស្គាល់ថា មានមហិទ្ធិរិទ្ធិដូចវា ។

អ្នកស្រុករស់នៅតំបន់ជួរភ្នំដងរែកបានឱ្យដឹងថា ការបំផ្លាញកូនខ្លួនឯងដូច្នេះ បណ្តាលមកពីមេហ្វូងខ្លាចក្រែងកូនឈ្មោលនៅក្នុងហ្វូងនោះ និងដណ្តើមអំណាចធ្វើជាមេហ្វូងទៅថ្ងៃក្រោយ ។

ទម្លាប់របស់ជ្រូកព្រៃនេះ ពុំមែនជារឿងចៃដន្យនៅក្នុងសង្គមសត្វដែលធ្វើឱ្យមានការរន្ធត់ចិត្តនោះទេ តែនេះជាច្បាប់ធម្មជាតិ ។

ពេលមេហ្វូងជ្រូកព្រៃជិតស្លាប់ ទើបវាទុកកូនឈ្មោលណា ដែលប្រកបដោយលក្ខណៈសម្បត្តិរឹងមាំ មានដុះខ្នាយវែងជាងគេបន្តិច ដើម្បីទុកឱ្យដឹកនាំហ្វូងជ្រូកព្រៃជាបន្តពីវាទៀត ។ ចំពោះមេហ្វូងជ្រូកព្រៃដល់ពេលវាចាស់ជរាខ្លាំងទៅ វាដើរទៅរកកន្លែងណាស្ងាត់ និងមានដើមឈើផង ដើម្បីយកខ្នាយគាន់របស់វាទាំងពីរទៅកាច់បំបាក់ទុកបង្កប់ចោលនៅនឹងដើមឈើនោះ ។

មហិទ្ធិរិទ្ធរបស់ខ្នាយគាន់នៅត្រង់ថា បារមី ឬវត្ថុស័ក្តិសិទ្ធិជាពន្លឺនៅលើថ្ងាសជ្រូកព្រៃ ដែលតាមថែរក្សាគាំពារជានិច្ចកាល ។ បារមីនេះឯង ដែលពិបាកនឹងមាននរណាមួយអាចសម្លាប់វាដោយងាយ១បានឡើយ ។ ហេតុដូច្នេះហើយ ប្រជាជនខ្មែរនៅតាមតំបន់ព្រៃភ្នំដងរែក និងតំបន់ខ្ពង់រាបដទៃទៀតមានជំនឿ

ថា អ្នកដែលរើសបានខ្នាយតាន់ជ្រូកព្រៃយកមកពាក់ គឺគេនឹងមានសេចក្តីសុខសិរីសួស្តីជាពុំខាន ។ បារមីនៃខ្នាយតាន់នេះ និងនៅរក្សាការពារមិនឱ្យសត្រូវជិតឆ្ងាយណាមកបៀតបៀន ឬយកឈ្នះលើខ្លួនគេបានឡើយ ។

អ្នកមានខ្នាយតាន់ជ្រូកព្រៃ គេតែងតែកាន់គ្រណាមមួយចំនួនឱ្យបានខ្ជាប់ខ្ជួន គួបផ្សំនឹងមន្តអាគមជាបន្ថែមទៀតផងនោះ ដែលកាន់តែធ្វើឱ្យខ្នាយតាន់ជ្រូកព្រៃមានបារមីកាន់តែខ្លាំងក្លាថែមទៀត ។

ចំពោះបងប្អូនជនជាតិខ្មែរលើក៏មានជំនឿដូចគ្នានេះដែរ ។ គេបានចាត់ទុកជំនឿនេះ ជាទំនៀមទម្លាប់ និងប្រពៃណីប្រចាំជនជាតិផងដែរ ។ គេយល់ថា បារមីខ្នាយតាន់ជ្រូកព្រៃសម្រាប់ជួយការពារ និងសត្វព្រៃដ៏កាចសាហាវផ្សេងៗ ឬអាវុធ ដូចជាព្រួញសរជាដើម ។ ដោយហេតុថា នៅតំបន់ព្រៃភ្នំពុំមានគ្រាប់កាំភ្លើង ឬជាតិផ្ទុះឡើយ ។

សរុបសេចក្តីមក ជំនឿលើខ្នាយតាន់ជ្រូកព្រៃរបស់ជនជាតិខ្មែរយើងអាចឆ្លុះបញ្ចាំងឱ្យឃើញថា ទស្សនៈរបស់មនុស្សពេលប្រឈមមុខនិងគ្រោះកំណាចណាមួយ គេមានប្រាថ្នាតែសេចក្តីសុខ និងភាពត្រជាក់ត្រជុំតែប៉ុណ្ណោះ ។ ហើយជំនឿនេះ ក៏ជាមែកធាងនៃខឿនវប្បធម៌ និងអារ្យធម៌របស់ជនជាតិមួយផងដែរ ។

គប្បីជម្រាបផងដែរថា ចំពោះខ្មែរសុរិន្ទ្របុរីរម្យសព្វថ្ងៃ ឆ្អឹងថ្គាមខ្នាយនិងឈាមសត្វព្រៃមួយចំនួន មានតួនាទីយ៉ាងសំខាន់ក្នុងការក្សារោគ ឬជំងឺ ។ ឧទាហរណ៍ គេយកថ្គាមដំរីទៅដុះនិងថ្មហើយស្រង់ទឹកយកទៅបរិភោគដើម្បីការពារពុលថ្នាំ និងធ្វើឱ្យត្រជាក់ខ្លួនប្រាណ ។ ខ្នាយដំរីនិងខ្នាយជ្រូកតាន់

វិញ គេប្រើសម្រាប់កែក្ដៅខ្លួនដែរ ។ ឆ្អឹងត្មាត និងឆ្អឹងអកកែរោគគ្រុនញាក់រវើរវាយ និងកែស្ត្រីដែលសម្រាលកូនមិនចេញដូចប្រក្រតី ។ ជួនកាលគេក៏យកឈាមរមាសដើម្បីកែក្រំ និងជាំ ខ្ទរ ពេលដែលធ្លាក់ពីខ្នងដំរី ឬដើមឈើជាដើម ។ ចំពោះចង្កូមខ្លា គេយកមកដាក់ពាក់ជាបន្តោងនៅក ដើម្បីការពារនិងសត្វព្រៃ ហើយបើចង្កូមខ្លានោះមានប្រហោង វាកាន់តែមានប្រសិទ្ធិភាព ព្រោះព្រាយបីសាចភ័យខ្លាចណាស់ ។

តើមនុស្សនៅភូមិស្នាយ មានជំនឿដូចនៅខាងលើនេះដែរឬទេ ? ចំពោះចម្លើយនិងសំណួរនេះ តាមការស្រាវជ្រាវសិក្សាប្រៀបធៀបរបស់យើងបានឱ្យដឹងថា អ្វីដែលទើបពោលខាងលើ មិនខុសប្លែកនិងជំនឿរបស់សហគមន៍ខ្មែរនៅភូមិស្នាយប៉ុន្មានឡើយ ។ ដោយហេតុថា សំណល់វប្បធម៌ជាវត្ថុបុរាណជាច្រើន ដូចជាឆ្អឹង ចង្កូមសត្វ ដែលគេកប់ជាមួយសព ពុំមែនជាការចៃដន្យទេ ក៏ប៉ុន្តែ ទាំងអស់នេះឆ្លើយតបតាមជំនឿប្រពៃណីរបស់មនុស្សខ្មែរនាសម័យបុរេប្រវត្តិសាស្ត្រយ៉ាងពិតៗ ។

## ១១-ពិធីបូជាក្របី

នៅលើជញ្ជាំងប្រាសាទបាយ័ន ដែលព្រះបាទជ័យវរ្ម័នទី៧បានស្ថាបនាឡើង ដើម្បីឧទ្ទិសដល់ព្រះអវលោកេស្វរៈ ដែលជាព្រះពោធិសត្វដ៏សំខាន់បំផុតនៃលទ្ធិព្រះពុទ្ធសាសនាមហាយាននៅចុងស.វ.ទី១២ និងដើមស.វ.ទី១៣ នៃគ.ស. គេបានឃើញរូបចម្លាក់បុរាណមួយល្អប្រណិត បង្ហាញពីការបូជាក្របី ។

ការបូជាក្របីនេះ ជាពិធីបូជាយ៉ាងធំបំផុតសម្រាប់មនុស្សខ្មែរជំនាន់នោះ ជាពិសេស សម្រាប់មេទ័ពប្រារព្ធឡើងមុនពេលចេញទៅសមរភូមិ ឬទៅ

ច្បាំងជូនចំពោះវិញ្ញាណក្ខន្ធបុព្វបុរស ដើម្បីសុំនូវសិរីមង្គល និងជ័យជំនះទៅលើបច្ចាមិត្ត ។ ការបូជាក្របី ក៏ជាពិធីពិសិដ្ឋមួយ ដើម្បីប្រមូលផ្តុំកម្លាំងថាមពលប្រឈមមុខនិងសត្រូវ ដែលគេប្រព្រឹត្តមុនពេលចេញទៅធ្វើសង្គ្រាម ដោយមានការប្រជុំគ្នាយ៉ាងអធិកអធ៌មជុំវិញការសម្លាប់ក្របី ។

តាមរយៈទំនៀមទម្លាប់របស់បងប្អូនខ្មែរលើ ដែលបានតពូជពង្សពីសម័យបុរេប្រវត្តិសាស្ត្រ ដូចជាពួករដែ, ស្ទៀង, និងឃ្នុ (ដូចពួកព្នង) ស្ថិតនៅក្នុងអម្បូរមន-ខ្មែរ បានឱ្យដឹងថា ក្រោយពិធីបូជាក្របីរួច គេបែងចែកសាច់ទៅតាមមនុស្សរួមអាវុធ ឬរួមលោហិត ដើម្បីយកទៅបរិភោគ ហើយជួនកាលត្រូវច្រៀងរាំយ៉ាងសប្បាយ ដើម្បីសេចក្តីអង់អាចឡើង ។

ទំនៀមទម្លាប់នេះ ខ្មែរយើងសព្វថ្ងៃឈប់និយមហើយ ព្រោះគេចាត់ទុកថាហួសសម័យ គួបសផ្សំនិងតម្លៃយ៉ាងខ្ពស់របស់សត្វ ដែលគេពិបាករកដោយងាយ ប៉ុន្តែបងប្អូនតាមព្រៃភ្នំខ្ពង់រាបនៅនិយមខ្លះ ។

ម្យ៉ាងវិញទៀត ការបូជាក្របីនៅសម័យបាយ័ន មានកំណើតយូរយាណាស់មកហើយ ដូចមានចម្លាក់ប្រាសាទបាយ័នជាសក្ខីភាពស្រាប់ ។ ទំនៀមទម្លាប់ប្រជាប្រិយខ្មែរនេះ និងទំនៀមទម្លាប់ពួកខ្មែរលើបានកើតចេញពីពុម្ពវប្បធម៌តែមួយ ដែលបានបដិសន្ធិឡើងនៅសម័យបុរេប្រវត្តិសាស្ត្រ ។

ហេតុដែលនាំឱ្យអ្នកស្រាវជ្រាវខ្មែរសន្និដ្ឋានថា ជាសំណង់វប្បធម៌បុរេប្រវត្តិសាស្ត្រ ព្រោះគេបានជួបប្រទះនូវលលាដិក្បាល និងឆ្អឹងក្របីតាមស្ថានីយបុរេប្រវត្តិសាស្ត្រជាច្រើន ។

ម្យ៉ាងទៀត ជួនកាលនៅសម័យប្រវត្តិសាស្ត្រនគរភ្នំ ពីស.វ.ទី១ដល់

ទី៦នៃគ.ស. គេតែងតែឃើញនូវស្នាកស្នាមនៃពិធីបូជាក្របីនោះ ដូចជាឆ្អឹងដែលគេចោលក្នុងអណ្តូង ឬកប់ក្នុងដី ឬស្ថានីយនានានៅក្នុងស្រុកអង្គរបុរីជាដើម ។ សរុបសេចក្តីមក វត្តមាននៃពិធីបូជាក្របីនៅលើជញ្ជាំងប្រាសាទខ្មែរ ជាវត្ថុសញ្ញាមួយបង្ហាញនូវចំណាស់ ក៏ដូចជាភាពសំយោគរបស់វប្បធម៌ អារ្យធម៌ខ្មែរដែរ ។

## ១២_ប្រភពលំពែង និងធ្នូ

ទាំងខ្មែរលើ ទាំងខ្មែរកណ្តាល សុទ្ធតែជាពូជពង្សលើទឹកដីប្រវត្តិសាស្ត្រនៃឥណ្ឌូចិន ជាជនជាតិរួមពូជសាសន៍តែមួយ ក៏ប៉ុន្តែជនជាតិខ្មែរបានបែកចេញពីកុលសម្ព័ន្ធអស់រយៈពេល២០០០ឆ្នាំមកហើយ ដោយឥទ្ធិពលវប្បធម៌ឥណ្ឌា ឬក្លិង្គ ។ បើនិយាយម្យ៉ាងទៀត ជនជាតិខ្មែរខុសពីពួកប្រវេសន៍ថៃ-វៀត គឺជាអ្នកស្រុកដើម ទទួលឥទ្ធិពលវប្បធម៌អារ្យធម៌ឥណ្ឌានាដើមស.វ.ទី១នៃគ.ស. ។

ថ្វីបើខឿនវប្បធម៌ដើមជនជាតិខ្មែរវិវត្តន៍២០០០ឆ្នាំ ខុសប្លែកពីពួងក៏ដោយ ក៏ប៉ុន្តែពួកគេរក្សាទម្រង់វប្បធម៌បរមបុរាណខ្លះ ដែលធ្លាប់មានតាំងតែមុនការហូរចូលនៃវប្បធម៌ឥណ្ឌាម្ល៉េះ ។ ដូចជាអាវុធមួយចំនួន ដូចជាលំពែង ធ្នូ ផ្គាក់ជាដើម ដែលជាអាវុធមានសារសំខាន់បំផុតសម្រាប់ការពារខ្លួន ត្រួសត្រាយផ្លូវនិងឆ្ការព្រៃ ។ល។

យោងទៅលើដើមកំណើតរួមគ្នារវាងខ្មែរនិងកុលសម្ព័ន្ធខ្មែរលើ គឺមានប្រភពតែមួយទេ ក្នុងការប្រើអាវុធ លំពែង ធ្នូ កើតចេញពីសម័យបុរេប្រវត្តិសាស្ត្រ ។ ដូច្នេះហើយ បានជាគេឃើញមានចម្លាក់ចម្លាក់លំពែងធ្នូមាន លក្ខណៈជារបស់ពួង ឆ្លាក់តាមប្រាសាទបុរាណខ្មែរនាសម័យមុនអង្គរ និងអង្គរ ។

## ១៣-ប្រភពនៃផ្គាក់ខ្មែរ

ជាទូទៅអ្នកធ្វើដំណើរទៅតំបន់ព្រៃភ្នំ ឬតាមតំបន់ខ្ពង់រាបនៃប្រទេសខ្មែរ ថៃ និងវៀតណាមខាងត្បូង រមែងតែងជួបអ្នកស្រុកប្រើកាំបិតផ្គាក់ជាប់និងខ្លួន ។ តើការនិយមប្រើកាំបិតផ្គាក់នេះ កើតឡើងតាំងពីពេលណាមក ?

### ផ្គាក់ជីវិតប្រចាំថ្ងៃ

ផ្គាក់គឺជាកាំបិតមួយប្រភេទ ដែលខ្មែរយើងប្រើតាំងពីបុរាណកាលមកម្លេះ ។ ផ្គាក់មានដងវែង ធ្វើអំពីឈើ ឬឫស្សីហើយ មានផ្លែធ្វើអំពីដែកមុត ។ គេប្រើកាំបិតផ្គាក់នេះ ក្នុងកិច្ចការជាច្រើន ដូចជាការត្រួសត្រាយកាប់ឆ្ការព្រៃ ឬក៏ការពារខ្លួនទប់ទល់និងសត្វសាហាវ ក្នុងពេលធ្វើដំណើរជិតឆ្ងាយតាមព្រៃភ្នំផ្លូវស្ងាត់ ។ កាំបិតផ្គាក់មានប្រយោជន៍ច្រើនប្រការណាស់ក្នុងជីវិតប្រចាំថ្ងៃរបស់អ្នកស្រុក ក៏ប៉ុន្តែកាំបិតផ្គាក់ក៏ជាអាវុធ ឬសាស្ត្រាវុធមួយគួរឱ្យភ័យខ្លាចក្នុងពេលសង្គ្រាម ។

នៅប្រាសាទបាយ័ន និងប្រាសាទអង្គរវត្ត ក៏មានចម្លាក់ផ្គាក់នៅលើជញ្ជាំងថ្មប្រាសាទដែរ ។ ហើយផ្គាក់ដែលយើងបានឃើញនេះ មានទម្រង់ទ្រង់ទ្រាយដូចជាផ្គាក់របស់បងប្អូនខ្មែរលើ (ព្នង)យើងដែរ រូបភាពនេះ បញ្ជាក់ឱ្យឃើញថា បងប្អូនខ្មែរលើយើងមានខឿនវប្បធម៌តែមួយជាមួយខ្មែរនៅវាលទំនាប ។ ដូច្នេះ កាំបិតផ្គាក់ត្រូវបងប្អូនខ្មែរយើងប្រើតាំងពីសម័យបុរេប្រវត្តិសាស្ត្រ ជាពិសេសសម័យអង្គរ ។ ដើម្បីទប់ទល់ប្រយុទ្ធប្រឆាំងតតាំងជាមួយបច្ចាមិត្ត កងទ័ពថ្មើរជើងខ្មែរប្រើផ្គាក់ ដើម្បីការពារទឹកដីកុំឱ្យបរទេសឈ្លានពាន ដូចជាចម្លាក់លើប្រាសាទបាយ័ន និងប្រាសាទអង្គរវត្តជាភស្តុតាងស្រាប់ ។

រហូតមកដល់បច្ចុប្បន្ន ខ្មែរយើងនៅតែប្រើកាំបិតផ្គាក់ ជាពិសេសសម័យប៉ុលពតកាន់អំណាចបីឆ្នាំ ទាហាន និងកងឈ្លបដើរទៅណាមកណាកាន់តែកាំបិតផ្គាក់ដែលមានមុខសស្គុស ហើយពួកគេប្រើកាំបិតនេះ សម្លាប់ប្រជាជនខ្លួនឯងអស់ (រាប់ម៉ឺនសែននាក់ទៀតផង) ។ សព្វថ្ងៃនេះ ក៏គេនៅតែឃើញមានប្រជាជននៅខេត្តកំពង់ធំ សៀមរាប រតនគិរី និងព្រះវិហារ និយមប្រើផ្គាក់នៅឡើយ ។ ប្រជាជនខ្មែរ ដែលរស់នៅស្រុកថៃបច្ចុប្បន្ន ក្នុងខេត្តស៊ីសាកេត, នគររាជសីមា, សុរិន្ទ, អូប៊ុន, ក៏នៅតែនិយមប្រើដែរ ។

នៅតំបន់ព្រៃភ្នំ បងប្អូនខ្មែរលើប្រើផ្គាក់ ដែលមានផ្លែតាពែក ហើយធំ ។ រីឯនៅប្រទេសឡាវ យួន និងសៀមបច្ចុប្បន្ននេះ ផ្គាក់របស់បងប្អូនខ្មែរនៅទីនោះ ក៏មានលក្ខណៈមិនខុសពីផ្គាក់របស់បងប្អូនខ្មែរលើនៅស្រុកយើងប៉ុន្មានដែរ ហើយការប្រើប្រាស់ក៏មិនខុសគ្នាដែរ ។ គេសៀតផ្គាក់នៅកន្លែងដែលខ្ពស់ពីដីនៅក្នុងផ្ទះរបស់គេ ។ ជួនកាលគេព្យួរ ឬក៏ដាក់វានៅលើក្បាលដំណេក ។ ក្នុងករណីអាសន្ន គេប្រើវាដើម្បីការពារខ្លួន ។

បងប្អូនខ្មែរបានឱ្យតម្លៃផ្គាក់ខ្ពស់បំផុត គឺគេមានតំណមនៅក្នុងការប្រើប្រាស់វាណាស់ ។ សុភាសិតខ្មែរក៏បានចែងអំពីកាំបិតផ្គាក់ដូចជាៈ ពេលបុណ្យទានហាមមិនឱ្យយកកាំបិតផ្គាក់ជាប់ខ្លួន, មិនយកផ្គាក់ដាក់លើក្បាលក្មេង, ដាក់ផ្គាក់មួយអន្លឺសិនមុននិងលើកផ្គាក់កាប់, ដាក់ផ្គាក់លើក្បាលដំណេក, ដេកជាមួយផ្គាក់, លេងផ្គាក់មុតដៃ ។ល។

យោងតាមការវិភាគអំពីផ្គាក់ខ្មែរលើ ខ្មែរទំនាបបានឱ្យដឹងថា ផ្គាក់ខ្មែរពិតជាបានកើតចេញពីខឿនវប្បធម៌តែមួយ ហើយវប្បធម៌ផ្គាក់នេះ ត្រូវបានប្រ

សូត្រឡើងតាំងពីសម័យបុរេប្រវត្តិសាស្ត្រមកម្ល៉េះ ។ សម័យវិទ្យាសាស្ត្រនេះ ទោះជាមានការរីកចម្រើនគ្រឿងអាវុធជាតិផ្ទុះក៏ដោយ ក៏នៅតែមានចំនួនមនុស្សនៅប្រើកាំបិតផ្គាក់ក្នុងជីវភាពប្រចាំថ្ងៃ និងការពារខ្លួនដែរ ។

## ១៤~ប្រភពប្លង់នៃក្បាំងខ្មែរ

រហូតមកដល់ចុងសង.វ.ទី១៩ ដើមស.វ.ទី២០ ពិតមែនតែវប្បធម៌អឺរ៉ុបបានជះឥទ្ធិពលទៅលើរបបនយោបាយ និងសង្គមខ្មែរយ៉ាងណាក៏ដោយ ក៏ទំនៀមទម្លាប់ខ្មែរ និងបងប្អូនខ្មែរលើមួយចំនួន ត្រូវបានប្រសូត្រចេញពីខឿនវប្បធម៌សម័យបុរេប្រវត្តិសាស្ត្រ ត្រូវបានរក្សាទុកនៅឡើយ ។

ការផ្លាស់ប្តូរទម្រង់សង្គម ត្រូវបានបង្កើតឡើងយ៉ាងសកម្ម ចាប់តាំងពីឆ្នាំ១៩២៩-១៩៣០មក ។ ក្នុងអន្តរកាលនោះ ប្រពៃណីខ្មែរមួយចំនួនត្រូវបានរលត់សាបសូន្យបន្តិចម្តងៗ ចាប់តាំងពីស.វ.ទី២០យើងនេះ ដូចជាការប្រើក្បាំង ឬខែលជាដើម ។ ការបាត់បង់នូវឧបករណ៍ការពារខ្លួននៅពេលមានសឹកសង្គ្រាមរបស់ជនជាតិខ្មែរខាងលើនេះ ក៏ឆ្លុះបញ្ចាំងឱ្យឃើញនូវការវិវត្តរបស់សង្គមខ្មែរ ។

ការស្រាវជ្រាវអំពីក្បាំងខ្មែរបានឱ្យដឹងថា ក្បាំងកើតចេញពីកិរិយាស័ព្ទបាំង មានន័យថា ការពារទប់ទល់គ្របដណ្តប់ ។ ក្បាំងគឺជារង្វង់ឈើសម្រាប់ការពារនឹងកាំបិត អាវុធ ដាវរបស់សត្រូវកុំឱ្យរបួសខ្លួនបាន ។

គួរកត់សម្គាល់ផងដែរថា នៅលើប្រាង្គប្រាសាទអង្គរ និងបាយ័ននាស.វ.ទី១២ និង១៣នៃគ.ស. គេបានឃើញការនិយមក្បាំងដោយកងទ័ពថ្មើរជើង ។ គេអាចចែកក្បាំង ដែលឆ្លាក់លើប្រាសាទថ្មខ្មែរជាពីរប្រភេទ គឺក្បាំង

ដែលមានរាងមូល និងក្បាំងដែលមានរាងវែង ។ ភាគច្រើនក្បាំងបុរាណត្រូវការពារដោយពាសដែកនៅខាងមុខផង ។

មិនមែនមានតែជនជាតិខ្មែរទេ ដែលប្រើក្បាំង គេក៏ជួបប្រទះនូវក្បាំងក្នុងកុលសម្ព័ន្ធខ្មែរលើមួយចំនួនដែរ ដូចជាពួកព្នងនៅកម្ពុជា និងពួកជ្រោយនៅសេជាំងនៅកម្ពុជាក្រោមដែរ ។

មុនសម័យអាណាព្យាបាលបារាំង១៨៦៣ ប្រវត្តិសាស្ត្របានកត់ត្រាថាពួកខ្មែរព្រៃភ្នំទាំងនោះបានប្រើប្រាសក្បាំងឈើ ដូចជាទាហានខ្មែរដែរ សម្រាប់ច្បាំងនឹងកុលសម្ព័ន្ធគ្នាឯង ។ តែបន្តិចម្តង១ ទំនៀមទម្លាប់ប្រើក្បាំងនេះ ក៏ត្រូវរលាយសាបសូន្យ ព្រោះតំបន់ខ្ពង់រាបទាំងនោះ ត្រូវបានគេបញ្ចុះបញ្ចូលក្នុងសហគមន៍ឥណ្ឌូចិន ដែលត្រួតត្រាដោយបារាំងសេស ។ សព្វថ្ងៃនេះ គេអាចឃើញនៅសារមន្ទីបារាំងគ្គេអាឡាំងសុងនូវក្បាំងខ្មែរមួយចំនួន ដែលគេបានយកមកពីខេត្តក្រចេះ ។

ក៏ប៉ុន្តែក្បាំងពុំទាន់បាត់បង់ពីទឹកដីខ្មែរភ្លាមនៅឡើយទេ ការប្រើក្បាំងនៅក្នុងពិធីបុណ្យប្រជាប្រិយនាដើមស.វ.ទី២០ នៅតែមានជាហូរហែនៅខេត្តកំពង់ធំ ក្រោមរូបភាពកីឡាប្រយុទ្ធគ្នានៅពេលមានបុណ្យទានម្តង១ ក៏ប៉ុន្តែបន្ទាប់ក៏ត្រូវបានបាត់បង់ទៅវិញ ។

គួររំលឹកផងដែរថា ក្នុងសង្គ្រាមនាសម័យលង្វែក ដែលខ្មែរបានប្រើក្បាំងនាសម័យនោះ កងទ័ពខ្មែរបានប្រើក្បាំងដើម្បីប្រយុទ្ធតតាំងការពារខ្លួនជាមួយនឹងកងទ័ពថៃឈ្លានពាន ។ វិចិត្រករខ្មែរបានចងចាំនូវអានុស្សាវរីយនេះហើយក៏បានគូររូបគំនូរមួយចំនួននាសម័យចតុមុខ ។ ប៉ុន្តែនៅក្នុងអម្លុងសង្គ្រាម

លោកលើកទីមួយ និងទីពីរ ក្បាំងក៏បាត់សំណាង់វប្បធម៌ខ្មែរ លើកលែងតែនៅប្រាសាទថ្មខ្មែរ នូវបានដាស់សតិខ្មែរថា ជនជាតិខ្លួនធ្លាប់ការពារប្រទេសខ្លួនដោយការប្រើក្បាំងនេះ ។

ដោយហេតុផលនៃការទាក់ទងរវាងក្បាំងខ្មែរ និងពួង អ្នកប្រាជ្ញខ្មែរបានសន្និដ្ឋានថា ក្បាំងទាំងពីរប្រភេទកើតចេញពីពុម្ពវប្បធម៌តែមួយ ពុម្ពនោះបានរីកចម្រើនរុងរឿងតាំងពីសម័យលោហធាតុ ក៏ប៉ុន្តែត្រូវសាបសូន្យនាស.វ.ទី២០នេះឯង ។

# ជំពូក៤
# ទំនៀមទម្លាប់មន-ខ្មែរ

## ១-ពាក្យផ្ដើម

ជនជាតិខ្មែរ ក៏ដូចជាជនជាតិដទៃទៀតដែរ ដំបូងបានជឿលើធម្មជាតិ មេឃ ដី ភ្លើង ខ្យល់ ផ្គរ រន្ទះ អារក្សអ្នកតា ព្រៃព្រឹក្សា មេបា គ្រូបាធ្យាយ ។ល។

របាំពួយ ស្គរ គង ជានិមិត្តរូបនៃការគោរពបូជាចំពោះអាទិទេព ទាំងអស់នេះ ដើម្បីអង្វរសុំសេចក្ដីសុខ ពេលមានទុក្ខភ័យ និងរាំថ្វាយពេលទទួលជ័យជំនះ ។ កុំភ្លេចថា ការបញ្ចេញសូរសៀង ឬសូរសៀង គឺជាសកម្មភាពមួយពាក់ព័ន្ធទៅនឹងពិធីសាសនាជានិច្ចកាល ។

បន្ទាប់មក ខ្មែរជឿលើព្រហ្មញ្ញសាសនា ដែលមានព្រះព្រហ្ម ព្រះសិវៈ និងព្រះវិស្ណុជាអាទិទេព ។ របាំព្រាហ្មណ៍ របាំទេវ៉ុន ជានិមិត្តរូបនៃការគោរពបូជាចំពោះអាទិទេពទាំងបី និងព្រះហរិហរៈ ដែលព្រះមហាក្សត្រខ្មែរបានបង្កើត ឡើង ដើម្បីបញ្ចៀសនូវទំនាស់រវាងជំនឿព្រះសិវៈ និងព្រះវិស្ណុ ។

រហូតដល់សព្វថ្ងៃ ខ្មែរគោរពព្រះពុទ្ធសាសនា តែក៏ពុំបានលុបចោលជំនឿទាំងឡាយកន្លងមកដែរ ។ បទសារ៉ាវ៉ាន់ខ្មែរជានិមិត្តរូបនៃការផ្ដាំផ្ញើរបស់បុព្វបុរសខ្មែរថា ការប្រមូលផ្ដុំជំនឿជាអង្គការឯកភាពនាំឱ្យកើតសេចក្ដីសុខ ។ របាំជាន្តបន្ទាប់ជាភាពរីករាយរបស់ប្រជារាស្ត្រខ្មែរក្នុងការបង្កបង្កើនផល ដើម្បីជីវភាពរស់នៅពេលសង្គមបានសន្តិភាព ដែលមានរបាំព្រាបជានិមិត្តរូប ។

ដូច្នេះ តទៅនេះយើងសូមរំលឹកឡើងវិញនូវមូលដ្ឋានវប្បធម៌មួយចំនួន

រវាងជនជាតិខ្មែរ និងខ្មែរលើតាមរយៈឧបករណ៍ភ្លេងមួយចំនួន ឆ្លុះបញ្ចាំងឱ្យឃើញនូវការវិវិត្តន៍របស់លក្ខណវប្បធម៌ខ្មែរយើងតាមយុគ្គ តាមសម័យកាល ។

## ២-ប្រភពមន-ខ្មែរនៃពួយ

វិស័យតូរតន្ត្រីនៃជនជាតិខ្មែរ ដូចដែលយើងបានជ្រាបមកហើយថា ក្នុងអម្បូរមន-ខ្មែរ មានកំណើតតាំងពីយូរយាណាស់មកហើយ គឺបុព្វបុរសខ្មែរនាសម័យបុរេប្រវត្តិសាស្ត្របានបង្កើតឡើង ដើម្បីបំពេញតម្រូវការក្នុងសង្គម ហើយបានបន្សល់ទុកជាមតិកវប្បធម៌រហូតមកដល់សព្វថ្ងៃនេះ ។ ចំណាស់នៃឧបករណ៍ភ្លេងពួយនេះ អាចបញ្ជាក់បានយ៉ាងច្បាស់តាមរយៈវត្ថុសិល្បៈ នាសម័យបុរេប្រវត្តិសាស្ត្រ ដែលគេបានរកឃើញដោយកំណាយនៅក្នុងស្ថានីយបុរេប្រវត្តិសាស្ត្រ និងតាមរយៈលក្ខណៈពិសេសរបស់វា ។ ដោយឡែកឧបកណ៍ភ្លេងនេះ ដែលមិនបានមានការវិវត្តផ្លាស់ប្តូរទម្រង់រូបរាងតាំងពីបុរាណកាលមក កំពុងពេញនិយមដោយជនជាតិភាគតិចជង និងព័រ ក្នុងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ននេះ ។

### ក-លក្ខណៈរបស់ឧបករណ៍ភ្លេងពួយ

ដូចឧបករណ៍ភ្លេងគែនដែរ ដែលស្ថិតនៅក្នុងប្រភេទឧបករណ៍ប្រភេទផ្លុំ ឧបករណ៍ពួយរបស់យើងមានលក្ខណៈខុសគ្នាបន្តិច ត្រង់ចំណុចបំពុងសម្លេងតែប៉ុណ្ណោះ ។

រូបរាងនៃឧបករណ៍ភ្លេងពួយ ដែលមាននៅក្នុងកុលសម្ព័ន្ធខ្មែរលើ មានទំនាក់ទំនងនិងធម្មជាតិព្រៃភ្នំក្រមថ្ម ជីវភាព និងជំនឿសាសនា តាមលក្ខណៈសង្កេតរបស់យើង ។ ភាពងាយស្រួលក្នុងការប្រឌិតស្ថាបនា ដែលទន្ទឹមនិងនេះ

បង្កប់នូវភាពប៉ិនប្រសប់ផង ដោយក្នុងតួឧបករណ៍ភ្លេងពួយ ត្រូវចែកចេញជាបីផ្នែកគឺ បំពង់សម្លេង ប្រអប់សម្លេង និងអណ្ដាតឧបករណ៍ ។

ជាទូទៅអ្នកស្រុកព្រៃភ្នំធ្វើពួយដោយដើមឫស្សីពកធម្មតា និងឫស្សីពកខ្សៀវ ដែលមានថ្នាំងរង្វើល ហើយបំពង់តូចត្រង់ តែមានចំណាស់ចាស់ ។ សូមបញ្ជាក់ថា បំពង់ឧបករណ៍ពួយមានបំពង់ចំនួន៥ ឬ៧ ហើយបំពង់វែងជាងគេមានប្រវែង១,១០ម ។ ខ្នាតនៃបំពង់ទាំងនេះ ដេញតរៀងមកពីវែងដល់ខ្លីខុសគ្នាត្រឹមតែ១០សម ឬ១៥សមទេ ។ ដូច្នេះ បានជាឧបករណ៍ពួយមានភាពសមសួន ហើយការចាត់ជាថ្នាក់១ រីឯសោភ័ណភាព ឬភាពស្រស់បស់របស់វាវិញ បំពង់នៃឧបករណ៍ភ្លេងនេះ ក៏ត្រូវបានបង្កើតមួយកម្រិតទៀតគួបផ្សំ និងប្រអប់សម្លេង និងអណ្ដាតរបស់វា ។

សូមជម្រាបថា តួនៃផ្នែកសម្លេងធ្វើអំពីផ្លែឃ្លោកស្ងួត ជាចំណែកមួយយ៉ាងសំខាន់នៃតួទាំងមូលរបស់ឧបករណ៍ពួយ មាននាទីជាប្រអប់ជួយសម្រាប់បិទភ្ជិតសន្ទប់ខ្យល់រុញច្រានតាមរយៈបំពង់អណ្ដាតសម្លេង ។ សូមជម្រាបថាផ្នែកប្រអប់សម្លេងមានសារសំខាន់ណាស់ ពីព្រោះផ្លែឃ្លោកមានរាងមូល ដូចជាផ្លែព្នៅ ដែលមានទងវែងជាសណ្ដង់ដូចចំពួយ ងាយស្រួលក្នុងការប្រើប្រាស់ជាបំពង់ផ្លុំខ្យល់បានងាយស្រួល ដោយគ្រាន់តែចោះសងខាងឱ្យល្មមបញ្ចូលបំពង់ទាំងប្រាំ ឬប្រាំពីរត្រឹមអណ្ដាត ហើយបិទភ្ជិតទៅដោយជ័រម្យ៉ាង ដែលផ្សំឡើងពីក្រមួនផ្អិតសត្វម្រោម និងសត្វផ្លុងជាអម្បូរសត្វឃ្មុំ ។ ក្នុងការផលិតប្រអប់សម្លេង គេ " ប្រើលលាដ៏ដូងជំនួសដោយត្រូវបន្ថែមបំពង់បឹត ធ្វើអំពីដើមបបុស ឬក៏បំពង់ " ។ ខាងលើនេះ គឺជាការបញ្ជាក់របស់ការស្រាវជ្រាវ

របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តពោធិ៍សាត់កាលពីឆ្នាំ១៩៩៩ ។

រីឯផ្នែកអណ្តាតសម្លេងវិញ ដែលធ្វើអំពីធាង ដើម ជក់ វាជាផ្នែកមួយចាំបាច់ក្នុងការបញ្ចេញសូរសៀង ។ អណ្តាតពួយមានរាងដូចអណ្តាតឧបករណ៍ប៉ីពក ហើយមាននៅគ្រប់បំពង់សម្លេង ដែលត្រូវបានគេចោះរន្ធ ដើម្បីឱ្យខ្យល់ចេញចូលបានងាយស្រួល ។ ម្យ៉ាងវិញទៀត ដើម្បីឱ្យជួយសម្លេងធូន់ និងល្អពិរោះ ជនជាតិព័រ និងជងនៃខេត្តបាត់ដំបងចូលចិត្តយកសំបកខ្យងចិញ្ចៀន ឬងាវមកដុសយកម្សៅលាយជាមួយនិងទឹកលាបពីលើអណ្តាតពក ហើយបាលឱ្យស្ងួតល្អ ។

## ខ-អត្ថប្រយោជន៍នៃឧបករណ៍ពួយ

អត្ថប្រយោជន៍នៃឧបករណ៍ភ្លេងពួយ គឺលក្ខណៈពិសេសមួយដែលប៉ះពាល់ទៅនិងទំនៀមទម្លាប់ប្រពៃណីពីរនៃបងប្អូនខ្មែរលើជន និងព័រ ។

ថ្វីបើយើងមិនទាន់វិភាគបញ្ហានេះឱ្យស៊ីជម្រៅ ដោយសារពេលវេលាកំណត់ ក៏យើងមានទិន្នន័យខាងជាតិពន្ធុវិទ្យា ជាច្រើនបង្ហាញនូវលក្ខណៈជីវចលនៃឧបករណ៍ភ្លេងខាងលើនេះ ។ កំណត់សំគាល់ ដែលគួរឱ្យចាប់អារម្មណ៍នោះគឺថា សម្លេងពួយដែលគេផ្លុំនោះ មានសូរសៀងដូចសម្លេងធម្មជាតិនៃសត្វកន្លង់ក្រេបកម្រងផ្កាក្នុងរបាំទន្សោង ។ ការវិភាគបានបញ្ជាក់ឱ្យដឹងទៀតថាសម្លេងពួយដែលគេត្រាប់តាមសត្វកន្លង់នោះ មានលក្ខណៈសំខាន់ដល់កុលសម្ព័ន្ធខ្មែរលើទាំងនោះ ដែលជីវភាពរបស់គេផ្តេកផ្តួលទៅលើការបរបាញ់សត្វព្រៃ ។ ចំពោះជនជាតិខ្មែរព្រៃភ្នំទាំងនោះ សម្លេងឧម្លេងឧបករណ៍ពួយមានតួនាទីពិសិដ្ឋមួយ គឺការដាស់ព្រលឹងធម្មជាតិឱ្យមកសណ្ឋិតក្នុងសង្គមមនុស្ស

ដោយឡែកក្នុងឧបករណ៍នេះផ្ទាល់តែម្តង ដើម្បីការពារ បីបាច់ថែរក្សា និងផ្តល់នូវសម្បត្តិធម្មជាតិគ្រប់បែបយ៉ាងដល់ពួកគេ ទាំងសត្វព្រៃទាំងរុក្ខជាតិនានា ដែលពួកគេត្រូវការដើម្បីតពូជពង្សវង្សត្រកូល ។

### គ-លក្ខណៈពិសិដ្ឋនៃឧបករណ៍ពួយ

អ្នកដែលផ្តល់នូវចម្លើយនៃបទសម្ភាសន៍មួយចំនួនបានឱ្យដឹងថា ជាប្រពៃណីសម្រាប់បងប្អូនជង និងព័រ ដែលមិនទុកឧបករណ៍ភ្លេងពួយនៅក្នុងផ្ទះឡើយ ដោយហេតុថា វាជាសម្បត្តិរួមរបស់សហគមន៍មនុស្ស ។ ដូច្នេះ គេត្រូវតម្កល់ឧបករណ៍នេះនៅក្នុងផ្ទះមេកន្ទ្រាញ ឬមេស្នឹងក្នុងភូមិ សម្រាប់ប្រើប្រាស់ក្នុងពិធីផ្សេងៗ ដែលមានលក្ខណៈជាប្រយោជន៍ក្នុងភូមិ ស្រុក ដូចជាពិធីសែនអ្នកតាចាស់ស្រុក ឬក្នុងរបាំទន្សោងមុនការបរបាញ់សត្វព្រៃ ។

ការរៀបរាប់ខាងលើនេះ អ្នកស្រុកខ្មែរព្រៃភ្នំបានបញ្ជាក់ឱ្យដឹងថា ក្នុងសង្គមពួយមិនមែនជាកម្មសិទ្ធិឯកជនទេ ក៏ប៉ុន្តែ ជាសម្បត្តិពិសិដ្ឋរបស់សហគមន៍ទាំងមូល ។

ដូចគ្នានេះដែរ ក្រោយពីផលិតឧបករណ៍ភ្លេងពួយនេះរួច គេត្រូវបំពេញនូវពិធីសែនព្រេនមួយ ដើម្បីឧទ្ទិសស្នាដៃនៃការធ្វើឧបករណ៍នេះ ឡើងជូនបុព្វការីជន ជាពិសេស គឺអ្នកតាអន្ទង់រីម អ្នកតារុង ដែលជាអ្នកបានផលិតឧបករណ៍ពួយនេះឡើងមុនគេបង្អស់ ហើយបានបង្ហាត់បង្រៀនការផលិតនេះជូនមនុស្សជំនាន់ក្រោយៗ ។

### ឃ-ពិធីសែនព្រេនអ្នកតាអន្ទង់រីម

ជាកាពិតណាស់ដែរ ចំពោះកុលសម្ព័ន្ធខ្មែរជនជាតិជង និងព័រ ជំនឿ

សាសនាមានឥទ្ធិពលគ្របដណ្តប់លើសង្គមរបស់ពួកគេយ៉ាងខ្លាំងក្លាបំផុត ។ ដូចនេះ ជំនឿជីវចលនិយម មានអានុភាពលើជីវិតប្រចាំថ្ងៃរបស់ជនជាតិខ្មែរព្រៃភ្នំទាំងនោះ ដែលខុសគ្នាត្រង់គេនៅរក្សានូវប្រពៃណីប្រចាំតំបន់ខ្ពង់រាបយ៉ាងខ្ជាប់ខ្ជួន ដូចជារបៀបរស់នៅ និងជាភាសាដែលស្ថិតក្នុងអម្បូរមន-ខ្មែរ ក៏ប៉ុន្តែពុំមានអក្សរសាស្ត្រដូចខ្មែរ ដែលរស់នៅតាមវាលទំនាបតែប៉ុណ្ណោះ ។

ព្រោះខ្មែរព្រៃភ្នំក្រំថ្មទាំងនោះ ដែលរស់នៅជ្រកកោនក្រោមឥទ្ធិពលនៃធម្មជាតិ ព្រោះអ្វីទាំងអស់សុទ្ធសឹងតែមានវិញ្ញាណ ពួកគេជឿថា គ្រប់បាតុភូតធម្មជាតិ ដូចជាខ្យល់ព្យុះ ភាពរាំងស្ងួត ជំងឺជាដើម សុទ្ធសឹងតែជាអំពើរបស់អារុក្ខអារក្សអ្នកតា ។ ដើម្បីសម្របសម្រួលតាមវត្ថុស័កសិទ្ធិទាំងនោះប្រយោជន៍និងផ្តល់ចំពោះគេ ឬកូនចៅរបស់ពួកគេនូវសេចក្តីសុខសប្បាយ ភាពចម្រុងចម្រើនពួកគេត្រូវសែនព្រេន ។ ដូច្នេះតាមរយៈពិធីសែនព្រេន ដែលក្នុងនោះ មានការរាំងច្រៀងរបស់អ្នកស្រុក ដើម្បីជាដង្វាយថ្វាយចំពោះដូនតាពួកគេជឿជាក់ថា និងទទួលនូវសិរីមង្គល ។

រួមសេចក្តីមក ឧបករណ៍ភ្លេងពួយមិនមែនគ្រាន់ធ្វើឡើងសម្រាប់ប្រគំកំសាន្តនោះទេ ។ តែសម្រាប់ឧទ្ទិស្សដល់វិញ្ញាណក្ខ័ន្ធព្រលឹងដូនតា ដែលជាអ្នកបីបាច់ថែរក្សាសង្គមឱ្យប្រកបដោយសុភមង្គល ដែលជាសេចក្តីប៉ងប្រាថ្នារបស់មនុស្ស ។

ទន្ទឹមនិងពិធីសែនព្រេននេះ នៅតាមស្រុកភូមិជារួម គេឃើញមានបង្អែមចំអាប មាន់ស្ងោរ ក្បាលជ្រូក ស្រាសជាក់ខូច ផ្លែឈើនិងម្លូរស្លាបារី ព្រមទាំងឧបករណ៍តន្ត្រីពួយមួយគូជាដើម ។ សូមជម្រាបថា នាសម័យបុរាណ

គេមានទម្លាប់សែនក្បាលដីរផង ក៏ប៉ុន្តែឥឡូវនេះ អ្នកស្រុកពុំមានលទ្ធភាពដូចអតីតកាលទៀតឡើយ ។

ផ្នែកមួយទៀតនៃការស្រាវជ្រាវរបស់យើងបានឱ្យដឹងថា បងប្អូនជនជាតិខ្មែរព្រៃភ្នំទាំងនោះ បានវាយតម្លៃយ៉ាងខ្ពស់បំផុត ចំពោះមេស្នឹង ឬអ្នកដែលស្នងរូបរបស់អ្នកតាចាស់ស្រុក ដែលតំណាងនូវវត្ថុស័ក្តិសិទ្ធនៃកម្លាំងធម្មជាតិ គឺស្នឹងនេះហើយ ដែលរៀបចំកម្មវិធីសែនព្រេននេះ ។

ជាការពិតណាស់ ដែលគេមិនអាចគេចវេសពីបុគ្គលដ៏សំខាន់ខាងលើនេះបានទេ ដែលជាអ្នកអាចនិងបំបាត់នូវរាល់មហន្តរាយ គ្រោះអាសន្នសម្រាប់សង្គម តាមរយៈការសែនព្រេន ដែលក្នុងចក្ខុវិស័យរបស់អ្នកស្រុកភូមិគឺជាពលិកម្មមួយ ដែលខកខានមិនបាន ។ ម្យ៉ាងវិញទៀត តាមរយៈពិធីពិសិដ្ឋនេះ យើងក៏អាចឃើញដែរថា បងប្អូនជនជាតិមិនបានផ្តាច់ចំណងពីបរិស្ថាន និងក្របខ័ណ្ឌរស់នៅរបស់ខ្លួនដោយសម្របសម្រួលតាមធម្មជាតិប្រយោជន៍ និងឈានទៅរកសមតា ឬស្ថេរភាពសង្គម ។

ហេតុដូច្នេះ គឺបុរសមេស្នឹងនេះហើយ ជាអ្នកទំនាក់ទំនងរវាងធម្មជាតិនិងសង្គមមនុស្ស ពីព្រោះក្នុងប្រព័ន្ធគំនិតរបស់អ្នកស្រុកព្រៃភ្នំក្រំថ្ម គ្មានការបែងចែករវាងភាពពិសិដ្ឋ ឬអច្ឆរិយៈ និងភាពប្រក្រតីនោះទេ ។ ហើយក្នុងក្របខ័ណ្ឌនៃទស្សនៈវិជ្ជានេះហើយ មេស្នឹងដែលតំណាងឱ្យព្រលឹងដូនតា ដែលជាអ្នកចែកឋានទៅហើយនោះ ហើយជាអ្នកកសាងវប្បធម៌ អារ្យធម៌ ដោយបានសាងសង់នូវលំនៅស្ថានដំបូងដូចជាភូមិស្រុក ត្រូវស្លៀកសំពត់ចងក្បិនដោយមានពានា ។ ម្យ៉ាងវិញទៀត ដោយខកខានពុំបាន ដែលគេត្រូវកាន់

ផ្លែដីង ពួចៅស្នាបធ្វើអំពីដែក ហើយស្ថិតក្នុងឥរិយាបថអង្គុយស្ងៀមស្ងាត់ ភ្នែកមើលទៅកាន់គ្រឿងសំណែន ដែលគេដាក់លើកន្ទេលមួយ ដែលក្រាលនៅផ្ទាល់នឹងដី ។

ជាមួយគ្នានេះដែរ គេឃើញមានអ្នកជំនួយការពីរនាក់ផ្សេងទៀត ដែលស្លៀកសំពត់ចងក្បិនដូចគ្នា ក៏ប៉ុន្តែលែងខ្លួនទទេ ។ ពួកគេអង្គុយប្រណម្យអមសងខាងមេស្នឹង ។ គឺពួកគេហ្នឹងហើយ ដែលនឹងចោទសំនួរឡើងនូវរាល់បញ្ហាពាក់ព័ន្ធទៅនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាជននៅពេលបច្ចុប្បន្ន ក៏ដូចជាសម្រាប់អនាគតខាងមុខនេះ ។ ការចោទសួរថា គួរធ្វើយ៉ាងណាឱ្យការបេះក្រវាញ ឬការបរបាញ់សត្វព្រៃមានផលដ៏បរិបូរណ៍ច្រើនឱ្យកូនចៅ ដែលរស់នៅក្នុងស្រុកភូមិមានសេចក្ដីសុខ សប្បាយជាដើម គឺជាពិធីមួយ សម្រាប់បង្កា ឬទប់ស្កាត់បាននូវរាល់ការីកដុះដាលនៃផលវិបាក ឬគុណវិបត្តិនានា ។

សរុបសេចក្ដីមក ចំពោះអត្ថន័យនៃពិធីសែនព្រេន គឺសំដៅទៅលើសេចក្ដីសុខ សេចក្ដីសម្បូរណ៍សប្បាយ ដែលអស្ថេរភាពនៃតំបន់ ដែលបណ្ដាលពីឥទ្ធិពលធម្មជាតិអាចបំផ្លាញ ធ្វើឱ្យបាត់បង់បានហើយ ដល់អ្នកដែលអាចកែតម្រូវគឺមេស្នឹង តាមពលិការរបស់ខ្លួន ។

ចំណុចមួយទៀតនៃពិធីសែនព្រេនខាងលើនេះ គឺការចូលរួមនៃមនុស្សគ្រប់ជាន់ថ្នាក់ក្នុងសង្គម មិនថាក្មេង ឬចាស់ មិនថាអ្នកមានឋានៈខ្ពស់ ឬទាបឡើយ ដូចជាខ្ញុំបម្រើជាដើម តាមរយៈការរាំរែក ឬច្រៀងរាំ ។ ទង្វើនេះ ជាបច្ច័យមួយយ៉ាងសំខាន់សម្រាប់ចងរិតជាបាច់នូវក្រុមមនុស្ស ឱ្យក្លាយជាផ្នួងមួយ ។ ក៏ប៉ុន្តែទន្ទឹមនិងនោះដែរ គេក៏ត្រូវរក្សាត្រណមមួយចំនួន តាមកាយ

វិការ ឬតាមពាក្យសម្ដី មុននិងចូលព្រៃជ្រៅដើម្បីបេះក្រវាញ ឬបរបាញ់ ក្រោយពីស៊ីផឹករាំរែកយ៉ាងសប្បាយ មួយយប់រួចមក ។

គប្បីរំលឹកឡើងវិញផងដែរថា ក្នុងអត្ថបទសិលាចារឹកប្រាសាទបាល្ល័ង្គ ខេត្តបាត់ដំបងឆ្នាំ៨៣០ ចារនៅសម័យអង្គរ មានការនិយាយដល់ពួកជង ព្រៅ និងយួង ដែលជាខ្ញុំបម្រើក្នុងប្រាសាទបុរាណខ្មែរ ។ ដូច្នេះវាគ្មានអ្វីជាអាថ៌កំបាំងទេថា ទំនាក់ទំនងរវាងខ្មែរ និងកុលសម្ព័ន្ធព្រៃភ្នំមានចំណាស់តាំងតែពីអតីតកាលមកម្ល៉េះ ។

## ៣-កេរ្តិ៍តំណែលមន-ខ្មែររបស់របាំត្រុដិ

របាំត្រុតជាកេរ្តិ៍តំណែលវប្បធម៌មន-ខ្មែរ ដែលជាជនជាតិខ្មែរព្រៃភ្នំ ដូច ជាពួកសម្រែ សួយ និងពណិជាដើម ព្រមទាំងជនជាតិខ្មែរនៅខេត្តស៊ីសាកេត សុរិន្ទ្រ សៀមរាប ពោធិសាត់ បាត់ដំបង តែងតែប្រារព្ធក្នុងពេលចូលឆ្នាំខ្មែរ ឬក្នុងពេល ដែលសត្វព្រៃរត់ចូលស្រុកភូមិជាដើម ។

តាមការពិតរបាំត្រុដិនេះ គឺជាបុណ្យឆ្លងពីឆ្នាំចាស់ចូលឆ្នាំថ្មី ពីភាពឧបទ្រពចង្រៃ ទៅជាភាពសម្បូរណ៍សប្បាយផ្លូវផង ។ ពាក្យត្រុដិជាពាក្យសំស្ក្រឹត ដែលបានន័យថា ដំណើរកាត់ ឬផ្ដាច់ ។ ដូចនេះ គេសម្ដែងរបាំត្រុដិក្នុងពេលដែល "ឆ្នាំចាស់ដាច់ ដើម្បីត្រេចផ្លាស់ចូលឆ្នាំថ្មី" ។ តាមអត្ថន័យនេះ របាំត្រុដិដែលត្រូវបានប្រារព្ធធ្វើនោះ គឺត្រូវកំណត់ដំណើរកាត់ផ្ដាច់នៃឆ្នាំនីមួយៗ ក្នុងទស្សនៈរបស់ជនជាតិខ្មែរ ដែលបានរស់នៅខ្ពង់រាប និងវាលទំនាប ។

ដូច្នេះហើយ ក្នុងពិធីបុណ្យឆ្លងនេះ គេប្រសិទ្ធិពរជ័យសព្វសាធុការសម្រាប់ឆ្នាំថ្មី ដែលចូលមកដល់ដោយសេចក្ដីរីករាយសប្បាយ ។ ក្នុងន័យ

ដដែលនេះ ការដែលគេមិនប្រារព្ធពិធីបុណ្យឆ្លង ឬការមិនចូលរួមអបអរសាទរនូវរបាំនេះ ដោយប្រការណាមួយ អាចនាំមកនូវរាល់អំពើទុក្ខសោកពុំខាន ។ នេះជាអត្ថន័យទីមួយនៃរបាំត្រុដិ ។ រីឯអត្ថន័យទី២ ក៏មានលក្ខណៈប្រហាក់ប្រហែលនិងនេះដែរ ពោលគឺគេរាំរបាំត្រុដិពេលដែលសត្វព្រៃ ដូចជាត្រកួតប្រើស ឈ្លូស ពស់ ចូលក្នុងភូមិ តាមពិតគេធ្វើឡើងក៏ដើម្បីផ្តាច់ចេញពីស្រុកភូមិរាល់ឧបទ្រពចង្រៃដែរ ហើយពិធីនេះ មានឈ្មោះថា វិធីឡើងភូមិ ឬពិធីរាំឡើងភូមិ ។

និមិត្តរូបដ៏សំខាន់នៃរបាំត្រុដិនេះ សម្រាប់បញ្ជាក់បង្ហាញនូវអត្ថន័យស៊ីជម្រៅ ក្រៅពីវត្តមានរបស់ពួកអ្នករាំកាន់សញ្ញា សម្រាប់កំណត់ទំនុកច្រៀងគឺវត្តមានរបស់អ្នករាំកាន់ដំបងកោងមួយ ធ្វើរបៀបផ្សេង ដូចតំណាងផាលនង្គ័ល ដែលនៅខាងចុង មានចងកណ្តឹង ឬរោមក្ងោក ។ និមិត្តរូបចំម្បងមួយទៀត គឺវត្តមានរបស់អ្នករបាំពីរនាក់ទៀតរាំត្រាប់តាមសត្វទន្សោង ដែលថៃចង់គ្នាដោយមានពាក់ស្នែងទន្សោងលើក្បាលរបស់គេថែមទៀតផង ។ សត្វប្រើសសូមជម្រាបថា អ្នករាំរបាំទន្សោងទាំងពីរនេះ តំណាងព្រានព្រៃដេញតាមសត្វប្រើសដែលគេត្រូវបរបាញ់ ។ ករណីមួយទៀត ដែលបង្ហាញនូវលក្ខណៈពិសិដ្ឋរបស់របាំនេះ គឺវត្តមានរបស់មនុស្សព្រៃម្នាក់ មុខលាបពណ៌ខ្មៅក្បាលរុំដោយផ្កា និងស្លឹកឈើជារុក្ខទេវតា ថែរក្សាព្រៃភ្នំដែលជួយពួកព្រានព្រៃក្នុងការបរបាញ់ ។

ដូចនេះ តាមរយៈវត្តមានរបស់តួអង្គ គឺអ្នករាំរបាំដែលខ្លួនជាសត្វ ឬរុក្ខទេវតា ដែលតំណាងនូវសភាវល្អ ឬអាក្រក់ យើងអាចសម្គាល់នូវលក្ខណៈពិសិដ្ឋ

របស់របាំត្រុដិ ដែលជាពិធីបុណ្យឆ្លងផ្កាច់ឆ្នាំចាស់ចូលឆ្នាំថ្មីនៃប្រជាពលរដ្ឋខ្មែរយើង ដែលមានលក្ខណៈជីវចលនិយម ហើយលើសពីនេះទៅទៀតនោះ គឺតួនាទីរបស់របាំនេះ ក្នុងសង្គមខ្មែរ គឺការផ្តល់នូវផលប្រយោជន៍សុភមង្គលរបស់មនុស្សក្នុងសង្គម ដោយរួមរិតសម្ព័ន្ធភាពសាមគ្គីភាពរបស់ពួកគេឡើងវិញ ។ ទស្សនៈបែបនេះ ពិតពុំមែនជាកេរមតិកវប្បធម៌ឥណ្ឌាទេ ក៏ប៉ុន្តែជាមតិកវប្បធម៌មន-ខ្មែរ ដែលមានអាយុច្រើនពាន់ឆ្នាំមកហើយ មានតម្លៃស្ថិតស្ថេរបហូរដល់សព្វថ្ងៃនេះ ។ គឺក្នុង "ពិធីរបាំឆ្លងនេះ" សាមគ្គីភាពរបស់មនុស្សខ្មែរគ្រប់ឋានៈវណ្ណៈក្នុងសង្គមត្រូវពង្រឹងសាជាថ្មីឡើងវិញ ដើម្បីឈានទៅរកវឌ្ឍនភាព និងសុភមង្គលដោយក្តីសង្ឃឹម ។ លក្ខណពិសិដ្ឋមួយទៀតរបស់របាំត្រុដិ គឺជំនឿលើបុព្វការីជន ក្រោមរូបភាពសត្វប្រើស ឬក្ងោកដែលឆ្លុះបញ្ចាំងនូវភាពឯកភាពផ្នែកជំនឿសាសនា ។ សូមជម្រាបថា ការដែលជនជាតិភាគតិច (ខ្មែរលើ) និងជនជាតិខ្មែរប្រារពរបាំនេះ ពុំមែនជាការចៃដន្យទេ ក៏ប៉ុន្តែទង្វើនេះបង្ហាញនូវខឿនវប្បធម៌រួមរវាងជនជាតិខ្មែរព្រៃភ្នំ (មន-ខ្មែរ) និងខ្មែរតែប៉ុណ្ណោះ ព្រមទាំងចំណាស់របស់ប្រពៃណីដ៏ល្អប្រពៃនេះផងដែរ ។

## ៤-ប្រវត្តិនៃការរកឃើញឡើងវិញឧបករណ៍ភ្លេងម៉ុម

អ្នកដើរទស្សនាតាមថែវនៃប្រាសាទបាយ័ន បានរកឃើញនូវទេពអប្សរម្នាក់អង្គុយកូតឧបករណ៍ភ្លេងម្យ៉ាងស្រដៀងនិងទ្រ ។ អ្នកណាក៏ឆ្ងល់ដែរថា តើគេកូតយ៉ាងមេចបើទ្រនោះអត់មានប្រអប់សូរសោះ ឬមួយក៏សិល្បករភ្លេចឆ្លាក់ឧបករណ៍នោះមិនឱ្យចប់ចុងចប់ដើមទៀត ។ អាថិកំបាំងនេះ ត្រូវបានអ្នកស្រីកែវ ណារុំ សាស្ត្រាចារ្យសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ បានរក

ឃើញតាមរយៈការស្រាវជ្រាវរបស់អ្នកស្រីនូវស្រុកអូជុំ ខេត្តរតនគីរី កាលពីពេលថ្មី១នេះ ហើយយើងសូមលើកយកមកបង្ហាញដូចខាងក្រោមនេះ ។

ឧបករណ៍នេះ ត្រូវបានរកឃើញនៅខេត្តរតនគីរី ស្រុកអូជុំ ដោយបងប្អូនខ្មែរលើជនជាតិទំពូន និងគ្រឹង ដែលកំពុងរក្សាមកទល់សព្វថ្ងៃនេះ ។ ជនជាតិខ្មែរលើបានហៅឧបករណ៍នេះថា " មិម" ។ ចំពោះខ្មែរកណ្ដាលមិនដែលឮហើយក៏មិនដែលថាមានឧបករណ៍នោះផង ។ មិម ឬម៉ឹម មានខ្យល់និងន័យប្រហាក់ប្រហែលគ្នា ។ ការដែលគ្មានប្រអប់សូរនោះ គឺលោកជំនួសដោយប្រើក្រអូមមាត់មានលក្ខណៈអាចពន្លឺសូរតាមចំណង់អ្នកកូត ។ គឺតន្ត្រីករមិម បានយកខ្សែអំបោះទៅចងនៅចុងក្រោម ជិតកន្លែងកូត រួចបន្ទាយមកដាក់ក្នុងមាត់ ។ ដើម្បីស្ថិតនៅក្នុងមាត់បាន គឺគេយកស្រកាពង្រួលមកចោះរន្ធ រួចស៊កខ្សែអំបោះក្នុងរន្ធនោះ ដោយបង្ខាំង និងកន្លាស់ឬស្សីតូចមួយ ហើយដាក់ចន្លោះធ្មេញលើក្រោមព្រៀបដូចទារកបៀម ឬបៅដោះម្ដាយ ។ ពាក្យបៅនេះ ខ្មែរតែងនិយាយទំយើកូនចៅថា ម៉ឹម រហូតដល់មិមក៏មាន ដូច្នេះហើយបានជាគេហៅឧបករណ៍នេះថា ម៉ឹម ។

ជនជាតិខ្មែរលើលេងមិមរួមជាមួយនិងឧបករណ៍តន្ត្រីពីរ-បីបែប ប្លែក១ទៀតនៅក្រោមដំបូលផ្ទះប្រក់ស្លឹកខាន់មាំ ឬលេងទោលតែឯងនៅក្នុងខ្ទមសង់កណ្ដាលស្រែចំការជិតជ្រោះជ្រលងដងអូរ កណ្ដាលព្រៃភ្នំ អមដោយធម្មជាតិខៀវស្រងាត់ និងជំនោខ្យល់ត្រជាក់កែអផ្សុកនៅពេលសម្រាកពីការងារ ។

ខុសប្លែកពីសម័យអង្គរ ឧបករណ៍មិមអាចមានតួនាទីលេងកំដររការរាំនាងទេពអប្សរ ជាមួយឧបករណ៍ (ពិណ) ដែលបាននិរាស្ដលាចាកពីប្រទេស

កម្ពុជាយើងក្នុងពេលបច្ចុប្បន្ននេះហើយ ។

អំពីប្រវត្តិនៃការរកឃើញឡើងវិញនៃឧបករណ៍ភ្លេងនេះ ដែលកំពុងនិយមក្នុងបណ្តាសហគមន៍ខ្មែរលើ ពិសេសបងប្អូននៅភូមិអូរជុំ ខេត្តរតនៈគិរី ដោយក្រសួងវិចិត្រសិល្បៈនៅឆ្នាំ១៩៩១ ។ សូមបញ្ជាក់ថា ទង្វើនេះ គឺធ្វើឡើងតាមយោបល់របស់យើងនិងអ្នកគ្រូកែវណារុំ ។ ពីព្រោះចំពោះយើងៗ ជឿថា ប្រភពនៃឧបករណ៍ដែលមានឆ្លាក់នៅលើចម្លាក់បុរាណខ្មែរ ពិតជានៅសេសសល់ក្នុងសង្គមខ្មែរពុំខាន ។ ដូចនេះ ការរកឃើញឡើងវិញនូវឧបករណ៍មិមនេះ ជាលទ្ធផលនៃការខិតខំស្វែងយល់របស់យើង ក៏ដូចជាមន្ត្រីនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈផងដែរ ។ សូមរំលឹកឡើងវិញផងដែរថា រូបភាពនៃឧបករណ៍នេះ ត្រូវបានឆ្លាក់នៅលើជញ្ជាំងប្រាសាទបាយ័ន នៅផ្នែកខាងកើតឈៀងខាងត្បូង តាមសំយាបនៃប្រាសាទបែរមុខទៅខាងត្បូង គឺចំពីមុខ ។ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ ត្រូវបានរៀបរាប់នូវអត្ថបទមួយនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ។

## ៥-ការរកឃើញឧបករណ៍តន្ត្រីមិម

"អ្នកស្រីកែវណារុំ អនុប្រធានគណៈកម្មការស្រាវជ្រាវក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សាស្ត្រាចារ្យផ្នែកតន្ត្រី រួមទាំងក្រុមអ្នកស្រាវជ្រាវផ្នែកតន្ត្រី បានរកឃើញឧបករណ៍ដែលមានតាំងពីសម័យអង្គរ តួយ៉ាងមានឃើញរចនាបថនៅលើថ្មជញ្ជាំងប្រាសាទបាយ័នចុងស.វ.ទី១២ ។ ហើយសព្វថ្ងៃនេះឧបករណ៍នេះ បានរកឃើញនៅក្នុងខេត្តរតនគិរី ដែលជនជាតិគ្រឹង្គ និងទំពួនកំពុងតែប្រើប្រាស់រាល់ថ្ងៃនេះហៅថា "ឧបករណ៍មិម" ។

លោកស្រីកែវណារុំ អនុប្រធានគណៈកម្មាធិការស្រាវជ្រាវ រួមទាំងអ្នកស្រាវជ្រាវទាំងអស់បានរកឃើញឧបករណ៍នេះបានឱ្យដឹងថា ឧបករណ៍មិមនេះ ឃើញមាននៅក្នុងខេត្តរតនគិរី ក្នុងស្រុកអូរជុំ ស្ថិតនៅក្នុងដៃបងប្អូនខ្មែរលើ (គ្រឹង្គ, និងទំពួន) ដែលជាឧបករណ៍កម្រ ហើយរកកលជិតផុតរលត់អស់ទៅហើយ ។ ជនជាតិគ្រឹង្គ និងទំពួនបានហៅឧបករណ៍នេះថា "មិម" ចំពោះប្រជាជនយើងសព្វថ្ងៃបច្ចុប្បន្ននេះ មិនស្គាល់ហើយថែមទាំងមិនដឹងថា មានឧបករណ៍តន្ត្រីនេះផង ។

តើនៅសម័យអង្គរ ខ្មែរកណ្ដាលបានដាក់ឈ្មោះហៅថាអ្វីដែរ ? អាចទំនងជាហៅមិម ឬម៉ិម ដែលមានខ្យល់និងន័យប្រហាក់ប្រហែលគ្នា ? ព្រោះការសម្ដែងឧបករណ៍នេះ មានលក្ខណៈកូតដូចទ្រ ។

ឯការដែលគ្មានប្រអប់សូរនោះ គឺលោកជំនួសដោយប្រើក្រអូមមាត់ដែលមានលទ្ធភាពអាចជួយបន្លឺសូរតាមបំណងនៃអ្នកកូត ។ បានសេចក្ដីថាតន្ត្រីករលេងឧបករណ៍ បានយកខ្សែរអំបោះចងនៅចុងខាងក្រោមជិតកន្លែងកូត រួចបន្លាយខ្សែមកដាក់ក្នុងមាត់ ។ ការស្ថិតក្នុងមាត់បាន គឺយកស្រកាពង្រួលមួយមកចោះរន្ធរួចស៊កខ្សែអំបោះក្នុងរន្ធនោះ ដោយបង្ខាំងនិងកន្លាស់ឬស្សីតូចមួយ ហើយដាក់ចន្លោះធ្មេញលើក្រោមប្រៀបដូចទារក ឬកុមារតូចៗបៀមដោះម្ដាយ ។ ចំពោះពាក្យបៅនេះ ខ្មែរតែងនិយាយទំយើជាមួយកូនចៅថាមិម ឬម៉ិម ឬរហូតដល់អ៊ឹមក៏មានដែរ ។

ដូច្នេះហើយបានជាយើងខ្ញុំយល់ថា អាចហៅក្នុងន័យដូចគ្នា គឺគ្រាន់តែការបញ្ចេញសូរមានលក្ខណៈច្រលីសគ្នាទៅតាមការនិយមតែប៉ុណ្ណោះ ។

ប៉ុន្តែឆាកសម្រាប់កូតរបស់មិមនេះ មិនមានលក្ខណៈដូចទ្រដែលយើងបានផលិតក្នុងពេលបច្ចុប្បន្ននេះទេ ។ ឆ្លងតាមការពិនិត្យឃើញឆ្លាក់លើសិលាចារឹករូបភាព ក៏អាចបញ្ជាក់ឱ្យយើងបានឃើញច្បាស់ដែរ ។ ឆាកមិមធ្វើពីឫស្សីដែលត្រូវបិទឱ្យស្តើង មានប្រវែងប្រហែលឆាកទ្រដែរ តែទំហំធ្លារជាងនិងគ្មានប្រើសរសៃសក់ទេ ។ គេយកឆាកឫស្សីនោះកូតផ្នែកខាងខ្នងនៃឫស្សី គឺផ្នែកខាងក្រៅដែលមានសាច់រលោងរលើង ហើយដុសរូតនិងជ័រដូចឆាកទ្រយើងដែរ ។ ជ័រដែលគេនិយមដុសបានស្អិតជាប់ល្អជាងគេគឺជ័រស្មុង ។ មិមមានខ្សែតែមួយ ចងភ្ជាប់ពីចុងខាងក្រោមនៃដៃបង្គួតទៅលើភ្ជាប់និងព្រលូតធ្វើពីឫស្សី ដែលគេចិតឱ្យដេញជាមួយរូបរាងដោយប្រើកាំបិត ។ ឯតួដងផ្នែកខាងលើធ្វើពីឫស្សីពីងពង់មួយដើម មានទំហំធំជាងខ្លុយខ្មែរកណ្តាលបន្តិច គ្រាន់តែមានបណ្តោយវែងជាងគឺ៦០ ស.ម ។ ផ្នែកខាងលើនៃតួដងនេះ ចុះមកក្រោមមានប្រវែង១៨ស.ម គេចោះរន្ធឱ្យធ្លាយពីម្ខាងទៅម្ខាងទៀត សម្រាប់ស៊កព្រលូត ។ ចំពោះតួដងផ្នែកខាងក្រោម គេចាំងចិតឈើឱ្យមានទំហំតូច ហើយមូលអាចស៊កចូលបំពង់ឫស្សីបានដោយលក្ខណៈជាប់តឹងណែន ។ ផ្នែកខាងចុងនៃឈើនេះ គេអាចចាំងចិតឱ្យមានរាងអែនបន្តិច និងខាងចុងបំផុតមានរាងមូលសំប៉ែតដូចប្រាក់កាក់ ។ តែក៏ត្រូវចិតឈើនោះឱ្យមានដុំតូចៗទៀត លើឈើមូលសំប៉ែតដោយចោះរន្ធតូចៗ សម្រាប់ស៊កខ្សែ ។ គេស៊កខ្សែឱ្យជាប់បានដោយការចងភ្ជាប់និងកន្លាស់ឫស្សីតូចមួយដែរ គឺទីនោះហើយដែរ ដែលគេត្រូវចងខ្សែចងខ្សែអំបោះបន្លាយមកភ្ជាប់និងស្រកាពង្រួល រួចដាក់បៀមក្នុងមាត់ ។ ដោយសារការបៀមជាប់ក្នុងមាត់មានភាពពិបាក សម្រាប់មនុស្ស

ចាស់បច្ចុប្បន្ននេះ គេបានយកខ្សែអំបោះមកភ្ជាប់និងបំពង់ឫស្សី ឬកំប៉ុងវិញ ។ ប៉ុន្តែគេត្រូវប្រើមនុស្សម្នាក់ទៀត សម្រាប់ជួយទាញបំពង់សូរនៅពេលកូតមិម ។ លើតួផ្នែកបំពង់ឫស្សីគេមាននិទខ្នង់ដោយក្រមួនឃ្មុំ ឬម្រោម ។ ខ្នង់នោះមានចំនួនបួនធ្វើអំពីឈើ ។

ជនជាតិខ្មែរលើ(គ្រឹង្គ) និង(ទំពួន) លេងមិមរួមជាមួយឧបករណ៍តន្ត្រីចំនួនពីរ ឬបីបែបប្លែកៗទៀត នៅក្រោមដំបូលផ្ទះប្រក់ស្លឹកខាន់ម៉ា ឬលេងទោលតែឯងនៅក្នុងខ្ទមសង់កណ្តាលវាលស្រែ ចម្ការជិតជ្រោះជ្រលងដងអូកណ្តាលព្រៃភ្នំអមដោយធម្មជាតិខៀវស្រស់ និងជំនោរខ្យល់ត្រជាក់ដ៏បរិសុទ្ធសម្រាប់កែអផ្សុកនៅពេលសម្រាកពីការងារ ។ ខុសប្លែកពីសម័យអង្គរ ឧបករណ៍នេះ អាចមានតួនាទីលេងកំដរការរាំរបស់នាងអប្សរានៅកណ្តាលក្រុងជាមួយនិងឧបករណ៍ (ពិណ) ដែលបាននិរាស លាចាកផុតពីប្រទេសកម្ពុជាហើយក្នុងពេលបច្ចុប្បន្ននេះ ។

## ៦_ប្រភពពូជនៃឧបករណ៍ភ្លេងមិម

ដូចបានអធិប្បាយរួចមកហើយថា នៅលើជញ្ជាំងនៃប្រាសាទបាយ័ន គេបានឃើញរូបចំលាក់អ្នកលេងភ្លេងជាច្រើននាក់ កាន់ឧបករណ៍ភ្លេងមួយប្រភេទនៅនឹងដៃ ដែលរហូតដល់ពេលនេះ គេពុំទាន់ដឹងនៅឡើយថា តើវាមានឈ្មោះអ្វី?

ជាងមួយសតវត្សមកហើយ អ្នកស្រាវជ្រាវអឺរ៉ុប ដែលជាអ្នកស្រាវជ្រាវវប្បធម៌ អារ្យធម៌ខ្មែរ ពុំទាន់បកស្រាយនូវបញ្ហានេះរួចនៅឡើយទេ ។

ក្រោមការដឹកនាំរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាពិសេស តាមការណែនាំរបស់រូបខ្ញុំបាទផ្ទាល់ ថ្មីៗនេះ អ្នកស្រាវជ្រាវ បានជួបប្រទះនូវឧបករណ៍ភ្លេងនេះនៅខេត្តក្រចេះ ដែលបងប្អូនខ្មែរលើនៅប្រើនៅឡើយ គឺមានឈ្មោះថា មិម ។

ការប្រើប្រាស់ឧបករណ៍ភ្លេងរួមគ្នារវាងខ្មែរ និងខ្មែរលើបញ្ជាក់ឱ្យដឹងថា នូវខឿនវប្បធម៌ដ៏ធំមួយ ដែលមានចំណាស់រាប់ពាន់ឆ្នាំមកហើយ ដោយទង្វើនេះ ក៏អាចសរបញ្ជាក់ថា ជនជាតិខ្មែរនេះ បានកើតនៅលើទឹកដីឥណ្ឌូចិននេះមែនពិត ដូចកុលសម្ព័ន្ធខ្មែរលើ ក៏ប៉ុន្តែពុំទទួលនូវឥទ្ធិពលវប្បធម៌ពីឥណ្ឌាតែប៉ុណ្ណោះ ។ មូលហេតុនៃការបាត់បង់មិមនេះ យើងសូមបញ្ជាក់ថា ប្រមាណជា ៨០០ ឆ្នាំមុននេះ សង្គមខ្មែរជាសម័យអង្គរ សម្បូរណ៍ដោយឧបករណ៍ភ្លេងច្រើនប្រភេទ ហើយនៅក្នុងបញ្ជីលំដាប់នៃឧបករណ៍ភ្លេងនៅជំនាន់នោះ មានឧបករណ៍ភ្លេងខ្លះ កើតចេញពីខឿនវប្បធម៌ពួង ដែលបានប្រសូតចេញមកតាំងពីសម័យបុរេប្រវត្តិសាស្ត្រមកម្ល៉េះ ។ ក្រោយពីព្រះបាទជ័យវរ្ម័នទី៧ សោយទីវង្គតទៅ ព្រះរាជាណាចក្រកម្ពុជាក្រោមចំបាំង ព្រះរាជាណាចក្រសៀម និងយួន មិនចេះស្រាកស្រាននៅក្នុងសង្គ្រាម រហូតដល់សម័យអាណានិគមបារាំងសែស ។ ក្រោយពីសម័យអង្គរស.វ.ទី១៦-១៨ នៃគ.ស. ការហូរចូលនៃវប្បធម៌អឺរ៉ុប និងឥទ្ធិពលនៃវប្បធម៌នេះ ដែលបានគ្របដណ្តប់ទៅលើខឿនវប្បធម៌ចាស់របស់ជនជាតិខ្មែរ ក៏បានធ្វើឱ្យប្រពៃណីទំនៀមទម្លាប់មួយចំនួនត្រូវបានបាត់បង់រូបរាងបន្តិចម្តងៗ គឺក្នុងករណីនេះហើយ ដែលប្រពៃណីយ៍មួយចំនួនត្រូវបានចាត់ទុកជាអត់ប្រយោជន៍ ។ ម្យ៉ាងទៀតការជម្លៀសខ្លួនសេចក្តីពី

ព្រះរាជធានីអង្គរនៅស.វ.ទី១៥ នៃគ.ស. ដោយព្រះមហាក្សត្រខ្មែរទៅកាន់ស្រីសន្ធរ លង្វែក ឧដុង្គ និងការកាន់កាប់អង្គរជាញឹកញាប់ ដោយកងទ័ពសៀមបានធ្វើឱ្យក្រុមភ្លេងក្នុងព្រះបរមរាជវាំងខ្មែរត្រូវបែកបាក់ខ្ចាត់ខ្ចាយ រហូតបាត់បងឧបករណ៍ភ្លេងខ្លះទាំងស្រុង ដូចជាពិណ និងមិម ដែលប្រហែលជាពិបាកដេញជាងគេ ។

មួយវិញទៀត ការបោះបង់ចោល ឬការបំភ្លេចសូន្យសុងនៃឧបករណ៍ខាងលើនេះ ក៏អាចបណ្តាលមកពីប្រការមួយទៀតដែរ គឺអសន្តិសុខ ដែលបានកើតមានឡើងក្នុងសម័យនោះ ធ្វើឱ្យសិល្បកររស់នៅចុងកាត់មាត់ញូកផ្តាច់ការទំនាក់ទំនងនឹងរាជធានីថ្មី ដែលស្ថិតនៅយ៉ាងឆ្ងាយពីតំបន់សៀមរាបអង្គរ គឺភ្នំពេញឯណោះ ។

ហេតុនេះហើយ បានជាយើងឃើញតែនៅតែចំលាក់នៃឧបករណ៍ភ្លេងនេះនៅលើប្រាសាទ និងនៅលើក្បាច់ផ្តែរសម័យចេនឡា ។ រីឯបងប្អូនខ្មែរលើនៅឯខេត្តរតនគីរី នៅតែនិយមប្រើភ្លេងនេះ ព្រោះពុំដែលបានទទួលវិបត្តិនយោបាយដូចអ្នកក្រុងឡើយ ។ យើងជឿជាក់ ថាពិតជានិងមានឧបករណ៍ភ្លេងមួយចំនួនទៀត ដែលយើងបានបាត់បង់ទៅហើយ ក៏ប៉ុន្តែខ្មែរយើងនាសម័យអង្គរបាននិយមយ៉ាងប្រាកដ ។

## ៧.គែនជាសម្បត្តិវប្បធម៌ខ្មែរ

គែនគឺជាឧបករណ៍សិល្បៈមួយប្រភេទ ដែលជនជាតិខ្មែរទាំងនៅតំបន់ខ្ពង់រាបនិងវាលទំនាបនៅតែពេញនិយមរាប់ស.វ.មកហើយ ។ រីឯនៅប្រទេសជិតខាងដូចជាជនជាតិថៃ-លាវនិងវៀតណាម ក៏ប្រើឧបករណ៍សិល្បៈប្រភេទនេះដូចគ្នាដែរ ដែលអាចមានមនុស្សខ្លះយល់ច្រឡំថា គែនជាឧបករណ៍សិល្បៈរបស់ជាតិសាសន៍គេទៅវិញ ។

តាមការស្រាវជ្រាវអំពីប្រភពវប្បធម៌ខ្មែរ គេពុំអាចផ្តាច់ទំនៀមទម្លាប់របស់ខ្មែរ ដែលរស់នៅតាមវាលទំនាប ចេញពីខឿនវប្បធម៌រួមនៃកុលសម្ព័ន្ធខ្មែរលើបានឡើយ ។ ព្រោះខ្មែរវាលទំនាប និងកុលសម្ព័ន្ធខ្មែរបានផ្សារភ្ជាប់យ៉ាងជិតស្និតស្នួត ពុំអាចផ្តាច់ចេញបានទាំងវប្បធម៌ពូជសាសន៍ និងប្រភេទឈាមរួមថែមទៀតផង ។

គែនគឺជាឧបករណ៍សិល្បៈរបស់កុលសម្ព័ន្ធ ដែលពួកគេមានដើមកំណើតចេញពីវប្បធម៌និងអារ្យធម៌មន-ខ្មែរ ឬខ្មែរ-មនតាំងពីមុនការហូរចូលនៃឥទ្ធិពលឥណ្ឌានិងចិនមកម្លេះ ។ ជនជាតិខ្មែរបានបង្កើតរដ្ឋចាប់តាំងពីដើមស.វ.ទី១ នៃគ.ស. ក្រោមឥទ្ធិពលនៃវប្បធម៌ឥណ្ឌា ដែលកាលណោះហៅថាជនជាតិមន- ខ្មែរ ។

ជនជាតិមន-ខ្មែរ ឬខ្មែរ-មនបានរស់នៅតាមព្រៃភ្នំ ដូចជាពួកស្ទួច, សម្រែ, ព្រូវ, កួយ, ពណិនិងចុងជាដើម ដែលនិយមហៅថាខ្មែរដើម ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏ទាំងជនជាតិខ្មែរមានរដ្ឋទាំងកុលសម្ព័ន្ធមន-ខ្មែរ ពុំទាន់មានរដ្ឋ ដែលរស់នៅតាមរបៀបបុរាណនោះ គេឱ្យឈ្មោះថាព្នង (ភ្នំ) ។

កុលសម្ព័ន្ធ គឺជាជនជាតិអម្បូរមន-ខ្មែរតែមួយ ដែលបានតពូជពង្សរហូតមក ជាមួយនិងការថែរក្សាសិល្បៈវប្បធម៌គែននេះផងដែរ ។ វត្ថុសិល្បៈគែននេះ ពុំត្រឹមតែមានការពេញនិយមនៅសម័យសង្គមបច្ចុប្បន្ននេះប៉ុណ្ណោះទេ តែការរកឃើញគ្រោងឆ្អឹងនៅក្នុងស្ថានីយបុរេប្រវត្តិសាស្ត្រ ក៏បានបង្ហាញឱ្យដឹងយ៉ាងច្បាស់ថា ឧបករណ៍សិល្បៈនេះ (គែន) គឺជាសម្បត្តិវប្បធម៌របស់ជនជាតិខ្មែរយ៉ាងពិតប្រាកដ ។

តែដោយឡែក ឧបករណ៍គែន ក៏ត្រូវបានជនជាតិប្រទេសជិតខាងកម្ពុជា ដូចជាជនជាតិវៀតណាមភាគកណ្តាល ភាគខាងត្បូងជនជាតិថៃ និងលាវរហូតមកដល់ជនជាតិភូមាទៀតផង ក៏នៅតែប្រើឧបករណ៍គែនជាសិល្បៈជនជាតិរបស់គេផងដែរ ។ ដោយគ្រាន់តែយើងយល់ថា ខ្មែរយើងពុំបានខ្ចីឧបករណ៍គែន មកប្រើដូចជាការយល់ច្រឡំនៃមនុស្សមួយចំនួនណានោះឡើយ ។

## ៨-ប្រភពពួចនៃឃ្មោះខ្មែរ

ពាក្យឃ្មោះកើតចេញពីពាក្យគោះ ជាឧបករណ៍តន្ត្រីមួយប្រភេទ ដែលធ្វើឡើងអំពីស្ពាន់សំរិទ្ធ។ ឃ្មោះនិងគងស្ថិតក្នុងប្រភេទឧបករណ៍តែមួយ ក៏ប៉ុន្តែមានខ្នាតខុសគ្នាតែប៉ុណ្ណោះ ។

នៅតាមវត្តអារាមខ្មែរបច្ចុប្បន្ននេះ គេប្រើឃ្មោះសម្រាប់គោះហៅពុទ្ធសាសនិកជន ឬប្រមូលផ្តុំអ្នកស្រុក ដើម្បីប្រារព្ធពិធីបុណ្យផ្សេងៗ ។ ដើម្បីបង្ករឱ្យមានបរិយាកាសរីករាយអង់អាចក្លាហាន ខ្មែរនៅសម័យព្រះបាទជ័យវរ្ម័នទី៧ (១១៦២-១២០១គ.ស) បានប្រើឧបករណ៍ភ្លេងជាច្រើន ដូចជាគង

រគាំង..។ល។ ប្រើក្នុងក្បួនហែទ័ពនៅពេលចេញទៅធ្វើសឹកសង្គ្រាមម្តងៗ ដែលគេរមែងតែងតែឃើញវង់ភ្លេងហែហមតាមក្បួនជានិច្ច ដូចមានបង្ហាញនូវក្នុងចម្លាក់នៅលើជញ្ជាំងប្រាសាទបាយ័នជាសក្ខីភាពស្រាប់ ។ លុះមកដល់សម័យទំនើប គឺសម័យអាណានិគមបារាំង (១៨៦៣) វង់ភ្លេងហែតាមក្បួនទ័ព ក៏ឈប់មានទៀត ក៏ប៉ុន្តែការប្រើឧបករណ៍ភ្លេងខ្លះ ដូចជាការនិយមឃ្មោះនៅតែជ្រួតជ្រាបក្នុងមជ្ឈដ្ឋានប្រជាពលរដ្ឋដែលរស់នៅតាមជនបទ វត្តអារាមជាដើម ។

ទោះជាតូរ្យតន្ត្រីខ្មែរមានការវិវត្តយ៉ាងណាក៏ដោយ ក៏ឧបករណ៍ភ្លេងខ្មែរមួយចំនួនធំ ដែលកើតចេញពីឡើនវប្បធម៌សម័យអង្គរ ឬមុនអង្គរ នៅតែរក្សានូវតួនាទីយ៉ាងសំខាន់របស់ខ្លួនក្នុងសង្គមខ្មែរដដែល ក្នុងវត្តអារាម ឬក្នុងពិធីការផ្សេងៗ ។ តាមរយៈនៃឧបករណ៍ភ្លេង គេអាចឃើញនូវនិរន្តរភាពរបស់វប្បធម៌ អារ្យធម៌ខ្មែរយើង ។

ចំពោះប្រភពរបស់ឧបករណ៍នេះ តាមការស្រាវជ្រាវរបស់យើងបានឱ្យដឹងថា គងឬឃ្មោះពិតជាឧបករណ៍ខ្មែរសុទ្ធសាធ ដែលបានកើតចេញពីឡើនវប្បធម៌មន-ខ្មែរ ហើយឡើនវប្បធម៌នេះ បានមានកំណើតច្រើនពាន់ឆ្នាំមុនសម័យប្រវត្តិសាស្ត្រ ។ គួរបញ្ជាក់ផងដែរថា បងប្អូនខ្មែរលើសព្វថ្ងៃនេះ នៅប្រើឧបករណ៍នេះដដែល ។ ឧបករណ៍នេះ បានឱ្យគេដឹងយ៉ាងច្បាស់នូវចំណាស់ឫសកែវវប្បធម៌ខ្មែរ ។

អ្វីដែលគួរកត់សម្គាល់ផងដែរនោះ គឺខុសពីជនជាតិអម្បូរមន-ខ្មែរនៅប្រទេសយួនខាងត្បូង និងលាវ ដែលគេនិយមគោះឧបករណ៍នេះដោយដៃ

ច្រើនជាងព្យួរ សម័យអង្គរ ខ្មែរប្រើវាក្នុងក្បួនដង្ហែទ័ព ដោយព្យួរលើឈើខ្ពស់មួយ ដែលមានមនុស្សពីរនាក់សែងលើស្មា ។

## ៩-ប្រវត្តិមន-ខ្មែររបស់គែនខ្មែរ

អ្នកស្រាវជ្រាវផ្នែកតូរ្យតន្ត្រីបែរជានៅស្ងៀម នៅពេលដែលឃើញជនជាតិលាវប្រើឧបករណ៍គែន ហើយរហូតមកដល់សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈខ្លះនិយាយថាៈ ឧបករណ៍ភ្លេងខ្មែរនេះ បានចម្លងមកពីជនជាតិលាវតែប៉ុណ្ណោះ ហើយបន្ថែមទៀតថា បច្ចុប្បន្នឧបករណ៍គែននេះ គឺជាភ្លេងប្រពៃណីរបស់ជនជាតិលាវទៀតផង ឯខ្មែរយើងគ្រាន់តែប្រើប្រាស់ ម្តងម្កាលតែប៉ុណ្ណោះ ។

ការយល់ឃើញបែបនេះ មិនបានបណ្តាលឱ្យប្រវត្តិសាស្ត្រពេញចិត្តនៅស្ងៀមឡើយ ដោយបានបង្ហាញថា គេភ្លេចថា ជនជាតិលាវដែលកំពុងរស់នៅលើទឹកដីឡាវបច្ចុប្បន្ននេះ ក៏ជាជនជាតិអន្តោប្រវេសន៍ ដូចជនជាតិមួយចំនួនទៀតដែរ ។

ប្រវត្តិសាស្ត្រលាវមាននយោបាយ និងសង្គមថ្មីថ្មោងណាស់ ដូចជាជនជាតិថៃ នៅស.វ.ទី១៣នៃគ.ស.នេះដែរ គឺមិនអាចនិយាយថា ឧបករណ៍ភ្លេងនេះជារបស់ជនជាតិលាវឡើយ ។

ដោយសម្អាងទៅលើវត្ថុសិល្បៈ ដែលគេបានរកឃើញនៅក្នុងស្ថានីយបុរេប្រវត្តិសាស្ត្រខ្លះ គេសង្កេតឃើញថា សហគមន៍ខ្មែរ-មនមួយចំនួន ដែលរស់នៅក្នុងភូមិភាគឥណ្ឌូចិនទាំងមូល យូនខាងត្បូង កណ្តាល និងប្រទេសលាវ

បច្ចុប្បន្នជាដើម និយមប្រើឧបករណ៍ភ្លេងនេះណាស់ ។ ដោយសារបុព្វបុរសខ្មែរនិយមចូលចិត្តប្រើប្រាស់ឧបករណ៍គែននេះ ប្រមាណជាជាង២៣០០ឆ្នាំមកហើយនោះ កេរ្តិ៍មតិកនេះក៏បានរីកផ្សព្វផ្សាយពេញឧបទ្វីបឥណ្ឌូចិន តាំងពីពេលនោះមក ។

ក្រឡេកមើលប្រវត្តិសាស្ត្រក្នុងភូមិភាគនេះ នៅជិតពាក់កណ្តាលដើម ស.វ.ទី១៣នៃគ.ស. គេអាចសន្និដ្ឋានបានថា ស្ថានភាពវប្បធម៌ នយោបាយនៃភូមិភាគនេះ ត្រូវបានប្រែប្រួល ដោយការបង្កើតនៃរដ្ឋថ្មីពីរទៀត គឺព្រះរាជាណាចក្រសៀម និងលាវ នៅលើតំបន់ដែលជាអតីតទឹកដីខ្មែរ ។ លើសពីនេះទៅទៀតនោះ ក្រោយពីទទួលបានជ័យជំនះ និងអំណាចក្នុងដៃអ្នកដឹកនាំប្រទេសថ្មីទាំងពីរនេះ ក៏បានប្រតិបត្តិព្រះពុទ្ធសាសនាថេរវាទ ដោយទទួលស្គាល់ព្រះពុទ្ធសាសនាជាសាសនាប្រចាំជាតិរបស់ខ្លួន ។ នេះជាបដិវត្តន៍សាសនាយ៉ាងធំ ពីព្រោះចាប់ពីនោះមក ព្រហ្មញ្ញសាសនាត្រូវចុះទន់ខ្សោយ ។ សំខាន់វប្បធម៌របស់ជនជាតិខ្មែរបានត្រូវជនអន្តោប្រវេសន៍ប្រើជាបន្តបន្ទាប់ ហើយក៏បានក្លាយទៅជាប្រពៃណីរបស់ជនជាតិទាំងនោះ ដូចជាឧបករណ៍គែនសព្វថ្ងៃនេះដែរ ។

គួររំលឹកផងដែរថា រចាំគែនដែលគេបញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈបច្ចុប្បន្ននេះ គឺជាស្នាព្រះសហស្ថរបស់ព្រះមហាក្សត្រខ្មែរ ហើយការបញ្ចូលរបាំគែននេះទៅក្នុងវិស័យតូរ្យតន្ត្រី បានធ្វើឱ្យវិស័យសិល្បៈខ្មែរមានមុខមាត់គួរជាទីមោទនភាព ។

ចុះហេតុដូចម្តេច បានជាខ្មែរក្នុងសម័យបុរាណមិនឆ្លាក់របាំគែននេះ

នៅតាមប្រាង្គប្រាសាទ ?

គ្មានអ្វីចម្លែកទេ ចុះហេតុអ្វីបានជាយើងមិនឆ្ងល់ថា របាំត្រុដិដែលខ្មែរយើងនិយមចូលចិត្ត និងល្បីល្បាញបំផុត ម្តេចក៏បុព្វបុរសយើងមិនឆ្លាក់នៅតាមប្រាង្គប្រាសាទដែរ ?។ ប្រការនេះ មិនមែនបញ្ជាក់ថា ខ្មែរមិនចូលចិត្តរបាំគែននោះទេ ក៏ប៉ុន្តែគែនជាឧបករណ៍ភ្លេងរបស់មនុស្សខ្មែរ ដែលរស់នៅតាមព្រៃភ្នំ ដែលមិនមែនជាប្រពៃណីរបស់មនុស្សនៅតាមវាលទំនាបនោះទេ ។

ក្នុងករណីនេះហើយ ដែលខ្មែរយើងបុរាណពុំបានចាត់ទុកថា គែនជារបាំដ៏ស័ក្តិសិទ្ធិក្នុងបញ្ជីឧបករណ៍របស់ខ្លួនឡើយ ។ ការចាត់ចំណាត់ថ្នាក់ ឧបករណ៍ភ្លេងខាងលើនេះ បណ្តាលមកពីការមិននិយមរបស់ខ្មែរ ដែលរស់នៅតាមវាលទំនាប ។

រួមសេចក្តីមក គេមិនអាចនិយាយថា ខ្មែរមិនស្គាល់ឧបករណ៍គែននេះទេក្នុងអតីតកាល ។ សូមបញ្ជាក់ថា មុននិងឈានដល់សម័យតន្ត្រីទំនើបខ្មែរ បានឆ្លងកាត់ប្រពៃណីគែនក្នុងអតីតកាលមកជាយូរលង់ណាស់មកហើយ ។

## ១០-រាំវង់ ជារបាំតំណែលមន-ខ្មែរ ដែលនៅតែមានប្រជាប្រិយភាព

របាំរាំវង់ជារបាំប្រពៃណី ដែលជនជាតិខ្មែរនិយមចូលចិត្ត មានរយៈពេលរាប់ពាន់ឆ្នាំមកហើយ ។ ទោះបីជារបាំនេះ មានប្រភពចេញពីសម័យមន-ខ្មែរ ដែលមានអាយុកាលរាប់ពាន់ឆ្នាំហើយក៏ដោយ ក៏របាំរបស់ខ្មែរមួយប្រភេទនេះ នៅតែជាការពេញនិយមនៅគ្រប់ជំនាន់ បន្តរហូតមកទល់សព្វថ្ងៃនេះ ។

របាំរាំវង់ជារបាំប្រពៃណីរបស់ខ្មែរ ដែលមានការនិយមចូលចិត្តរាំលេងសប្បាយនៅពេលបុណ្យទានផ្សេងៗ ដូចជាចូលឆ្នាំ ឡើងផ្ទះ និងពិធីតូចធំ ទាំងក្នុងគ្រួសារ ក៏ដូចជាពិធីរបស់ជាតិជាដើម ។ របាំរាំវង់ជាកេរ្តិ៍តំណែលពីសម័យមន-ខ្មែរ ដែលបានប្រសូត្រពីឋឿនវប្បធម៌បុរេប្រវត្តិសាស្ត្រ ។ តឹកតាងនៃរបាំនេះ បានបង្ហាញជារូបភាពរង្វង់មូល ដូចជាគំនូរផាត់ពណ៌នៅតាមជញ្ជាំងភ្នំ ដែលគេដឹងថា ជារបាំប្រពៃណី កើតមានឡើងតាំងពីមុនពេលខ្មែរទទួលឥទ្ធិពលពីឥណ្ឌាមកម្ល៉េះ ។

ពាក្យពីរម៉ាត់ "រាំវង់" គឺជាពាក្យមន-ខ្មែរ ដោយមានន័យថា គេរាំវង់ជារង្វង់មូល ឈរបន្តគ្នា និងមានការសប្បាយរីករាយ ។ របាំរាំវង់ដែលជានិមិត្តរូបនៃវង់មូល ឬរង្វង់មូលនេះ វាមានតម្លៃជាសាកល មានអាយុកាលច្រើនពាន់-ម៉ឺនឆ្នាំមកហើយ ដែលទាក់ទិនជានិច្ចកាលទៅជាមួយនិងមនោគមន៍វិជ្ជាសាសនា ។

តាមទស្សនៈរបស់ខ្មែរ ក៏ដូចជាមនុស្សនៅលើសាកលលោកដែរ វង់មូលជាសញ្ញាមួយ ដែលមានលក្ខណៈពិសិដ្ឋ ដែលតំណាងនូវភាពសុខសប្បាយសិរីមង្គល និងភាពគ្រជាក់ត្រជំ ។ មនុស្សណា ឬវត្ថុណាស្ថិតនៅក្នុងរង្វង់មូលនេះ អាចគេចផុតពីគ្រោះភ័យទាំងឡាយបាន ។

ទស្សនៈរបស់ខ្មែរបុរាណ រង្វង់មូលតំណាងនូវជីវិត និងភាពអមតៈ ។ គេមានទស្សនៈយល់ឃើញថា នៅក្នុងក្រសែភ្នែករបស់មនុស្ស បានកើតចេញពីរង្វង់មូលនៃកែវភ្នែកនេះឯង ។ ឯទឹកអង្គជាតិរបស់បុរស ដែលផ្ទុកនូវឫសកែវនៃជីវិត ដែលផ្សំគ្នាក្នុងគភ៌ស្ត្រីភេទ រហូតក្លាយទៅជារូបរាងកាយទារក ក៏

កើតចេញពីចំណុចរង្វង់មូលនេះដែរ ។ ឯសញ្ញាដែលពាក់ព័ន្ធទៅនិងរង្វង់មូល ជាច្រើនទៀត ដូចជាតួចខ្សែង ទឹក, ព្យុះសង្ឃរា, និងព្រះអាទិត្យ ព្រះច័ន្ទ ជាដើម វាជានិមិត្តរូបនៃរង្វង់មូលនៃជីវិត ។ ដូចនេះ បុព្វការីជនខ្មែរបានប្រសិទ្ធនាមពាក្យថា រាំវង់នេះ វាពុំមែនជាការចៃដន្យឡើយ ។

កត្តាខាងលើនេះហើយ ដែលជាមូលហេតុនាំឱ្យជនជាតិខ្មែរយើង "បង្កើតរបាំរាំវង់" នេះឡើង ជារបាំប្រពៃណី មុននិងក្លាយជារបាំប្រជាប្រិយ ។ ទាំងខ្មែរជនជាតិភាគតិច ទាំងខ្មែរកណ្តាល មានការនិយមរបាំនេះបន្តរហូតមក ទើបជាភស្តុតាងបង្ហាញថា របាំរាំវង់នេះ មានប្រភពចេញមកតាំងពីសម័យមន-ខ្មែរ ដែលជាមតិកវប្បធម៌របស់ខ្មែរ បានប្រសូត្រឡើងពីសម័យបុរេប្រវត្តិសាស្ត្រយ៉ាងពិតប្រាកដ ។ សូមរំលឹកថា ជនជាតិថៃ លាវ ប្រើពាក្យ ឡាំវង់តាមពាក្យខ្មែរដែរ ។

**សំយោគ**

គប្បីត្រូវដឹងថា " គ្មានវប្បធម៌ណាមួយដែលពុំមានការចងចាំនោះទេ" បើពុំដូច្នោះទេ គឺពុំមែនជាវប្បធម៌លើយ ។

អត្តសញ្ញាណជាតិសាសន៍ខ្មែរ ដែលស្ថិតនៅក្នុងអម្បូរមន-ខ្មែរ មិនអាចផ្តាច់ចេញពីខឿនវប្បធម៌បុរេប្រវត្តិសាស្ត្រ និងពីកុលសម្ព័ន្ធខ្មែរ ឬជនជាតិព្រៃភ្នំបានឡើយ ។

ភាពខុសគ្នារវាងខឿនវប្បធម៌មន-ខ្មែរ ទៅនិងខឿនវប្បធម៌នៃជនជាតិសាសន៍ដទៃ ដែលស្ថិតនៅក្នុងអម្បូរចិន គឺអម្បូរថៃ-វៀត ដែលក្នុងអម្បូរនេះ គេបានបញ្ចូលជនជាតិលាវឬឡាវផងនេះ គឺអាចសន្និដ្ឋានតាមរយៈសម្លៀក

បំពាក់ ទំនៀមទម្លាប់ ដែលចុងក្រោយបង្ហាញឱ្យដឹងពីអត្តសញ្ញាណនៃជាតិសាសន៍នីមួយៗ ដែលមានលក្ខណៈសម្បត្តិខុសគ្នា ។

បើទោះបីតាមរយៈការសិក្សាស្រាវជ្រាវវិភាគ បានបង្ហាញឱ្យដឹងថា ទំនាក់ទំនងខាងវប្បធម៌ខ្មែរដើម ប្រមាណជា២០០០ឆ្នាំមកហើយក៏ដោយ ដោយព្រឹត្តិការណ៍ឥណ្ឌូបនីយកម្ម ក៏អត្តសញ្ញាណជាតិសាសន៍ខ្មែរបច្ចុប្បន្ន ដែលប្រកាន់នូវប្រពៃណីបែបឥណ្ឌា និងកុលសម្ព័ន្ធខ្មែរលើ ពុំអាចផ្តាច់ចេញពីគ្នាឱ្យ ដាច់ស្រឡះបានឡើយ ។

វាកាន់តែច្បាស់លើសនេះទៀត គឺការសិក្សាខាងមុខវិជ្ជាបុរាណវិជ្ជា ជាពិសេសខាងបុរេប្រវត្តិសាស្ត្រវិទ្យា និងជាតិពន្ធុវិទ្យា កាន់តែធ្វើឱ្យយើងយល់ច្បាស់អំពីឥទ្ធិពលនៃវប្បធម៌ឥណ្ឌាមកលើសង្គមខ្មែរក្នុងអតីតកាល ជាហេតុបណ្តាលឱ្យមានគម្លាតខាងហេដ្ឋារចនាសម្ព័ន្ធ ពោលគឺការរៀបចំសង្គមរវាងជនជាតិខ្មែរដែលរស់នៅវាលទំនាប ឬតាមឆ្នេរសមុទ្រ និងជនជាតិខ្មែររស់នៅតាមខ្ពង់រាប ឬតាមព្រៃភ្នំទាំងឡាយ ។ គឺការប្រែប្រួលនៃហេដ្ឋារចនាសម្ព័ន្ធនេះហើយ ដែលជាមូលហេតុនៃការបង្កើតរដ្ឋខ្មែរដំបូង ដែលយើងបានសិក្សាវិភាគរួចមកហើយ ។

ក៏ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ជនជាតិខ្មែរដែលបានរស់នៅក្នុងសង្គមនាសម័យបុរេប្រវត្តិសាស្ត្រ តាមរយៈសំណល់វត្ថុវប្បធម៌បុរាណ និងសង្គមនាសម័យប្រវត្តិសាស្ត្រ ដែលបានចាប់ផ្តើមឡើងចាប់ពីស.វ.ទី១នៃគ.ស.មក ថ្វីដ្បិតតែបានកាន់ប្រពៃណីឥណ្ឌាមួយចំនួនធំក៏ដោយ ពួកគេបានបន្សល់ទុក ជាមួយនិងកុលសម្ព័ន្ធខ្មែរលើបច្ចុប្បន្ន នូវកេរ្តិ៍មតិកវប្បធម៌រួមគ្នា គួរឱ្យមោទនៈ ។

ទាំងនេះ ជាសញ្ញាណបង្ហាញឱ្យឃើញនូវប្រភពរួមនៃវប្បធម៌ពូជសាសន៍ រវាងខ្មែរដែលរស់នៅតាមវាលទំនាប និងខ្មែរដែលរស់នៅតាមព្រៃភ្នំជាច្រើនរាប់មិនអស់ ។

ភាពឧត្តុង្គឧត្តម ឬឧត្តមភាព ក៏ដូចជាចំណាស់នៃខឿនវប្បធម៌ អារ្យធម៌ខ្មែរ និងពូជសាសន៍ខ្មែរ ដែលបានកើតនៅលើជ្រោយឥណ្ឌូចិននេះ ចេញពីមូលដ្ឋានមន-ខ្មែរ ឬខ្មែរ-មនតាំងពីសម័យបុរេប្រវត្តិសាស្ត្រ រួមមានសម្លៀកបំពាក់ ដូចជាប៉ឹង សំពត់ (សារ៉ុង) និងគ្រឿងអលង្កា ដូចជាត្រសាលត្រចៀក កងដៃ កងជើង ជាភស្តុតាងនៃនិរន្តរភាពខាងវប្បធម៌ ដែលគេមិនអាចមិនចាប់អារម្មណ៍កាលបើគេចង់ស្វែងយល់អំពីខ្មែរ ។

សូមជម្រាបថា ទំនៀមទម្លាប់បែបនេះ វាពុំអាចប្រើសម្រាប់មនុស្សអម្បូរចិន ឬជាតិសាសន៍ដទៃទៀតបានឡើយ ដែលជាមនុស្សចំណូលថ្មីក្នុងតំបន់ ។ ដោយហេតុថា ពូជសាសន៍និងសង្គមវប្បធម៌នីមួយៗ ពុំអាចកើតឡើង ដោយពុម្ពតែមួយដូចគ្នានោះបានទេ ។

គឺឯកភាពផ្នែកខឿនវប្បធម៌ ដែលឆ្លុះបញ្ចាំងតាមរយៈវត្ថុវប្បធម៌បុរាណ ដែលបានរកឃើញក្នុងស្ថានីយបុរេប្រវត្តិសាស្ត្រក្នុងប្រទេសកម្ពុជា ប្រទេសថៃ លាវ ប្រទេសវៀតណាមបច្ចុប្បន្ន ធ្វើឱ្យយើងសន្និដ្ឋានយ៉ាងត្រឹមត្រូវបានថា ខឿនវប្បធម៌ខ្មែរបច្ចុប្បន្ន ដែលជាមែកធាងនៃខឿនវប្បធម៌ បានប្រសូត្រចេញពីខឿនមូលដ្ឋានគ្រឹះនៃមន-ខ្មែរ នាសម័យបុរេប្រវត្តិសាស្ត្រ ។

ម្យ៉ាងវិញទៀត ត្រូវជ្រាបថា អត្តសញ្ញាណជាតិសាសន៍ខ្មែរមិនត្រូវផ្តាច់ចេញពីកុលសម្ព័ន្ធមន-ខ្មែរ ដែលរស់នៅព្រៃភ្នំ ឬវាលទំនាបបានឡើយ ។

ភាពខុសគ្នារវាងខឿនវប្បធម៌មន-ខ្មែរ ទៅនិងខឿនវប្បធម៌នៃជាតិសាសន៍ដទៃ ដែលស្ថិតក្នុងអម្បូរឡាវ-ថៃ-វៀតណាម និងចិន គឺអាចសន្និដ្ឋានតាមរយៈសម្លៀកបំពាក់ ទំនៀមទម្លាប់ ដែលចុងក្រោយបង្ហាញឱ្យដឹងពីអត្តសញ្ញាណនៃជាតិសាសន៍នីមួយៗ ។

បើទោះបីជាតាមរយៈការសិក្សាស្រាវជ្រាវបានបង្ហាញឱ្យដឹងថា ទំនាក់ទំនងខាងវប្បធម៌កុលសម្ព័ន្ធខ្មែរលើ និងខឿនវប្បធម៌មន-ខ្មែរ បានបែកបាក់ពីគ្នាប្រមាណ២០០០ឆ្នាំហើយក៏ដោយ ក៏អត្តសញ្ញាណជាតិសាសន៍ទាំងខ្មែរបច្ចុប្បន្ន និងកុលសម្ព័ន្ធខ្មែរលើ ពុំអាចផ្ដាច់ចេញពីគ្នាបានឡើយ ។

វាកាន់តែច្បាស់ជាងនេះទៅទៀតនោះ គឺការសិក្សាខាងមុខវិជ្ជាបុរាណវិទ្យា និងជាតិពន្ធុវិទ្យា កាន់តែធ្វើឱ្យយើងយល់កាន់តែច្បាស់ ពីឥទ្ធិពលវប្បធម៌ឥណ្ឌាមកលើសង្គមខ្មែរក្នុងអតីតកាល ។

សង្គមខ្មែរនាសម័យបុរេប្រវត្តិសាស្ត្រ តាមរយៈវត្ថុវប្បធម៌បុរាណ និងសង្គមប្រវត្តិសាស្ត្រ ជាមួយនិងកុលសម្ព័ន្ធខ្មែរ ពិតជាបានបន្សល់ទុកនូវកេរ្តិ៍មតិកវប្បធម៌រួម រវាងខ្មែរវាលទំនាប និងខ្មែរលើ ជាច្រើនរាប់សិបមិនអស់ ។

ភាពឧត្ដុងឧត្ដមរបស់ពូជសាសន៍ខ្មែរ ដែលកើតចេញពីមូលដ្ឋានខ្មែរ-មន រួមមានសម្លៀកបុំពង់ និងការពាក់កងដៃ កងជើង ចិញ្ចៀន ក្រវិលត្រចៀកធ្វើអំពីស្ពាន់ ឬសរិទ្ធិជាដើម ។

ក្រៅពីនេះ មនុស្សខ្មែរវាលទំនាប និងខ្មែរលើ ដែលបានរួមឈាមជ័រពូជសាសន៍ជាមួយគ្នានាពេលអតីតកាលនោះ ពួកគេជាភេទស្រី តែងនិយមចូលចិត្តសំពត់ ឬសម្លៀកបំពាក់សម្រាប់បិទបាំងកេរ្តិ៍ខ្មាស់និងរាងកាយ ។ ទំនៀម

ទម្លាប់បែបនេះ វាពុំអាចប្រើសម្រាប់មនុស្សអម្បូរចិន ឬជាតិសាសន៍ដទៃទៀតបានឡើយ ។ ម្យ៉ាងវិញទៀត ចំពោះពូជសាសន៍ និងសង្គមវប្បធម៌នីមួយៗ ពុំអាចកើតឡើងដោយពុម្ពតែមួយដូចគ្នាបានឡើយ ។

វប្បធម៌អម្បូរចិន ពិតជាបានកើតឡើងមុនសម័យឥណ្ឌូបនីយកម្មយ៉ាងប្រាកដ ។ ចំណែកនិរន្តរភាពនៃខឿនវប្បធម៌ខ្មែរ ដែលបានប្រសូត្រចេញពីខឿនវប្បធម៌មន-ខ្មែរ នាសម័យបុរេប្រវត្តិសាស្ត្រ គឺមានភស្តុតាងជាច្រើនឥតគណនា ដែលគេបានរកឃើញក្នុងប្រទេសកម្ពុជា, ឡាវ, ថៃ ដែនដីសណ្ដនិងនៅតាមឆ្នេរសមុទ្រនានា ដែលនេះ គ្រាន់តែជាមែកធាងនៃវប្បធម៌មន-ខ្មែរតែប៉ុណ្ណោះ ។

# ជំពូក៥

## ឧបសម្ព័ន្ធ

## សេចក្ដីផ្ដើម

ក្នុងការចងក្រងសៀវភៅនេះឡើង យើងបានជួបប្រទះនូវអត្ថបទមួយចំនួនចុះផ្សាយក្នុទំព័រកាសែតរស្មីកម្ពុជា ដែលមានតម្លៃវប្បធម៌ គួរឱ្យចាប់អារម្មណ៍ជាអតិបរមា ។ ដោយមិនចង់ឱ្យគេបំភ្លេចចោលនូវន័យស៊ីជម្រៅរបស់អត្ថបទទាំងនោះ យើងក៏បានភ្ជាប់វាក្នុងឯកសាររបស់យើងនេះ គ្រាន់តែទុកជាឯកសារយោង ឬពិចារណា ។ សូមឱ្យអ្នកនិពន្ធនៃអត្ថបទស្រាវជ្រាវទាំងនោះទទួលនូវក្ដីស្រឡាញ់គោរពនិងអំណរគុណដ៏ជ្រាលជ្រៅអំពីខ្ញុំ ដែលជានិច្ចកាលមានមនោសញ្ចេតនាដូចពួកគេដែរ ក្នុងពេលដែលជួបបងប្អូនជនជាតិខ្មែរលើទាំងនោះម្ដង១ ទោះជាស្ថិតក្នុងកាលៈទេសៈណាក៏ដោយចុះ ។

សូមជម្រាបផងដែរថា រាល់ការបកស្រាយរបស់អ្នកនិពន្ធទាំងនោះ សឱ្យដឹងថា នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងនៅមានកុលសម្ព័ន្ធខ្មែរ-មន ឬខ្មែរលើជាច្រើនលើសលប់ តាមខេត្តនានាមួយចំនួនពុំទាន់បានក្លាយទៅជាពុទ្ធសាសនិកថេរវាទនៅឡើយទេ ហើយពួកគេនៅថែរក្សាទម្រង់វប្បធម៌មន-ខ្មែរដើមរបស់ពួកគេ ដែលជាភស្ដុតាងវប្បធម៌មានអាយុរាប់ពាន់ឆ្នាំមកហើយ ។ អ្វីដែលអាចនាំមកឱ្យយើងកាន់តែយល់ច្បាស់នូវសារៈជាតិដើម នៃប្រព័ន្ធគំនិតរបស់មនុស្សខ្មែរ ។

## ១-ជនជាតិគួយនិងការរស់នៅ (១)

"ជនជាតិគួយក៏ត្រូវបានគេអះអាងថា ជាខ្មែរដើមដែរ តែសព្វថ្ងៃជនជាតិគួយគឺជាកុលសម្ព័ន្ធ ដែលរស់នៅតាមភូមិដាច់ស្រយាលភាគខាងជើងនៃខេត្តកំពង់ធំ និងមួយផ្នែកទៀតរស់នៅក្នុងខេត្តព្រះវិហារ ។

តាមការសិក្សាស្រាវជ្រាវរបស់លោកអ៊ុម សុខ ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ធំ លោកបានគូសបញ្ជាក់ថា ក្រុមកុលសម្ព័ន្ធនេះ ត្រូវបានគេបែងចែកជាច្រើនពួកទៅទៀត ដូចជាកួយ អន្ត្រែរ កួយដឺរ កួយនលី និងកួយអកជាដើម ។ ប៉ុន្តែរបៀបរបបនៃការរស់នៅរបស់ពួកគេ ស្រដៀងគ្នាគ្រាន់តែភាសានិយាយខុសគ្នាបន្តិចបន្តួចប៉ុណ្ណោះ ។ តាមឯកសាររបស់លោកអ៊ុម សុខបានសរសេរថា ជនជាតិកួយច្រើនមានមាឌតូច ទាប មានសម្បុរសណ្ដែកបាយ ។ ពួកប្រុសៗច្រើនស្លៀកខោខ្លី ឬពាក់អាវបំពង់ជ្រលក់ពណ៌ខ្មៅ (កាលសម័យដើម) ចំណែកឯស្រីៗវិញ ច្រើនស្លៀកសំឡុយ ពាក់អាវបំពង់ (កាលសម័យដើម) ហើយទុកសក់បួកគ្រប់គ្នា ។ លក្ខណៈពិសេសរបស់ក្រុមនេះ គឺដើរលឿន ពូកែរែក ឬទូលបានយ៉ាងមាំទាំ ហើយពូកែអត់ធន់និងការងារហត់នឿយទៀតផង ពួកកួយមិនចេះខ្លាចសត្វសាហាវទេ ។

ចំណែកឯផ្ទះសម្បែងរបស់ពួកកួយ មានលក្ខណៈមិនខុសគ្នាប៉ុន្មានពីផ្ទះរបស់ខ្មែរយើងទេ គឺគេនិយមសង់ផុតពីដី ក្រាលរនាបឬស្សី ប្រក់ស្បូវ ឬស្លឹកជញ្ជាំងច្រើនតែបាំងស្លឹក ឬបន្ទាំងឬស្សី ។ ថ្វីត្បិតតែពួកកួយរស់នៅក្នុងស្រុក

---

១-រស្មីកម្ពុជា ថ្ងៃទី១៨ កុម្ភៈ ២០០០

សម្បូរព្រៃឈើ ហើយប្រកបមុខរបរអាររណ្ដៅលក់ដីដោយ ក៏ពួកគេពុំសូវសង់ផ្ទះ ឬបាំងជញ្ជាំងក្ដាឡើយ ។ គេនិយមចិញ្ចឹមសត្វឆ្កែណាស់ ព្រោះឆ្កែអាចការពារផ្ទះ និងដេញចាប់សត្វព្រៃធ្វើជាអាហារបាន ។ រីឯមុខរបរវិញពួកគេប្រកបមុខរបរធ្វើស្រែនិងធ្វើចំការ បោចវល្លិ រើសជ័រ កាប់ឈើ អារឈើ ប្រមាញ់ និងការដាក់អន្ទាក់ ឬដេញចាប់សត្វព្រៃ ។ល។ ពួកកួយបានកាប់ព្រៃធ្វើចម្ការផ្លាស់ប្ដូរពីកន្លែងមួយទៅកន្លែងមួយផ្សេងទៀតរៀងរាល់ឆ្នាំ ព្រោះគេយល់ថា ការធ្វើចម្ការនៅកន្លែងដដែល១ពុំសូវបានផលទេ ។ ពួកគេដើរទៅធ្វើចម្ការឆ្ងាយ១ពីភូមិរហូតដល់១០ ឬ១៥គម ប៉ុន្តែពួកគេមិនដែលត្អូញត្អែថាឆ្ងាយឡើយ ។ គេបានពិពណ៌នាថា កំលោះកួយនៅពេលយប់ច្រើនតែដើរ "លួក" ក្រមុំ១ ។ ការលួកនេះ គឺរាវ"ប្រចាច់" ដោះលេង ប៉ុន្តែអាចធ្វើទៅបាន បើក្រមុំរូបនោះពេញចិត្តឱ្យ "លួក" តែបើមិនពេញចិត្ត គឺគេគេចទៅដេកកន្លែងផ្សេង ឬកន្លែងដែលមានរនាបជិតមិនអាច "ស្ទាប" កើត ។ តែកួយមិនអាចប្រើមនោសញ្ចេតនាស្រលាញ់គ្នាកំលោះ និងក្រមុំដោយស្ងាត់កំបាំងពីភ្នែកចាស់ទុំបានទេ ព្រោះគេខ្លាចខ្មោចចាស់ទុំធ្វើឱ្យឈឺដល់បងប្អូនដសាច់ញាតិ ។ មុខរបរម្យ៉ាងទៀត គឺស្លដែក ប៉ុន្តែបច្ចុប្បន្ននេះ ការស្លរដែកស្ទើរតែបាត់បង់ទៅហើយ ។ ការឆ្លងទន្លេរបស់ជនជាតិកួយ គឺពួកគេមាន "យាយមប" ឬឆ្មប ដែលជាចាស់ទុំក្នុងភូមិ ហើយធ្លាប់បង្កើតកូន ដូច្នេះពេលឈឺនោះ ត្រូវទៅអញ្ជើញឆ្មបនោះមកជួយមើល និងជួយបង្កើតកូន ។

ប៉ុន្តែមកដល់បច្ចុប្បន្ននេះ អ្វី១ដែលជាប្រពៃណីពួកកួយត្រូវបានរលាយសាបសូន្យជាបណ្ដើរ១ហើយ សូម្បីតែភាសារបស់ពួកគេ ក្មេង១ជំនាន់ក្រោយ

ស្ទើរតែពុំចេះផង ប៉ុន្តែគេសង្កេតឃើញជីវភាពរស់នៅរបស់ជនជាតិកួយនៅតែក្រខ្វះខាតរហូត នៅតាមភូមិនានា ដែលជនជាតិកួយរស់នៅ ច្រើនតែស្ថិតនៅដាច់ស្រយាលពីទីផ្សា ឬទីប្រជុំជន ។ ហើយគេតែងតែឃើញពួកកួយទាំងហ្នូងទូលកញ្ជើផ្លែឈើមកលក់ ខ្លះទូលអុស ខ្លះទូលផ្សិត ខ្លះទូលសម្បកឈើ (ដើមថ្នាំ) ឬផលអនុផលព្រៃឈើយកមកលក់នៅផ្សា ដែលគ្រាន់តែបានប្រាក់បន្តិចបន្តួចទិញប៊ីចេង ទិញអំបិល ប្រហុក ស្ករ ឬសម្លៀកបំពាក់ត្រឡប់ទៅផ្ទះវិញប៉ុណ្ណោះ" ។

## ២_យកជនជាតិព័រ២នាក់ មកបង្រៀនភាសាព័រ ដើម្បីស្រាវជ្រាវថា តើសិលាចារឹកប្រាសាទបុរាណ ជាប់ពាក់ព័ន្ធទៅនឹងភាសាព័រយ៉ាងណា [១] ?

"ជនជាតិព័រពីរនាក់ ត្រូវបានសាស្ត្រាចារ្យជនជាតិបារាំងទៅនាំយកមកពីភូមិកំណើតរបស់គាត់ឱ្យមកបង្រៀនភាសាព័រ ប្រយោជន៍ដើម្បីស្រាវជ្រាវ ថាតើភាសាព័រអាចពាក់ព័ន្ធទៅនិងអក្សរ ដែលឆ្លាក់នៅលើសិលាចារឹកតាមប្រាសាទនានាដែរឬទេ ។ លោកអ៊ុម សុខ ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បខេត្តកំពង់ធំ និងសហការីរបស់លោកពីរនាក់ផ្សេងទៀត ក៏បានចូលរៀននិងកត់ត្រាភាសាព័រនៅពេលនោះដែរ ។

ជនជាតិព័រពីរនាក់ដែលសាស្ត្រាចារ្យបារាំងឈ្មោះ Gerard Diffloth មកពីសាកលវិទ្យាល័យក័រណែល USA នាំយកមកឱ្យស្នាក់នៅ សណ្ឋាគារសម្បូរណ៏

---

១- រស្មីកម្ពុជា ថ្ងៃទី៩ កុម្ភៈ ២០០០

ព្រៃគុកហ៏ខេត្តកំពង់ធំតាំងពីថ្ងៃទី២កុម្ភៈឆ្នាំ២០០០ ហើយឱ្យពួកគាត់បង្រៀនភាសា និងសាកសួរពត៌មានទាន់ទិនទៅនិងប្រពៃណីដើមរបស់ជនជាតិព័រ ។ លោកអ៊ុម សុខ ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បខេត្ត កំពង់ធំបាននិយាយឱ្យដឹងថា លោកក៏មានបំណងនាំសហការីរបស់លោក២នាក់ទៀតចូលទៅសិក្សាដែល ដើម្បីស្វែងយល់ពាក្យពេចន៏ទាំងឡាយ ដែលមាននៅលើសិលាចារឹកតាមប្រាសាទសម្បូរណ៏ព្រៃគុកហ៏ និងប្រាសាទកោះកេរថា តើវាមានការពាក់ព័ន្ធគ្នាយ៉ាងណា ព្រោះប្រវត្តិសាស្ត្រក៏បានចារថា ជនជាតិព័រទាំងពីរក៏ជាជននជាតិដើមរបស់ខ្មែរដែរ ។ ជនជាតិព័រទាំងពីរនាក់នោះ ម្នាក់ឈ្មោះឡុងភួន អាយុ៥៥ឆ្នាំ និងម្នាក់ទៀតឈ្មោះសព្រំ អាយុ៦០ឆ្នាំ ជាប្រធានភូមិ ។ លោកទាំងពីរនាក់រស់នៅក្នុងភូមិឪឡឹក ឃុំរំដោះ ស្រុករវាង ខេត្តព្រះវិហារ ។ លោកអ៊ុម សុខនិយាយថា មុនឆ្នាំ១៩៦២ ស្រុករវាងនេះ គឺស្ថិតនៅក្នុងខេត្តកំពង់ធំនៅឡើយទេ លុះក្រោយឆ្នាំ១៩៦២ដីខេត្តកំពង់ធំមួយចំនួនបានកាត់ទៅឱ្យខេត្តព្រះវិហារ ហេតុនេះហើយទើបភូមិរបស់ជនជាតិព័រនៅខេត្តព្រះវិហារឯណ្ណោះទៅវិញ ។ តាមប្រសាសន៏រស់លោកសព្រំ ជនជាតិព័របាននិយាយថា នៅក្នុងភូមិឪឡឹករបស់លោក មានជនជាតិព័ររស់នៅប្រហែលជា៨០ភាគរយ ប៉ុន្តែប្រពៃណីរបស់ព័របានបាត់បង់បន្តិចម្តងៗ ស្ទើរតែអស់ទៅហើយ ដូច្នេះក្មេងៗ ស្រករក្រោយពុំបានចាំទេ ដោយសារតែសង្គ្រាមបានញាំញីពួកគាត់ពីមួយជំនាន់ទៅមួយជំនាន់ តែក៏មានចាស់ៗជាច្រើនទៀត ដែលនៅចាំបាននូវប្រពៃណីទំនៀមទម្លាប់នេះខ្លះ និងចេះចាំភាសាបាន ។

តាមនវិទ្យា ដែលមានលោកប៉ារ៉ាដាត Baradat លោកជ.ព្រុយណោ

J.Brunet លោកជ. អែលលុល J.Ellul បានសិក្សាអំពីកុលសម្ព័ន្ធសំរែ ឬព័រនេះ ថា ពួកសំរែ ឬព័រ គឺជាក្រុមរងខ្មែរមន ដែលរស់នៅក្នុងប្រទេសកម្ពុជា ពិសេសក្នុងខេត្តពោធិសាត់ ខេត្តបាត់ដំបង និងខេត្តកំពង់ធំ ។ តាមទស្សនៈរបស់លោកអៀវ កើសថា ពួកនេះ គឺជាអ្នកថែរក្សារបាសាទបុរាណ និងជាពួកព្រៃ ដែលមាននៅក្នុងខេត្តសៀមរាប និងកំពង់ធំ ព្រោះខេត្តទាំងពីរនេះ សម្បូរណ៍ទៅដោយប្រាសាទច្រើនជាងគេ ។ ប៉ុន្តែ ក្រោយមក ពេលដែល ព្រហ្មញ្ញសាសនាសាបសូន្យទៅ ពួកគេក៏លែងនៅថែរក្សាប្រាសាទបុរាណទៀត ហើយបែកជាកូនពូនជាចៅទៅរកកន្លែងរស់នៅក្នុងព្រៃរៀង១ខ្លួន ។

តាមការប្រាប់អំពីភាសាខ្លះ១របស់ជនជាតិព័រថា ហូបបាយ ព័រថា "ចាក្លង់" ផ្ទះ "តង់" ទៅ "វឿ" ។ល។ ហើយជនជាតិព័ររាប់បានត្រឹមតែ៤ប៉ុណ្ណោះ នៅពេលរាប់ដល់៥ គឺដូចខ្មែរដែរ ។

ទោះបីជាមានការសិក្សាយ៉ាងសង្ខេបខ្លះ១ហើយក៏ដោយ ក៏លោកអ៊ុមសុខពុំទាន់បានបញ្ជាក់ថា សិលាចារឹកនៅប្រាសាទសម្បូរណ៍ព្រៃគុកហ៏ និងប្រាសាទកោះកេរ ជាប់ពាក់ព័ន្ធយ៉ាងណាទៅនិងភាសាព័រនៅឡើយទេ តែលោកនិងព្យាយាមសិក្សាបន្តទៅទៀត ។ លោកសុខនិយាយថា បន្ទាប់ពីបញ្ជូនជនជាតិព័រទាំងពីរនាក់ខាងលើត្រឡប់ទៅវិញ និងអញ្ជើញជនជាតិព័រដដែលនេះមកសិក្សាបន្តទៀត" ។

## ៣-ជនជាតិខ្មែរព័រ និងជនក្លួងជីវភាពរស់នៅប្រចាំថ្ងៃ (១)

"បងប្អូនជនជាតិខ្មែរព័រ និងជង គឺជាអម្បូរដែលបន្សល់មកពីក្រុមកុលសម្ព័ន្ធភូមិភាគអាស៊ី ។ គេមានទម្លាប់រស់នៅជារបៀបពាក់កណ្តាលពនេចរលើទីតាំងភូមិសាស្ត្រ ស្ថិតនៅតាមតំបន់ខ្ពង់រាបជួរជើងភ្នំក្រវាញ ខេត្តពោធិសាត់ គឺជាជីវិតព្រៃភ្នំ គេរស់នៅនិងបង្កើតកូនចៅជាសង្គមគ្រួសារហូរហែរក្បែរទីកន្លែងណាដែលមានប្រភពទឹក ដូចជាភូមិអូរសោម វាលវែង ត្រែងធំ អូរដាឆៃកា ដំណាក់កោះ ស្រែពាំង ផ្ទះម្តៃ ។ល។ ហេតុដែលមានភូមិរកើតរកូតបែបនេះ ព្រោះថា គេមានទម្លាប់រស់នៅមិននឹងមួយកន្លែងទេ ។ ទី១ដោយផ្អែកលើបញ្ហារករស់ និងទី២ទៀតគេសង្ឃឹមទាំងស្រុងទៅលើផ្នែកខាងជំនឿអរូបិយ ដូចជា ប្រសិនបើនៅក្នុងភូមិដែលគេកំពង់រស់នៅត្រូវមាននរណាម្នាក់ស្លាប់ ទោះនៅក្នុងគ្រួសារណាក៏ដោយ ឈឺស្លាប់ ឬស្លាប់ដោយប្រការណាក្តី ។ ក្រោយពីរៀបចំពិធីបុណ្យតាមប្រពៃណីបញ្ចុះសពរួច អ្នកនៅរស់ទាំងអស់ រួមទាំងគ្រួសារនៃសពផង ត្រូវនាំគ្នាដឹកកូនជញ្ជូនចៅចាកចេញពីភូមិនោះ ទៅតាំងទីលំនៅនៅក្នុងភូមិថ្មីមួយផ្សេងទៀត ដែលគេសង្ឃឹមថា បានក្តីសុខដល់គ្រួសាររបស់ពួកគេ ។ ចំពោះសាកសពរបស់អ្នកដែលបានស្លាប់ទៅនោះ គឺគេបញ្ចុះសពនៅក្នុងភូមិ ហើយនៅក្បែរទីលំនៅដែលធ្លាប់រស់នៅ ។ ប៉ុន្តែ ជំនាន់ក្រោយ១មកទៀត ទម្លាប់នេះ ត្រូវបានគេបោះបង់ចោល ដោយសារភាពអសន្តិសុខនៅក្នុងសង្គមជាតិ និងដើម្បីធានាដល់សុវត្ថិភាពក្នុងគ្រួសារ ទើបពួកគេសុខ

១- រស្មីកម្ពុជា ថ្ងៃទី៧-៨ សីហា ២០០០

ចិត្តរស់នៅក្នុងភូមិចាស់ក្បែរគ្នា និងនៅជិតកន្លែងដែលមានសុវត្ថិភាព មិនផ្លាស់ប្តូរចល័តលំនៅស្ថានដូចទម្លាប់មុនៗទៀតឡើយ ។

អំពីជីវភាព អាស្រ័យដោយទឹកដីព្រៃភ្នំក្រំថ្ម ភូមិករដែលគេបានរស់នៅសម្បូរបែបនិងអំណោយផលធម្មជាតិ ។ ដូចនេះ បងប្អូនជនជាតិខ្មែរព័រ និងខ្មែរជង មានមុខរបររករស់ទាញយកផលពីធម្មជាតិដោយផ្ទាល់តែម្តង ដូចជាប្រកបរបរផេះផ្លែក្រវាញ ផ្លែដង្កោ ឆូត ជ័ររុង បំបែកថ្មកែវ និងរកកាប់ខ្លឹមចន្ទន៍គ្រឹស្នា ។ល។ ភោគផលទាំងឡាយ ដែលគេរកបានមួយចំនួន ត្រូវនាំយកមកលក់នៅខ្មែរភូមិភាគកណ្តាលយើងនេះ ដូចជាថ្មកែវ បម្រើតម្រូវការជាងចម្លាក់ទូទាំងខេត្តពោធិសាត់ និងទូទាំងក្នុងប្រទេស ។ ផ្លែក្រវាញ ដង្កោ ជ័ររុង បម្រើតម្រូវការគ្រូឱសថបុរាណផ្សំថ្នាំព្យាបាលរោគ និងខ្លឹមចន្ទន៍គ្រឹស្នា សម្រាប់អ្នកជំនួញធំៗ គេទិញយកមកចម្រាញ់យកជាតិប្រេងសុទ្ធលក់ចេញទៅក្រៅប្រទេស ។ មួយចំនួនទៀត ត្រូវបងប្អូនយើងឆ្លៀតនាំយកទៅលក់នៅជាយដែនប្រទេសថៃនិងកម្ពុជា ព្រោះងាយស្រួលប្តូរយកតម្រូវការចំបាច់ ដូចជាសម្លៀកបំពាក់ និងគ្រឿងឧបភោគបរិភោគផ្សេងៗ ។ មុខរបរទាំងអស់នេះ គឺនៅក្នុងគ្រួសារនីមួយៗ ត្រូវតែសស្រាក់សស្រាំព្យាយាមបំពេញតាមរដូវកាល ដោយខានមិនបាន ។ ជាងនេះទៅទៀតនោះ គេនៅឆ្លៀតឱកាសប្រកបរបរធ្វើស្រែដាំស្រូវ (ស្រូវបុកដាំ) នារដូវវស្សា និងធ្វើចម្ការរួមផ្សំ សម្រាប់ឧបត្ថម្ភជីវភាពគ្រួសារទៀតផង ។ សូមជម្រាបអំពីជីវភាពរស់នៅ និង តម្រូវការរបស់គេគឺមួយគ្រប់គ្រាន់ក្នុងគ្រួសារ ។ ក្រៅពីនេះ គេចែករំលែកទៅឱ្យបងប្អូននៅក្នុងភូមិស្រុកដែលខ្វះខាតដោយរកពុំបាន ។ ម្យ៉ាងវិញទៀត ក្នុងការរស់នៅរបស់

ពួកគេ និងប្រកាន់សច្ចៈភាពបំផុត និយាយយ៉ាងណាគឺធ្វើយ៉ាងនោះ ។ ប្រសិនបើមានអ្នកណាម្នាក់ប្រព្រឹត្តខុស មេភូមិទាំងគ្រួសារគេទាំងអស់ និងកាត់ទោសទៅតាមច្បាប់ទម្លាប់របស់គេ ដូចជាត្រូវដេញចេញពីក្រុមពីភូមិ ។ លើសពីនេះទៅទៀតនោះ បើទោសធ្ងន់ អាចត្រូវគេព្រួតគ្នាវាយដំរហូតដល់ស្លាប់ផងក៏មានដែរ ។ គេសម្រឡាញ់គ្នាណាស់ នៅពេលដែល គេប្រមាញ់សត្វព្រៃបានយកមកចងព្យួរនៅខាងមុខផ្ទះ ហើយប្រកួកហៅគ្នាឱ្យ មកពន្លះសាច់យកទៅធ្វើម្ហូបរៀង១ខ្លួន តាមគ្រួសារនីមួយ១ ត្រូវការ ដោយមិនលក់ដូរអ្វីឡើយ ។

និយាយអំពីជំនឿសាសនា និងវប្បធម៌ អារ្យធម៌ជាតិខ្មែរព័រ និងខ្មែរផង គឺមានពណ៌សម្បុរឈាមជ័រជាខ្មែរដូចខ្មែរយើងនៅពេញប្រទេសដែរ ។ ប៉ុន្តែ ខុសត្រង់គេនៅរកបានទំនៀមទម្លាប់ប្រពៃណីប្រចាំតំបន់របស់ពួកគេ គឺរបៀបរស់នៅនិងការប្រើភាសា ។ ដោយខុសត្រង់ថា ផ្នែកអក្សរសាស្ត្រពុំមាននៅសេសសល់ប៉ុណ្ណោះ ។ ជាធម្មតាគេអាចប្រើភាសាពីរសម្រាប់កូនចៅនៅក្នុងសង្គមគេដូចគ្នាដែរ ។ មិនតែប៉ុណ្ណោះ គេនៅមានជំនឿខាងពុទ្ធសាសនាផង និងព្រហ្មញ្ញសាសនាផង ។ គេកាន់សាសនាព្រះពុទ្ធមានវត្តធ្លាប់បួសរៀនស្ទើរគ្រប់គ្នា ។ ប៉ុន្តែចំណុចសំខាន់ គឺផ្ចត់គំនិតនៅក្នុងជំនឿដែលតាំងតែពីរាប់សែនឆ្នាំមកហើយ នៅតែមានរក្សាយ៉ាងមុតមាំលើលទ្ធិព្រលឹង ឬលទ្ធិជីវចលនិយមនៃយុគសម័យថ្មបំបែកមកម្ល៉េះ ។ ជាការពិតណាស់ គេរស់នៅក្នុងតំបន់ព្រៃភ្នំក្រំថ្មដូចនេះគេត្រូវតែមានជំនឿលើកម្លាំងធម្មជាតិ ។ ព្រោះវិសាលភាពនេះ បានលាតត្រដាងអំណាចឱ្យគ្របដណ្តប់ទៅលើពួកគេ ដើម្បីសេចក្តីសុខ និងដើម្បីសម្រេចជោគជ័យក្នុងកិច្ចការចេញប្រកបមុខរបរផ្សេង១ ។ គេត្រូវតែបន់ស្រន់បួងសួង

សែនព្រេនសុំឱ្យព្រលឹងនៃភាពអស្ចារ្យក្នុងធម្មជាតិ "កាច ឬស្លូត" ដែលគេបានសន្មតថា ជាវត្ថុស័ក្តិសិទ្ធិនេះ? ជួយគេ អាណិតគេ ព្រមផ្តល់អ្វីៗឱ្យដល់ពួកគេរាល់គ្នានូវរាល់សេចក្តីត្រូវការតាមរយៈការបួងសួង សែនព្រេន ។ ចំពោះអត្ថន័យដ៏សំខាន់ក្នុងពិធីសែនព្រេនចំពោះលទ្ធិព្រលឹង តាមរយៈឯកសារជាច្រើនស្តីអំពីអារ្យធម៌ និងវប្បធម៌ខ្មែរ ដែលបានចែងគូសបញ្ជាក់យ៉ាងច្បាស់នៅក្នុងពិធីមួយៗ ដែលមានព្រះអាទិទេព អារុក្ខអារក្សអ្នកតាព្រៃភ្នំ ឬព្រលឹងវត្ថុស័ក្តិសិទ្ធិណាមួយចូលចិត្ត គ្មានអ្វីក្រៅពីតន្ត្រីនិងការរាំច្រៀងរបស់នាដក ឬនាដការ ជាសាវ័ក ហើយគេត្រូវតែរៀបចំធ្វើឡើងទៅតាមរូបនិយម នៃតំបន់នីមួយៗទៀតផង ។

តាមរយៈទំនាក់ទំនងគ្នារវាងទីតាំងរស់ ស្ថានភាពរស់ និងជំនឿសាសនានៅក្នុងការរស់នៅ ជាមធ្យោបាយផ្ទៀងផ្ទាត់ទាំងបីចំណុចខាងលើរបស់ជនជាតិព័រ និងជង គឺពិតជាបានផ្តល់ឱ្យយើងបានដឹង និងឃើញនូវចំណុចពិសេសខ្លះៗ អំពីភាពចាំបាច់ ភាពសំខាន់នៅក្នុងជីវភាពរស់នៅរបស់ជនជាតិទាំងពីរនេះថា គឺរស់ពឹងផ្អែកទាំងស្រុងទៅលើធម្មជាតិ និងទៅលើជំនឿយ៉ាងជឿជាក់បំផុត" ។

## ៤-រលាក់កខេង "ដែនដីដែលគេធ្លាប់ប្រមាថ"[១]

"គឺជាដែនដីមួយ ដែលប្រជាជនទីនោះរងនូវការមាក់ងាយពីសំណាក់ប្រជាជននៃតំបន់នានារាប់សិបឆ្នាំមកហើយ ។

១- រស្មីកម្ពុជា ថ្ងៃទី២៦-២៧ កុម្ភៈ២០០១

ខ្លះគ្រាន់តែពួកម៉ាកផឹកស្រា អាក្រក់ក៏ជេរ្យលថា ផឹកអាក្រក់មើលតែពួករលាក់កងជើង ស៊ីអាក្រក់ ស្លៀកពាក់មិនចុះសម្រុងនិងសង្គមមើលតែពួករលាក់កងជើង ។ នៅមានពាក្យតិះដៀលដទៃទៀតជាច្រើន និយាយឱ្យចំទៅគេចាត់ទុកថា អ្នករលាក់កងជើងជាមនុស្សមិនគួរសេពគប់ ជាមនុស្សនៅស្រទាប់ក្រោមរបស់សង្គមកម្ពុជា ។

តាមពិត អ្នកដែលតិះដៀលអ្នករលាក់កងជើងបែបនេះ គេមិនទាំងដឹងថា ប្រជាជនរលាក់កងជើងជាមនុស្សប្រភេទណានោះទេ ហើយរលាក់កងជើងនោះនៅទីណាផង ។

លោកព្រឹទ្ធាចារ្យ ពាល ឡឹម ជនជាតិព័រ ដែលមួយជីវិតរបស់លោក កុំថាឡើយកំពង់ស្ពឺ សូម្បីតែថ្នល់កៅស៊ូមានរាងយ៉ាងមេច ក៏លោកតាមិនទាំងស្គាល់ផងនោះបានឱ្យដឹងថា ឈ្មោះដើមនៃរលាក់កងជើងគឺ "លាក់កងជើង" ។

លោកតាពាល ឡឹមគាត់ស្ទាត់ជំនាញក្នុងការនិយាយភាសាព័រ ដែលជាភាសាកំណើតរបស់គាត់ គាត់និយាយភាសាខ្មែររដើន១ ពិបាកក្នុងការស្តាប់តែបានអ្នកបកប្រែជួយ ។ លោកតានិទានថា កាលពីយូរលង់ណាស់មកហើយនគរខ្មែរមានចម្បាំងជាមួយសៀម តែខ្លះគេថា ចម្បាំងជាមួយចម្ប៉ា ។ ដោយច្បាំងចាញ់គេ ស្តេចអង្គនោះ ក៏គេចខ្លួនកាត់ព្រៃមកដល់តំបន់រលាក់កងជើងសព្វថ្ងៃនេះ ដែលកាលនោះ មិនទាន់មានឈ្មោះទេ ។ គេនិយមហៅស្តេចថា "ហ្លួង"។

អ្នកស្រុកតំបន់នោះ ស្គាល់អ្នកភៀសខ្លួននោះថា ជាហ្លួងគ្រប់គ្រងនគរខ្មែរ ។ ដោយអស់កម្លាំង ហ្លួងនោះក៏ឈប់សម្រាកយកកម្លាំងហៅទូលមួយ

ឈ្មោះទទួលស្រមរ ដើម្បីសោយក្រយា ។ ទីទួលនោះ ក៏ត្រូវគេដាក់ឈ្មោះថា ទួលស្រមរហ្លួងរហូតដល់សព្វថ្ងៃនេះ ។

ក្រោយពីសម្រាកមានកម្លាំង ហ្លួងអង្គនោះក៏យាងបន្តទៅទៀត ។ ដោយនឿយព្រះកាយ ស្ដេចក៏បានសម្រាកមួយខណៈយកកម្លាំង ។ ស្ដេចបានផ្អែកខ្នងទៅនិងដើមគ្រើលមួយដើម ។ លុះស្ដេចបន្តដំណើរទៅទៀត អ្នកស្រុកនៅទីនោះបានហៅកន្លែងនោះថា "គ្រើលហ្លួងផ្អែក" ទល់សព្វថ្ងៃនេះ ។

ស្ដេចជិនាន់ដើមមានពាក់កងជើងធំៗណាស់ ។ ដោយចង់បន្លំខ្លួនជាមួយប្រជាជន ដើម្បីការពារក្រែងលោកកម្លាំងបច្ចាមិត្តមកទាន់នោះ ស្ដេចអង្គនេះ ក៏បានសម្រេចចិត្តដោះកងជើងលាក់ទុកនៅតំបន់នោះ ។ គេក៏ហៅតំបន់នោះថា "លាក់កងជើង" ទៅ តែក្រោយមកមិនដឹងជាយ៉ាងមេចទេ ស្រាប់តែក្លាយទៅជា "រលាក់កងជើង" ទៅវិញ ។

ក្រោយពីលាក់កងជើងហើយ ស្ដេចបន្តដំណើរទៅដល់ភូមិមួយ អ្នកភូមិនៅទីនោះ នៅតែស្គាល់ព្រះរាជារបស់ខ្លួន ទោះបីជាក្លែងខ្លួនជាប្រជារាស្ត្រក៏ដោយ ។ ព្រះមហាក្សត្របានបញ្ជាទៅតាសាល ដែលជាព្រឹទ្ធាចារ្យនៃភូមិនោះ ឱ្យធ្វើជារោងដ៏ធំមួយដើម្បីរៀបចំពិធីបុណ្យ ។ រោងតាសាលធ្វើនោះ មិនត្រឹមតែមិនសព្វព្រះទ័យព្រះមហាក្សត្រប៉ុណ្ណោះទេ តែថែមទាំងបណ្ដាលឱ្យមហាក្សត្រខ្ញាល់ថែមទៀតផង ។ ព្រះរាជាដោយខ្ញាល់និងតាសាល បានដាក់បណ្ដាសារដល់អ្នកភូមិនោះថា បើតាសាលមានជីវភាពធូរធារ អ្នកភូមិនោះត្រូវតែធ្វើស្រែចម្ការមិនបានផល និងកើតចម្បាំងរាំងជលទៀតផង ។ តែបើតាសាលជួបប្រទះភាពគោកយ៉ាកនោះ ទើបអ្នកភូមិនោះបានសេចក្ដីសុខ ។

ដោយសារតែមានរឿងរ៉ាវរបស់តាសាលបែបនេះហើយ ទើបភូមិនោះមានឈ្មោះថា ភូមិតាសាលរហូតមកដល់សព្វថ្ងៃនេះ ។

**ដែនដីមេម៉ាយខ្លឹម ឬដែនដីទាក់ងាយ**

រលាក់កងជើង ស្ថិតក្រោមក្រសែភ្នែកមាក់ងាយពីសំណាក់មនុស្សតំបន់ផ្សេងៗ មួយផ្នែកដោយសារបណ្តាសាររបស់ស្តេចចំពោះតាសាល ។ នៅមានរឿងអាម៉ាសមួយទៀត ដែលបណ្តាលឱ្យមនុស្សតំបន់ផ្សេងៗ ហាក់មើលស្រាលអ្នករលាក់កងជើង ។

លោកស៊ឹម ហឿន ជាអ្នកស្រុករក្រោយមួយរូប ដែលដឹងរឿងរ៉ាវនៃប្រវត្តិសាស្ត្ររលាក់កងជើងច្រើនពីចាស់ៗ ជំនាន់មុននោះ បាននិយាយថា នៅរលាក់កងជើងរបរសំខាន់របស់គេ គឺបរបាញ់ ចូលព្រៃរកខ្លឹម រកជ័រ...។ ចំណែកប្រុសៗដែលជាប្តីទៅព្រៃម្តងៗ យ៉ាងតិចណាស់ក៏៣ខែដែរទើបត្រឡប់មកវិញ ជាហេតុធ្វើឱ្យប្រពន្ធដែលនៅផ្ទះឯណោះដាច់របបយូរ ហើយក៏ចាត់ទុកខ្លួនឯងថា អ្នកមេម៉ាយ ។

ប្រុសពីចម្ងាយតែងតែទៅរកទិញជ័រនៅតំបន់រលាក់កងជើង ។ ឃើញស្រីៗទាំងនោះគ្មានប្តីនៅជាមួយ ពួកគេក៏ហៅស្រីៗទាំងនោះថា មេម៉ាយខ្លឹម (មេម៉ាយខ្លឹមចន្ទន៍) ។ ប្រុសៗកំហិលទាំងនោះ តែងតែប្រើសម្តីលែបខាយចំពោះស្ត្រីទាំងនោះ យូរៗស្រីទាំងនោះយល់ព្រមរួមរក្សជាមួយ ព្រោះខ្លួនក៏ដាច់របបយូរដែរហើយ ។

ករណីបែបនេះ ចេះតែឮតៗគ្នា ហើយអ្នកទៅទិញជ័យ ទិញខ្លឹមតែងតែរួមរក្សជាមួយប្រពន្ធគេជានិច្ច ។ យូរៗទៅរឿងនេះ ល្បីសុសសាយដល់គេ

ឯង បណ្ដាលឱ្យគេតិះដៀលស្រីៗនៅរលាក់កងជើងថា ស្រីគ្មានប្រពៃណីត្រឹមត្រូវ ។ អ្វីៗទាំងអស់នេះ សុទ្ធតែជាការនិទានតៗគ្នាតែប៉ុណ្ណោះ ។

អ្នករលាក់កងជើងទាំងមូល បានទទួលការមាក់ងាយដោយសារតែស្ត្រីក្នុងតំបន់នោះធ្វើខ្លួនបែបនេះ ។ តែលោកស៊ឹម ហឿនបាននិយាយទៀតថា វាជាការនិទានតៗគ្នាតែប៉ុណ្ណោះ ។

## ប្រវត្តិឡានស៊ីស្នៅ

រឿងនិទានពីការដាក់ស្នៅឱ្យឡានស៊ី ក៏ត្រូវគេអះអាងថា កើតចេញពីតំបន់នេះរលាក់កងជើងនេះដែរ ។ លោកតាពាល ឡឹមនិយាយថា កាលនោះលោកតាមិនទាន់ដឹងក្ដីទេ តែឪពុកម្ដាយរបស់លោកនិយាយថា មានពួកបារាំងបើកឡានទៅដល់តំបន់នោះ ។ ដោយផ្លូវឆ្ងាយម៉ាស៊ីនរថយន្តក្ដៅ ម្ចាស់ឡានក៏បើកគម្របម៉ាស៊ីន ដើម្បីឱ្យម៉ាស៊ីឆាប់ចុះត្រជាក់ ។ ពួកអ្នកស្រុកឃើញបែបនេះ ក៏ថាឡានហាមាត់ ហើយយកស្នៅមកដាក់ឱ្យឡានស៊ី ។ បារាំងម្ចាស់ឡានខឹងក៏បិទគម្របម៉ាស៊ីនយ៉ាងខ្លាំង ហើយបើកឡានយកដែករវៃបញ្ឆេះឡានចេញទៅ ។

ពួកអ្នកស្រុកឃើញគេរវៃបញ្ឆេះឡានបែបនេះ ក៏និយាយថា "អានេះចាក់ច្រមុះទៅចេះស្រែក" ។

## រស់ផ្ទុក

រលាក់កងជើង គឺជាតំបន់សម្បូរណ៍ទៅដោយឈើប្រណីតៗ តែលំនៅស្ថានប្រជាជនតូចៗ ដែលមើលទៅមិនសមជាអ្នករស់នៅតំបន់សម្បូរណ៍ឈើឡើយ ។ តែលោកតាពាល ឡឹម បាននិយាយថា ពួកគេមិនធ្វើផ្ទះធំ ដោយសារ

តែកន្លងមករលំតែរត់ព្រៃ គឺរត់ពេញព្រៃគេចពីសង្គ្រាម ។

**អនុខេត្តថ្មកែវ**

កាលពីទសវត្សរ៍ទី៦០ សម្តេចព្រះមហាក្សត្រនរោត្តមសីហនុចង់អភិវឌ្ឍន៍តំបន់នោះ ឱ្យមានការរីកចម្រើននិងគេ ។ ព្រះអង្គក៏សម្រេចបង្កើតអនុខេត្តមួយនៅតំបន់នោះ គឺអនុខេត្ត "ថ្មកែវ" ។ ព្រះអង្គបានប្រមូលខ្មែរកម្ពុជាក្រោមនិងអ្នកគ្មានលំនៅឱ្យទៅរស់នៅទីនោះ ។

ដោយសារតែតំបន់ដាច់ស្រយាលខ្វះទឹក គួបផ្សំនិងជាតំបន់គ្រុនចាញ់ផងនោះ ហើយរត់ទៅតំបន់ទីប្រជុំជនអស់ទៅ ។ ម្លោះហើយទីនោះ នៅតែជាតំបន់ដាច់ស្រយាល ដែលគេទៅមិនដល់ និងគ្មានអ្នកណាទឹកនាដដែល ។

**រលាក់កងជើងពេលនេះនៅជិតបង្កើយ**

បើគិតពីភ្នំពេញទៅរលាក់កងជើង មានចម្ងាយជាង១៣០គម តែបើគិតពីខេត្តកំពង់ស្ពឺទៅមានចម្ងាយជាង៩០គម ។ លោកថៃម សារីម អភិបាលស្រុកឱរ៉ាល់បាននិយាយថា កន្លងមក មិនដែលមានអង្គការណាចង់ជួយអ្នករលាក់កងជើងទេ ព្រោះឆ្ងាយពេក ។ ពីមុនគេមកដល់រលាក់កងជើងដោយជិះម៉ូតូឌុបកំពង់ស្ពឺ រលាក់កងជើងទៅមក១៥០ដុល្លារឯណ្ណោះ តែពេលនេះ Maeda បានស្ថាបនាផ្លូវទៅកាន់រលាក់កងជើងបានរួចជាស្ថាពរ ក្រោមគម្រោងថវិការបស់ LWS ។

ផ្លូវលំថ្មីនេះ អាចបើករថយន្តក្នុងល្បឿន១០០គមក្នុងមួយម៉ោង ។ ក្នុងមួយថ្ងៃគេអាចទៅមករលាក់កងជើងបាន២ឬ៣ជើង មិនតែប៉ុណ្ណោះ មានរថយន្តឈ្នួលរត់ទៅដល់ទីនោះទៀតផង ។

លោកចៅហ្វាយស្រុកបាននិយាយទៀតថា សព្វថ្ងៃអ្នករលាកកងជើងលែងចូលព្រៃរកជ័រទៀតហើយ គឺគេចាប់ផ្ដើមរានដីធ្វើស្រែចម្ការ តែក៏នៅមានអ្នកភូមិខិលខូចខ្លះទៅលួចដុតព្រៃយកសត្វផងដែរ ។ លោកពន្យល់ថា តាមពិតទៅការដុតព្រៃនេះ គោលបំណងធំរបស់អ្នកភូមិ មិនមែនដើម្បីយកសត្វនោះទេ គឺដើម្បីឱ្យខ្លោចដើមឈើធំៗ ដើម្បីកាប់ឈើនោះលក់ ។ ឯពួកអ្នកស្រុកនិយាយថា កាប់ឈើដែលឆេះទើបអាជ្ញាធរ ឬមេព្រៃមិនរករឿង ។

អ្នករលាក់កងជើង គឺជាមនុស្សស្មោះត្រង់ ហើយឆាប់ជឿទុកចិត្តគេណាស់ ។ ពួកគេមិនបានរៀនសូត្រចេះដឹងឡើយ តែថាបើរត់ចូលព្រៃឱ្យរ៉ាល់ កុំសង្ឃឹមថារួចខ្លួនឱ្យសោះ គឺព័ទ្ធចាប់បានភ្លាមតែម្ដង ។

លោកចៅហ្វាយស្រុកនិយាយទៀតថា ផ្លូវលេខ៤២ មកកាន់រលាក់កងជើងមានអូរ១៦កន្លែង លោកចង់បានស្ពានចំនួន៦ នៅតំបន់អូរធំៗជាបន្ទាន់ តែមិនដឹងថាទៅសុំអ្នកណា ។ លោកបញ្ជាក់ថា បើមានស្ពានច្បាស់ជាមានអ្នកចង់មកស្គាល់រលាក់កងជើងច្រើនជាមិនខាន ។

សម្រាប់ខែប្រាំង គេអាចបើកបរដោយគ្មានស្ពានបាន ព្រោះទឹកអូរខ្លះរាក់ ខ្លះរីង ដូច្នេះគេបើកបរកាត់អូរដោយគ្មានបញ្ហា ” ។

## ៥_ជនជាតិនៅមណ្ឌលគិរី
## ចោះត្រចៀកសម្គាល់ "អ្នកជា"[១]

"មានការពន្យល់ហេតុផលមួយចំនួន របស់បងប្អូនជនជាតិភាគតិចនៅខេត្តមណ្ឌលគិរីថា បុរសស្ត្រីចាស់ៗនៅទីនោះ ណាដែលឃើញមានរន្ធប្រហោងចោះត្រចៀក គឺសម្គាល់ថា "អ្នកជា" ។ ការធ្វើដូច្នេះ ត្រូវពួកគាត់ធ្វើឡើងក្នុងអំឡុងពេលមានជម្លោះរវាងជាតិសាសន៍ ជនជាតិខុសគ្នា នៅសម័យអាណានិគមបារាំង (១៨៦៣-១៩៥៥) និងសម័យកងទ័ពជប៉ុនឈ្លានពានស្រុកខ្មែរ (១៩៣៩-១៩៤៥) ។

លោកតាអែន ចយ ជនជាតិព្នងនៅភូមិពូរតាំង ឃុំរមនា ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី ដែលនិយាយដោយមានអ្នកបកប្រែ បានប្រាប់យើងកាលពីពេលថ្មីៗនេះថា មូលហេតុដែលគាត់ និងបុរសចំណាស់ៗជនជាតិព្នងក៏ដូចជាជនជាតិស្ទៀង កួយ រដែរ ចារាយ ទំពួន ក្រោល ....នៅមណ្ឌលគិរីចោះត្រចៀកមកពីមុនសម័យបារាំងចូលស្រុកខ្មែរ គេបានកេណ្ឌជនជាតិភាគតិចឱ្យធ្វើទ័ព ឬក៏មានជនជាតិបានចេញបះបោរតស៊ូរើបម្រេះពីអំណាចបរទេស ។

លោកតាអែន ចយ បញ្ជាក់ថា កាលនោះ បើអ្នកណាមិនចោះត្រចៀក គឺសម្គាល់អ្នករឹងទទឹង ឬក៏ជាអ្នកក្លាហាន ដែលត្រូវគេកេណ្ឌធ្វើទ័ព ។ តែបើចោះត្រចៀកវិញ គេក៏សម្គាល់ថា ប្រជាជនជាសាមញ្ញ ឬជាអ្នកស្ដាប់បង្គាប់អាជ្ញាសឹក ។ ប៉ុន្តែលោកតាបានការពារថា អ្នកចោះត្រចៀក (បុរសៗ) ទាំង

---

១-រស្មីកម្ពុជា ថ្ងៃទី៨ ធ្នូ ២០០២

ឡាយ ពុំមែនមានន័យថាកម្សាកញ្ជី ខ្លាចអំណាចបរទេស ឬខ្លាចអំណាចជាតិសាសន៍ដទៃនៃជនជាតិផ្សេងទៀតនោះទេ តែជា"ល្បិច" ដើម្បីបន្លំភ្នែកសត្រូវដែរ ។ គឺពេលយប់ចេញទៅច្បាំងតតាំងនិងសត្រូវ ដល់ពេលថ្ងៃមកធ្វើការនៅផ្ទះធម្មតា ។ ដល់ពួកសត្រូវឃើញក៏មិនចាប់ចងធ្វើបាបដែរ ។ មិនមាននិយាយអំពីការពាក់អលង្ការអ្វីនៅនិងត្រចៀកចោះដូចស្ត្រីទេ គឺគ្រាន់តែចោះចំណាំ និងសម្គាល់បុរសស្លូតបូត មិនបង្ករគ្រោះថ្នាក់ពោលគឺជា "អ្នកជា" ។ អ្នកចោះត្រចៀកជាអ្នកមិនធ្វើទាហាន អ្នកមិនច្បាំង គឺមិនបានទៅច្បាំងខាងកម្លាំងអាវុធចេញមុខ និងជនជាតិភាគតិចដទៃ និងបរទេស (យួន បារាំង ជប៉ុន) ។

បងប្អូនជនជាតិខ្លះទៀតនិយាយថា មានបងប្អូនជនជាតិរាប់រយពាន់នាក់ពិសេសរស់នៅស្រុកកោះញែក ត្រូវគេកេណ្ឌយកទៅធ្វើទាហានខ្មែរក្រហម ។ ជាយុទ្ធជនខ្មែរក្រហមដ៏ស្មោះត្រង់ ហើយធ្វើដោយលង់ខ្លួនងងឹតងងល់យូរជាងគេ ។ ពួកគេជាប់តាំងនៅតំបន់អន្លង់វែង (ទីតាំងមាំចុងក្រោយរបស់ពួកឧទ្ទាមខ្មែរក្រហម) រហូតដល់ឆ្នាំ១៩៩៨ ។

លោកតា អែន ចយ បានអះអាងខ្លួនឯងថា គាត់មានអាយុ១១៨ឆ្នាំ (ស្លាប់កាលពីពាឆ្នាំមុន) ។ គាត់បាននិយាយយ៉ាងច្បាស់ពីប្រវត្តិនៃយុវវ័យរបស់គាត់នាដើមសម័យអាណានិគមបារាំង (១៨៦៣-១៩៥៣) ។ ទោះជាយ៉ាងណាក៏គ្មានសាក្សី និងការពន្យល់ផ្សេងទៀតឱ្យល្មមជឿបាននោះឡើយ ។

គាត់ចេះភាសាខ្មែរ (និយាយ)តិចតួចបំផុត ។ គាត់រស់នៅក្នុងភូមិពូតាំង រួមគ្នានិងលោកតាជនជាតិព្នងពីរនាក់ ដែលបានថតរូបរួមជាមួយព្រះករុណាសម្តេចព្រះនរោត្តមសីហនុ ។ តាអែន ចយ និងអ្នកភូមិអះអាងថា តាពីរ

នាក់នោះស្លាប់អស់ហើយគឺ១ឈ្មោះ ផ្តើច ណាយ ២ឈ្មោះពីច្រើប ហ្មើត ។

បើតាមចៅប្រុសរបស់គាត់ឈ្មោះទើប រ៉ាន្នី ជាគ្រូបង្រៀននៅសាលាបឋមសិក្សាពូរតាំងបានឱ្យដឹងថា តាអែន ចយអាយុវែងដោយសារគាត់បរិភោគតែចំណីធម្មជាតិសុទ្ធសាធរៀបចំកន្លែងរស់នៅមានអនាម័យ ពិសាទឹកថ្នាំចម្រុះជាប្រចាំ បរិភោគបានច្រើន និងបញ្ចេញពលកម្មឱ្យប៉ាន់និងកម្លាំង ។ ជាពិសេសទៅទៀត គឺទទួលទានដំណេកឱ្យគ្រប់គ្រាន់ ។

ឱ្យទាហរណ៍ដូចជា នៅរដូវត្រជាក់ចាប់ពីខែតុលា ដល់កុម្ភៈ រាល់ថ្ងៃពួកគាត់តែងដុតភ្លើងកម្តៅក្នុងផ្ទះ ។ ការហូបបាយដោយរើសអង្ករនិងហូបសម្លម្យ៉ាងដែលគេស្ងួក្នុងបំពង់ឬស្សី ។ ផ្នាំសម្លធ្វើអំពីបំពង់ឬស្សីនោះ ធ្វើឱ្យសម្លឆ្ងាញ់ទ្វេដង និងរសជាតិគ្មានសារធាតុគីមី "។

## ៦. ស្រាទឹកកាន់តែខ្លាំង ជំងឺកន្លាកាន់តែតិច[1]

"ស្រាពាងរបស់បងប្អូនជនជាតិភាគតិច នៅភូមិភាគឦសាននៃប្រទេសកម្ពុជា ពិតជាមានក្លិន និងរសជាតិឈ្ងុយឆ្ងាញ់ មិនអន់ជាងស្រាដបមកពីបរទេសបារាំងឡើយ ព្រោះស្រាពាងទាំងនោះ ត្រូវបានផលិតចេញពីអង្ករ អង្កាម មើមឈើសុទ្ធសាធ ដោយបិទយ៉ាងស្អាតទៀតផង ។

ស្រាពាងដ៏ជាទីពេញនិយមរបស់បងប្អូនជនជាតិ តាំងពីដើមរហូតមកដល់សព្វថ្ងៃនេះ គ្មានដាក់លក់នៅលើទីផ្សារទេ ព្រោះគេផលិតសម្រាប់តែចែកគ្នាបឹត (ផឹក) នៅក្នុងភូមិកររបស់ពួកគេនោះ មិនចាំបាច់ទិញដូរឡើយ ។

---

១-កោះសន្តិភាព

បងប្អូនជនជាតិភាគតិចជាទូទៅអ្នកណាក៏ចេះផឹកស្រានេះដែរ មិនថាក្មេងចាស់ប្រុសឬស្រីទេ ហើយស្រាដែលផលិតដាក់ក្នុងពាងតូចឬធំនេះ ក៏មានកម្រិតខ្លាំងនិងកម្រិតខ្សោយ មានផ្អែមមានល្វីងដែរ ។ តែចំពោះស្រាផ្អែមដែលស្រួលលេបនោះ ងាយនិងឆាប់ស្រវឹងណាស់ ។

ស្រាពាងរបស់បងប្អូនជនជាតិនេះ គេមិនបានចាក់ដាក់ផ្តិល ឬកែវយកមកផឹកទេ បើគេត្រូវការផឹក គឺដាក់បំពង់បឺតជាច្រើនដើមនៅក្នុងពាងនោះតែម្តង ។ ការដាក់បំពង់បឺតចូលទៅនេះ បើអ្នកមិនធ្លាប់ទេ គឺដាក់ទៅបឺតមកវិញដោយអង្កាមហើយ ។

ស្រាពាងនេះ ផឹកមិនងាយរីងស្ងួតឡើយ ព្រោះពេលគេបឺតស្រកបន្តិច ចាក់ទឹកថែមបន្តិច គេធ្វើរបៀបនេះ ទាល់តែបឺតមកលែងមានជាតិស្រា ទើបគេឈប់ ។ ឯទឹកសម្រាប់ចាក់បន្ថែមនេះ ឱ្យតែទឹកផឹកចាក់ទៅបានទាំងអស់ ។

ការបឺតស្រាពាងរបស់បងប្អូនជនជាតិភាគតិចនេះ ទោះជាស្រវឹងដេកដួលរលេជុំវិញពាងស្រានោះយ៉ាងណាក៏ដោយ ក៏ពួកគេមិនដែលឈ្លោះទាស់ទែងគ្នាដែរ ។ ស្រវឹងកាន់តែខ្លាំងជជែកគ្នាកាន់តែពូកិច នេះជាទម្លាប់មួយ ដែលគេថា មានតាំងពីដូនតារបស់ពួកគេមក ។

ស្រាពាងធំៗនិងឆ្ងាញ់ៗ គេផលិតឡើងសម្រាប់ពេលមានពិធីផ្សេងៗម្តងម្កាល ហើយចំពោះស្រាពាងធំមួយពាងៗនោះ អាចបម្រើសេចក្តីត្រូវការបានរាប់សិបនាក់ ។ ស្រាពាងនោះ កាន់តែមានរសជាតិឆ្ងាញ់ គឺនៅពេលអ្នកផឹកទាំងអស់ឱនក្បាលបឺតព្រមៗគ្នានោះតែម្តង ។

នៅក្នុងពិធីប្រពៃណីធំៗ របស់បងប្អូនជនជាតិនីមួយៗ អ្នកដែលបាន

ចូលរួមទាំងប៉ុន្មាន គឺត្រូវស្រវឹងទាំងអស់ ហើយទោះស្រវឹងហើយក៏ដោយ បើពិធីមិនទាន់ចប់ទេ គឺពួកគេដេករលេជុំវិញពាងស្រា ដែលមិនចេះរីងស្ងួតនោះ រហូតដល់ថ្ងៃរះទើបងើបទៅផ្ទះរៀង១ខ្លួន "។

## ៧_ជនជាតិខ្មែរលើ និងជំនឿលើចេកត្រណម[១]

"ចេកត្រណម គឺជាចេកមួយប្រភេទរបស់ជនជាតិខ្មែរលើ ដូចជាជនជាតិគ្រឹង ទំពួន ប្រូវ....ដែលតែងតែដាំស្ថិតនៅចំកណ្តាលភូមិជានិច្ច ហើយស្ថិតនៅក្បែររោងបុណ្យរួមទៀតផង ។ ចេកត្រណមនេះ ត្រូវបានជនជាតិខ្មែរលើគោរពប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួន ទៅតាមគន្លងធម៌កេរ្តិ៍មតិកដូនតាខ្លួន ដែលបន្សល់ទុកនូវជំនឿពីសម័យបុរាណកាល ឱ្យកូនចៅនៅថែរក្សាកុំឱ្យបាត់បង់រហូតមកដល់សម័យបច្ចុប្បន្នកាលនេះថែមទៀតផង ។

### ការកាប់ឆ្ការព្រៃ

តាមទម្លាប់របស់បងប្អូនខ្មែរលើ នៅពេលណាមេកន្ត្រាញភូមិចង់ផ្លាស់ប្តូរភូមិចាស់ ទៅតាំងនៅភូមិថ្មី ដោយប្រការណាមួយ ឬដោយរំដោះគ្រោះកម្មកំណាចចង្រៃណាមួយ ដោយយល់ឃើញថា ពុំមានសេចក្តីសុខសប្បាយដូចកូនចៅខ្លួនពេលនោះ មេកន្ត្រាញភូមិនាំកូនចៅក្នុងភូមិទាំងអស់គ្នា ចេញទៅស្វែងរកដីព្រៃភ្នំទៅទីកន្លែងណាមួយ ហើយសន្មតថា អាចផ្តល់សេចក្តីសុខកាយសប្បាយចិត្ត ហើយដាំដំណាំក៏បានផលច្រើនដែរ ។

បន្ទាប់មកពួកគេក៏នាំគ្នាកាប់ឆ្ការព្រៃ រុករានទន្ទ្រានដីឱ្យស្អាតបាតល្អ

---

១-រស្មីកម្ពុជា ថ្ងៃទី២៦ ឧសភា ២០០០

ព្រមទាំងចាប់ផ្ដើមកាប់ឈើយកមកអារកាត់ ពុះច្រៀកសម្រាប់សង់លំនៅស្ថាន និងកាប់ដើមឫស្សី ផ្ដៅ វល្លិ ស្លឹកខាំម៉ា ស្លឹកស្បូវ ទុកធ្វើជាដំបូលផ្ទះ ជញ្ជាំងផ្ទះ រនាបផ្ទះ.......និងសម្រាប់ធ្វើអ្វីផ្សេងៗទៀត ។

**ការដាំដើមចេកត្រណាមនៅក្នុងភូមិថ្មី**

ក្រោយពីបានធ្វើជាលំនៅស្ថានស្រួលបួលរួចរាល់ហើយ ពេលនោះ បងប្អូនជនជាតិក្នុងភូមិទាំងមូល ដែលដឹកនាំដោយមេកន្ត្រាញភូមិ ក៏ពុំភ្លេចដាំដំណាំផ្សេងៗដែរ នៅក្នុងដីថ្មី ជាពិសេសដើមចេកត្រណាមតែម្ដង ។

នៅពេលដាំចេកត្រណាមនេះ គេតែងតែរៀបចំពិធីបុណ្យចូលភូមិថ្មីតាមប្រពៃណីសង្គមជនជាតិ ដើម្បីបញ្ជាក់ឱ្យឃើញនូវជំនឿដូនតា ដែលជឿទៅលើអារុក្ខអារក្សអ្នកតាថា មកសណ្ឋិតនៅក្នុងគុម្ពចេកនេះ ។ ហើយដើមចេកត្រណាមរបស់ជនជាតិខ្មែរលើនេះ គឺគេជ្រើសរើសយកតែពូជ "ចេកណាំវ៉ា" ទេ ដែលមានសារប្រយោជន៍ចំពោះអ្នកភូមិ ។

**ជំនឿព្រលឹងដូនតានៅក្នុងគុម្ពចេកត្រណាម**

ក្រោយពីបានដាំចេកហើយ បងប្អូនជនជាតិក្នុងភូមិទាំងអស់គ្នា តែងតែតាមដានសង្កេតនៃការលូតលាស់របស់ដើមចេកនេះទៀត ។ ពីព្រោះគេជឿថាៈ

-បើសិនជាដាំដើមចេកណាំវ៉ានេះទៅ ពុំឃើញមានការដុះលូតលាស់ទេ ឬងាប់តែម្ដង គឺជានិមិត្តរូបនៃប្រផ្នូលអាក្រក់ បង្ហាញឱ្យឃើញថា ការរស់នៅក្នុងភូមិថ្មីនេះ ពុំអាចផ្ដល់សេចក្ដីសុខចម្រើនបានទេ នៅក្នុងជីវភាពរស់នៅ ។

-បើសិនជាដាំដើមចេកណាំវ៉ានេះទៅ ឃើញមានការដុះលូតលាស់បានល្អស្រស់បំព្រង គឺជានិមិត្តរូបបញ្ជាក់ឱ្យឃើញថា ការរស់នៅក្នុងភូមិថ្មីនេះ

ប្រាកដជាបានរស់នៅសុខស្រួលត្រជាក់ត្រជុំ និងការដាំដុះដំណាំធ្វើស្រែចម្ការ តំបន់ព្រៃភ្នំច្បាស់ជាបានទទួលផលច្រើន ហើយគេជឿថា នៅក្នុងកុម្ពចេកនោះដែរ តែងមានព្រលឹងម្ចាស់ស្រុក ឬដូនតាចូលមកសណ្ឋិតនៅខាងក្នុងជានិច្ច ព្រមទាំងជួយថែរក្សាដល់វាសនាពួកអ្នកភូមិទាំងអស់គ្នា ឱ្យជួបប្រទះតែសេចក្ដីសុខសប្បាយជួបជុំគ្នា និងជួយឱ្យសម្បូរណ៍ភោគផលទៀតផង ។

ម្យ៉ាងវិញទៀត បើសិនជាដើមចេកណាំវ៉ានេះ ដុះលូតលាស់កាន់តែច្រើន បែកគុម្ពចេញកូនកាន់តែល្អ ក៏ជានិមិត្តរូបបញ្ជាក់ឱ្យឃើញថា ព្រលឹងអ្នកតាមម្ចាស់ទឹកម្ចាស់ដី តែងតែស្ថិតនៅក្បែរជីវិតកូនចៅជាដរាប ហើយប្រទានពរជ័យសេចក្ដីសុខគ្រប់ពេលវេលា ។

**ការថែទាំចេកត្រណាម**

ចេកត្រណាមដែលជនជាតិខ្មែរលើបានដាំរួចរាល់ហើយ គេតែងតែថែទាំការពារដោយធ្វើរបងព័ទ្ធជុំវិញមានរាងជា៤ជ្រុងស្មើរ ហើយញឹកណាស់ដោយបោះបង្គោលរបងនៅជិត១គ្នា ព្រមទាំងមានកំណាត់ឈើ ឬកំណាត់ឬស្សីដាក់ឃាំងទទឹងបង្គោលទៀតផង ។ របងចេកត្រណាមនេះ មានកម្ពស់ពី ១.៣០ម ទៅ១.៥០ម ឬលើសពីនេះទៅទៀតក៏សឹងមាន ហើយមានរាងជា៤ ជ្រុងស្មើពី៥ម ទៅ៦ម ។

**ការតាក់តែងវិន័យដើម្បីសងជំងឺចិត្ត**

ចេកត្រណាមនេះ គេតមខ្លាំងណាស់ ហាមមិនឱ្យពាល់ជាដាចខាត ទាំងមនុស្ស ទាំងសត្វ ។ បើសិនជាមានមនុស្សណាម្នាក់ ឬជនចម្លែកមិនមែនរស់នៅក្នុងភូមិនេះ ឬក៏មានសត្វគោក្របីមកហែកស្លឹក ឬបេះបោចស៊ីស្លឹកចេក

ត្រណមនេះ........ ប្រសិនបើគេមើលឃើញ គេនិងចាប់ផាកពិន័យយ៉ាងតឹងរឹង ឱ្យសងទៅតាមជំងឺរបស់ពួកអ្នកភូមិ ដែលដឹកនាំដោយមេកន្ត្រាញភូមិ "ទា ប៉ុន្មាន ត្រូវសងប៉ុណ្ណឹង"។

ការសងជំងឺចតិរបួសក្នុងផ្លូវចិត្ត គឺគ្មានអ្វីក្រៅពីទាមទាឱ្យសងគោ ក្របី ជ្រូកមាន់ទា ឬសាច់គោ និងស្រាពាងឡើយ ដែលគេបានរៀបចំធ្វើឡើង នៅពេលមករស់នៅក្នុងភូមិថ្មី ហើយសុទ្ធសឹងជាអំណោយរបស់ពួកអ្នកភូមិ ស្រុក ។ ការសងជំងឺចិត្តនេះ គឺគេចង់បញ្ជាក់ឱ្យឃើញថា គ្រប់មនុស្ស ឬសត្វ ទាំងឡាយណា ដែលបានទៅប៉ះពាល់ចេកត្រណម ដោយគ្មានការអនុញ្ញាតិ គឺ សុទ្ធតែជាមនុស្ស ឬសត្វមានខ្លួនមិនស្អាត ហ៊ានប៉ះពាល់ដល់ព្រលឹងអារក្សអ្នក តាម្ចាស់ស្រុក ដែលកំពុងតែតាមថែរក្សាកូនចៅក្នុងភូមិ ឱ្យជួបប្រទះតែ សេចក្ដីសុខគ្រប់ប្រការ ។

ម្យ៉ាងទៀត ការសងជំងឺចិត្តជូនដល់អ្នកស្រុកភូមិនេះ ដើម្បី"ធ្វើបុណ្យ លាងបាប" ដែលមានន័យថា ត្រូវតែសងរាល់របស់របរ ឬសាច់សត្វ ដែលពួក អ្នកស្រុកគេបានធ្វើបុណ្យរួចរាល់ទាំងប៉ុន្មាន សងឱ្យគ្រប់ចំនួនឡើងវិញ ដើម្បី បញ្ចៀសរឿងរ៉ាវចង្រៃអពមង្គលក្នុងស្រុក កុំឱ្យពើបប្រទះ ក៏ដូចជាធ្វើឱ្យ ព្រលឹងម្ចាស់ទឹកដីក្នុងភូមិបានស្ងប់ស្ងៀម ហើយនៅតាមថែរក្សាកូនចៅតទៅ ទៀត ។

**ផលប្រយោជន៍ចេកត្រណម**

ចំពោះផលដំណាំចេកត្រណមនេះវិញ បើសិនជាចេកត្រណមចេញត្រ យោង គេកម្រកាច់ត្រយូងចេកនេះចោលណាស់ ប្រសិនបើជាកាច់វាចោលវិញ

គឺត្រូវតែមានការឯកភាពគ្នារវាងមេកន្ទ្រាញភូមិ និងអ្នកភូមិ ។ ចំណែកឯផ្លែចេកវិញមានទាំងស្ងួតៗ នោះ ក៏គេកម្រយកមកទទួលទានដែរ ។ និយាយរួមគឺគេយកទៅបោះចោលតែម្តង ។

ប្រសិនណាគេទទួលទានវិញ គឺគេត្រូវតែបែងចែកផ្លែចេកនោះឱ្យបានគ្រប់ៗគ្នា គ្រប់មនុស្សនៅក្នុងភូមិ ។

សព្វថ្ងៃនេះ ការគោរពជំនឿចេកត្រណមរបស់ជនជាតិខ្មែរលើ ឬក្រុមកុលសម្ព័ន្ធខ្មែរដើម នៅខេត្តរតនគិរីមានច្រើនណាស់ ជាពិសេសជនជាតិដែលស្ថិតនៅឆ្ងាយពីទីប្រជុំជន ។ ប៉ុន្តែក៏មានជនជាតិខ្មែរលើខ្លះ គេឈប់ជឿទៅលើការគោរពជំនឿចេកត្រណមដែរ ដោយគេជឿថា "វាគ្មានប្រសិទ្ធិភាពអ្វីទាំងអស់នៅក្នុងជីវិតរស់នៅសព្វថ្ងៃ" ។ ការរស់នៅសុខស្រួល ហើយធ្វើស្រែចម្ការបានផលច្រើន គឺអាស្រ័យទៅលើកត្តាធម្មជាតិ និងការថែទាំដំណាំឱ្យជិតដល់ ទើបបានផលច្រើន"។

## ៨-ជនជាតិភាគតិចខេត្តមណ្ឌលគិរី គេបានអ្វីខ្លះមកលក់នៅទីផ្សារ [១]

"បើទៅលេងខេត្តមណ្ឌលគិរី សូមកុំភ្លេចចូលទៅមើលផ្សារលក់ដូរក្នុងខេត្តមួយនេះ ។

ផ្សារមណ្ឌលគិរីមានលក្ខណៈតូចតាចទេ បើប្រៀបធៀបទៅនឹងផ្សារទីប្រជុំជននៅភូមិភាគកណ្តាល ។ នៅទីនោះ អ្វីៗក៏មានសម្រាប់បម្រើតម្រូវការ

---

១-រស្មីកម្ពុជា. ថ្ងៃទី៩-១០ ធ្នូ ២០០២

សម្រាប់អ្នកស្រុកហូបចុក និងប្រើប្រាស់ទូទៅដែរ ។ តែបើទេសចរកសាច់សត្វព្រៃហូប ឬទិញយកមកផ្ទះវិញ គឺពិបាកជាងនៅត្រែងត្រយឹងទៅទៀត ។

ផ្សារមណ្ឌលគិរី មានជនជាតិភាគតិចមកផ្សារនេះជារៀងរាល់ព្រឹក នេះជាចំណាប់អារម្មណ៍របស់ភ្ញៀវទេសចរណ៍ ក៏ប៉ុន្តែពួកគេភាគច្រើនជាស្ត្រី និងកូនក្មេង ដើរដោយជើងទទេ មានកាផាស្ពាយពីក្រោយខ្នង ដោយនាំយកមកនូវបន្លែផ្លែឈើមកលក់នៅក្នុងទីផ្សារ ។ មានស្ត្រីជនជាតិខ្លះមានទាំងកូនខ្ចី ឬកូនតូចៗមកជាមួយផងដែរ ។ គេធ្វើដំណើរដោយជើងទទេមានចម្ងាយផ្លូវមិនតិចជាង១០គីឡូម៉ែត្រទៅ២០គីឡូម៉ែត្រឡើយ ។

ជនជាតិភាគតិចមកផ្សារដើម្បីអ្វី ? ម្ចាស់ផ្ទះសំណាក់មួយនៅទីរួមខេត្តសែនមនោរម្យបាននិយាយឱ្យដឹងថា គេយកបន្លែផ្លែឈើជាដំណាំដាំដុះមកលក់ ។ ក៏ប៉ុន្តែជនជាតិភាគតិចមិនយកបន្លែមកដាក់លក់ជាជួរដូចអ្នកលក់ដទៃៗទេ ។ ផ្ទុយទៅវិញ គេដើរលក់ពីកន្លែងមួយទៅកន្លែងមួយទៀត ទាល់តែអ្នកស្រុកនៅទីនោះទើបស្គាល់ និងគេដឹងថាជនជាតិភាគតិចលក់អ្វី! ។

អ្នកចង់ទិញអីវ៉ាន់ពីជនជាតិ ត្រូវមើលទំនិញក្នុងការផាដែលគេស្ពាយពីក្រោយខ្នង រួចតថ្លៃគ្នាទិញយកតែម្តង ។

ជាទម្លាប់របស់បងប្អូនជនជាតិ គេមិនសូវចេះនិយាយតថ្លៃច្រើនទេ ។ បើគេថាថ្លៃប៉ុន្មានប៉ុណ្ណឹងហើយ ។ បើយើងមិនទិញទេ គេសុខចិត្តយកទៅផ្ទះវិញ ឬក៏បោះចោលកណ្តាលផ្លូវតែម្តង ។ ប្រសិនបើគេបានលុយ គេនិងទិញអីវ៉ាន់ខ្លះទៅផ្ទះវិញ ។ តែគ្មានអ្វីធំដំទេ ក្រៅតែពីចំណីអាហារសម្រាប់ហូបចុក ។

គ្មានហេតុផលណាមួយឱ្យមានការវិវឌ្ឍជឿនលឿន ខាងផ្នែកស្មារតី

របស់ជនជាតិភាគតិចនោះទេ ។ វាគ្រាន់តែជាចរន្តប្រពៃណីមួយនៅក្នុងជីវភាពធម្មតាប៉ុណ្ណោះ ។ ក៏ប៉ុន្តែសម្រាប់ភ្ញៀវអ្នកទេសចរអាចជាការទាញអារម្មណ៍មួយគួរឱ្យគយគន់ ។ ថ្វីត្បិតតែពួកជនជាតិភាគតិចខ្លះមានការស្លៀកពាក់ដូចយើងគ្រប់គ្នានៅពេលបច្ចុប្បន្ននេះក៏ពិតមែន តែពួកគេសុទ្ធតែជាមនុស្សមិនសូវចេះនិយាយច្រើនទេ ។ ស្ទើរតែមិនចង់រវីរវល់ជាមួយយើងទៀតផង ។

អ្វីដែលធ្វើឱ្យមានការកត់សម្គាល់នោះ គឺគេសង្កេតឃើញជនជាតិភាគតិចរបស់យើងពេលឡើងមកដល់ផ្សារស្រុកសែនមនោរម្យ គេចេះចូលរោងមើលខ្សែវីដេអូភាគទៀតផង មិនដឹងជាគេយល់សាច់រឿងបែបណានោះទេ ។ តែខ្សែវីដេអូធ្វើឱ្យជក់អារម្មណ៍ មើលទាល់តែចប់ទើបចេញពីរោង ។

អ្នកស្រុកសែនមនោរម្យបាននិយាយថា បើយើងឃើញគាត់ (ជនជាតិភាគតិច) ដើរតាមផ្លូវរហើយ បក់ដៃហៅគាត់ឱ្យជិះឡានជាមួយនឹងយើង ក៏គាត់មិនព្រមជិះឡានជាមួយនិងយើងដែរ គាត់សុខចិត្តដើរដោយថ្មើរជើងរហូតដល់ផ្ទះរបស់គាត់ ។ ខេត្តមណ្ឌលគីរីជាខេត្តមួយមានជនជាតិភាគតិចរស់នៅច្រើន គ្របដណ្តប់លើជនជាតិខ្មែរយើងដែលទៅរស់នៅទីនោះ ។ ទំនៀមទម្លាប់ប្រពៃណីរស់នៅរបស់គេត្រូវបានថែរក្សាជាប់ជាប្រចាំ ។ បរិស្ថានរស់នៅរបស់គេមិនបានបំផ្លាញ ឬបំពានដោយជនណាមួយឡើយ ។

អ្នកចាស់ស្រុកនៅខេត្តមណ្ឌលគីរីបានពោលពាក្យថា ទោះបីជាមានភាពខ្វះខាតកើតមានឡើងដល់ជីវភាពរស់នៅរបស់គេ ដូចជាអំបិល ថ្នាំពេទ្យ អង្ករ ឬសម្ភារៈផ្សេងៗទៀតក៏ដោយ ក៏ជនជាតិភាគតិចនៅមណ្ឌលគីរីគ្មានស្រែកទ្រហោយំសុំទាពីរដ្ឋាភិបាល ឬអាជ្ញាធរខេត្តណាបន្តិចសោះឡើយ ។ គេរស់

នៅក្នុងភាពចំណុះឱ្យធម្មជាតិទាំងស្រុង ។ ហើយកន្លងមកក៏រដ្ឋាភិបាល និង អាជ្ញាធរខេត្តគ្មានរវីរវល់ពីការជួយឧបត្ថម្ភដល់ពួកគេដែរ ។

តើពួកគេលើកទឹកចិត្តដល់ជនជាតិបែបណា ឱ្យពួកគេមានជីវភាពប្រសើរជាងនេះ ហើយអភិវឌ្ឍន៍បែបណាឱ្យសង្គមបរិស្ថាននៅតំបន់ជនជាតិមានភាពស្រស់បំព្រងជាងអតីតកាល ។

អាចនិយាយបានថា ខេត្តមណ្ឌលគិរី ជាគ្រាប់ពេជ្រមួយមិនទាន់ច្នៃនៅឡើយ ។ ពិសេសរមណីយដ្ឋានធម្មជាតិ អាចជាទីតាំងមួយស្រូបយកទេសចរយ៉ាងច្រើនឱ្យទៅទស្សនានៅទីនោះ សម្រាប់បណ្ដាឆ្នាំខាងមុខទៀត " ។

## ៩-ទំនៀមទម្លាប់ជក់បារីរបស់បងប្អូនជនជាតិភាគតិច[1]

"ជាទូទៅ បងប្អូនជនជាតិភាគតិចរស់នៅក្នុងខេត្តរតនគិរី ភាគច្រើនពួកគេចេះជក់បារីតាំងពីអាយុ៤ឆ្នាំឡើងទៅ ព្រោះការជក់បារីនេះ វាជាទំនៀមទម្លាប់របស់ពួកគេតាំងពីយូរយាណាស់មកហើយ ។

លោកខ្វែងអ៊ឹម មេឃុំរងសាមគ្គី ស្រុកអូរជុំ ខេត្តរតនគិរីបានឱ្យដឹងថា កុមារដែលជាកូនបងប្អូនជនជាតិភាគតិច ភាគច្រើនគេចេះជក់បារីតាំងពីនៅក្មេងម្លេះ ។ មានកុមារខ្លះ គេចេះជកបារីតាំងពីអាយុ១ឆ្នាំក៏មានដែរ ។ កុមារខ្លះទៀតចេះជក់បារីពីអាយុ៤ឆ្នាំឡើងទៅ ។ លោកអ៊ឹមបានបញ្ជាក់ទៀតថា ការជក់បារីនេះ វាជាទំនៀមទម្លាប់របស់ពួកគេ តាំងពីសម័យយូរលង់ណាស់មកហើយ ព្រោះពួកគេគិតថា ការជក់បារីនេះវាមានផលប្រយោជន៍ដល់ពួកគេ

[1] ១-រស្មីកម្ពុជា ថ្ងៃទី២៩-៣០ កក្កដា ២០០២

ទី១អាចការពារមូសកុំឱ្យខាំ និងទី២ជាវិធីមួយអាចលួងលោមកូនកុំឱ្យយំបាន ។ មានន័យថា ជនជាតិភាគតិចភាគច្រើននៅពេលកូនៗរបស់គេយំ គេតែងតែយកខ្សែជក់បារីយកមកឱ្យកូនៗគេបៀមលេង ព្រោះជនជាតិភាគតិចចេះជក់បារីទាំងប្រុសទាំងស្រី ។

គួរបញ្ជាក់ថា ភាគច្រើនជនជាតិភាគតិចដាំថ្នាំនៅតាមផ្ទះរបស់គេ ឬក៏នៅតាមចម្ការ ។ គេមិនបានទិញបារីមូរដៃ ឬបារីដាក់កញ្ចប់អ្វីទេ ព្រោះបើគេជក់បារីទាំងនោះ ក៏គ្មានប្រាក់ទិញដែរ ។ ការជក់បារីនេះ ពួកគេមិនបានដឹងពីផលប៉ះពាល់សុខភាពអ្វីឡើយ ។ ប៉ុន្តែលោកម៉ម ប៊ុនហេងរដ្ឋលេខាធិការក្រសួងសុខាភិបាលបាននិយាយថា ការជក់បារីធ្វើឱ្យកើតជំងឺមហារីក ជំងឺសួត និងអាចធ្វើឱ្យប្រព័ន្ធខួរក្បាលមានបញ្ហាផងដែរ"។

## ១០.គងនិងជំនឿរបស់ជនជាតិខ្មែរលើ[1]

" "គង"ជាឧបករណ៍តន្ត្រីបុរាណរបស់ជនជាតិព្រៃភ្នំ ដូចជាទំពួន ចារាយ ប្រូវ កាចក់ កាវែត គ្រឹង....ដែលរស់នៅជាលក្ខណៈប្រមូលផ្តុំគ្នាក្នុងភូមិ ឬជាលក្ខណៈក្រុមកុលសម្ព័ន្ធ ដែលដឹកនាំទៅដោយមេកន្ត្រាញក្នុងភូមិ ។

ក្នុងចំណោមជំនឿទាំងឡាយរបស់ជនជាតិខ្មែរលើ ក៏មានជំនឿមួយទៅលើឧបករណ៍តន្ត្រី "គង" នេះដែរ ដែលគេតែងនិយាយថា "ជំនឿគង Gong"។

---

១-រស្មីកម្ពុជា, ៦ តុលា ១៩៩៥

**រូបរាងគង**

គងជាឧបករណ៍ភ្លេងដែលមានទម្រង់រូបរាងជារង្វង់ ដូចកង់រទេះគោ ហើយវាមានទំហំច្រើនប្រភេទណាស់ ដូចជាខ្លះធំ ខ្លះតូច ហើយសុទ្ធតែមានសម្លេងខុសៗពីគ្នាទៀតផង ។ គងតូចគេមានវិជ្ជមាត្រ ឬអង្កត់ផ្ចិត២តឹក និងគងមានទំហំធំជាងគេ គឺមានវិជ្ឍមាត្រ ឬអង្កត់ផ្ចិត១ម៉ែត្រ ។ ក្រៅពីគងទាំងពីរខាងលើនេះ ដែលមានទំហំធំជាងគេ និងតូចជាងគេនោះ ក៏មានគងជាច្រើនទៀត ដែលស្ថិតនៅក្នុងចន្លោះលំដាប់ថ្នាក់គងទាំងពីរនេះដែរ ។

ឧទាហរណ៍ គងនេះមានលក្ខណៈជារាងមូលសំប៉ែត មានទ្រនាប់ពត់តែមទៅក្រោយបន្តិចហើយ នៅផ្នែកខាងលើចំកណ្តាលមានដុំពក (ពុំនក) ចេញមកលើបន្តិច ។ បើពិនិត្យមើលឱ្យហ្មត់ចត់ទៅលើឧបករណ៍គងនេះ មានលក្ខណៈស្រដៀងគ្នាទៅនឹងឆ្នាំងបន្តិច ។ ចំណែកឯកម្រាស់វាវិញ គឺក្រាស់បន្តិចហើយធ្ងន់ទៀតផង ។

**រូបធាតុគងនិងការផលិត**

គងរបស់ជនជាតិតំបន់ព្រៃភ្នំនេះ មានសូរសម្លេងលាន់ឮខ្លាំងណាស់ ទោះបីជាគេវាយវាតិចក៏ដោយ ។ ដើម្បីផលិតគងនេះឡើង គេត្រូវយកល្បាយលោហធាតុមួយចំនួន ដូចជាលង្ហិន ស័រិទ្ធិ ប្រាក់ ស្ពាន់ មកស្លបញ្ចូលគ្នារួចហើយយកទៅចាក់លើពុម្ពដីឥដ្ឋណាមួយ ។ លុះដល់ពេលវានឹងត្រជាក់ ក៏យើងបានគងមួយដូចក្តីប៉ងប្រាថ្នា ។ ប៉ុន្តែចំពោះកំដៅរលាយរបស់វាវិញ គឺមានកម្រិតខ្ពស់ណាស់ រហូតដល់អាចទៅដល់៨០០អង្សារ ឬ១០០០អង្សារ ។

ឧបមារថា ប្រសិនបើយើងមិនល្បាយលោហធាតុនេះទេ គឺវាអាចពុ

ដែរ តែមិនសូវមានប្រសិទ្ធិភាពច្បាស់ ហើយក៏ពិបាកកន្ត្រាក់អារម្មណ៍ដែរ ។ ប៉ុន្តែសព្វថ្ងៃនេះ ការផលិតគងពុំមានសកម្មភាពដូចពីមុនឡើយ ។

**អាយុកាលរបស់គង**

គងរបស់បងប្អូនជនជាតិ ដែលរស់នៅទឹកដីខេត្តរតនគិរីនៃភូមិភាគឦសានក្នុងប្រទេសកម្ពុជានេះ ពុំមែនទើបតែបានផលិតក្នុងពេលថ្មីៗនេះទេ ពោលគឺគងរបស់ជនជាតិទឹកដីព្រៃភ្នំនេះ មានអាយុកាលរាប់រយឆ្នាំ ឬរាប់ស.វ. កន្លងមកហើយ គងខ្លះមានអាយុកាលលើសពី៣០០ឆ្នាំ ឬ៥០០ឆ្នាំទៅទៀត ។

គងដែលមានអាយុច្រើនជនជាតិខ្មែរលើចាត់ទុក គឺជាគងប្រវត្តិសាស្ត្ររបស់ជនជាតិខ្មែរលើ ដែលពួកគេត្រូវតែរក្សាបានយ៉ាងខ្ជាប់ខ្ជួននូវសំណល់មតិករបស់ដូនតាគេ ហើយនៅតែបន្តការប្រើប្រាស់រហូតមកដល់បច្ចុប្បន្ននេះ ។

**ការសម្តែងគងក្នុងវិស័យសិល្បៈក្រោមរូបភាពជំនឿ**

នៅរាល់ពេលធ្វើពិធីបុណ្យរបស់ជនជាតិ ដូចជាពិធីបុណ្យរំដោះគ្រោះ ពិធីបុណ្យសព ពិធីបុណ្យផ្លាស់ប្តូរទីកន្លែង ពិធីរៀបមង្គលការ....តែងតែមានសិល្បៈក្រុមគងចូលទៅសម្តែងជានិច្ច ដើម្បីបម្រើអារម្មណ៍បងប្អូនអ្នកភូមិទាំងអស់គ្នាឱ្យបានសប្បាយរីករាយ ។ ក្នុងឱកាសបុណ្យ ពួកអ្នកភូមិទាំងអស់គ្នាតែងតែទុកចោលការងារមួយរយៈសិន ដើម្បីប្រមូលគ្នីគ្នាទាំងតូចទាំងធំមកចូលរួមពិធីបុណ្យក្រោមសូរនៃគងបន្លឺឡើងយ៉ាងកងរំពង ដែលក៏អាចទាក់ទាញទឹកចិត្តអ្នកនៅឆ្ងាយៗឱ្យចូលមកកម្សាន្តមើលគងដែរ ។ ម្យ៉ាងវិញទៀត គងមិនគ្រាន់តែអាចទាក់ទាញចិត្តមនុស្សពីចម្ងាយទេ វាថែមទាំងមានអានុភាពខ្លាំងក្លាណាស់ ដែលអាចបន្លឺសូរឡើងយ៉ាងគ្រលួច "វាយតិចឮខ្លាំង" ក្នុងការ

ស្រែកហៅ ឬដាស់អញ្ជើញពពួកអារក្ស អ្នកតាព្រៃភ្នំ ម្ចាស់ទឹកម្ចាស់ដី និងព្រលឹងដូនតាឱ្យចូលមកក្នុងពិធីបុណ្យនេះផង ដើម្បីមកទទួលដង្វាយផ្លែឈើ សាច់សត្វ ស្រាពាង ។

ក្រោយពីព្រលឹងរូបអារក្ស អ្នកតាព្រៃភ្នំ ម្ចាស់ទឹកម្ចាស់ដី ព្រលឹងដូនតាបានទទួលដង្វាយទាំងប៉ុន្មានមកហើយ បងប្អូនអ្នកស្រុកអ្នកភូមិ ដែលដឹកនាំដោយមេកន្ត្រាញនោះ គឺគ្មានអ្វីក្រៅពីចង់បានពរជ័យ សុំសេចក្តីសុខគ្រប់ពេលវេលា និងបង្កបង្កើនផលស្រែចម្ការឱ្យបានទទួលផលច្រើននោះឡើយ ជាពិសេសកុំឱ្យមានសត្វល្អិតមកស៊ីបំផ្លិចបំផ្លាញឱ្យសោះ ។ ការសុំពរជ័យនេះហើយគឺជាបំណងប៉ងប្រាថ្នារបស់អ្នកភូមិ ដែលសុំសេចក្តីអង្វរករយ៉ាងទទូចចំពោះព្រលឹងអ្នកថែរក្សាភូមិ ថែរក្សាផ្ទះ ថែរក្សាដីស្រែចម្ការ ដែលគេតែងតែនិយាយថា "រស់នៅសព្វថ្ងៃ កុំឱ្យជួបប្រទះរឿងរាវចង្រៃក្នុងជីវិត បើដាំដុះនៅឆ្ងាយជិតសូមឱ្យបានផលច្រើន" ។

ចំពោះការសម្តែងសិល្បៈគងនេះ គឺមានច្រើនបែបច្រើនយ៉ាងណាស់ ទៅតាមគេរៀបចំនួនគង ហើយគេតែងហៅថា "ផ្លែ" ដូចជាគេរៀបគងចំនួន ៥ គេហៅថា "គង៥ផ្លែ" គេរៀបចំនួនគង១២គេហៅថា "គង១២ផ្លែ" ។ ការសម្តែងសិល្បៈគងនៅរាល់ពិធីបុណ្យផ្សេងៗ ពួកគេមិនប្រកាន់ពីអ្នកសម្តែងវាយគងដែរ ។ ប៉ុន្តែសិល្បៈគង ដែលមានរបាំជួយរាំផងនោះ ក៏មិនកំណត់មនុស្សតាមប្រភេទដែរ ពោលគឺឱ្យតែអ្នកចេះរាំ គឺអាចរាំតាមចង្វាក់ភ្លេងគងបាន ដូចផ្ទៃទឹករលករត់មករកច្រាំង ។ រហូតមកដល់សព្វថ្ងៃនេះ សិល្បៈសម្តែងគង និងមានអ្នករាំ ក៏ក្លាយទៅជាទំនៀមទម្លាប់ប្រពៃណីសិល្បៈមួយទៅហើយ

ដែលសម្តែងឡើងដោយក្រុមយុវវ័យ ។

**ជំនឿគងរបស់ជនជាតិខ្មែរលើ**

បងប្អូនជនជាតិព្រៃភ្នំខ្លះនៅខេត្តរតនគិរី គេមានជំនឿថា "គង" មានឫទ្ធានុភាពស័ក្តិសិទ្ធិណាស់ ដែលត្រូវណាមរបស់គេ ។

ក្រោយពីសម្តែងគងរួច ពួកគេតែងតែយកគងនេះទៅរក្សាទុកនៅកន្លែងណាមួយនៅក្នុងផ្ទះ ។ បើសិនជាយើងទៅដល់ទីនោះ ហើយឃើញគងខ្លះមានទម្រង់រូបរាងល្អស្អាត ស្រាប់តែយកដៃទៅគោះលេងនោះ....ពេលបើយើងមានជោគជតារាសីទាប ប្រាកដជាដល់ពេលយប់ និងឃើញមានស្រមោលអ្វីមួយមកគ្របសង្កត់ពីលើខ្លួនរបស់យើងជាមិនខានឡើយ ។ ពីព្រោះថា ការគោះគងនេះ ដូចជាការស្រែកហៅពពួករូបអារក្ស អ្នកតាម្ចាស់ស្រុកទឹកដីព្រៃភ្នំ និងព្រលឹងដូនតាឱ្យមកទទួលយកដង្វាយ ។ ប៉ុន្តែលុះដល់ព្រលឹងគេមកដល់ហើយស្រាប់តែមិនឃើញមានអ្វីទាំងអស់ ក៏ធ្វើឱ្យពួកគេខឹង រួចហើយក៏ធ្វើឱ្យឃើញស្រមោលរហូតដល់ទៅឈឺក៏មានដែរ ពិសេសអ្នកដែលជាជនចម្លែកចូលទៅស្រុកភូមិគេ ហើយបានទៅប៉ះពាល់គេងនោះ ។ តាមពិតទៅយើងគ្រាន់តែសាកល្បងយកដៃគោះលេងចង់ដឹងពីសូរសម្លេងរបស់គេទេតើ ? ។

ហេតុដូច្នេះហើយ បើយើងចុះទៅដល់តំបន់របស់ជនជាតិ ដែលមានគងតាមផ្ទះ សូមមេត្តាកុំប៉ះពាល់របស់របរគេឱ្យសោះ ព្រោះជំនឿគងរបស់ពួកគេទាំងនោះភាគច្រើន សុទ្ធតែមានឫទ្ធានុភាពជំនឿស័ក្តិសិទ្ធិ ហើយសុទ្ធតែមានអាយុកាលរាប់ស.វ.មកហើយ ដែលមានរូបអារក្សអ្នកតាកាន់ ឬសណ្ឋិតនៅក្នុងនោះ ហើយរស់នៅតាមថែរក្សាកូនចៅគេគ្រប់ពេលវេលា " ។

# ១១-ការសម្រាលកូនរបស់ស្ត្រីជនជាតិព្នង[១]

"ជនជាតិព្នង គឺជាក្រុមកុលសម្ព័ន្ធខ្មែរដើមមួយប្រភេទ ដែលរស់នៅក្នុងភូមិភាគឦសាន ដូចជានៅខេត្តរតនគិរី មណ្ឌលគិរី ស្ទឹងត្រែង និងក្រចេះ .....។ ជនជាតិទាំងនេះ មានទំនៀមទម្លាប់ប្រពៃណីជាច្រើន ដែលដូនតាបានបន្សល់ទុកកេរ្តិ៍មតិកតាំងពីសម័យអតីតកាល រហូតមកដល់បច្ចុប្បន្នកាលនេះ ហើយនៅតែខិតខំគោរពប្រណិប័តន៍តាមគន្លងជំនឿបុរាណដដែល ដូចជា "ការសម្រាលកូនរបស់ស្ត្រីជនជាតិព្នង" ជាដើម ។

## ១-ការសម្រាលកូនតាមលក្ខណៈបុរាណរបស់ជនជាតិព្នង

នៅមុនពេលសម្រាលកូន ឬឆ្លងទន្លេរបស់ស្ត្រីជនជាតិព្នង បុរសជាប្តីបានត្រៀមរៀបចំម្ហូបអាហារនំចំណីផ្លែឈើ និងសម្ភារៈប្រើប្រាស់ទុកជាស្រេច ។ ជាពិសេស គឺការសង់រោងតូចមួយសម្រាប់ទុកឱ្យប្រពន្ធ និងកូនរបស់ខ្លួនរស់នៅទីនោះមួយរយៈពេលខ្លី ។

កាលបើប្រពន្ធបានឆ្លងទន្លេហើយ បុរសជាប្តីក៏នាំប្រពន្ធកូនទៅសម្រាកនៅទីនោះ ។ នៅពីមុខរោងនេះ គេមានដោតដើមបបុសទុកជាសញ្ញាសម្រាប់សម្គាល់ ដើម្បីការពារពួកប្រេត ព្រាយ បិសាច ឬពួកអារក្សព្រៃភ្នំ បង់បត់នានា កុំឱ្យចូលមកបៀតបៀន ឬយាយីដល់រោងដែលមានស្ត្រីកូនខ្ចី ។ ការដោតបបុសនេះ គឺគ្មានអ្វីក្រៅពីប្រាថ្នាបួងសួងសុំសេចក្តីសុខកាយសប្បាយចិត្តចំពោះប្រពន្ធកូនឡើយ ដើម្បីរស់នៅជួបជុំគ្នា ។

---

១-រស្មីកម្ពុជា, ២៦ វិច្ឆិកា ២០០០

## ២-អំណោយជូនយាយឆ្មប

ចំពោះអំណោយជូនយាយឆ្មប គឺគ្មានអ្វីក្រៅពីជូនទៅតាមសទ្ធាទឹកចិត្ត និងកម្រិតជីវភាពនោះទេ ។

-ប្រសិនប្រើគ្រួសារណាមានជីវភាពធូធារ គេអាចជូនជ្រូកមួយគូរ ឬគោមួយនិម ឬក្របីមួយនិម ។

-ប្រសិនបើគ្រួសារណាមានជីវភាពក្រីក្រ គេអាចជូនមាន់មួយគូ (មាន់ពណ៌សមួយ និងមាន់ពណ៌ខ្មៅមួយ) ។

-ប្រសិនបើគ្រួសារណាមានជីវភាពក្រីក្របំផុតមិនចាំបាច់ជូនអំណោយក៏បានដែរ ។

## ៣-បើប្រពន្ធស្លាប់ប្ដីទាប់ផ្ដើមដើរចេញពីភូមិ

ប្រសិនបើការឆ្លងទន្លេរបស់ស្ត្រីជនជាតិព្នងស្លាប់ (ព្រាយក្រឡាភ្លើង) ពេលនោះ ពួកអ្នកភូមិអ្នកស្រុក និងមេកន្ទ្រាញភូមិ ក៏នាំគ្នានីរទេសដេញបុរសដែលត្រូវជាប្ដីនោះ ឱ្យចាកចេញពីភូមិស្រុករបស់ខ្លួនរយៈពេលចំនួន៣ខែ ឬ ១០០ថ្ងៃ ដោយឱ្យទៅរស់នៅក្នុងព្រៃស្មសានស្ងាត់ជ្រងំកម្សត់តែម្នាក់ឯង ។ ពីព្រោះពួកអ្នកភូមិអ្នកស្រុក និងមេកន្ទ្រាញភូមិមានជំនឿថា "បើបុរសណាមានប្រពន្ធស្លាប់ក្នុងពេលឆ្លងទន្លេ បុរសនោះគឺជាមនុស្សចង្រៃបំផុត" ។

លុះដល់ពេលវេលាផុតកំណត់ចំនួន៣ខែ ឬ១០០ថ្ងៃ ពេលនោះអ្នកភូមិអ្នកស្រុក និងមេកន្ទ្រាញភូមិ ក៏អនុញ្ញាតិឱ្យបុរសកម្សត់ប្រពន្ធស្លាប់ចោលនោះអាចវិលត្រឡប់មករកផ្ទះសម្បែងខ្លួនវិញ ហើយរស់នៅក្នុងភូមិតាមបែបលក្ខណៈសាមញ្ញដូចមនុស្សដទៃទៀតក្នុងភូមិដែរ ។

ហេតុនេះហើយ ទំនៀមទម្លាប់ប្រពៃណីឆ្លងទន្លេរបស់ស្ត្រីជនជាតិព្រៃភ្នំព្នងតាមលក្ខណៈបុរាណនៅក្នុងភូមិភាគឦសានប្រទេសកម្ពុជា គឺពុំសូវមានច្រើនឡើយ ។ ដោយសារគេយល់ថា បញ្ហានេះមានលក្ខណៈតឹងរឹង ហើយចាប់បង្ខំឱ្យប្តីចាកចេញពីផ្ទះសម្បែង និងព្រាត់កូនមួយគ្រាទាំងអាឡោះអាល័យរស់នៅក្នុងព្រៃកម្សត់កណ្តោចកណ្តែងតែម្នាក់ឯងគួរឱ្យអាណិតអាសូរជាទីបំផុត" ។

## ១២_កងដៃមតិករបស់ក្រមុំព្រៃភ្នំ [១]

"ក្រមុំព្រៃភ្នំក្នុងខេត្តរតនគិរី តែងតែជួបប្រទះរឿងរ៉ាវជាច្រើននៅក្នុងជីវិតដែលរស់នៅជាលក្ខណៈក្រុមកុលសម្ព័ន្ធខ្មែរដើម ហើយមានទំនៀមទម្លាប់ប្រពៃណីដ៏បុរាណបំផុត ។ ជាពិសេសទំនៀមទម្លាប់ដ៏បុរាណមួយ ដែលពួកគេនៅតែបន្តអនុវត្តនឹមកដល់បច្ចុប្បន្ននេះ គឺ "កងដៃមតិករបស់ក្រមុំព្រៃភ្នំ" ។

នៅពេលណាកូនស្រីមានអាយុពេញក្រមុំហើយ ឪពុកម្តាយជីដូនជីតា ឬអ្នកបីបាច់ថែរក្សាកូនចៅ តែងតែគិតគូរដល់នាងវ័យក្រមុំជានិច្ច ក្នុងការតុបតែងលំអរខ្លួនប្រាណ ពិសេសគ្រឿងអលង្ការ ។ ព្រោះថា កាលពី៦០ឆ្នាំមុននោះនៅតំបន់ព្រៃភ្នំខេត្តរតនគិរី គឺសម្បូរណាស់នូវលោហធាតុដែក ដែលបងប្អូនជនជាតិចេះកែច្នៃប្រឌិតស្លលោហធាតុ ដំពន្លូតលោហធាតុ កែប្រែរ៉ែធម្មជាតិទាំងនោះមកជាគ្រឿងរបស់ប្រើប្រាស់ប្រចាំថ្ងៃ.... ហើយអ្វីដែលសំខាន់មានតម្លៃពុំអាចបោះបង់ចោលបាន ដែលជាសំណល់កេរ្តិ៍មតិកពីអតីតកាលនោះ គឺ "កងដៃក្រមុំជនជាតិ" ។

---

១-រស្មីកម្ពុជា, ៤ សីហា ១៩៩៥

កងដៃក្រមុំជនជាតិនេះ គឺជាគ្រឿងអលង្ការធ្វើអំពីស្ពាន់ស ឬដែកមាន រង្វង់ច្រើន ហើយពាក់នៅជុំគ្នាដៃទាំងពីរត្រង់កដៃ ។ កងដៃនេះ មានរង្វង់កង មួយៗដាច់ដោយឡែកៗ ហើយមានទំហំខុសៗគ្នា ដោយចាប់ផ្តើមចេញពីកង ដៃតូចនៅត្រង់កដៃ រួចហើយពង្រីកទៅធំនៅត្រង់កំភួនដៃ ដោយដាក់ត្រួតគ្នា ។ កងដៃខ្លះ គេពាក់មានមចំនួន៥..., ១០....., ១២....., ១៥....., ២០....., វា អាស្រ័យទៅលើចំណង់ចំណូលចិត្តរបស់បុគ្គលតែប៉ុណ្ណោះ ។

ការពាក់កងដៃរបស់ក្រមុំជនជាតិនេះ មិនមែនគ្រាន់តែជាគ្រឿងលំអរ ប៉ុណ្ណោះទេ តែវាគឺជានិមិត្តរូបនៃជំនឿរបស់ជនជាតិផងដែរ ដែលគេបានជឿថា វាបានផ្តល់សេចក្តីសុខគ្រប់ពេលវេលា និងប្រកបមុខរបរជាអ្នកស្រែចម្ការតំបន់ ព្រៃភ្នំក៏បានភោគផលច្រើនដែរ ហើយក៏ពុំសូវមានសត្វល្អិតតូចធំមកបំផ្លិច បំផ្លាញដែរ ។

កងដៃខ្លះ ពុំមែនទើបតែផលិតឡើងក្នុងពេលថ្មីៗនេះទេ ពោលគឺគេ បានផលិតឡើងតាំងពីយូរយាណាស់មកហើយ ។ ខ្លះទៀតជាមតិករបស់ម៉ែ របស់យាយ ដែលបានបំពាក់ជូនដល់កូនចៅ ក៏ដូចជាទុកជាកេរ្តិ៍ដំណែលដល់កូន ចៅ ឱ្យចេះរក្សានូវអ្វីដែលមានតម្លៃនៅក្នុងសម័យមនុស្សដើម ហើយកងដៃ ខ្លះទៀត ក៏មានបញ្ចុះអាគមគាថា ឬផ្លុំផ្សែងឱ្យជះទៅលើដៃទៀតផង ដើម្បីឱ្យ កូនស្រីវ័យក្រមុំរស់នៅត្រជាក់ត្រជុំបានយូរអង្វែងតរៀងទៅ និងទៅណាមក ណាមានគេនិយមចូលចិត្តរាប់អានគ្រប់ៗគ្នា ។

ការពាក់កងដៃនេះ ក៏ជាការបង្ហាញឱ្យឃើញដែរថា បើសិនជាកូនក្រមុំ ណាម្នាក់ពាក់កងដៃនេះសុទ្ធតែអភិជន ឬជនអ្នកមានក្នុងតំបន់ព្រៃភ្នំហើយ

ព្រោះថា ការរស់នៅរបស់បងប្អូនជនជាតិទាំងនោះ ក្នុងសម័យអតីតកាល គឺសុទ្ធសឹងតែរស់នៅក្នុងលក្ខណៈសមភាព ស្ថានភាពស្មើរគ្នា ហើយពោរពេញទៅដោយសាមគ្គីធម៌ ភាតរធម៌គ្រប់ពេលវេលា ។ មានន័យថា កូនក្រមុំព្រៃភ្នំពីមុនសុទ្ធតែជាកូនសេដ្ឋីព្រៃភ្នំទាំងអស់គ្នា ។

ក្រមុំខ្លះ មិនគ្រាន់តែពាក់កងដៃច្រើនប៉ុណ្ណោះទេ ថែមទាំងមានពាក់ចិញ្ចៀនទៀតផង ។ ចិញ្ចៀនរបស់ពួកគេទាំងនោះ គឺសុទ្ធតែជារបស់ផលិតឡើងដោយដែក ឬស្ពាន់ស ហើយមានចំនួនច្រើនណាស់ ស្ទើរតែពាក់គ្រប់ម្រាមដៃទៅហើយ ។ ម្រាមដៃខ្លះមានពាក់ចញ្ចៀនពី១ទៅ៥វង្វង់ (វង់) ។ មិនត្រឹមតែប៉ុណ្ណោះទេ ក្រមុំជនជាតិខ្លះ មានពាក់កងដៃខ្សែវល្លិ និងចិញ្ចៀនខ្សែវល្លិទៀតផង ។ កងដៃខ្សែវល្លិ និងចិញ្ចៀនខ្សែវល្លិនេះ គឺគេយកវល្លិព្រៃមកដង្កួញវេញដូចជាខ្សែគោ ដែលមានពីធ្លុង ហើយវាក៏មានអានុភាពខ្លាំងក្លាក្នុងជំនឿអាចបញ្ចៀសរឿងរ៉ាវសៅហ្មងចង្រៃអ្វីផ្សេងៗបាន ដូចកងដៃកើ្តមតិកដែរ ។

សព្វថ្ងៃនេះ ការពាក់កងដៃកើ្តមតិកពីដែក ឬស្ពាន់ស និងកងដៃខ្សែវល្លិព្រៃ ចិញ្ចៀនខ្សែវល្លិព្រៃ មានសេសសលលស្លាកស្នាមចំពោះតែស្ត្រីព្រៃភ្នំដែលមានវ័យចំណាស់ពីអាយុ៥០ឆ្នាំឡើងទៅ ព្រោះថា ពួកស្ត្រីទាំងនោះ នៅតែមានចំណង់ចំណូលចិត្តស្រឡាញ់នូវអ្វី ដែលជាលក្ខណៈសាមញ្ញភាពរបស់បុព្វការីជនពីអតីតកាល ។ ហើយក៏មានស្ត្រីវ័យចំណាស់ខ្លះៗ ក៏បោះបង់ចោលជាបណ្តើរៗដែរ ។ ប៉ុន្តែចំពោះក្រមុំព្រៃភ្នំបច្ចុប្បន្ននេះ គឺពួកគេបោះបង់ចោលទាំងអស់គ្នាតែម្តង ព្រោះគេគ្មានបំណងចំណង់ចំណូលចិត្ត ឬស្រឡាញ់កងដៃមានកាំថ្នាក់ច្រើនឡើយ ហើយក៏គ្មានលក្ខណៈភ្លឺថ្លារលោង ពណ៌ក្រហមស្រស់ដូចមាស

ប្លាទីន ឬស្ពាន់ក្រហមទេ ហើយណាមួយទៀត ពាក់ច្រើនពេកនាំឱ្យតែធ្ងន់ដៃ ពិបាកដេក និងធ្វើការងារទៀតផង ។ ម្យ៉ាងទៀតពួកនាងៗក្រមុំសព្វថ្ងៃនេះ គេក៏នាំគ្នាទោទន់បមបែរមុខព្រួញជីវិតមករកគ្រឿងមាស ស្ពាន់ក្រហម ប្លាទីនដែរ ដែលគេយល់ថា ជាគ្រឿងលោហធាតុធម្មជាតិមានតម្លៃជាងគេ ហើយមានគេចូលចិត្តច្រើន........." ។

## ១៣-ឧបករណ៍ភ្លេង "ពួយ" របស់ជនជាតិព័រ និងជង[1]

"ជនជាតិព័រ និងជងនៅលើទឹកដីនៃខេត្តពោធិសាត់ និយមយកផ្លែឃ្លោកពួយមកប្រើប្រាស់ជាឧបករណ៍ប្រអប់សម្លេង ។ ព្រោះថា ផ្លែឃ្លោកមួយមានរាងមូលដូចជាផ្លែល្ពៅ ដែលមានទងវែងជាសណ្តង់ដូចចំពួយ ងាយក្នុងការប្រើប្រាស់ជាបំពង់បឺតផ្លុំខ្យល់បានយ៉ាងស្រួល ដោយគ្រាន់តែចោះសងខាងឱ្យល្មមបញ្ចូលបំពង់ទាំងប្រាំ ឬប្រាំពីរត្រឹមអណ្តាត ហើយបិទភ្ជិតដោយជ័យម្យ៉ាងដែលផ្សំឡើងអពីក្រមួនផ្លិតសត្វម្រោម និងសត្វស្អុងជាអម្បូរឃ្មុំ ដែលចូលចិត្តរស់នៅក្នុងរន្ធឈើនោះជាការស្រេច ។

ចំណែកខាងផ្លែឃ្លោកពួយវិញ ក្រៅពីសម្រាប់កែច្នៃធ្វើជាប្រអប់សម្លេងនៃឧបករណ៍ភ្លេង និងគ្រឿងលំអតាំងផ្ទះ ផ្លែឃ្លោកពួយគឺមិនអាចប្រើការជាអ្វីទៀតបានឡើយ សូម្បីតែផ្លែរបស់វានៅខ្ចីក៏គេមិនអាចយកមកធ្វើបន្លែបរិភោគដូចជាផ្លែឃ្លោកដទៃទៀតបានដែរ ។ ហេតុនេះហើយ ទើបមកដល់ពេលបច្ចុប្បន្ននេះ គឺពិបាករកណាស់ ។ រីឯការផលិតឧបករណ៍ពួយវិញ

---

១-រស្មីកម្ពុជា. ១៩-២០ មិថុនា ២០០០

ប្រអប់សម្លេង គឺត្រូវប្រើលលាដ៍ដូងជំនួសវិញ ដោយត្រូវបន្ថែមនូវបំពង់បឺតធ្វើអំពីដើមបបុស ឬក៏បំពង់ពកនេះឯង ។

**ផ្នែកអណ្តាត**

អណ្តាតសម្លេង គឺជាផ្នែកមួយ ដែលចាំបាច់បំផុតក្នុងការបញ្ចេញនូវសនៀង ។ អណ្តាតនៃឧបករណ៍ភ្លេងពួយ គេនិយមធ្វើឡើងអំពីធាងរបស់ដើមជក់ ។ ដើមនេះ ច្រើនមានដុះនៅតាមជញ្ជាំងភ្នំ ក្បែរៗមាត់ជ្រោះ ដូចជាភ្នំជញ្ជាំងភ្នំទឹកផុស និងភ្នំជីកត្បូង ។ ទាំងដើម ធាង និងស្លឹកមានសណ្ឋានដូចគ្នាបេះបិទ និងដើមដូង ខុសតែត្រង់ផ្លែបែរជាដូចផ្លែទន្សែទៅវិញ ។ បច្ចុប្បន្នដើមជក់ពិបាកនឹងរកណាស់ ព្រោះត្រូវរងនូវការកាប់បំផ្លាញយកគមមកបរិភោគ ខ្លះយកមកធ្វើជាបន្លែ ។ អណ្តាតពួយមានរាងដូចអណ្តាតនៃឧបករណ៍ប៉ីពក ឬអណ្តាតស្នែងដែរ គ្រាន់តែអណ្តាតភ្លេងពួយ គេរៀបដាក់គ្រប់បំពង់សម្លេង មិន ប្រើតែមួយទេ គឺគេសកយកខាងខ្នងនៃធាងហាលឱ្យស្ងួត ។

ក្រោយពីធ្វើរួច គេត្រូវចោះបំពង់ពកល្មមនិងបញ្ចូលអណ្តាត បិទឱ្យខ្យល់ចេញចូលបានតាមតែចន្លោះអណ្តាតប៉ុណ្ណោះ ។ លើសពីនេះទៅទៀតនោះអណ្តាតភ្លេងពួយត្រូវមានពិធីមួយទៀតជួយឱ្យសម្លេងធ្ងន់ និងយោបល់បានល្អគឺគេយកសម្បកខ្យងចិញ្ចៀន ជាប្រភេទខ្យងគ្គក់ គ្រាន់តែធំជាង ប្រើយកមកដុះយកម្សៅវាលាយជាមួយនិងទឹក រួចលាបពីលើអណ្តាតពកហាលឱ្យស្ងួតល្អនោះជាការស្រេច ។ ប៉ុន្តែបញ្ហាមួយទៀត ចំពោះសំបកខ្យងចិញ្ចៀននេះបច្ចុប្បន្នគឺពិបាករកបន្តិច តែគេអាចប្រើប្រាស់សំបកងាវមកជំនួសបាន ។ ព្រោះសំបកងាវ ប្រើយកមមដុសអាចចេញម្សៅដូចគ្នានិងសំបកខ្យងចិញ្ចៀនដែរ ។

តាមការពិនិត្យសង្កេតទៅលើឧបករណ៍ភ្លេងពួយនេះ បង្ហាញឱ្យឃើញថា ពួយមានលក្ខណៈពិសេសមួយចំនួន ខុសប្លែកពីឧបករណ៍ភ្លេងដទៃផងដែរ ។ ក្រៅពីវត្ថុធាតុដើមដែលជ្រើសចេញពីធម្មជាតិព្រៃភ្នំពិសេស ។ ពួយនៅមានលក្ខណៈពិសេសនៃសម្លេង និងលក្ខណៈពិសេសក្នុងការរៀបចំពិធីសែនព្រេនរក្សាទុកទៀតផង ។

សម្លេងពួយ គឺមានប្រឌិតចេញឡើងត្រាប់តាមសម្លេងធម្មជាតិនៃសត្វកន្លង់ក្រេបផ្កាយ៉ាងប្រាកដឥតប្រកែកបានឡើយ ។ រីឯលក្ខណៈពិសេសមួយទៀត គឺជាឧបករណ៍ភ្លេងពួយ ក្រោយពីត្រូវបានផលិតរួចរាល់ជាស្ថាពរហើយ គេត្រូវរៀបចំពិធីសែនព្រេនមួយឡើង ក្នុងបំណងឧទ្ទិសស្នាដៃនៃការកសាងឧបករណ៍នេះ ដល់អ្នកតាចាស់ស្រុក ពិសេសគឺអ្នកតាអន្ទង់រីម ឬអ្នកតានរុង ។ ការដែលត្រូវតែធ្វើពិធីសែនព្រេនអ្នកតានរុងនេះ ព្រោះអ្នកតានរុងនេះហើយ ដែលជាអ្នកច្នៃប្រឌិតរកឃើញ និងកសាងឧបករណ៍ពួយនេះឡើងដំបូងបំផុត ។ ចំណេរក្រោយមក ឱ្យតែឧបករណ៍នេះត្រូវបានផលិតជាថ្មីរួច គឺគេត្រូវតែរៀបចំពិធីនេះឡើង ក្នុងបំណងសុំបំពាក់ថ្វាយឱ្យព្រលឹងធម្មជាតិពិតមកសណ្ឋិតក្នុងឧបករណ៍នេះ ។ ពិសេសទៅទៀត ឧបករណ៍ភ្លេងពួយពីបុរាណកាលមក គឺគ្មានអ្នកណាម្នាក់អាចយកមករក្សាទុកជាកម្មសិទ្ធិនៅលើផ្ទះខ្លួនបានឡើយ ក្រៅពីរក្សាទុកនៅទីដ៏សមគួរមួយ សម្រាប់ប្រើប្រាស់ជាទូទៅនៅក្នុងភូមិស្រុករបស់គេតែប៉ុណ្ណោះ " ។

## ១៤-ឧបករណ៍ភ្លេងរហេតរហូត[1]

"បងប្អូនកុលសម្ព័ន្ធខ្មែរលើ ដូចជាជនជាតិទំពួន គ្រឹង ព្រៅ កួយជាដើម ដែលរស់នៅប៉ែកឦសាននៃខេត្តរតនគិរី និងមណ្ឌលគិរី និយមឧបករណ៍ភ្លេងមួយយ៉ាងដែលមានឈ្មោះថា រហេតរហូតតាំងពីក្មេងមកម្លេះ ។

ឧបករណ៍ភ្លេងនេះ កំពង់និយមនៅឡើយ ដោយយុវវ័យ មិនគ្រាន់តែកំដរអារម្មណ៍ ឬបំបាត់ការអផ្សុក ទុក្ខព្រួយក្នុងជីវិតតែប៉ុណ្ណោះទេ លើសពីនេះទៅទៀត គឺគេផ្លុំឧបករណ៍ភ្លេងនេះអន្ទងទៅរកគូរស្នេហ៍ថែមទៀតផង ។ ប្រសិនបើនៅពេលដែលនារីផ្លុំហើយ មានការផ្លុំតមកវិញពីសំណាក់បុរសស្នេហ៍ ពួកគេនិងណាត់ជួបគ្នានៅកន្លែងណាមួយ ដើម្បីផ្ដោះផ្ដងស្នេហាគ្នាទៅវិញទៅមកពុំខាន ។

ឧបករណ៍រហេតរហូតនេះ ជាឧបករណ៍ខ្យល់ ដោយមានបំពង់ផ្លុំដល់ទៅប្រាំពីរបំពង់ ។ យើងច្បាស់ជាឃើញពុំខានទេ នូវឧបករណ៍ភ្លេងនេះ នៅលើចម្លាក់នៃប្រាង្គប្រាសាទខ្មែរបុរាណ"។

## ១៥-ទំនាក់ទំនងរវាងទីតាំងរស់, ស្ថានភាពរស់ និងជំនឿសាសនា ជាការបញ្ជាក់ពីប្រវត្តិនៃឧបករណ៍ភ្លេងពួយ[2]

"ពួយជាឧបករណ៍ភ្លេងផ្លុំមួយបែប ក្នុងចំណោមឧបករណ៍ភ្លេងផ្លុំទាំងអស់របស់ខ្មែរ ដែលបុព្វបុរសនៃអម្បូរជនជាតិព័រ និងជងបានបន្សល់ទុកមក ។

---

១- (កំណត់ហេតុ) មីសែល ត្រាណេ ២០-៩- ១៩៩៨

២-រស្មីកម្ពុជា ថ្ងៃទី២ កញ្ញា ២០០០

ប៉ុន្តែឧបករណ៍ភ្លេងពួយ គឺមានលក្ខណៈពិសេសមួយដោយឡែកនោះ គឺជាលក្ខណៈពិសេសដែលស្តែងឡើងពីចិរិធម្មជាតិព្រៃភ្នំក្រមថ្ម ដែលគេអាចធ្វើការវិនិច្ឆ័យបានអំពីសារសំខាន់នោះ ដោយពឹងផ្អែកទាំងស្រុងលើស្ថានភាពទំនាក់ទំនងរវាងទីតាំងរស់ស្ថានភាពរស់ និងជំនឿសាសនា ។ បងប្អូនជនជាតិខ្មែរព័រ និងជង គឺជាអម្បូរដែលបន្សល់មកពីក្រុមកុលសម្ព័ន្ធភូមិភាគអាស៊ី ។ ពួកគេមានទម្លាប់រស់នៅជារបៀពាក់កណ្តាលពនេចរលើទីតាំងភូមិសាស្ត្រ ស្ថិតនៅតំបន់ខ្ពង់រាបជួរភ្នំក្រវាញខេត្តពោធិសាត់ ។ នៅក្នុងជីវភាពរស់នៅ គឺពឹងផ្អែកទាំងស្រុងទៅលើធម្មជាតិ ទៅលើជំនឿជឿជាក់នៃតំបន់ដែលពួកគេរស់នៅនោះ ។ ដូច្នេះដើម្បី បម្រើបានតាមសំណូមពរផ្សេងៗក្នុងការជឿ គឺពួកគេត្រូវខិតខំប្រឹងប្រែងកែលំអរ លៃលក រាវរកនូវអ្វីដែលអាចផលិតបាននូវឧបករណ៍តន្ត្រីសម្រាប់បម្រើសេចក្តីត្រូវការរបស់ពួកគេ ដែលរស់នៅក្នុងជម្រកធម្មជាតិ ទើបឆ្នៀតបង្កើតបាននូវឧបករណ៍ភ្លេងពួយឡើង ដោយនិកស្មានមិនដល់សម្រាប់ប្រគំថ្វាយអារុក្ខអារក្សអ្នកតាម្ចាស់ទឹកម្ចាស់ដីព្រៃភ្នំក្រមថ្ម ក្នុងពិធីសែនព្រេនជាប្រពៃណី ដូចជាពិធីរៀបមង្គលការកូនប្រុសស្រី និងបុណ្យទានផ្សេងៗទៀត ។

តាមរយៈការទំនាក់ទំនងគ្នារវាងទីតាំងរស់ ស្ថានភាពរស់ និងជំនឿសាសនានៅក្នុងការរស់នៅ ជាមធ្យោបាយផ្ទៀងផ្ទាត់របស់ជនជាតិព័រ និងជងខាងលើនេះ បានបង្ហាញឱ្យដឹង និងឃើញនូវចំណុចពិសេសខ្លះៗ អំពីភាពចាំបាច់ភាពសំខាន់ ពិសេស គឺអំពីប្រវត្តិនៃឧបករណ៍ភ្លេងពួយនេះតែម្តង ដែលផ្សារភ្ជាប់យ៉ាងស្អិតរមួតនៅក្នុងជីវិតពិតរបស់ជនជាតិនេះ" ។

## ១៦_លេកសម្លេងចាប៉ីឃ្លោករបស់ជនជាតិខ្មែរលើ [១]

"ចាប៉ីឃ្លោក គឺជាឧបករណ៍តន្ត្រីមួយប្រភេទរបស់បងប្អូនជនជាតិទំពួន គ្រឹង ចារាយ ព្នង ព្រៅ.....ដែលរស់នៅជាយក្រុង ឬរស់នៅតាមតំបន់ព្រៃភ្នំជ្រលងភ្នំ ខ្ពង់រាបដាច់ស្រយាល ។ ចាប៉ីឃ្លោកនេះ គេធ្វើឡើងដោយបំពង់ឬស្សីពក មានប្រវែង៦តឹក (០,៦ម៉ែត្រ) ឬអាចវែងជាងនេះបន្តិច ឬក៏អាចខ្លីជាងនេះបន្តិច អាស្រ័យទៅនឹងចំណង់ចំណូលចិត្តរបស់អ្នកផលិតឧបករណ៍តន្ត្រីចាប៉ីឃ្លោក ។ ចាប៉ីឃ្លោកនេះ មានខ្សែទាំងអស់១០ ឬ៨ ហើយមានកំណាត់ឈើ ១០ ឬ៨ខ្ទង់ទៅតាមចំនួនខ្សែ សម្រាប់រឹតខ្សែចាប៉ីឃ្លោកទៀតផង ។ នៅក្បែរកំណាត់ឈើនោះ មានសំបកឃ្លោកដែលជួយធ្វើជាទម្រ ឬក៏ជួយបំពងសម្លេងខ្សែលួសឱ្យកាន់តែមានលក្ខណៈពិរោះល្អប្រសើរមួយកម្រិតថែមទៀត ប្រៀបបានទៅនឹងសម្លេងតន្ត្រីបុរាណទ្រខ្មែរ ដែលមានត្រឡោកជួយបញ្ចេញ ឬបំពងសម្លេងនោះដែរ ។

ចំពោះការលេងតន្ត្រីចាប៉ីឃ្លោករបស់បងប្អូនជនជាតិ ដែលរស់នៅក្នុងខេត្តរតនគិរីនោះវិញ គឺពួកគេលេងចាប៉ីឃ្លោកតែនៅពេលយប់ ហើយអ្នកលេងចាប៉ីឃ្លោកនេះ គឺជាយុវវ័យពេញកំលោះ ក្រមុំ ដែលកំពុងតែស្ថិតនៅក្នុងស្ថានភាពមួយស្វែងរកគូរកំណាន់ចិត្ត ដើម្បីសាងជីវិតរៀបចំអនាគតរបស់ខ្លួន ។

នៅពេលយប់មកដល់ម្តង១ កូនកំលោះខ្លះសែនអផ្សុកណាស់ ក៏ដើរទៅស្កាត់ជួបកូនក្រមុំក្នុងភូមិជាមួយគ្នា ដើម្បីសម្តែងឱ្យឃើញនូវបេះដូងមនោ

---

១-រស្មីកម្ពុជា, ២៦ មិនា ១៩៩៥

សញ្ចេតនាស្នេហារបស់យុវវ័យ ។ ឯកំលោះៗខ្លះ ពេលលេងចាប៉ីឃ្លោកបណ្ដែតអារម្មណ៍ខ្លួនឯងផង និងអន្ទងអារម្មណ៍ស្នេហ៍របស់ក្រមុំៗ ឱ្យចាប់អារម្មណ៍មកលើខ្លួនទៀតផង ។

ចំពោះការសម្ដែងសិល្បៈក្នុងពេលរាត្រីរបស់យុវវ័យកំលោះ និងវ័យក្រមុំជនជាតិវិញ គឺក្នុងន័យជាការផ្ដោះផ្ដងវាចាស្នេហាលែបខាយដាក់គ្នា ដើម្បីបង្កើតបរិយាកាសក្នុងពេលរាត្រី ឱ្យកាន់តែសប្បាយរីករាយ ក៏ដូចជាស្វែងរកគូស្នេហ៍ប្រចាំជីវិត។

តាមរយៈប្រសាសន៍របស់បងប្រុសម្នាក់ ដែលធ្លាប់ឆ្លងកាត់ការសម្ដែងសិល្បៈចាប៉ីឃ្លោកក្នុងពេលរាត្រី ហើយរកឃើញស្រីដែលខ្លួនបានស្រឡាញ់ស្មោះស្ម័គ្រធ្វើជាប្រពន្ធអស់មួយជីវិតនោះ បានបង្ហើបឱ្យយើងដឹងថា "ការលេងចាប៉ីឃ្លោក គឺធ្វើឡើងតែចំពោះក្មេងជំទង់ពេញកំលោះៗ ពេញក្រមុំៗ ដើម្បីដើររកប្ដីរកប្រពន្ធតែប៉ុណ្ណោះ ហើយការលេងចាប៉ីឃ្លោកនេះ មានច្រើនបទច្រើនបែបណាស់ ។ បទចម្រៀងខ្លះដែលពួកគេច្រៀងនោះ គឺមានបែបបទនិងមានក្បួនច្បាប់ត្រឹមត្រូវ ហើយចម្រៀងខ្លះទៀតពុំមានបែបបទទេ គឺអាស្រ័យទៅលើមាត់អ្នកកេះចាប៉ីឃ្លោកតែម្ដង ។ និយាយឱ្យអស់សេចក្ដីទៅ ចម្រៀងចាប៉ីឃ្លោករបស់បងប្អូនជនជាតិនៅខេត្តរតនគីរីនេះ គឺមានច្រើនបទណាស់រហូតដល់ជាង១០០បទឯណ្ណោះ........."។ ចំពោះសូរសម្លេងឧបករណ៍តន្ត្រីចាប៉ីឃ្លោកនេះ មានរលកសម្លេងពិរោះណាស់ អាចកន្ត្រាក់អារម្មណ៍ ឬបេះដូងយុវវ័យ កំលោះក្រមុំឱ្យទោទន់ទៅរកម្ចាស់ចាប៉ីឃ្លោកតែម្ដង "។

## ១៧_សិល្បករភ្លេងមិមជាជនជាតិគ្រឹងនៅខេត្តរតនគិរី [១]

"ភ្លេងមិម ជាឧបករណ៍តន្ត្រីបុរាណរបស់ជនជាតិក្រុមកុលសម្ព័ន្ធខ្មែរដើម ដែលរស់នៅតាមតំបន់ព្រៃភ្នំក្នុងខេត្តរតនគិរី ដូចជាជនជាតិគ្រឹង ទំពួន..... ហើយអ្នកចេះសម្តែងសិល្បៈឧបករណ៍ភ្លេងមិមនេះ សុទ្ធសឹងតែជាអ្នកអត់ធ្មត់ព្យាយាមរៀនសូត្រយ៉ាងយកចិត្តទុកដាក់បំផុត ។

លោកផេង ដៅ ជាសិល្បករជនជាតិគ្រឹងមួយរូប ដែលមានទេពកោសល្យដ៏ខ្ពង់ខ្ពស់ក្នុងការសម្តែងសិល្បៈភ្លេងម៉ិម ធ្វើឱ្យអ្នកទស្សនាតែងតែអួតសរសើរប្រាប់គ្នីគ្នាថា "ពិតជាល្អអស្ចារ្យមែនភ្លេងខ្មែរបុរាណ" ។ ព្រោះឧបករណ៍ភ្លេងនេះ មានតែខ្សែមួយសម្រាប់កូត ហើយមានខ្សែមួយទៀតសម្រាប់ទាញទៅដាក់ក្នុងមាត់ដូចបៅដោះម្តាយ (ម៉ិម-មឹម..) ។

លោកចេះសម្តែងសិល្បៈភ្លេងម៉ិមនេះ តាំងពីលោកនៅជាកុមារាមកម្លេះ ។ ដោយសារតែលោកមានហាត់រៀនបន្ថែមទៀត ជាមួយលោកគ្រូតាវ៉ៅ ដែលជាព្រឹទ្ធាចារ្យម្នាក់ មានជំនាញខាងភ្លេងម៉ិមនៅក្នុងស្រុកកំណើតរបស់លោក គឺភូមិក្មេង ឃុំពក ស្រុកវ៉ឺនសៃ (ឬស្រុកវីរជ័យ) ខេត្តរតនគិរី ។

ការហាត់រៀនពីឧបករណ៍ភ្លេងម៉ិមនេះ ទាំងការសម្តែងសិលៈកូតភ្លេងម៉ិម ច្រៀងតាមភ្លេងម៉ិម និងការធ្វើឧបករណ៍ភ្លេងម៉ិម លោកត្រូវព្យាយាមចំណាយពេលវេលារយៈពេលជាង១០ឆ្នាំទៀត (តាំងពីឆ្នាំ១៩៩១) ទើបស្ទាត់ជំនាញ ចេះល្អឥតខ្ចោះ ហើយស័ក្តិសមតាមបំណងប្រាថ្នារបស់ខ្លួន ។

---

១-រស្មីកម្ពុជា . ២១ មេសា ២០០១

នៅពេលសម្តែងសិល្បៈកូតភ្លេងម៉ុមនេះម្តងៗ ធ្វើឱ្យអ្នកមើល អ្នកស្តាប់សែនស្រណោះស្រណោក លន្លង់លន្លោចទៅតាមរលកសម្លេង ចង្វាក់ភ្លេងម៉ុមដ៏ស្រួយស្រិបពិរោះស្រទន់ ហាក់បបោសអង្អែល លួងលោម បំពេរអារម្មណ៍ឱ្យនឹកឃើញទៅដល់កម្រងអានុស្សាវរីយកាលពីនៅកុមារភាព ដែលចិត្តចងចាំពុំភ្លេចឡើយដូចជាចម្រៀង:

១-បទ "ជំហរស្នេហា" ភាសាជនជាតិគ្រឹងហៅថា "គូរីស" ។

២-បទ "នារីបុកស្រូវ" ភាសាជនជាតិគ្រឹងហៅថា "នារីតាវេះចេស" ។

៣-បទ "ឆ្នាំថ្មីបងរង់ចាំអូន" ភាសាជនជាតិគ្រឹងហៅថា "កំម៉ហ៊ុន ជីអ៊ុណាចាំ" ។

៤-បទ "អស់ពេលរង់ចាំ" ភាសាជនជាតិគ្រឹងហៅថា "តុចចាំ" ។

ក្នុងចំណោមបទចម្រៀងទាំងនេះ បទចម្រៀងដែលលោកស្រលាញ់ពេញចិត្តជាងគេគឺបទ "អស់ពេលរង់ចាំ" ដែលបង្ហាញពីចំណងស្នេហារបស់យុវវ័យពីរនាក់ ដែលស្រឡាញ់គ្នាប្តូរផ្តាច់តាំងពីវ័យជំទង់ ។

លុះមកដល់ពេលពេញវ័យរៀងខ្លួន គូរស្នេហ៍ស្រីក៏ត្រូវឃ្លាតឆ្ងាយពីបុរសដោយសារម្តាយជាអ្នកបំបែកបំបាក់ ។ ការរង់ចាំរបស់បុរសអស់រយៈពេលជាច្រើនឆ្នាំ ហើយនៅតែពុំឃើញនាងវិលត្រឡប់មករកបុរសម្ចាស់ស្នេហ៍ ។ ទីបំផុត គឺនៅសល់តែភ្លេងម៉ុមសម្រាប់កំដរជីវិត ដែលធ្លាប់សាងអានុស្សាវរីយនៅទីវាលក្នុងព្រៃភ្នំមាត់ជ្រោះ មាត់បឹង មាត់អូរ ។

ឆ្នាំនេះលោកផន ដៅមានអាយុ៥៥ឆ្នាំហើយ រស់នៅក្នុងស្រុកអូរជុំ ខេត្តរតនគិរី ។ សព្វថ្ងៃលោកជាប្រធានការិយាល័យវប្បធម៌ស្រុកអូរជុំ និងជា

កសិករស់នៅក្នុងស្រុកភូមិនេះដែរ ។ លោកមានប្រពន្ធឈ្មោះអ្នកស្រីណុត វុន ដាង បានស្លាប់នៅខែកញ្ញាឆ្នាំ២០០០ ។ លោកមានកូន៥នាក់ គឺស្រី៤នាក់ និងប្រុសម្នាក់ ចំណែកកូនច្បងជាកូនស្រីអាយុ២៦ឆ្នាំ ហើយកូនពៅជាកូនប្រុស អាយុ២ឆ្នាំ ។

ក្នុងចំណោមកូនទាំង៥នាក់របស់លោក គឺពុំមានកូនណាម្នាក់មាននិស្ស័យស្រឡាញ់ចូលចិត្តសម្ដែងសិល្បៈភ្លេងម៉ុមដូចលោកឪពុកឡើយ ។ ជាពិសេសក្នុងស្រុកអូរជុំ ក៏គ្មានយុវវ័យណាចង់រៀនសូត្រចង់ចេះចង់ដឹងពីឧបករណ៍ភ្លេងម៉ុមនេះក៏គ្មានដែរ ។ ប៉ុន្តែទោះបីជាក្នុងភូមិលោករស់នៅពុំមានអ្នកចង់ចេះចង់ដឹងពីឧបករណ៍ភ្លេងម៉ុមនេះក៏ដោយ ក៏មានយុវជននៅតំបន់ឆ្ងាយៗ ចង់ចេះសម្ដែងសិល្បៈភ្លេងម៉ុមនេះដែរ ដូចជានៅស្រុកវិនសៃជាដើម ។

លោកបានជួយបង្ហាត់បង្រៀនដល់យុវវ័យក្មេងនៅស្រុកវ៉ឺនសៃបាន២-៣នាក់ឱ្យចេះសម្ដែងសិល្បៈភ្លេងម៉ុម ។ ព្រោះយុវវ័យក្មេងៗ ២-៣នាក់នេះ មាននិស្ស័យស្រឡាញ់ពេញចិត្តណាស់ ចំពោះឧបករណ៍ភ្លេងបុរាណរបស់ជនជាតិខ្លួន ហើយខិតខំថែរក្សាទុកមិនឱ្យបាត់បង់ ។

នៅពេលណាលោកឃើញពួកយុវវ័យ យកចិត្តទុកដាក់ចំពោះភ្លេងម៉ុមនេះ ធ្វើឱ្យអារម្មណ៍របស់លោកសែនសប្បាយរីករាយក្នុងចិត្តណាស់ ហើយសង្ឃឹមថា ភ្លេងម៉ុមរបស់ជនជាតិខ្មែរលើមានតម្លៃសំខាន់ណាស់ សម្រាប់កូនចៅជំនាន់ក្រោយ ស្នងមតិកវប្បធម៌សិល្បៈជាតិឱ្យស្ថិតនៅគង់វង្សគ្រប់សម័យកាលដែលមានរូបចម្លាក់នៅប្រាសាទបាយ័នជាភស្តុតាងស្រាប់" ។

## ១៨-ជនជាតិភាគតិចនៅភូមិភាគឦសាន [១]

"ក្រោយពីចេះយកកប្បាស មកហូតជាអំបោះ ការត្បាញសាច់ក្រណាត់ដើម្បីធ្វើសម្លៀកបំពាក់ ឬភួយក៏បានកើតឡើងដែរ ។ ដំបូងឡើយនារីជនជាតិយកអំបោះមកអន្ទង ដោយទទឹងធ្មេងឈើប្រហែលជាកន្លះម៉ែត្រ និងបណ្ដោយប្រហែលជាពីម៉ែត្រប៉ុណ្ណោះ ។ ការត្បាញនេះ គេពុំឃើញប្រើកីដូចនៅតំបន់វាលទំនាបឡើយ ។ នារីជនជាតិនិយមយកចុងអំបោះ ដែលអន្ទងរួចទៅចងជាប់និងសរសរផ្ទះ ហើយយកចុងម្ខាងទៀតចងភ្ជាប់ទៅនឹងចង្កេះ ។ នៅពេលណាគេត្បាញ ចង្កេះរបស់គេប្រឹងទាញអំបោះ ដែលគេអន្ទងរួចនេះឱ្យតឹង ហើយដៃម្ខាងបោះត្រល់ចុះឡើង ដៃម្ខាងទៀតកាន់ធ្មេញឈើគោះបង្ហាប់សាច់ក្រណាត់ ។

នៅភូមិភាគឦសាន គេកត់សម្គាល់ឃើញសំពត់នារីៗ មានពតិប្លែកៗគ្នា ទៅតាមជនជាតិនីមួយៗ ។ នារីជនជាតិគ្រឹង ព្រៅ គេនិយមចូលចិត្តសំពត់ពណ៌ក្រហម មានលាយពណ៌ខ្មៅបន្តិចបន្តួច ។ ឯជនជាតិទំពួន និងចារ៉ាយ គេចូលចិត្តសំពត់ពណ៌សលាយខ្មៅ ។ នារីការ៉ែត ចូលចិត្តសំពត់ពណ៌ខ្មៅលាយក្រហមតិច ។ ទោះជាមានករណីប្លែកគ្នាក៏ដោយ ក៏សំពត់របស់ជនជាតិនានានៅភូមិភាគឦសានសុទ្ធតែមានក្រណាត់ប៉ះគួទពីលើបន្ថែមដូចគ្នា ដើម្បីឱ្យបានក្រាស់ និងប្រើប្រាស់បានយូរ ពីព្រោះថា នៅពេលសំពត់រហែកគួថ គេគ្រាន់តែដូរក្រណាត់ប៉ះគួថនេះចេញជាការស្រេច ។ គួរបញ្ជាក់ផងដែរថា សំពត់នេះពុំមែនយកក្រណាត់មកដេរភ្ជាប់មុខដូចសារុងទេ ក៏ប៉ុន្តែ គេយកក្រណាត់មករុំ

---

១-កល្យាណមិត្ត

ដូចស្បៀកក្រមា ។ ភាសាជនជាតិជាទូទៅហៅសំពត់ថា "កាដាង" ឬ "អន់ជុ" ។

នៅពេលមានពិធីបុណ្យទានម្តងៗ នារីជនជាតិព្រៅ គ្រឹង ទំពួន ចារ៉ាយ និយមស្លៀកពាក់ស្អាតៗ ដែលមានក្រណាត់ប៉ះគូថ ប្រកបដោយក្បូរក្បាច់រចនាល្អៗទៀតផង ។ នៅជាយម្ខាងនៃសំពត់ គេច្រើនធ្វើរំយោល ហើយជានិច្ចកាលនៅពេលស្លៀកគេបត់រំយោលនេះចេញមកក្រៅ ។ នៅជើងសំពត់វិញ គេសង្កេតឃើញមានពណ៌ឆ្នូតៗជាច្រើន របៀបជាជួរដូចជើងសំពត់ឡាវ ។ អាស្រ័យដោយមានការតុបតែងរចនាបែបនេះ ទើបសំពត់របស់បងប្អូនជនជាតិព្រៅ គ្រឹង ចារ៉ាយ មានឈ្មោះ និងមានតំម្លៃខុសៗគ្នាទៅតាមគុណភាពរបស់វា ដូចជា "កាដាងកាដ្រូ" "កាដាងសាទ្រ" "កាដាងស្រុ" "កាដាងក្រណាលយុ" ។ ក្នុងចំណោមកាដាងទាំងនោះ មានតែកាដាងកាដ្រូទេ ដែលមានតម្លៃជាងគេ ហើយក៏មានតែគ្រួសារជនជាតិអ្នកមានប៉ុណ្ណោះ ដែលអាចមានកាដាងនេះស្លៀក ។

ចំពោះជនជាតិកាវ៉ែត ក៏មានដូចគ្នាច្រើនដែរ ។ យើងមានការសោកស្តាយណាស់ ដោយពុំទាន់បានស្រាវជ្រាវឱ្យបានល្អិតល្អន់ពីបញ្ហានេះ ។

ដោយឡែកពីនេះទៅទៀត ទំនាក់ទំនងរបស់ឡាវ និងខ្មែរមកលើភូមិភាគឦសាន្ត បានធ្វើឱ្យសម្លៀកបំពាក់របស់នារីៗនៅទីនោះ មានការប្រែប្រួលមួយចំនួនធំ ។ សំពត់ដែលពួកនារីជនជាតិទិញពីស្រុកឡាវយកមប្រើគេហៅថា "អន់ជុឡាវ" ឬកាដាងឡាវ" ឬសំពត់ដែលទិញមកពីខ្មែរវិញមានឈ្មោះថា "អន់ជុខ្មែរ" ។ នៅដើមស.វ.ទី២០នេះ គេបានសង្កេតឃើញនារីទំពួន ដែលកើតក្នុងគ្រួសារអ្នកគ្រាន់បើបានយកហូល "អន់ជុហូល" និងផាមួង " អន់ជុអតិអន់

ទ្រុន" មកស្លៀកពាក់ក្នុងពិធីបុណ្យផ្សេងៗ ។

សម្លៀកបំពាក់របស់កុមារី ទាំងទ្រង់ទ្រាយ ទាំងរបៀបកាត់ដេរ ពុំមានលក្ខណៈខុសប្លែកគ្នាពីសម្លៀកបំពាក់មនុស្សធំទេ ។ បើពិនិត្យឱ្យល្អិតល្អន់ទៅសម្លៀកបំពាក់កុមារ និងមនុស្សធំមានសភាពខុសគ្នាតែខ្នាតតូចធំប៉ុណ្ណោះ ។

**សម្លៀកបំពាក់បុរស**

នៅសម័យដើមប៉ឹងត្រូវបានគេធ្វើពីសំបកឈើ ។ ក្រោយពីគេចេះត្បាញសាច់សំពត់មក ការយកសំបកឈើមកធ្វើប៉ឹង ក៏បានត្រូវគេបោះបង់ចោលបន្តិចម្តងៗ ជនជាតិការ៉ែតពុំសូវចូលចិត្តត្បាញសំពត់ ដើម្បីកាត់សម្លៀកបំពាក់ទេ ពីព្រោះពឹងផ្អែកលើធម្មជាតិសុទ្ធសាធ ។ ក្នុងការធ្វើប៉ឹងស្លៀកពាក់បិទបាំងកេរខ្មាស គេនិយមយកសំបកឈើម្យ៉ាង ដែលមានដើមនិងស្លឹកដូចខ្នោរព្រៃសុទ្ធសាធ ដែលតាមភាសាព្រៅហៅថា "ដើមប៊ិនត្រៃ" ។ របៀបធ្វើដំបូងគឺគេយកអន្លូងទៅវាយសាច់ដើមប៊ិនត្រៃខ្វែងចុះខ្វែងឡើង ។ បន្ទាប់មក គេច្រៀកត្រង់ចុះមកក្រោម ហើយកាត់ផ្តាច់ចេញពីដើម ។ ជនជាតិការ៉ែតយកសំបកប៊ិនត្រៃនេះមកដំបន្ថែមទៀតពីក្នុងផង និងពីក្រៅផង រួចហើយទើបយកទៅបោកគក់ក្នុងទន្លេ ស្ទឹង បឹង ។ គេធ្វើរបៀបនេះជាច្រើនលើក ច្រើនសារ រហូតដល់សំបកប៊ិនត្រៃចេញជ័រអស់ ហើយនៅសល់តែសរសៃទន់ៗ ចាកស្រែសគ្នាដូចគេត្បាញ ។ ក្រោយពីបោកគក់ជ្រះជ័រអស់ហើយ ទើបគេយកសំបកឈើនេះទៅហាលឱ្យស្ងួត រួចយកទៅដេរដោយសរសៃធ្មៃ ដើម្បីតភ្ជាប់ឱ្យបានមាំទាំ ។

សព្វថ្ងៃបងប្អូនជនជាតិបានយកសាច់ក្រណាត់មកធ្វើប៉ឹងវិញ ។ សាច់

ក្រណាត់នេះ ត្រូវបានត្បាញ ជាពិសេសសម្រាប់ប៊ឹងមួយតែប៉ុណ្ណោះ ដែលមានធ្មេញឈើប្រហែល៤,៤០ម៉ែត្រ និងបណ្ដោយពី ឬបីម៉ែត្រ ។ ក្បាលប៊ឹងនិងកន្ទុយប៊ឹងអាចជាលក្ខណៈសម្គាល់នូវជនជាតិនីមួយៗបាន ។ ជនជាតិការ៉ែតនិយមទម្លាក់ក្បាលប៊ឹងរបស់ខ្លួនឱ្យធ្លាក់ចុះមកក្រោម វែងជាងកន្ទុយប៊ឹង ។ រីឯជនជាតិទំពួន គ្រឹង ព្រៅ ចារ៉ាយវិញ គេទម្លាក់កន្ទុយប៊ឹងឱ្យវែងជាងក្បាលប៊ឹង ។

ក្នុងពេលធម្មតា គេស្លៀកប៊ឹងមិនសូវនិយមពាក់អាវទេ ។ ប៊ឹងនេះមានពណ៌ប្លែកៗគ្នាទៅតាមជនជាតិ ។ នៅពេលបុណ្យទាន អាពាហ៍ពិពាហ៍ ឬមានការប្រជុំផ្សេងៗ បណ្ដាជនជាតិនិយមស្លៀកពាក់ស្អាតបាតសមរម្យ មានប៊ឹង មានអាវ (ដៃខ្លី ឬដៃវែង) មានក្រមា ។ ពេលគេទៅធ្វើពលកម្ម ស្រែចម្ការ ឬចូលព្រៃពួកគេស្លៀកប៊ឹង មានខ្លះពាក់អាវ ខ្លះអត់អាវ តែគេច្រើនពាក់មួក ដែលធ្វើអំពីបន្ទះឬស្សីស្តើងៗ ព្រមទាំងមានលាបជ័រចុងផង ដើម្បីកុំឱ្យជ្រាបទឹក ។

ជនជាតិទាំងអស់ពុំសូវប្រើស្បែកជើងទេ គេធ្វើដំណើរទៅណាមកណាដោយជើងទទេ ។ ក្នុងពេលចូលព្រៃ ទើបគេរកស្បែកជើងមកពាក់ ។ ស្បែកជើងនេះ គេនិយមធ្វើពីស្បែកក្របីក្រៀម ឬសំបកឈើ ចាប់ពីឆ្នាំ១៩៦០មកដោយមានការរៀនសូត្រ ឬដោយមានការទទួលឥទ្ធិពលពីជនជាតិវៀតណាមទើបជនជាតិនៅតាមតំបន់ជិតព្រំដែន ចេះពាក់ស្បែកជើងធ្វើពីកង់ឡានចាស់ៗ ។

# ឯកសារយោង

## ១-អត្ថបទស្រាវជ្រាវ ជាភាសាបារាំង និងអង់គ្លេស


TRANET ( MICHEL)

1981 "La chronique d'Ayuthya (Manuscrit d'Adhémard Leclère en français)", Péninsule, N° 8-9.

1982(déc)"Contribution à l'étude de l'origine de la civilisation et de la religion khmères: Les religions chtoniennes au Cambodge", Seksa Khmer, n° 5, Cedoreck, P.199-206 (Position de thèse).

1983: "Étude sur la Savatar Vatt Sampuk", Seksa Khmer, n° 6, Cedoreck, p.75-107.

1984: "Adhémard Leclère: Sa vie, ses travaux", Seksa Khmer, n° 7, Cedoreck, p.3-34.

1987(2^e^sem.) "Réflexions sur l'esclavage au Cambodge post-angkorien (14^e^-18^e^ siècles)", Cahiers de l'Asie du Sud-Est, n°22 p.13-33.

1990 Rebirth of khmer bouddhist in Cambodia with P. Gyallap, Radical Conservation, Bangkok.

1991 "Présentation de la chronique royale", Khmeritude 1, Paris. (BNPP).

1991 "Un site Môn-Khmer proto-historique à Nagara Rajasima dans l'actuelle Thaïlande", Khmeritude, Pierres d'Angkor, Association Culturelle, p.121-169.

1991 "Le symbolisme des enfers khmers d'après le traibhumi khmer", Cahiers de l'Asie du Sud-Est, N°29-30. 1992.

1991 " À propos d'un bronze représentant un homme assis sur un éléphant" in Southeast Asian Archaeology 1990. Hull: Proceedings of the third Conference of the European Association of Southeast Asian Archaeologists. Centre fo South-East Asian Studies, Ian Glover (éd.), p.25-28.

1994 "Nouvelles découvertes d'inscriptions au Cambodge", Recueil des articles de la 5è Conférence Internationale du "European Association of Southeast Asian Archaeologists", effectuée à Paris, au Musée Guimet du 24 au 28 octobre 1994 University of Hull. (BNPP). ( de Ka 1à Ka 23).

1998 " New discoveries in Angkor Borei, capital of Funan (1st-7st century)" in Southeast Asian Archaeology 1996. Hull: Proceedings of the sixth Conference of the European Association of Southeast Asian Archaeologists. Leiden, 1996.

1998 "Les premières représentations de Bouddha au Cambodge Ancien" in Khmer Studies, La Khmerologie, Proceedings of international Conference on Khmer Studies, 1996, 26-30 août, ( Sorn Samnang, éd. [vol.1], Phnom Penh, p. 427-474.

1999 "Géographie coloniale: le Darlak, une province ( cambodgienne) sauvage en Indochine. Un document inédit d'Adhémard Leclère présenté par le Dr Michel Tranet", Communication du 2è Congrès National de la recherche Socio-culturelle sur le Cambodge, 3-5 féfrier 1999 Université Royale de Phnom Penh.

1999 "Découvertes récentes d'inscriptions khmères ( 2è partie) de Ka 23 à Ka 94)", La khmerologie, Connaissance du Passé et Contribution au Renouveau du Cambodge vol3. 2000-2001.

2000 "Notes sur quelques pièces romaines découvertes à Angkor-Borei" National Socio-cultural Research on Cambodia, 15-17Nov. 2000 (Papers communications).

2000 "L'animisme dans le premier art khmer" , National communication.........op.cit.

2000 "Les découvertes récentes d'inscriptions khmères 1ère partie et 2è partie), The 2nd international conférence on khmer studies, 26-28 Jan. 2000. (Proceedings).

2002 "Le symbolisme des couleurs chez les Cambodgiens", The 4th Socio- cultural Research Congress on Cambodia, 6-8 Nov. 2001.

2004 "Note sur une pièce commomérative du style môn découverte à Angkor-Borei" The 6th Socio- cultural Research Congress on Cambodia, 18-20 Nov. 2003.

2005 "Une inscription bouddhique Ye Dhamma pré-angkorienne d'Angkor-Borei" The 7th Socio cultural Research Congress on Cambodia, Nov. 2004.

2005 "Note sur une statue représentant Vajrapani à Angkor-Borei" The 7 th Socio cultural Research Congress on Cambodia.

2005 "Quelques nouvelles donneés relatives à l'usage du pali au Cambodge pré-angkorien", the 8 th Socio cultural Research Congress on Cambodia 21-23 Nov. 2005.

## ២- សៀវភៅជាភាសាបារាំង

TRANET MICHEL

1981 "L'origine de la culture et de la civilisation khmères", Phnom Penh. (Thèse de Doctorat de 3è cycle).

1995-96 Sambaur-Prei-Kuk, Monuments d'Içanavarma 1er (615-628 AD), vol .1, Phnom Penh.

1996-97 Sambaur-Prei-Kuk, Monuments d'Içanavarma 1er (615-628 AD), vol .2.

1997-98 Sambaur-Prei-Kuk, Monuments d'Içanavarma 1er (615-628 AD) et ses environs, vol.3.

1999 Aperçu sur le Ramakerti, Phnom Penh (BNPP).

2000 Les Proto-Khmers.

2000 Le sdach Kân.

2006-07 Sambaur-Prei-Kuk. Les bas-reliefs d'Içanavarma 1er (615-628 AD), vol.4.

2007 La symbolique khmère, Phnom Penh.

2007 Les linteaux khmers de Thaïlande ( à paraître).

## ៣-អត្ថបទជាភាសាខ្មែរ

ត្រាណេ មីសែល

២០០០ "សិលាចារឹកបាលីចាស់ជាងគេបំផុត នៅក្នុងអតីតប្រទេសកម្ពុជា". សន្និសីទអន្តរជាតិខេមរវិទ្យាលើកទី២. ២៦-២៨ មករា ២០០០.

២០០២ "អត្ថបទសិលាចារឹកបាលីចាស់ជាងគេបំផុត នៃអតីតព្រះរាជាណាចក្រកម្ពុជា Ka១១០". កម្ពុជសុរិយា លេខ៣ ២០០២. ។

២០០២ "ទីក្រុងអង្គរបុរីជាទីក្រុងនៃទម័កដីរ៍ ឬវ្យាធបុរៈ ក្នុងខេត្តតាកែវ" សមាជស្រាវ ជ្រាវសង្គម-វប្បធមិអំពីកម្ពុជាលើកទី៤. ៦-៨ វិច្ឆិកា ២០០១. ។

២០០៣ "សិលាចារឹកស្រះឈូកជាភាសាខ្មែរ (Ka ១១០) ភាគ២" . កម្ពុជសុរិយា លេខ២ . ២០០៣. ។

២០០៣ "សាស្ត្រាខ្មែរនៅភាគឦសាននៃប្រទេសថៃបច្ចុប្បន្ន". កម្ពុជ សុរិយា. លេខ៤. ២០០៣.

២០០៤ "ការចុះបញ្ជីសារពើភណ្ឌនូវសិលាចារឹកជាអាទិទេពសម្រាប់ខេមរវិទ្យា" សមាជស្រាវជ្រាវសង្គម-វប្បធមិអំពីកម្ពុជាលើកទី៦ . ១៨-២០ វិច្ឆិកា ២០០៣. ។

២០០៤ "សិលាចារឹក Ka ៥៩ នៅភូមិគោកក្អាង ខេត្តបុរីរម្យ". កម្ពុជ សុរិយាលេខ២. ២០០៤. ។

២០០៥ "អាណាចក្រគោត្របង". កម្ពុជសុរិយា. លេខ១. ២០០៥.

## ៤_សៀវភៅជាភាសាខ្មែរ នៅភ្នំពេញ និងបរទេស

**ត្រាណេ, មីសែល**

១៩៨៥. ពង្សាវតារខ្មែរ (របស់លោក ឡឺវ៉េស៊ីដង់ដឺភ្នំពេញ អាជ៊ីមារ ឡើក្លែរ) មុន្សន់ មូនិច (ប្រទេសអាឡឺម៉ាញ).

១៩៨៧ ប្រជុំច្បាប់ខ្មែរ JSRC, ជំរំ KID, នៅថៃ.

១៩៨៩ ប្រវត្តិសាស្ត្រនៃកម្ពុជា ពីបុព្វសម័យដល់ស.វ.ទី៨ ជំរំសម្តេចឪ ដោយសង្ខេប ជំរំសម្តេចឪ ប្រទេសថៃ.

១៩៩០ បុណ្យប្រពៃណីខ្មែរបុរាណ, JSRC, KID ជំរំនៅប្រទេសថៃ.

១៩៩១ ព្រះរាជពង្សាវតារនគរខ្មែរ តាមសាស្ត្របុរាណ JSRC, KID ជំរំនៅប្រទេសថៃ និងភ្នំពេញ.

១៩៩៤ សិក្សាអំពីរឿងរាមកេរ្តិ៍ខ្មែរ , រឿងព្រេងខ្មែរស្តីអំពីភ្នំ.

១៩៩៥ បុរេប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា តូក្យូ ប្រទេសជប៉ុន.

១៩៩៦ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ពីសម័យបុរេប្រវត្តិសាស្ត្រដល់ ស.វ.ទី៨នៃគ.ស. (ការកែសម្រួលនៃសៀវភៅប្រវត្តិសាស្ត្រ នៃកម្ពុជាពីបុព្វសម័យ ដល់ស.វ.ទី៨, ជំរំសម្តេចឪ)

១៩៩៦ ព្រះបាទជ័យវរ្ម័នទី៧, ភ្នំពេញ.

១៩៩៧ រឿងព្រេងខ្មែរ ស្តីពីប្រាសាទបុរាណ.

១៩៩៨ ប្រវត្តិសាស្ត្រកម្ពុជា អាណាចក្រចេនឡា ស.វ.ទី៦ដល់ទី៨

១៩៩៨ ប្រព័ន្ធគំនិតខ្មែរ (ភាគទី១)

១៩៩៨ ប្រាសាទបន្ទាយស្រី.

១៩៩៨ ប្រាសាទ បាពួន .

២០០២ ប្រវត្តិសាស្ត្រកម្ពុជា អាណាចក្រភ្នំ ( ស.វ.ទី១ ដល់ទី៦ )

២០០២ ប្រវត្តិសាស្ត្រនៃកម្ពុជា ការបង្កើតរដ្ឋខ្មែរ

២០០៣ ប្រវត្តិសាស្ត្រកម្ពុជាសង្ខេប ពីសម័យបុរេប្រវត្តិសាស្ត្រ ដល់ការបង្កើតរដ្ឋ ។

២០០៣ ប្រវត្តិសាស្ត្រនៃកម្ពុជា សង្គមខ្មែរក្នុងរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៧

២០០៣ វប្បធម៌ខ្មែរសុរិន្ទ្រ ភាគ១

២០០៤ វប្បធម៌ អារ្យធម៌ខ្មែរ អំពីសាសនាខ្មែរតាំងពីសម័យបុរេប្រវត្តិសាស្ត្រ (សង្ខេប).

២០០៤ ប្រព័ន្ធគំនិតខ្មែរ ( ភាគ២)

២០០៤ ការគ្រប់គ្រងរដ្ឋនាសម័យមហានគរ. ពីស.វ.ទី៩ ដល់ស.វទី១៣ នៃគ.ស. សាកលវិទ្យាល័យកម្ពុជា.

២០០៤ ប្រវត្តិសាស្ត្រខ្មែរ ពាក្យកាព្យរបស់ឡឿ វ៉ាន់ ចងក្រងដោយបណ្ឌិត មីសែល ត្រាណេ.

២០០៥ វប្បធម៌ខ្មែរសុរិន្ទ្រ ( ភាគ២) កម្រងក្បួនវេទមន្ត .

២០០៥ សម្ព័ន្ធភាពរវាងប្រជាជនខ្មែរ និងប្រជាជនថៃ ចាប់តាំងពីស.វ. ទី១៣នៃគ.ស.

២០០៥ ប្រវត្តិសាស្ត្រកម្ពុជា វប្បធម៌អង្គរបុរីពីស.វ.ទី១ ដល់ទី៦នៃគ.ស ( ភាគ១).

២០០៥ ប្រវត្តិសាស្ត្រនៃកម្ពុជា វប្បធម៌អង្គរបុរី ពីស.វ.ទី១ ដល់ទី៦នៃគ.ស. ( ភាគ២).

២០០៥ ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ចក្រភពកម្ពុជទេស. ពីស.វ.ទី៩ ដល់ស.វ.ទី១៣នៃគ.ស.

២០០៦ ស្ថាបត្យកម្មប្រាសាទរបស់ព្រះបាទជ័យវរ្ម័នទី៧ នៅប្រទេសថៃបច្ចុប្បន្ន .

២០០៦ មតិកវប្បធម៌មន-ខ្មែរ (ភាគ១).


## ៥-ឯកសារយោង របស់អ្នកនិពន្ធផ្សេងៗ


KANGVOL, Khatshima,

2004 "Sabbak Inscription: Impotant Evidence of Vajrayana buddhist school in khmer and word sruk khmer in Inscriptions". The 6th Socio-cultural Research Congress on Cambodia, 18-20 November 2003, Papers of the Congress, 2004 (Royal University of Phnom Penh).

CHAREONGPONGS, S-CHUTIPONGSPISIT,A.

2004 "King Chulachomklao's historical visit to Malaya territories under Siam's rule", Kinnaree, Oct 2004. Bkk.

COEDES, G. The Vajnañāna National Library, Bkk.

DUPONT, P .

1942. "Le Buddha de Grahi et l'école de Caiya", Variétés archéologiques, BEFEO, t. XLII.1943.

1951, Le premières images brahmaniques d'Indo-China, BSEI, t . XXVI , n$^0$ 2, 10.

BRUGUIER, B.

1999 , Bibliographie du Cambodge ancien, 2 tomes, EFEO, Paris.

VANN MOLYVANN,

1999. Les cités khmères, Phnom Penh.

POU, S.

1989. Nouvelles Inscriptions du Cambodge, t .I,
2001. Nouvelles Inscriptions du Cambodge. t.II et III, EFEO, Paris.

COEDES, G.

1973-1966. Inscriptions du Cambodge, 8 vol. Hanoi, Paris.

1948. Les Etats hindouisés d'Indo-Chine et d'Indonésie.

MALLERET, L.

1959-1963. Archéologie du Delta du Mékong, ,4 vol. EFEO, Paris.

LONG SEAM,

1981 "Contacts externes des langues Môn-khmer", BEFEO, t. LXX.

**យាង វិព្យុត្រ**

២០០៤ "សិលាចារឹកសំរោងទង . Ka ១០" ទស្សនាវដ្តី សង្គមសាស្ត្រ មនុស្សសាស្ត្រ លេខ៤៩.ឆ្នាំ៣៤. ខែតុលា. វិច្ឆិកា ធ្នូ ២០០៤

# រូបភាពឯកសារ

# ប្រវត្តិរូបភាពឯកសារ


១-　ផែនទីទីតាំងកលសម្ព័ន្ធ ឬ ខ្មែរ-មន(ខ្មែរលើ)

២-　ផែនទីទីតាំង កលសម្ព័ន្ធមន-ខ្មែរ ឬខ្មែរ-មន(ខ្មែរលើ)នៅកម្ពុជា យៀកណាម ខាងត្បូង និង លាវ

៣-　ផែនទីទីតាំងកលសម្ព័ន្ធ មន-ខ្មែរ នៅជ្រោយបលយូ ឬ ម៉ាឡាការបស់លោក SKEAT និង BLAGEN ១៨០៦

៤-　ផែនទីទីតាំងនៃឈាមក្រហមប្រភេទ HE (He'moglobine E) នៅភូមិ ភាគអាស៊ីអាគ្នេយ៍ និង នៅកោះជ្វា ម៉ាឡាកា បឹងបាល

៥-　ផែនទីទីតាំងនៃ HE នៅកម្ពុជា

៦-　មេទ័ព្វខ្មែរលើប្រដាប់ដោយលំពែង និង ខែល , អាដឺម៉ាឡឺក្លែរ , ចុង ស.វទី១៩ សារមន្ទីរខេត្តអាឡាំងសុង ,បារាំង

៧-　ចម្លាក់កងទ័ព្វខ្មែរ សម័យបាយ័ន, ស.វទី១២ គ.ស

៨-　កលសម្ព័នសកាយមន-ខ្មែរ ឬ ខ្មែរលើ / នៅលើជ្រោយម៉លយូ, រូបថតរបស់ SKEAT និង Blagen ១៨០៦

៩-　ជនជាតិខ្មែរលើកាន់ធ្នូ និង លំពែង នៅអតីតកម្ពុជាក្រោមរូបថតដើមស.វទី២០

១០-　ជនជាតិខ្មែរលើ កលសម្ព័នខា នៅជាប់ជាយដែនឯកសារ បារាំង ខ្មែរ លាវ, អាដឺម៉ាឡឺក្លែរ

១១-　ចម្លាក់មេទ័ព្វលើប្រសាទអង្គរវត្តកាន់ខែល សារមន្ទីរ អាឡាំងសុង បារាំង

១២-　គំនូរកលសម្ព័ន្ធនាសម័យបុរេប្រវត្តិសាស្ត្រ កាន់ខែលប្រទេសថៃ បច្ចុប្បន្ន

១៣-១៤-　អាវុធដែកនាសម័យបុរេប្រវត្តិសាស្ត្រ នៅភូមិស្នាយខេត្តបន្ទាយមាន ជ័យ សម័យចុងយុគ្គលោហធាតុ

១៥-១៦- ចម្លាក់ទ្វាពល កាន់ខែល ត្រចៀកពាក់ក្រសាល់, ប្រសាទលលៃ ស.វទី១០ និង ចម្លាក់ពលខ្មែរ ប្រើធ្នូ ស ប្រាសាទបាយ័ន

១៧- ជនជាតិខ្មែរ កំណើតគួយនៅខេត្តកំពង់ធំ កំពង់ច្បាំងគ្នា ក្នុងពិធី របាំខែល ជូនភ្ញៀវ ឯកសារអាដឺមារ ឡឺក្លែរ, ចុងស.វទី១៩

១៨- ចម្លាក់ប្រាសាទបាយ័នព្រះរាជាខ្មែរ ឬ មេទ័ពកំពុងទត បើកការប្រយុទ្ធសាកគ្នាមុនពេលទៅច្បាំងចុងស.វទី ១២

១៩- ពួងនៅខេត្តក្រចេះប្រើប៉ឹងបួងសក់និងមួកលំអដោយខ្នាយជ្រូកព្រៃ, ឯកសារ អាដឺមារ ឡឺក្លែរ

២០- ឧបករណ៍ភ្លេងពួយ របាំក្ងោក ដោយកលសម្ព័ន្ធខ្មែរលើជន និង ពរិដើមសតវត្សទី២០ នៅខេត្តពោធិសាត់ ឯកសារបារាំង

២១- ចម្លាក់ឧបកិច្ចជារូបគោសម័យបុរេប្រវត្តិសាស្ត្រសារមន្ទីរជាតិពន្ធុវិទ្យា, ទួលគោក

២២- ទ្រហាក់ជិះសត្វដំរី, សិរិទ្ធិ, ស្វាយ, កម្មសិទ្ធឯកជនដែលដាក់លក់នៅផ្សារទួលតាពូង (២០០៥)

២៣- ទ្រហាក់ដំរីចម្លាក់សិរិទ្ធមកពីស្រុកព្រះនេត្រព្រះ ភូមិព្រីងជូខេត្តបន្ទាយមានជ័យ អំណោយរបស់លោកដាំឈឿន ឆ្នាំ១៩៤៨ ដឹកលប់ប៉ុណ្ដោះអាសន្ននៅសារមន្ទីរជាតិភ្នំពេញ

២៤- គំនូរមនុស្សនាំគោដោយមានខ្សែចងនៅ, ដៃ, យុគ, លោហធាតុប្រទេសថៃបច្ចុប្បន្ន (រូបថតថៃ)

២៥- ចម្លាក់ដីដុតស្ត្រីកំពង់ផ្លិចង្ក្រាន, សម័យនគរភ្នំ ស.វទី ៤ -ឯគ.សសារៈមន្ទីរជាតិពន្ធុវិទ្យា ទួលគោក

២៦-២៧ ក្រឡមានពណ៌ក្រហមដោយមានក្បាច់ គូថខ្សែងកប់ជាមួយសពក្មេង Pottien ថតនៅបារាយ៍រូបថតអស់លោក Patter នៅបារាយណ៍ខេត្តសៀមរាបនិងកំណាយនៃស្ថានីបុរេប្រវត្តិសាស្ត្រនៃបារាយ៍ទឹកថ្លាថតដោយអ្នកនិពន្ធ

២៨-៣០- គំនូរពណ៌បង្ហាញកលសម្ព័ន្ធមនខ្មែរប្រើធ្នូសនាសម័យបុរេប្រវត្តិសាស្ត្រា ដោយបានផ្សាំងឆ្អែផង ប្រទេសថៃ (ឯកសារថៃ) របាំត្រុតពេលចូលឆ្នាំខ្មែរ, រូបថត រាំពេជ្រក្រវិល និងរូបក្របីឧបកិច្ច នៅពេលបុណ្យដូនតា នៅខេត្តសៀមរាប

៣១-៣៣- ឧបករណ៍ជាពុម្ពក្បាច់ដីដុតសំរាប់ប្រើពុម្ពក្បាច់លើក្រណាត់ស្នាយ, សម័យលោហធាតុ (សារមន្ទីរជាតិពន្ធុវិទ្យា)

៣៤-៣៥- រូបថតពង្រីកនៃសរសៃអំបោះ ឬ ក្រណាត់ សម័យបុរេប្រវត្តិសាស្ត្រ រកឃើញនៅបានឈៀនប្រទេសថៃ (ឯកសារថៃ)

៣៦-៣៧- ផ្លែត្រល់សម្រាប់រវៃអំបោះ, ភូមិស្នាយ សម័យលោហ ធាតុ, សារមន្ទីរជាតិពន្ធុវិទ្យាទួលគោក

៣៧-៣៩- ស្ត្រីខ្មែរលើកលសម្ព័ន្ធ ប៉ូឌី នៅយៀកណាមខាងត្បូង ឬកម្ពុជាក្រោម នាដើមស.វទី២០ រូបភាពឯកសារបារាំង និងចម្លាក់ស្ត្រីខ្មែរលែងខ្លួនលើប្រាសាទអង្គរវត្ត

៤០- ចម្លាក់ស្ត្រីដៃខ្មែរពាក់ប៉ុងខ្លី បែបពួងប្រាសាទអង្គរវត្ត

៤១-៤២- ស្ត្រីខ្មែរលើ នៅយួនពាក់ប៉ឹងដូចស្ត្រីខ្មែរសម័យអង្គររូបថតលោក Boulbet.

៤៣- រូបថតកំបិតស្មៀត, មនុស្សស្រីពាក់ សារុងឬ សំពត់, មកពីកំពុងឆ្នាំង, សារមន្ទីរជាតិភ្នំពេញ

៤៤-៤៥- ស្ត្រីពួងស្លៀកសំពត់បែបខ្មែរលែងខ្លួនដៃពាក់កងដៃវែងរូបថត អាដឺម៉ារឡឺក្លែរចុងស.វទី ១៩ នៅខេត្តក្រចេះកងដៃស្ពាន់មកពីស្នាយ សម័យបុរេប្រវត្តិសាស្ត្រ និងរូបអ្នករាំលែងខ្លួន នៅប្រាសាទអង្គរវត្ត,ស.វទី១២ គ.ស

៤៧- ស្ត្រីជនជាតិខ្មែរលើ នៅរតនៈគិរី ថតដោយលោក Voge ដកស្រង់ពី Phnom Penh Post ថ្ងៃទី ២-១៥ ដូ ១៩៨៤

៤៨-៤៩- ស្ត្រីជនជាតិខ្មែរលើដក់ស្រង់ចេញពី Pnom Penh Post ថ្ងៃទី May 30 June ១២ ១៩៩៦ និង រូបថតរបស់លោក Nolat Phnom Penh Jan ២៦ Feb ៨,១៩៩៦ (ភ្នំពេញ)

៥០-៥៣- ក្មេងស្លៀកប៊ុងនៅស្រុក ខេត្តសុរិន្ទបច្ចុប្បន្នចម្លាក់ដីដុតស្ត្រី និង សរីរូបនាសម័យនរគភ្នំ ពាក់ប៊ីង គ្រវិលត្រចៀកកែវមកពីអង្គរបុរីសារមន្ទីរជាតិវិទ្យាទួលគោក

៥៤-៥៥- ដងខ្លួនសត្វគោដែលមានស្នាមសាក់ដីដុត ភូមិស្នាយ និង ដងខ្លួនស្ត្រីគ្មានដោះ ដែលកើតខ្ទាស់មានស្នាមសាក់ជុំវិញសម័យថ្មរំលីវ មកពីខេត្តកំពតសារមន្ទីរជាតិស្ថានីល្អាងស្ពានពន្ទុវិទ្យា

៥៦- លិង្គឧបកិច្ចធ្វើអំពីឈើ, ស្រុកអង្គរបុរី

៥៧-៥៨- គំនូរមនុស្សពាក់អាវវែង សម័យលោហធាតុនៅប្រទេសថៃបច្ចុប្បន្ន (ឯកសារថៃ) និង ចម្លាក់រាជាខ្មែរលើប្រាសាទបាយ័នពាក់អាវវែងដៃកាន់ធ្នូ

៥៩-៦១ ជនជាតិខ្មែរលើនោរតនៈគីរី រូបថត ឯកឧត្តម ឃឹមសារិទ្ធ, ជនជាតិខ្មែរលើកំពុងមើលចម្លាក់នៅប្រាសាទបាយ័នដោយស្លៀក ប៊ីង ដូចចម្លាក់ព្រះបាទជ័យវរ្ម័នខ្មែរទី ៧នៅលើប្រាសាទបន្ទាយឆ្មារ ។

៦២- មេទ័ពខ្មែរពាក់រូបសត្វលើក្បាលនៅពេលចេញច្បាំង,ប្រាសាទអង្គរវត្ត

៦៣- ទិដ្ឋភាពជារូបគំនូរស្តីពីការប្រណាំងទូកលើដងទន្លេមេគង្គ ដោយលោក ម៉ូហូត៍ ឆ្នាំ ១៨៦០ ដែលកាលនោះប្រុស១ នៅស្លៀកពាក់ប៊ីង

៦៤-៦៥- ក្រុមភ្លេង និង មនុស្សនៅទីផ្សារស្លៀកពាក់តាមពួកខ្មែរលើ នៅសម័យអង្គរចម្លាក់ប្រាសាទ

៦៦-៦៨- ក្រសាលត្រចៀកជាឆ្អឹង និង គ្រវិលត្រចៀកសំរិទ្ធមកពីស្នាយសារមន្ទីរជាតិពន្ទុវិទ្យា, ស្ត្រីខ្មែរលើពាក់ប្រាសាលត្រចៀករូបថតនៅដើម ស.វ ទី២០ ឯកសារបារាំង

៦៩- គ្រោងឆ្អឹងមនុស្សស្រីសម័យបុរេប្រវត្តិសាស្ត្រពាក់ក្រសាលត្រចៀក (ឯកសារថៃ)

៧០-៧១- រូបថតស្ត្រីខ្មែរលើនៅយួនខាងត្បូងឈរពាក់ក្រសាលត្រចៀក ឯកសារបារាំង ចម្លាក់សម័យបាពួនស.វទី១១ បង្ហាញស្ត្រីម្នាក់ពាក់ក្រសាល ត្រចៀក, ឯកសារបារាំង សារមន្ទីរជាតិភ្នំពេញ ។

៧២-	សម្តេចព្រះបាទនរោត្តមសីហនុ សួរសុខទុក្ខកលសម្ព័ន្ធខ្មែរលើនៅរតនគីរីនៅឆ្នាំ ១៩៦៨

៧៣-	រូបមនុស្សប្រុសស្លៀក ប៊ុង សិរិទ្ធ សម័យមកពីភូមិលោហធាតុស្ពាយតំកល់ជាបណ្តោះអាសន្ននៅសារមន្ទីរជាតិភ្នំពេញ ។

៨០-៨៣-	គ្រឿងអលង្ការជាកែវស្លូ និង ថ្មមកពីស្ពាយសារមន្ទីរជាតិពន្ធុវិទ្យាជាតិទូលគោក

៨៤-	ចម្លាក់តំណាងការបូជាក្របីផឹកស្រាមុនការទៅច្បាំងលើសមរភូមិ. ប្រាសាទបាយ័ន ស.វទី១២គ.ស

៨៥-៨៧-	ស្ត្រីខ្មែរមានកូននៅដៃពាក់ក្រវិលត្រចៀកអង្គរបុរី និង ក្រវិលត្រចៀក កែវស្លូមកពីស្ពាយ‹ សារមន្ទីរជាតិពន្ធុវិទ្យាទូលគោក

៨៨-៨៩-	ក្រវិលត្រចៀក សារមន្ទីជាតិភ្នំពេញ និង ចម្លាក់សម័យអង្គរ ដែលបង្ហាញការពាក់ ក្រវិលត្រចៀកបែបសម័យបុរេអង្គរ

៩០-៩១-	ស្ត្រីខ្មែរលើឧបករណ៏រនាតហួតខ្មែរលើ រូបថត ទំពេជ្រក្រវិល

៩២-	មនុស្សកំពុងផ្លុំឧបករណ៏ភ្លេងពួយចម្លាក់សម័យលោហធាតុឯកសារយៀកណាមខាងត្បូងបច្ចុប្បន្ន

៩៣-	ឧបករណ៏ភ្លេងពួយនៅខេត្តពោធិសាត់រូបថតដកស្រង់ចេញពីរស្មី កម្ពុជា

៩៤-	ជនជាតិខ្មែរលើ កំពុងរាំរែក និងលេងភ្លេងគេនរូបថតឯកសារ បារាំង

៩៥-	ជនជាតិខ្មែរអ្នកភៀសខ្លួននៅស្រុកបារាំង កំពុងផ្លុំឧបករណ៏គេន

៩៦-	ក្រមុំកម្លោះជនជាតិខ្មែរលើ នៅខេត្តរតនះគីរី កំពុងរាំរែកពត់ពែន

៩៧-	អ្នកនិពន្ធ និងជនជាតិខោញ ដែលបានស៊ើបរកឃើញនៅឆ្នាំ ២០០០

៩៨-៩៩-	ការប្រគុំឧបករណ៏ម៉ឹមនៅរតនះគីរី រូបថត ពេជ្រទុំក្រវិល និងចម្លាក់ម៉ឹម នៅលើប្រាសាទបាយ័ន

១០០-	ឃ្មោះ ឬ គងប្រគុំដោយ កលសម្ព័ន្ធខ្មែរលើ រូបថតទុំពេជ្រក្រវិល

១០១-១០២-ឧបករណ៏ភ្លេងឃ្មោះ នៅលើចម្លាក់ប្រាសាទ អង្គរវត្ត និងការនិយមឃ្មោះបច្ចុប្បន្ននៅស្រុក ព្រៃកប្បាស ខេត្តតាកែវ

១០៣-១០៤- ខ្សៀជក់បារីអំពីដីដុត និងសំរិទ្ធស្នាយ (សារមន្ទីរជាតិពន្ធុវិទ្យាទួលគោក)
១០៥- ការនិយមខ្សៀជក់បារីសម័យកលសម័្ពន្ធខ្មែរ រូបថតទុំពេជ្រក្រវិល
១០៦- ការប្រើបំពង់បើតស្រា រូបថតឯកសារបារាំងដើមស.វ ទី២០
១០៧- ការប្រើបំពង់បើតស្រា រូបថតរស្មីកម្ពុជា
១០៨-១១០- ចម្លាក់លើប្រាសាទបាយ័ននៅអង្គរបង្ហាញការប្រើបំពង់បើតខ្មែរលើនៅសម័យរាជានរគ
១១១-១១២- ចម្លាក់ដីដុតដំណាងលិង្គ,សម័យថ្មរំលីងមកពីស្ថានីល្អាងស្ពាន នៅខេត្តកំពត លិង្គឆ្អឹងមកពី ម្លូព្រៃ ខេត្តកំពុងធំសារមន្ទីរជាតិពន្ធុវិទ្យា
១១៣-១១៤- ថ្មអ្នកតាជាលិង្គ នៅខេត្តសៀមរាបឆ្នាំ ២៧៥ និង គំនូរមនុស្សធ្វើស្រែចំការដោយប្រើគោក្របីលើជញ្ជាំងថ្មដាគំនូរយុគលោហធាតុនៅប្រចាំថ្ងៃបច្ចុប្បន្ន (ឯកសារថៃ)
១១៥-១១៧- ខ្សែកធ្វើអំពីខ្យងនឹងឆ្អឹងសត្វ និងកងដៃស្នែងក្របីស្នាយសារមន្ទីរ និងពិន្ធុវិទ្យាទួលគោក
១១៨- កងដៃសំរិទ្ធរូបក្របីនិងក្បាច់កូចខ្យង, ស្នាយសារមន្ទីរជាតិពិន្ធុវិទ្យាទួលគោក
១១៩-១២០- គ្រឿងអលង្ការជាខ្នាយជ្រូកព្រៃធ្មេញខ្លា និងស្នែងប្រើស, ស្នាយសារមន្ទីរជាតិពន្ធុវិទ្យាទួលគោក
១២១- លលាក្បាលសពដែលមានពាក់ខ្នាយជ្រូកព្រៃននៅស្ថានីបុរេប្រវត្តិសាស្ត្រនៅប្រទេសថៃបច្ចុប្បន្ន (ឯកសារថៃ)
១២២- បុព្វការីជន ធ្វើអំពីឆ្អឹងស្នាយ សារមន្ទីរជាតិពិន្ធុវិទ្យាទួលគោក
១២៣-១២៤-ស្មៀតសិតសក់ធ្វើអំពីឆ្អឹងជំនីគំនូរ(សារមន្ទីរជាតិពន្ធុវិទ្យាទួលគោក) និងរូបស្ត្រីខ្មែរសុរិន្ទមានលក់បួង (២០០៤)
១២៥-១២៦- វត្ថុស័ក្តិសិទ្ធិ និងដែលលក់នៅលើភ្នំគូលែន ខេត្តសៀមរាប កាលពីឆ្នាំ ២០០៥

១២៧-១២៨- ភស្តុតាងដែលទំនាក់ទំនង និង ចិនទាសម័យបុរេប្រវត្តិសាស្ត្រ ចំណែកស្គរមហាធិក សំរិទ្ធិ ទំហំ ៣៦-១០ សម មកពីស្ពាយ ទិញនៅផ្សារ ( សារមន្ទីរជាតិពិន្ទុវិទ្យាទួលគោក និងស្គរមកស្រុក វ៉ារិន ខេត្តសៀមរាប នៅសារមន្ទីរអភិរក្ស ឆ្នារអង្គរ ខេត្តសៀមរាប

១២៩-( ក,ខ) គ្រាប់ស្រូវនៅខេត្តនរគរាជសិមា ប្រទេសថៃបច្ចុប្បន្នសម័យបុរេប្រវត្តិសាស្ត្រ ឯកសារថៃ

១៣០-( ក,ខ) គ្រាប់ស្រូវនិងផ្លែនង្គល រកឃើញនៅម៉ុំអូរកែវកម្ពុជាក្រោម ( ឯកសារវៀតណាម)

១៣១-១៣២- ផ្លែចប. ដែក. ពីភូមិស្នាយសំគាល់ជាបណ្តោះអាសន្ននៅសារមន្ទីរជាតិភ្នំពេញ

១៣៣- ចម្លាក់មេទ័ពខ្មែរ នៅប្រាសាទអង្គរវត្តកាន់ផ្គាក់ជាអាវុធ នៅពេលច្បាំង. នៅស.វទី១២ គ.ស

១៣៤- ជនជាតិព្នងនៅកម្ពុជាក្រោមប្រើផ្គាក់នាដើមស.វទី២០. ដើម្បីការពារពេលដើរថែកសំបុត្រនៅតាមតំបន់ព្រៃភ្នំ ( ឯកាសារប្រទេសបារាំង) ។

# ផែនទី ១


MUNDA
FAMILY
KURKU
KORA
SANTALI
MUNDARI
KHARIA
HO
JUANG
GADABA
SAVARA
KHASI
PALAUNG
RIANG
WA
KHMU
KHMU
MI
SO
MON
NIAMON
KOUI
RADE
JARAI
XONG
SAMRÉ
KHMER
CHAM
STIENG
SEMANG
SAKAI

# ផែនទី ២


BOLOVEN
KOUY
KOUY
CHENG
SEDANG
KRAVET
LAMAN
KOUY
BANHAR
SAMRÉ
BRAO
KRUNG
TAMPUON
DIARAI
CHONG
PÉAR
Rol PÉAR
Grand Lac
RHADÉ
PÉAR
Mékong
KIL
CHONG
STIENG
LAT
S'RÉ
ANRAK?
SAOCH
TCHURU
MA
GOLFE DU SIAM
MER DE CHINE

รูปที่ ๓



SKETCH MAP showing the distribution of the Languages of the Aborigines of the Malay Peninsula.
SEMANG
AND
PANGAN
NORTHERN
SAKAI
CENTRAL
SAKAI
EASTERN
SAKAI
SOUTHERN SAKAI
Malay Speaking Sakai
Malay-Speaking Jakun Tribes
K. Kelantan
K. Pahang
K. Selangor
Penang
P. Pangkor
Malacca Town
Singapore
P. Tioman
Orang Laut
Semang Sakai Jakun

រូបទី ៤


មហាសមុទ្រ ប៉ាស៊ីហ្វិច
ហ្វីលីពីន
បាំងហ្កាល
ភូមា
ឈូងសមុទ្រ ចិន
ប្រទេស ថៃ
ព្រះរាជាណាចក្រ កម្ពុជា
ឈូងសមុទ្រ បាំងហ្កាល
កម្ពុជា ក្រោម
ឥណ្ឌូណេស៊ី
ស្រីលង្កា
មហាសមុទ្រ ឥណ្ឌា
ស៊ូម៉ាត្រា
ហ្សាវ៉ា

រូបទី ៥


THAILAND
LAOS
SIEM-REAP
22,2
STONG-TRENG
60,8 ?
BATTAMBANG
23,5
KOMPONG-THOM
8,7 ?
KRATIE
53,8 ?
PURSAT
42,- ?
KOMPONG-CHUANG
36,- ?
KOMPONG-CHAM
25,3
KOMPONG-SPEU
36,5
PNOM-PENH
PREY-VENG
30,9
KANDAL
23,6
GOLFE du SIAM
KAMPOT
32,2
SVAY-RIENG
37,1
TAKEO
29,4
COCHINCHINE



រូបទី ៦



រូបទី ៧



រូបទី ៨



រូបទី ៩



រូបទី ១០



រូបទី ១១



រូបទី ១២



រូបទី ១៦



រូបទី ១៣



រូបទី ១៥



រូបទី ១៤

รูปที่ ๑๗



រូបទី ១៩





រូបទី ២០



រូបទី ២១



រូបទី ២២

រូបទី ២៣



រូបទី ២៤



រូបទី ២៥





រូបទី ២៦



រូបទី ២៧

រូបទី ២៨



រូបទី ២៩







រូបទី ៣១



រូបទី ៣២



រូបទី ៣៣



រូបទី ៣៤



រូបទី ៣៥



រូបទី ៣៦



រូបទី ៣៧



រូបទី ៣៧



រូបទី ៣៨



រូបទី ៣៩



រូបទី ៤០



រូបទី ៤១



រូបទី ៤២



រូបទី ៤៣



រូបទី ៤៤



រូបទី ៤៦



រូបទី ៤៥



រូបទី ៤៧



រូបទី ៥០



រូបទី ៤៨



រូបទី ៤៩



រូបទី ៥១



រូបទី ៥២





រូបទី ៥៣

រូបទី ៥៧



រូបទី ៥៨



រូបទី ៥៤



រូបទី ៥៥





រូបទី ៥៦



រូបទី ៥៩



រូបទី ៦២



រូបទី ៦១



រូបទី ៦០



រូបទី ៦៣



រូបទី ៦៤



រូបទី ៦៥



រូបទី ៦៦

រូបទី ៦៧



រូបទី ៦៩



រូបទី ៦៨





រូបទី ៧២



រូបទី ៧០

រូបទី ៧១





រូបទី ៧៣

រូបទី ៨០



រូបទី ៨១





រូបទី ៨២



រូបទី ៨៤

រូបទី ៨៣



រូបទី ៨៥





រូបទី ៨៩



រូបទី ៨៦



រូបទី ៨៧



រូបទី ៨៨



រូបទី ៩០

រូបទី ៩១





រូបទី ៩២

រូបទី ៩៣





រូបទី ៩៤



រូបទី ៩៦



រូបទី ៩៥



រូបទី ៩៧



រូបទី ៩៨



រូបទី ៩៩



រូបទី ១០០



រូបទី ១០១



រូបទី ១០២



រូបទី ១០៣



រូបទី ១០៤



រូបទី ១០៥



រូបទី ១០៦

រូបទី ១០៧





រូបទី ១០៨



រូបទី ១០៩

រូបទី ១១០





រូបទី ១១១

រូបទី ១១២





រូបទី ១១៣



រូបទី ១១៤



រូបទី ១១៥



រូបទី ១១៦



រូបទី ១១៧



រូបទី ១១៨


រូបទី ១១៩


រូបទី ១២០


រូបទី ១២១


រូបទី ១២១



រូបទី ១២២



រូបទី ១២៣



រូបទី ១២៤



រូបទី ១២៥



រូបទី ១២៦




รูปที่ ๑๒๗



รูปที่ ๑๒๘



រូបទី ១២៩ ក . ខ





រូបទី ១៣០ ក . ខ





រូបទី ១៣១



រូបទី ១៣២

រូបទី ១៣៣





រូបទី ១៣៤





- ការប្រើកងដៃ កងជើង និង ធ្នូស (សារៈមន្ទីរហ្គីមេ) នាសម័យអង្គរដូចពួកកលសម្ព័ន្ធ សម័យបុរេប្រវត្តិសាស្ត្រ ។

# ឯកសារពិគ្រោះ


១- ពេជ្រ ទុំក្រវិល ២០០៣ ទស្សនីយភាពខ្មែរ គណៈកម្មការស្រាវជ្រាវសិល្បៈ វប្បធម៌ឧត្តមភ្នំបោះពុម្ពដោយរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

២- ត្រាណែ មីសែល ១៩៨១ ប្រភពនៃអារ្យធម៌ និងជំនឿសាសនាខ្មែរ (ជាភាសារបារាំងបោះពុម្ពឡើងវិញ ១៩៨៣ " ការសិក្សាអំពីសាវតារវត្តសប្បុក " ភ្នំពេញ សិក្សាខ្មែរ លេខ៦ ១៩៨៣ (ជាភាសារបារាំង)

៣- សេដេស, ហ្ស៊ក, ១៩៦២ រដ្ឋនានាដែលបានទទួលវប្បធម៌ឥណ្ឌូណេស៊ី (ជាភាសារ បារាំង) ប៉ារីស)

៤- ស្កុត, វ.វ និង ប្លាកដេន . ១៩០៦ ជនជាតិសៃយសាសន៍ទាំងឡាយ នៅក្នុងជ្រោយមាឡាយូ, ភាគ១ និងភាគ២ (ជាភាសា អង់គ្លេស ឡុងដ្រ៍ )

៥- អាំងជូលៀន, ១៩៨៦ សត្វអធិធម្មជាតិក្នុងសាសនាអ្នកស្រុកខ្មែរ (ជាភាសារបារាំង) នៅប៉ារីស, មណ្ឌលស្រាវជ្រាវឯកសារ វប្បធម៌ខ្មែរ

៦- ឌីហ្វឡុថ,ហ្សេរ៉ាដ៍ ១៩៨៤ "ភាសារមនចាស់ សម័យនគរទ្វារវតី និងភាសារញ៉ះគួរ "សកលវិទ្យាល័យចុឡាសង្ករណ៍, ឈុតសិក្សាត្រកូលភាសារមន, ភាគ១, ១៦៨៤, បាងកក់ ( ជាភាសារអង់គ្លេស)

៧- ម៉ៃត្រ, ហង់រី ១៩១២ ព្រៃស្បាតព្នង បេសកម្មរបស់ហង់រីមៃត្រ (ឆ្នាំ១៩០៩ -១៩១១) ភាគកណ្ដាលនៃឥណ្ឌូចិនខាងត្បូងរបស់ពួកព្នង នៅប្រទេសកម្ពុជា អណ្ណាម កូសាំងស៊ីន និងលាវភាគខាងក្រោមប៉ារីស (ជាភាសារបារាំង)

៨- ម៉ាសេរ៉ូ, ហ្ស៊ក ១៩១៥ វេយ្យាករណ៍ភាសារខ្មែរ ប៉ារីស (ជាភាសារបារាំង)

៩- ដាវរឿងវិទ្យារដ្ឋ ១៩៩៩ ស្ថាននាមក្នុងភូមិភាគជ្រោយនៃប្រទេសថៃ ដែលមានដើមកំណើតជាភាសារខ្មែរវិទ្យាស្ថានជាតិនៃភាសារ និង អារ្យធម៌នៃបូពាណិប្រទេស,សារណាបរិញ្ញបត្រ៍ ឆ្នាំ១៩៩៩ ជាភាសាបារាំងមិនទាន់បោះពុម្ពផ្សាយ

១០- ប្រោន, ម៉ារិន, ១៩៨៥ " ពីភាសារថៃបូរាណដែលបណ្ដា ត្រាមភាសារ បច្ចុប្បន្ន និង ការនិពន្ធដទៃទៀតស្ដីពីភាសារសាស្ត្រប្រវត្តិសាស្ត្រ ថៃ បាងកក, ភាសាអង់គ្លេស "

១១- ១៩៧៥ " បណ្ដាភាសាមន-ខ្មែរ នៅប្រទេសម៉ាឡេយូ ការចាត់ថ្នាក់ និង ការបញ្ចូលរបៀបថ្មី, ក្នុងអាស៊ីអាគ្នេយ៍, លេខ ៦(៤), ១៩៧៥ ដោយ ភាសាបារាំង

១២- ស្មិត្ថ វិល្ហែម ១៩០៧ ជនជាតិមន-ខ្មែរ, ស្ពានចម្លងរវាងជនជាតិ នៅអាស៊ីកណ្ដាល និង ជនជាតិ អូស្ត្រូណេស៊ី, ព្រឹត្តប័ត្រភាសាបារាំងសែស នៃចុងបូព៌ាប្រទេស លេខ៧ ឆ្នាំ ១៩០៧ និង លេខ ៨ ឆ្នាំ ១៩០៨

១៣- ត្រឹង គី ១៩៧៩ ដំណើរដ៏វែងឆ្ងាយនៃការត្រួតត្រា អាស៊ីអាគ្នេយ៍ ដោយប្រទេសចិន, ប៉ារីស

១៤- ត្រឹង ងា ១៩៧៣ ប្រវត្តិសាស្ត្រកម្ពុជា, ភាគ១ និង ភាគ២, ភ្នំពេញ ដោយប្រទេសចិន, ប៉ារីស

១៤- ស្ពែក និង ប៉្លូ, ហ្គេន, ១៩០៤, ប៉ាហ្គាន នឹង ពូជសាសន៏ មនុស្ស នៅជ្រោយម៉ាឡាយូ, ភាគ១ និង ភាគ២ ។